# បំណិនជីវិតតាមមូលដ្ឋាន

## សៀវភៅណែនាំអនុវត្ត



រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ខែកញ្ញា ឆ្នាំ២០២៤

ការបោះពុម្ពផ្សាយនេះត្រូវបានធ្វើឡើងដោយក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា(ខេប) រួមជាមួយអង្គការដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត ក្នុងគោលបំណងជួយដល់ការយល់ដឹង និងការអនុវត្តមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន នៅគ្រប់សាលារៀនបឋមសិក្សា និងមធ្យមសិក្សាក្នុងប្រទេសកម្ពុជា។

**សូមដកស្រង់ការបោះពុម្ពផ្សាយនេះចេញពីឯកសារខាងក្រោម៖**

MoEYS (2024). Local Life Skills Training Manual. Phnom Penh.

**រចនាក្របៈ** ដោយអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ©

© ក្រសួងអប់រំ យុវជន និងកីឡា, ២០២៤

អ្នកអានអាចថតចម្លង ឬបោះពុម្ពការបោះពុម្ពនេះសម្រាប់តែការប្រើប្រាស់ផ្ទាល់ខ្លួន នៅក្នុងឯកសារការបោះពុម្ពផ្សាយ ប្លុក គេហទំព័រ និងឯកសារបង្រៀន ដោយត្រូវផ្តល់ការទទួលស្គាល់ត្រឹមត្រូវពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងនាមជាប្រភពដើម និងម្ចាស់កម្មសិទ្ធិបញ្ញា។

# គណៈកម្មការ

## គណៈកម្មការគ្រប់គ្រង

| | | |
|---|---|---|
| ១ - ឯកឧត្តមបណ្ឌិតសភាចារ្យ | **ហង់ជួន ណារ៉ុន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ២ - ឯកឧត្តមបណ្ឌិតសភាចារ្យ | **ណាត ប៊ុនរឿន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៣ - ឯកឧត្តម | **អ៊ុង បូរាត** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៤ - ឯកឧត្តមបណ្ឌិត | **ចាន់ សុភា** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៥ - ឯកឧត្តម | **អ៊ុង ជីនណា** | អគ្គនាយក នៃអគ្គនាយកដ្ឋានអប់រំ |
| ៦ - ឯកឧត្តមបណ្ឌិត | **ឱម សិទ្ធី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអប់រំ |
| ៧ - លោកបណ្ឌិត | **កាន់ ពុទ្ធ** | ប្រធាននាយកដ្ឋានបឋមសិក្សា |
| ៨ - លោក | **ឈុន រ៉ាមី** | អនុប្រធាននាយកដ្ឋានបឋមសិក្សា |

## គណៈកម្មការរៀបចំ និងកែសម្រួលខ្លឹមសារ

| | | |
|---|---|---|
| ៩ - ឯកឧត្តមបណ្ឌិត | **ចាន់ សុភា** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ១០ - ឯកឧត្តម | **អ៊ុង ជីនណា** | អគ្គនាយក នៃអគ្គនាយកដ្ឋានអប់រំ |
| ១១ - លោកបណ្ឌិត | **កាន់ ពុទ្ធី** | ប្រធាននាយកដ្ឋានបឋមសិក្សា |
| ១២ - លោក | **ឈុន រ៉ាមី** | អនុប្រធាននាយកដ្ឋានបឋមសិក្សា |
| ១៣ - លោក | **តុង បូរិទ្ធ** | អនុប្រធាននាយកដ្ឋានបឋមសិក្សា |
| ១៤ - លោក | **នួន វណ្ណាសឿន** | អនុប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| ១៥ - លោក | **លី គាង** | អនុប្រធានគ្រប់គ្រងបណ្ដោះអាសន្ន នាយកដ្ឋានកិច្ចការរិក្រឹតការ |
| ១៦ - លោក | **ព្រំ វិបុល** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| ១៧ - កញ្ញា | **សេង ស៊ីណែត** | អនុប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានវិទ្យា |
| ១៨ - លោក | **ហុង ពិដោរ** | ប្រធានការិយាល័យ នា.បឋមសិក្សា |
| ១៩ - លោក | **ឈឹម គំនិត** | ប្រធានការិយាល័យ នា.មធ្យមសិក្សាចំណេះទូទៅ |
| ២០ - លោក | **គុយ ច័ន្ទមង្គល** | ប្រធានការិយាល័យ នា.បឋមសិក្សា |
| ២១ - លោក | **ហង់ ពិសិដ្ឋ** | ប្រធានការិយាល័យ នា.បឋមសិក្សា |

២២ - លោក **ឈួន ត្រី** អនុប្រធានការិយាល័យ នា.បឋមសិក្សា

២៣ - លោក **សេង ពិសិដ្ឋ** អនុប្រធានការិយាល័យ នា.បឋមសិក្សា

២៤ - លោកស្រី **អ៊ាង សេងលីម** អនុប្រធានការិ. នា.កិច្ចការបណ្តុះបណ្តាល

២៥ - លោកស្រី **ហ៊ុន សោភ័ណ** អនុប្រធានការិយាល័យ នា.សុខភាពសិក្សា

២៦ - លោក **លឹម សេងហួត** អនុប្រធានការិយាល័យ នា.ធានាគុនភាពអប់រំ

២៧ - លោក **ផេង ទិមាន** អនុប្រធានការិយាល័យ នា.តម្រង់ទិសវិជ្ជាជីវៈ

២៨ - កញ្ញា **អយ សុគន្ធា** មន្ត្រីនាយកដ្ឋានបឋមសិក្សា

២៩ - លោក **ម៉ម ទិបុល** មន្ត្រីនាយកដ្ឋានបឋមសិក្សា

៣០ - លោកស្រី **ទ៉ា ចិន្តា** មន្ត្រីនាយកដ្ឋានបឋមសិក្សា

៣១ - លោកស្រី **សួស ធាវី** មន្ត្រីនាយកដ្ឋានបឋមសិក្សា

៣២ - លោក **ឡៀង ផល្លា** មន្ត្រីនាយកដ្ឋានបឋមសិក្សា

៣៣ - លោក **លី រតនា** មន្ត្រីនាយកដ្ឋានបឋមសិក្សា

៣៤ - លោក **ជា យុទ្រី** មន្ត្រីនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ

៣៥ - លោក **ញឹក ទិបុល** មន្ត្រីនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

៣៦ - លោក **សោមនស្ស តិរម្យ** មន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

៣៧ - លោក **អ៊ុង សារ៉ាត់** មន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

៣៨ - លោក **ស ប្រុស** មន្ត្រីនាយកដ្ឋានសុខភាពសិក្សា

៣៩ - លោក **សួង សិទ្ធី** នាយកសាលាបឋមសិក្សាអង្គរុន ខេត្តតាកែវ

៤០ - លោកស្រី **ព្រំ សុឡួន** នាយិការរងអនុវិ.ហ៊ុន សែន រលួស ខេត្តសៀមរាប

៤១ - លោក **ព្រឿន ប្រុញ** នាយកអនុវិទ្យាល័យអរញ្ញរង្សី ខេត្តសៀមរាប

៤២ - លោក **តោគ ឆួក** នាយកអនុវិទ្យាល័យ ថ្មស ខេត្តតាកែវ

៤៣ - តំណាងអង្គការ UNICEF

៤៤ - តំណាងអង្គការ KAPE

៤៥ - តំណាងអង្គការ Plan International

៤៦ - តំណាងអង្គការ Room To Read

៤៧ - តំណាងអង្គការ Child Right Foundation

៤៨ - តំណាងអង្គការ World Education

៤៩ - តំណាងអង្គការ Save The Children International

៥០ - តំណាងអង្គការ Child Fund

៥១ - តំណាងអង្គការ RTI

# មាតិកា


បុព្វកថា.................................................................vii

១. សេចក្តីផ្តើម.................................................................1

១.១ ទិដ្ឋភាពទូទៅនៃឯកសារ.................................................................1

១.២ គោលបំណង និងខ្លឹមសារនៃឯកសារ.................................................................2

១.៣ របៀបប្រើប្រាស់ឯកសារ.................................................................6

២. ផែនការមេរៀនសម្រាប់អ្នកសម្របសម្រួល.................................................................9

ផ្នែកទី១៖ សេចក្តីណែនាំការអប់រំបំណិនជីវិតនៅកម្ពុជា.................................................................10

មេរៀនទី១៖ ការអប់រំបំណិនជីវិត និងការអប់រំបំណិនជីវិតតាមមូលដ្ឋាននៅកម្ពុជា................. 11

មេរៀនទី២៖ ដំណើរការជ្រើសរើសប្រធានបទ.................................................................27

ផ្នែកទី២៖ វិធីសាស្ត្រការសិក្សាអាស្រ័យលើបញ្ហាសម្រាប់ការអប់រំបំណិនជីវិតតាមមូលដ្ឋាន.................................................................39

មេរៀនទី៣៖ ទ្រឹស្តីការសិក្សាបែបស្ថាបនានិយម ការសិក្សាបែបគម្រោង និងការអប់រំបំណិនជីវិតតាមមូលដ្ឋាន.................................................................40

មេរៀនទី៤៖ គំរូអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន៖ ការអនុវត្ត ៦ដំណាក់កាល................53

មេរៀនទី៥៖ វិធីបញ្ចូល ICT នៅក្នុងដំណើរការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន .....................78

មេរៀនទី៦៖ ការបង្កើតភាពស៊ីសង្វាក់គ្នាសម្រាប់ធ្វើឱ្យការសិក្សាប្រសើរឡើង.........................94

មេរៀនទី៧៖ វាយតម្លៃគម្រោង និងការសិក្សាអាស្រ័យលើបញ្ហា ..................................... 110

ផ្នែកទី៣៖ ការបង្កើតបរិស្ថានគាំទ្រនៅតាមសាលារៀន.................................................................123

មេរៀនទី៨៖ គាំទ្រការបង្កើតប្រព័ន្ធអេកូឡូស៊ីនៅតាមសាលារៀន ..................................... 124

មេរៀនទី៩៖ យន្តការគាំទ្រគ្រូបង្រៀន និងនាយក នាយិកាសាលារៀន............................... 139

៣. ឯកសារចែកសម្រាប់អ្នកចូលរួម.................................................................155

ឯកសារផ្នែកទី១៖ សេចក្តីណែនាំការអប់រំបំណិនជីវិតតាមមូលដ្ឋាននៅកម្ពុជា155

ឯកសារ ១.១៖ ការបង្រៀនបំណិនជីវិត.................................................................155

ឯកសារ ១.២៖ ករណីសិក្សារបស់សម្បត្តិ និងមករា.................................................................156

ឯកសារ ១.៣៖ មុខវិជ្ជាបំណិនទន់ និងបំណិនជីវិតតាមមូលដ្ឋាន ..................................... 158
ឯកសារ ១.៤៖ ការអប់រំបំណិនជីវិតនៅកម្ពុជា .................................................................. 159
ឯកសារ ២.១៖ កម្មវិធីសិក្សាដែលបានចរចានៅសាលារៀន ..............................................161
ឯកសារ ២.២៖ ការជ្រើសរើសប្រធានបទ (វីដេអូ) ........................................................... 162
ឯកសារ ២.៣៖ ការកំណត់បញ្ហា ...................................................................................... 163
ឯកសារ ២.៤៖ ប្រធានបទ និងការរំពឹងទុកនៃការសិក្សា ................................................. 165
ឯកសារ ២.៥៖ បំណែងចែកកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន-ឧទាហរណ៍លើប្រធានបទ 166
ឯកសារផ្នែកទី២៖ វិធីសាស្ត្រការសិក្សាអាស្រ័យលើបញ្ហាសម្រាប់ការអប់រំបំណិនជីវិតតាមមូលដ្ឋាន......................................................................................................167
ឯកសារ ៣.២៖ ការសិក្សាបែបស្ថាបនានិយម និងវិធីសាស្ត្រពាក់ព័ន្ធការសិក្សាស្ថាបនានិយម .. 167
ឯកសារ ៣.៣៖ ឧទាហរណ៍នៃការងារគម្រោងនៅក្នុងថ្នាក់រៀន ........................................ 168
ឯកសារ ៣.១៖ ការសិក្សាបែបស្ថាបនានិយម និងការងារគម្រោង ......................................171
ឯកសារ ៣.៤៖ ការសិក្សាអាស្រ័យលើគម្រោង និងអាស្រ័យលើបញ្ហា.............................. 172
ឯកសារ ៣.៥៖ ដំណើរការ ៦ដំណាក់កាល ...................................................................... 173
ឯកសារ ៣.៦៖ ផ្ទាំងប៉ុស្តិ៍រដំណើរការ ៦ដំណាក់កាល........................................................ 175
ឯកសារ ៣.៧៖ បំណិនទន់នៅក្នុងប៉ុស្ទ័របំណិនជីវិតតាមមូលដ្ឋាន .................................... 176
ឯកសារផ្នែកទី៣៖ ការបង្កើតបរិយាកាសគាំទ្រនៅក្នុងសាលារៀន.........................225
ឯកសារ ៨.១៖ ក្រោយបណ្តុះបណ្តាល ...............................................................................225
ឯកសារ ៨.២៖ គំរូសិក្សា ៧០-២០-១០ ...........................................................................226
ឯកសារ ៨.៣៖ សេណារីយ៉ូ៖ សុភា និងការសិក្សាថ្មីៗ .......................................................227
ឯកសារ ៨.៤៖ ប្រព័ន្ធអេកូគរុកោសល្យនៅតាមសាលារៀនរបស់អ្នក ..................................229
ឯកសារ ៨.៥៖ អ្នកដឹកនាំល្អ និងអ្នកដឹកនាំខ្សោយ ...........................................................230
ឯកសារ ៨.៦៖ ករណីសិក្សានៅសាលារៀនបឋមសិក្សាភ្នាក់ ...........................................232
ឯកសារ ៨.៧៖ បញ្ជីត្រួតពិនិត្យការគ្រប់គ្រងធនធាន.........................................................234
ឯកសារ ៩.១៖ ការវាយតម្លៃចំណេះដឹងរបស់អ្នកអំពីបញ្ញត្តិ និងដំណើរការនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ...........................................................................................................237

ឯកសារ ៩.២៖ ក្របខណ្ឌការងារ CPD នៅកម្រិតសាលារៀន ........................................ 238
ឯកសារ ៩.៣៖ សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលត្រូវពិចារណាសម្រាប់សាលារៀនរបស់អ្នក
........................................................................................................................ 239
ឯកសារ ៩.៤៖ ការបង្កើតប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដ៏ជោគជ័យមួយ............................. 241
ការដាក់ផែនការរួមគ្នាមួយដើម្បីដាក់ប្រព័ន្ធ CPD មួយតាមសាលារៀន............................... 241
ឯកសារ ៩.៥៖ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ................................................................... 244

# បុព្វកថា

ការអប់រំបំណិនជីវិតតាមមូលដ្ឋាន ជាការបណ្តុះបំណិនសតវត្សទី២១ ដល់សិស្សានុសិស្សចាប់ពីកម្រិតបឋមសិក្សា រហូតដល់មធ្យមសិក្សា និងបន្តទៅឧត្តមសិក្សា ដើម្បីឱ្យក្លាយជាពលរដ្ឋពេញលេញ។ កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ត្រូវបានអនុវត្តនៅកម្ពុជាក្នុងឆ្នាំ២០០៦ និងបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាចាប់ពីថ្នាក់ទី៤ ដល់ទី១២ ក្នុងឆ្នាំ២០១៦។ ការលើកកម្ពស់មុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន ជាអាទិភាពមួយរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការរួមចំណែកកែលម្អគុណភាពនៃការបង្រៀន និងរៀននៅគ្រប់កម្រិតសិក្សា។

**សៀវភៅណែនាំអនុវត្ត ស្តីពីបំណិនជីវិតតាមមូលដ្ឋាន សម្រាប់សាលារៀន** ត្រូវបានចងក្រង ផ្អែកលើវឌ្ឍនភាព និងឧត្តមានុវត្តន៍ល្អៗអំពីការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋានកន្លងមក ស្របតាមអាទិភាពកំណែទម្រង់វិស័យអប់រំ ដើម្បីគាំទ្រដល់គណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ និងអ្នកអប់រំនៅមូលដ្ឋានក្នុងការអនុវត្តមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាននៅគ្រប់សាលារៀនទាំងអស់ក្នុងប្រទេសកម្ពុជា សំដៅអភិវឌ្ឍបំណិនទន់ដល់សិស្សានុសិស្សប្រកបដោយគុណភាព។ សៀវភៅណែនាំនេះ បានរំលេច និងជំរុញនូវការអនុវត្តវិធីសាស្ត្របង្រៀនមួយចំនួន រួមមានការសិក្សាបែបគម្រោង ការសិក្សាផ្អែកលើបញ្ហា ការស្រាវជ្រាវ ការពិភាក្សាក្រុម ការធ្វើបទបង្ហាញ និងការដោះស្រាយបញ្ហា។ សៀវភៅណែនាំនេះ ក៏ជាឯកសារសម្រាប់ប្រើប្រាស់ក្នុងការបណ្តុះបណ្តាលគ្រូតាមសាលាគរុកោសល្យ កម្មវិធីសិក្ខាសាលា និងជាឯកសារជំនួយសម្រាប់ការប្រតិបត្តិផ្ទាល់នៅតាមសាលារៀនផងដែរ។

ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ ដែលបានខិតខំអស់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតីក្នុងការរៀបចំសៀវភៅណែនាំនេះឡើង។

ក្រសួងសង្ឃឹមថា **សៀវភៅណែនាំអនុវត្ត ស្តីពីបំណិនជីវិតតាមមូលដ្ឋាន សម្រាប់សាលារៀន** នឹងត្រូវបានផ្សព្វផ្សាយដល់គ្រប់គ្រឹះស្ថានសិក្សា និងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីចូលរួមអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន និងធ្វើទំនើបកម្មការបង្រៀននៅគ្រប់សាលារៀនទូទាំងប្រទេស។

ថ្ងៃចន្ទ ៦រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ២៣ ខែកញ្ញា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# ១. សេចក្តីផ្តើម

## ១.១ ទិដ្ឋភាពទូទៅនៃឯកសារ

ឯកសារបច្ចុប្បន្ននេះនឹងផ្តល់នូវទិដ្ឋភាពទូទៅផ្នែកបច្ចេកទេសគន្លឹះមួយ ដែលអ្នកអប់រំអាចយកទៅប្រើប្រាស់ដើម្បីអនុវត្តមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាននៅតាមសាលារៀនរបស់ពួកគាត់បាន និងការបំពេញបន្ថែមការណែនាំមុខវិជ្ជាសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច ដែលអាចចូលទៅប្រើប្រាស់បានតាមរយៈប្រព័ន្ធគេហទំព័រ MoEYS e-learning និងឯកសារណែនាំអនុវត្តដែលបានផលិតរួចមកហើយកាលពីឆ្នាំមុន ដោយមានសេចក្តីពន្យល់លម្អិត បញ្ញត្តិសំខាន់ៗ ដូចជាវិធីសាស្ត្របង្រៀន និងយុទ្ធសាស្ត្រអនុវត្តជាក់ស្តែងនៅតាមសាលារៀន។

កម្មវិធីបំណិនជីវិតតាមមូលដ្ឋានត្រូវបានណែនាំដំបូងនៅកម្ពុជាក្នុងឆ្នាំ២០០៦ ហើយវាត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សាផ្លូវការទាំងកម្រិតបឋមសិក្សា និងមធ្យមសិក្សានៅឆ្នាំ២០១៦។ ចាប់តាំងពីពេលនោះមកអង្គការ UNICEF ក្នុងកិច្ចសហការជាមួយ ក្រសួងអប់រំ យុវជន និងកីឡា បានគាំទ្រការអនុវត្តសាកល្បងដោយទទួលបានលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់។ ការបង្រៀនដែលដាក់ចេញនៅក្នុងបរិបទនៃបំណិនជីវិតតាមមូលដ្ឋាន គឺពិតជាមានឫសគល់នៅក្នុងគោលការណ៍នៃការគ្រប់គ្រងតាមសាលារៀន។ វាងាកចេញពីការបង្រៀនតាមកម្មវិធីសិក្សាបែបប្រពៃណីមកជាការបង្រៀនបែបថ្មីដោយចាប់ផ្តើមជាមួយបញ្ហា ឬឱកាសដែលបានកំណត់នៅមូលដ្ឋាន ដែលមានបញ្ហាប្រឈម និងវិធីសាស្ត្របង្រៀនធម្មតា។ វិធីសាស្ត្រនេះបានផ្លាស់ប្តូរពីការសិក្សាដោយផ្តោតលើការទទួលបានចំណេះដឹងជាចម្បង មកជាការសិក្សាដោយទទួលបានការអភិវឌ្ឍបំណិនជាសំខាន់។ សិស្សចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពដែលជំរុញការលូតលាស់ផ្នែកបំណិនទន់របស់ពួកគេ លើកកម្ពស់ស្វ័យភាពក្នុងការសិក្សា ធ្វើឱ្យពួកគេយល់កាន់តែច្បាស់ យកឈ្នះលើបញ្ហាប្រឈម និងហានិភ័យនានាដែលកើតមានឡើងនៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។ ការផ្លាស់ប្តូរនេះឆ្ពោះទៅរកវិធីសាស្ត្រការសិក្សាសកម្មជាងមុនដែលបង្កឱ្យមានបញ្ហាប្រឈមដ៏សំខាន់ដល់អ្នកអប់រំជាច្រើន។ ដើម្បីគាំទ្រការផ្លាស់ប្តូរនេះ ឯកសារបណ្តុះបណ្តាលបច្ចុប្បន្នត្រូវបានបង្កើតឡើងក្នុងគោលបំណងណែនាំពីវិធីសាស្ត្របង្រៀនអាស្រ័យលើគម្រោង និងអាស្រ័យលើបញ្ហា។ វិធីសាស្ត្រទាំងនេះ ស្របគ្នាទៅនឹងទ្រឹស្តីការសិក្សាបែបស្ថាបនានិយមនៃការអប់រំ ដែលសិស្សធ្លាប់តែរៀនដោយផ្អែកលើការចងចាំ និងយល់ដឹង មកជាការបង្កើតចំណេះដឹងថ្មីយ៉ាងសកម្មតាមរយៈការងារគម្រោង។ អ្នកចូលរួមក្នុងការអនុវត្តការបង្រៀននេះនឹងទទួលស្គាល់ពីសារៈសំខាន់នៃការរៀនតាមបែបគម្រោង និងអាស្រ័យលើបញ្ហាក្នុងការអនុវត្តមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន។ វិធីសាស្ត្របង្រៀនទាំងនេះនឹងផ្តល់ឱ្យសិស្សនូវឱកាសចូលរួមក្នុងគម្រោងពិតប្រាកដ ពិភពពិត និងដោះស្រាយបញ្ហាស្មុគស្មាញ។ តាមរយៈការអនុវត្តចំណេះដឹង និងបំណិនរបស់ពួកគេក្នុងស្ថានភាពជាក់ស្តែង សិស្សនឹងអភិវឌ្ឍន៍ការយល់ដឹងកាន់តែស៊ីជម្រៅលើប្រធានបទ និងទទួលបានបំណិនដ៏មានតម្លៃដូចជាការគិតពិចារណាស៊ីជម្រៅ ការដោះស្រាយបញ្ហា និងការសហការគ្នា។

ឯកសារបណ្ដុះបណ្ដាលនេះត្រូវបានរៀបចំឡើងដើម្បីរួមបញ្ចូលទាំងផែនការបង្រៀនសម្រាប់អ្នកសម្របសម្រួលនៅពេលខាងមុខ ដែលក្រសួងអប់រំនឹងប្រគល់ភារកិច្ចឱ្យបណ្ដុះបណ្ដាលនាយកសាលារៀន និងគ្រូបង្រៀនក្នុងការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាននៅតាមសាលារៀន ព្រមទាំងសំណុំឯកសារដែលអ្នកសម្របសម្រួលអាចចែករំលែកដល់អ្នកចូលរួម។ ការណ៍នេះនឹងធានាបានថាអ្នកចូលរួមទាំងអស់មានឯកសារយោងត្រឹមត្រូវ ហើយពួកគេអាចពិនិត្យមើលឡើងវិញបន្ទាប់ពីបញ្ចប់វគ្គបណ្ដុះបណ្ដាល។ អ្នកអភិវឌ្ឍឯកសារនេះ ព្យាយាមចៀសវាងការប្រើប្រាស់ការបរិយាយរៀបរាប់ច្រើនពេក ដែលអាចនឹងពិបាកយល់ និងកាន់តែពិបាកសម្រាប់អ្នកសម្របសម្រួលនៅថ្ងៃខាងមុខក្នុងការចែករំលែកជាមួយគ្រូបង្រៀន និងអ្នកអប់រំផ្សេងទៀតនៅកម្រិតសាលារៀន។ ដូច្នេះ ឯកសារនេះផ្ដល់ការណែនាំច្បាស់លាស់ដល់អ្នកបណ្ដុះបណ្ដាលពីរបៀបប្រើប្រាស់សកម្មភាព និងសម្ភារជាក់ស្ដែងដើម្បីធានាថាអ្នកចូលរួមទទួលបានចំណេះដឹងល្អប្រសើរនូវវិធីអនុវត្តបំណិនជីវិតតាមមូលដ្ឋាននៅតាមសាលារៀន។ អ្នកចូលរួមនឹងចូលរួមយ៉ាងសកម្មក្នុងដំណើរការសិក្សាតាមរយៈការប្រើប្រាស់យ៉ាងទូលំទូលាយនៃបច្ចេកទេសជាច្រើនតាមរយៈអ្នកសម្របសម្រួល ដែលនឹងរួមបញ្ចូលទាំងការបំផុសគំនិត ករណីសិក្សា ការសម្ដែងតួ កិច្ចពិភាក្សាយ៉ាងសកម្ម និងរៀនពីបទពិសោធន៍របស់គ្រូបង្រៀន សិស្ស និងនាយកសាលារៀននៅកម្ពុជាផ្សេងទៀតដែលពួកគេទទួលបានជោគជ័យក្នុងការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាននៅក្នុងសាលារៀន។

## ១.២ គោលបំណង និងខ្លឹមសារនៃឯកសារ

គោលបំណងនៃឯកសារនេះ គឺផ្ដល់សេចក្ដីណែនាំជារចនាសម្ព័ន្ធដល់អ្នកសម្របសម្រួលដែលត្រូវបានជ្រើសរើសដើម្បីបណ្ដុះបណ្ដាលគ្រូបង្រៀន និងនាយកសាលាអំពីរបៀបអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន និងអនុវត្តវិធីសាស្ត្រការសិក្សាអាស្រ័យលើគម្រោង ឬ អាស្រ័យលើបញ្ហា ដោយពន្យល់ច្បាស់ៗពីឧទាហរណ៍ជាក់ស្ដែង ករណីសិក្សាពិតប្រាកដ និងឧបករណ៍បណ្ដុះបណ្ដាលផ្សេងទៀតដែលពន្យល់ពីការអនុវត្តការងារគម្រោង និងការបង្កើតប្រព័ន្ធអេកូគរុកោសល្យនៅតាមសាលារៀនដែលអាចគាំទ្រដល់ការអនុវត្តទាំងអស់។ ឯកសារនេះមានបណ្ដុំផែនការបណ្ដុះបណ្ដាលងាយស្រួលចំនួន **៩មេរៀន** ដើម្បីណែនាំដល់អ្នកសម្របសម្រួលក្នុងការធ្វើបទបង្ហាញក្នុងវគ្គបណ្ដុះបណ្ដាលជាក់ស្ដែងដល់អ្នកពាក់ព័ន្ធពីបញ្ញត្តិមូលដ្ឋានខ្លះនៃការងារគម្រោង និងប្រព័ន្ធអេកូគរុកោសល្យ។ ផែនការបណ្ដុះបណ្ដាលនីមួយៗរួមបញ្ចូលព័ត៌មានដូចខាងក្រោម៖

- វត្ថុបំណងសិក្សា
- រយៈពេលប្រើសម្រាប់សកម្មភាពនីមួយៗ
- សេចក្ដីណែនាំស្ដីពីសកម្មភាពដែលអ្នកសម្របសម្រួលគួរត្រៀមទុកមុន
- ដំណើរការអនុវត្ត

- បញ្ជីសម្ភារៈ និងធនធានចាំបាច់ដើម្បីសម្របសម្រួលការបណ្តុះបណ្តាល។ ក្នុងន័យនេះគួរកត់សម្គាល់ផងដែរថា នៅក្នុងឯកសារណែនាំនេះមានឯកសារចែកសម្រាប់អ្នកចូលរួមដើម្បីឱ្យពួកគេអាចប្រើប្រាស់ជាឯកសារយោងបន្ទាប់ពីសិក្ខាសាលាបណ្តុះបណ្តាលបានបញ្ចប់ផងដែរ។

### ១.២.១ ខ្លឹមសារលម្អិត

ឯកសារស្តីពីការបណ្តុះបណ្តាលបំណិនជីវិតតាមមូលដ្ឋាន ត្រូវបានរៀបចំជាបីផ្នែកផ្សេងគ្នា ដែលផ្នែកនីមួយៗរៀបរាប់អំពីធាតុជាក់លាក់នៃការអនុវត្តមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន។ គោលបំណងចម្បងនៃឯកសារនេះគឺបង្កើនការយល់ដឹងរបស់នាយកសាលា និងគ្រូបង្រៀនទាក់ទងនឹងការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន និងផ្តល់វិធីសាស្រ្តបង្រៀនបែបគម្រោងជាឯកសារយោង។ វាជាការសំខាន់ក្នុងការកត់សម្គាល់ថាសាលារៀន និងដៃគូអភិវឌ្ឍន៍នីមួយៗនឹងមានសេរីភាពក្នុងការជ្រើសរើសប្រធានបទជាក់លាក់របស់គម្រោង។

ផ្នែកទី១ ដើរតួជាការណែនាំអំពីបញ្ញត្តិសំខាន់ៗដែលទាក់ទងនឹងការអប់រំបំណិនជីវិតនៅកម្ពុជា។ ផ្នែកនេះមានគោលបំណងយ៉ាងច្បាស់ថា អ្នកចូលរួមទាំងអស់នឹងមានការយល់ដឹងកាន់តែច្បាស់អំពីបញ្ញត្តិជាមូលដ្ឋាន ដូចជាការអប់រំបំណិនជីវិត ការអភិវឌ្ឍបំណិនទន់ និងរបៀបដែលពួកវាទាក់ទងគ្នានឹងការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន។ អ្នកចូលរួមនឹងមានឱកាសពិនិត្យមើលឡើងវិញ និងឆ្លុះបញ្ចាំងពីដំណើរការជ្រើសរើសប្រធានបទសម្រាប់មុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាននៅដើមឆ្នាំសិក្សា ដោយពិចារណាលើតថភាព និងពិនិត្យមើលលើការអនុវត្តគំរូពីសាលារៀននានានៅកម្ពុជា។

ផ្នែកទី២ ផ្តោតលើគរុកោសល្យនៃការបង្រៀនមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន ដោយសង្កត់ធ្ងន់លើទស្សនវិជ្ជាបែបស្ថាបនានិយម និងការពាក់ព័ន្ធរបស់វាជាមួយវិធីសាស្រ្តការសិក្សាបែបគម្រោង និងអាស្រ័យលើបញ្ហា។ អ្នកអប់រំនឹងទទួលបានការយល់ដឹងអំពីរបៀបអនុវត្តគម្រោងជាមួយសិស្សក្នុងបរិបទនៃប្រធានបទកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ដែលជាធម្មតាចាប់ផ្តើមពីបញ្ហាក្នុងជីវិតពិត ឬទាក់ទងស្ថានភាពនៅក្នុងសហគមន៍ និងសាលារៀន។ អ្នកចូលរួមនឹងស្វែងយល់ពីទំនាក់ទំនងគ្នាទៅវិញទៅមករវាងការបង្រៀនបែបគម្រោង ការសិក្សាអាស្រ័យលើបញ្ហា និងការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន និងប្រៀបធៀបពួកវាជាមួយនឹងវិធីសាស្រ្តបង្រៀនតាមបែបប្រពៃណី ការវិភាគគុណសម្បត្តិ និងបញ្ហាប្រឈមនានាដែលពួកគេមាន។ តាមរយៈការសិក្សាលើករណីសិក្សាដែលបានជ្រើសរើសដោយប្រុងប្រយ័ត្ន អ្នកចូលរួមនឹងទទួលបានចំណេះដឹងអំពីរបៀបដែលវិធីសាស្រ្តទាំងនេះអាចអនុវត្តបានយ៉ាងមានប្រសិទ្ធភាពនៅក្នុងថ្នាក់រៀនបំណិនជីវិតតាមមូលដ្ឋាន។ លើសពីនេះ អ្នកចូលរួមនឹងត្រូវបានណែនាំពីគំនិតផ្តួចផ្តើមផ្សេងទៀតដោយក្រសួងអប់រំ យុវជន និងកីឡា នៅគ្រប់ជាន់ថ្នាក់ ចាប់ពីកម្រិតសាលារៀនរហូតដល់កម្រិតអន្តរជាតិ ដែលលើកកម្ពស់ការចូលរួមយ៉ាងសកម្មរបស់យុវជន និងការស្ម័គ្រចិត្តក្នុងសហគមន៍។ ពួកគេនឹងត្រូវបានណែនាំឱ្យកំណត់ពីការស៊ីសង្វាក់គ្នាដ៏មានសក្តានុពលរវាងប្រធានបទបំណិនជីវិតតាមមូលដ្ឋាន និងឧត្តមានុវត្តដែលមានស្រាប់។

**ផ្នែកទី៣** ណែនាំអំពីបញ្ញត្តិនៃប្រព័ន្ធអេកូគរុកោសល្យនៅក្នុងសាលារៀន ដោយសង្កត់ធ្ងន់ពីការកែលម្អសាលារៀនប្រកបដោយភាពជោគជ័យ មិនមែនពឹងផ្អែកតែលើការលើកកម្ពស់វិធីសាស្ត្រសិក្សាបែបថ្មីៗតែមួយមុខនោះទេ។ អ្នកចូលរួមនឹងវិភាគសមាសធាតុផ្សេងៗនៃប្រព័ន្ធអេកូគរុកោសល្យ ពិនិត្យមើលគំរូសាលារៀនជំនាន់ថ្មី និងសាលារៀនរដ្ឋផ្សេងទៀតនៅកម្ពុជាដែលទទួលបានជោគជ័យ និងធ្វើការឆ្លុះបញ្ចាំងពីការអនុវត្ត ឆ្លុះបញ្ចាំងពីសារៈសំខាន់នៃភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាព ការចូលរួមរបស់សហគមន៍ និងប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD) ដែលមានរចនាសម្ព័ន្ធនៅក្នុងសាលារៀនដើម្បីបង្កើនគុណភាពបង្រៀន និងរៀន។

**ខ្លឹមសារបណ្តុះបណ្តាល និងអ្នកចូលរួមគោលដៅ** នៅពេលបង្កើតឯកសារសម្រាប់ទាំងគ្រូបឋមសិក្សា និងគ្រូមធ្យមសិក្សា និងនាយកសាលា អាចមានសារៈប្រយោជន៍ក្នុងការបែងចែកក្រុមគោលដៅជាសំខាន់សម្រាប់មេរៀននីមួយៗ។ ខណៈពេលដែលខ្លឹមសារមេរៀនទាំងអស់អាចមានតម្លៃសម្រាប់ការបណ្តុះបណ្តាលជារួមចំពោះក្រុមដែលបានគ្រោងទុក ការផ្តល់អាទិភាពលើខ្លឹមសារនៃការបណ្តុះបណ្តាលនឹងជួយដល់អ្នកសម្របសម្រួលក្នុងការគ្រប់គ្រងពេលវេលាប្រកបដោយប្រសិទ្ធភាព។ វិធីសាស្ត្រនេះអនុញ្ញាតឱ្យអ្នកសម្របសម្រួលកំណត់មេរៀនដែលជាអាទិភាព ដោយផ្អែកលើតម្រូវការជាក់លាក់នៃក្រុមគោលដៅនីមួយៗ ដំណើរការបណ្តុះបណ្តាល និងធានាឱ្យបាននូវការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព។

| មេរៀន | ក្រុមគោលដៅចម្បង | | |
|---|---|---|---|
| | គ្រូបង្រៀន | នាយក ឬ នាយិកា សាលារៀន | បុគ្គលិកអប់រំ ថ្នាក់ជាតិ និង ថ្នាក់ក្រោម ជាតិ |
| **មេរៀនទី១**<br>ការអប់រំបំណិនជីវិតតាមមូលដ្ឋាននៅកម្ពុជា | ✓ | ✓ | ✓ |
| **មេរៀនទី២**<br>ការជ្រើសរើសប្រធានបទ៖ កម្មវិធីសិក្សាតាមសាលារៀន | | ✓ | ✓ |
| **មេរៀនទី៣**<br>ទ្រឹស្តីការសិក្សាបែបស្ថាបនានិយម៖ សេចក្តីណែនាំ | ✓ | ✓ | ✓ |
| **មេរៀនទី៤**<br>គំរូអនុវត្តបំណិនជីវិតតាមមូលដ្ឋាន៖ ការសិក្សាអាស្រ័យលើបញ្ហា | ✓ | | |
| **មេរៀនទី៥**<br>វិធីបញ្ជ្រាប ICT នៅក្នុងដំណើការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន | ✓ | | |
| **មេរៀនទី៦**<br>ការបង្កើតភាពស៊ីសង្វាក់គ្នាសម្រាប់ធ្វើឱ្យការសិក្សាប្រសើរឡើង៖ បំណិនជីវិតតាមមូលដ្ឋាន និងការអនុវត្តរបស់ក្រសួងអប់រំ និងអង្គការក្រៅរដ្ឋាភិបាលដទៃទៀត | ✓ | | |
| **មេរៀនទី៧**<br>វង្វាយតម្លៃការសិក្សាតាមបែបគម្រោង ឬអាស្រ័យលើបញ្ហា៖ អ្វីត្រូវវាស់វែង និងតាមរបៀបណា | ✓ | | |

| | | | |
|---|---|---|---|
| **មេរៀនទី៨**<br>ការគាំទ្រការបង្កើតប្រព័ន្ធអេកូឡូស៊ីនៅក្នុងសាលារៀន | | ✓ | ✓ |
| **មេរៀនទី៩**<br>គាំទ្រយន្តការសម្រាប់គ្រូបង្រៀន និងនាយក ឬនាយិកាសាលារៀន | ✓ | ✓ | ✓ |

## ១.៣ របៀបប្រើប្រាស់ឯកសារ

ឯកសារណែនាំនេះ ប្រើប្រាស់និមិត្តសញ្ញាស្តង់ដាមួយចំនួនដូចខាងក្រោមដើម្បីជួយអ្នកសម្របសម្រួលឱ្យមានភាពងាយស្រួលក្នុងការប្រើប្រាស់ឯកសារ។ និមិត្តសញ្ញាទាំងនេះបង្ហាញពីប្រភេទសកម្មភាពត្រូវប្រើជាមួយអ្នកចូលរួមសម្រាប់ជំហានផ្សេងៗនៃផែនការបង្រៀននីមួយៗ។

**រយៈពេលបណ្តុះបណ្តាល**

**សកម្មភាពអ្នកសម្របសម្រួលគួរត្រៀម៖** មានព័ត៌មានពីរបៀបរៀបចំកន្លែងបណ្តុះបណ្តាលរបស់អ្នកសម្រាប់សកម្មភាពសិក្សា។ វាក៏ផ្តល់យោបល់ពីរបៀបរៀបចំសម្ភារដែលត្រូវការសម្រាប់សកម្មភាពផ្សេងៗផងដែរ។

**ធនធាន និងសម្ភារៈ** ផ្នែកនេះបង្ហាញពីសម្ភារចាំបាច់ផ្សេងៗមានដូចជាហ្វ៊ីត ឬក្រដាសផ្ទាំងធំជាដើម។ សម្ភារសិក្ខាសាលាផ្សេងទៀតនឹងមានភ្ជាប់មកជាមួយបន្ថែមក្នុងឯកសារចែកសម្រាប់អ្នកចូលរួម។ ជាទូទៅ អ្នកសម្របសម្រួលគួរត្រៀមថតចម្លងឯកសារចែកឱ្យបាន ២ច្បាប់។

**វត្ថុបំណងសិក្សា៖** បង្ហាញពីអ្វីដែលអ្នកចូលរួមនឹងទទួលបានពេលចប់ផ្នែកនីមួយៗនៃការបណ្តុះបណ្តាល និងរបៀបក្នុងការវាស់វែងការយល់ដឹងរបស់អ្នកចូលរួម។

## និមិត្តសញ្ញាបង្ហាញពីជំហាន និងដំណើរការ៖

សៀវភៅណែនាំនេះផ្តល់នូវវគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់អំពីរបៀបបណ្តុះបណ្តាលគ្រូដែលរំពឹងថានឹងអនុវត្តមុខវិជ្ជាជំនាញជីវិតតាមមូលដ្ឋានដោយយកចិត្តទុកដាក់លើការប្រើប្រាស់វិធីសាស្រ្តការសិក្សាបែបគម្រោងនៅតាមសាលារៀន និងបង្កើតសហគមន៍វិជ្ជាជីវៈនៃការរៀនដើម្បីគាំទ្រចំណេះដឹង និងឧត្តមានុវត្ត។ និមិត្តសញ្ញាខាងក្រោមត្រូវបានប្រើប្រាស់ដើម្បីណែនាំពីផែនការបណ្តុះបណ្តាលជាក់ស្តែង។ និមិត្តសញ្ញាទាំងនេះនឹងប្រាប់អ្នកសម្របសម្រួលពីសកម្មភាពគួរត្រៀមជាមុនសម្រាប់ការបណ្តុះបណ្តាល។ ផ្នែកនេះរួមមានសកម្មភាពអាចអនុវត្តបាន ការបង្កើតសំណួរគន្លឹះ ឧទាហរណ៍គំរូពីការអនុវត្តជាក់ស្តែង និងសកម្មភាពផ្សេងៗបន្ថែមទៀត។ ទោះជាមានការណែនាំថាអ្នកសម្របសម្រួលទាំងអស់ត្រូវអានមេរៀនទាំងមូលឱ្យបានច្បាស់លាស់ជាមុនក៏ដោយ តែពួកគេក៏អាចមើលទៅនិមិត្តសញ្ញាទាំងនេះ ហើយយល់ពីសកម្មភាពត្រូវអនុវត្តជាមួយអ្នកចូលរួមបានដែរ។


**សកម្មភាពត្រូវអនុវត្ត៖** និមិត្តសញ្ញានេះបង្ហាញថាអ្នកសម្របសម្រួលត្រូវធ្វើសកម្មភាពជាក់ស្តែងដូចជាចែកឯកសារ រៀបចំកន្លែងអង្គុយ រៀបចំក្រុមអ្នកចូលរួម។ល។


**ការសួរសំណួរ៖** និមិត្តសញ្ញានេះបង្ហាញថាអ្នកសម្របសម្រួលត្រូវសួរសំណួរគន្លឹះ ដើម្បីឱ្យអ្នកចូលរួមចាប់ផ្តើមការពិភាក្សា ឬធ្វើសកម្មភាពអ្វីមួយ។


**ការពិភាក្សា៖** និមិត្តសញ្ញានេះបង្ហាញថាអ្នកសម្របសម្រួលត្រូវដឹកនាំការពិភាក្សា ឬទុកឱ្យអ្នកចូលរួមពិភាក្សាអ្វីមួយជាក្រុម។


**ការកត់ត្រា៖** និមិត្តសញ្ញានេះបង្ហាញថាអ្នកចូលរួមត្រូវសរសេរ ឬកត់ត្រាអ្វីមួយលើក្រដាសផ្ទាំងធំ បំពេញកិច្ចការណាមួយ ឬការងារសរសេរផ្សេងៗ ។


**ការពន្យល់៖** និមិត្តសញ្ញានេះបង្ហាញថាអ្នកសម្របសម្រួលត្រូវបកស្រាយ ឬពន្យល់អ្វីមួយទៅអ្នកចូលរួម។

# ពាក្យជាអក្សរកាត់

| | |
|---|---|
| CPD | ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ |
| DCD | នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| DIT | នាយកដ្ឋានព័ត៌មានវិទ្យា និងបច្ចេកវិទ្យា |
| DOE | ការិយាល័យអប់រំស្រុក |
| EMIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ |
| HR | ធនធានមនុស្ស |
| HRMIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស |
| LSE | ការអប់រំបំណិនជីវិត |
| LLS | បំណិនជីវិតតាមមូលដ្ឋាន |
| LNGO | អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| NIE | វិទ្យាស្ថានជាតិអប់រំ |
| PLC | សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន |
| POE | មន្ទីរអប់រំខេត្ត |
| SBM | ការគ្រប់គ្រងតាមសាលារៀន |
| SEAMEO | អង្គការរដ្ឋមន្ត្រីអប់រំអាស៊ីអាគ្នេយ៍ |
| TTI | វិទ្យាស្ថានបណ្តុះបណ្តាលគ្រូ |
| TPAP | ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន |
| UNESCO | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ |
| UNICEF | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ |
| VMC | អង្គការស្ម័គ្រចិត្តសម្រាប់សហគមន៍យើង |
| VOD | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |

# ២. ផែនការមេរៀន សម្រាប់ អ្នកសម្របសម្រួល

# ផ្នែកទី១៖ សេចក្តីណែនាំការអប់រំបំណិនជីវិតនៅកម្ពុជា

## ២ មេរៀន

**សេចក្ដីសង្ខេប៖** នៅក្នុង២មេរៀនបន្ទាប់ យើងនឹងណែនាំការអប់រំបំណិនជីវិតតាមមូលដ្ឋាននៅកម្ពុជា និងសង្ខេបបញ្ញត្តិសំខាន់ៗដែលបានរៀនក្នុងអំឡុងវគ្គដំបូងនៃការរៀនតាមប្រព័ន្ធអេឡិចត្រូនិករបស់អ្នកចូលរួម។ យើងនឹងពិនិត្យមើលបញ្ញត្តិជាមូលដ្ឋានមួយចំនួនឡើងវិញដែលជាប់ពាក់ព័ន្ធនឹងបំណិនជីវិតតាមមូលដ្ឋានដើម្បីធានាបាននូវការយល់ដឹងរួមរវាងអ្នកចូលរួមទាំងអស់ និងបរិបទកម្មដ៏ត្រឹមត្រូវនៃកម្មវិធីបំណិនជីវិតតាមមូលដ្ឋានដែលជាអាទិភាពនៃការអប់រំនៅកម្ពុជាក្នុងសតវត្សរ៍ទី២១។ អ្នកចូលរួមនឹងឆ្លុះបញ្ចាំងពីសារៈសំខាន់នៃការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន និងកំណត់បាននូវវាក្យសព្ទមួយចំនួនដែលជារឿយៗត្រូវបានប្រើប្រាស់ជំនួសគ្នាទៅវិញទៅមក ដើម្បីជៀសវាងការភាន់ច្រឡំដូចជា បំណិនជីវិត បំណិនទន់ បំណិនដែលអាចផ្ទេរបាន ឬបំណិនសតវត្សរ៍ទី២១។ យើងនឹងពិភាក្សាអំពីទំនាក់ទំនងរវាងការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន ការសិក្សាបែបសកម្ម និងការអភិវឌ្ឍបំណិនទន់ក្រោមទស្សនវិជ្ជាការសិក្សាតាមបែបស្ថាបនានិយម ដែលជាចំណុចចាប់ផ្ដើមក្នុងការរៀនបំណិនជីវិតតាមមូលដ្ឋាន និងវិធីសាស្ត្របង្រៀនដែលសមស្របជាងនេះ។ នៅក្នុងមេរៀនចុងក្រោយអ្នកនឹងយល់កាន់តែស៊ីជម្រៅពីដំណើរការជ្រើសរើសប្រធានបទបានត្រឹមត្រូវ និងរបៀបដែលដំណើរការនេះអាចអនុវត្តដោយជោគជ័យ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធសំខាន់ៗព្រមទាំងសិស្សផងដែរ។



# មេរៀនទី១៖ ការអប់រំបំណិនជីវិត និងការអប់រំបំណិនជីវិតតាមមូលដ្ឋាននៅកម្ពុជា

រយៈពេលមេរៀន៖ បង្រៀន **៥ម៉ោង** (បន្ថែម១០ម៉ោងសម្រាប់ស្វ័យសិក្សា ការហាត់សម និងការអនុវត្ត)

សកម្មភាពអ្នកសម្របសម្រួលត្រូវត្រៀម៖

- ពិនិត្យមើលស្លាយទាំងអស់សម្រាប់មេរៀន រួមទាំងគោលបំណងសិក្សា
- ថតចម្លងឯកសារទាំងអស់ខាងក្រោម

ធនធាន និងសម្ភារៈ

- ស្លាយ (PPT) កុំព្យូទ័រ និងម៉ាស៊ីនបញ្ចាំងស្លាយ (LCD projector)
- ថតចម្លងឯកសារតេស្តដើមគ្រា
- ក្រដាស A4 & ប៊ិក
- ថតចម្លងឯកសារចែក ១.១៖ *ការបង្រៀនបំណិនជីវិត*
- ថតចម្លងឯកសារចែក ១.២៖ *សម្បត្តិ និងមកពា*
- ថតចម្លងឯកសារចែក ១.៣៖ *បំណិនទន់ និងបំណិនជីវិតតាមមូលដ្ឋាន*
- ថតចម្លងឯកសារចែក ១.៤៖ *ការអប់រំបំណិនជីវិតនៅកម្ពុជា*

វត្ថុបំណងមេរៀន៖

ពេលបញ្ចប់មេរៀនទី១ អ្នកចូលរួមនឹងអាច៖

- ពិពណ៌នាអំពីអាទិភាពនៃការអប់រំនៅសតវត្សរ៍ទី២១
- កំណត់លក្ខណៈសំខាន់ៗនៃការអប់រំបំណិនជីវិតតាមមូលដ្ឋាន
- ពន្យល់ពីទំនាក់ទំនងរវាងកម្មវិធីបំណិនជីវិត និងការអប់រំបំណិនជីវិតតាមមូលដ្ឋាននៅកម្ពុជា
- ពិពណ៌នាអំពីបញ្ញត្តិសំខាន់ៗទាក់ទងនឹងមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន
- ពិពណ៌នាអំពីធនធានដែលជាប់ពាក់ព័ន្ធសំខាន់បំផុតទៅនឹងការអប់រំបំណិនជីវិតតាមមូលដ្ឋាន

ការឆ្លុះបញ្ចាំង និងការអនុវត្តទ្រឹស្តីផ្សារភ្ជាប់ទៅនឹងការងារជាក់ស្តែង៖ អ្នកចូលរួមនឹង៖

- ឆ្លុះបញ្ចាំងពីរបៀបដែលការអប់រំបំណិនជីវិតតាមមូលដ្ឋានត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធអប់រំនៅកម្ពុជា
- ឆ្លុះបញ្ចាំងពីរបៀបដែលបំណិនជីវិតតាមមូលដ្ឋានឆ្លើយតបទៅនឹងអាទិភាពនៃការអប់រំសតវត្សរ៍ទី២១ នៅក្នុងបរិបទកម្ពុជា
- ឆ្លុះបញ្ចាំងលើទំនាក់ទំនងរវាងបំណិនជីវិតតាមមូលដ្ឋាន និងការគ្រប់គ្រងតាមសាលារៀន (SBM)

ឯកសារ និងការអាន៖

- ក្រសួងអប់រំ យុវជន និងកីឡា (ឆ្នាំ២០២១)៖ ក្របខណ្ឌការងារសេតវត្សរ៍ទី២១ សម្រាប់ប្រទេសកម្ពុជា៖ ជំពូកទី២ "ហេតុអ្វីបានជាប្រទេសកម្ពុជាត្រូវការក្របខណ្ឌការងារគរុកោសល្យថ្មី"។ ភាសាខ្មែរ និងភាសាអង់គ្លេស( Khmer version, English version. )។
- ក្រសួងអប់រំ យុវជន និងកីឡា (ឆ្នាំ២០១៩)៖ ឯកសារណែនាំសម្រាប់ការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន។ ជំពូកទី២៖ បញ្ញត្តិ និងគំរូនៃការអប់រំបំណិនជីវិត។

# ផែនការបង្រៀន-មេរៀនទី១

## ពិនិត្យឡើងវិញនូវគោលបំណងមេរៀន

បិតក្រដាសផ្ទាំងធំលើក្តារខៀន ឬស្លាយ ដែលសង្ខេបលទ្ធផលសិក្សាសម្រាប់ម៉ូឌុលនេះ។ ចូរពន្យល់ពីលទ្ធផលសិក្សា ហើយនេះគឺជាអ្វីដែលអ្នកចូលរួមគួរតែអាចធ្វើបាននៅពេលបញ្ចប់ម៉ូឌុល។ បន្ទាប់មកពន្យល់ពីគោលបំណងសិក្សាសម្រាប់មេរៀនទី១នេះ។

**ការធ្វើតេស្តដើមគ្រា** (Pre-test) កំណត់សមត្ថភាពមូលដ្ឋានរបស់អ្នកចូលរួម៖ ពន្យល់ដល់អ្នកចូលរួមថា នៅចុងបញ្ចប់នៃវគ្គសិក្សាពួកគេនឹងត្រូវស្នើសុំឱ្យធ្វើតេស្តចុងគ្រាម្តងទៀត ដើម្បីវាស់វែងសមត្ថភាពដែលទទួលបានពីវគ្គបណ្តុះបណ្តាលើប្រធានបទនីមួយៗ។ សូមអានសំណួរឱ្យឮៗ និងសូមបញ្ជាក់ចំណុចណាមួយតាមតម្រូវការរបស់អ្នកចូលរួម។ (ពេលវេលារំពឹងទុក៖ ៣០នាទី)។

## ចាប់ផ្តើមមេរៀនទី១

### ការអប់រំសម្រាប់សតវត្សរ៍ទី២១៖ បញ្ញត្តិគន្លឹះនៅកម្ពុជា

**សេចក្តីផ្តើម** មេរៀនទីមួយនេះណែនាំអំពីបញ្ញត្តិសំខាន់ៗ ដែលអាចឱ្យអ្នកចូលរួមរុករកតាមរយៈវគ្គបណ្តុះបណ្តាលដែលនៅបន្ទាប់។ អ្នកសម្របសម្រួលនឹងស្វែងរកប្រភពដើមនៃបញ្ញត្តិដូចជា ការអប់រំបំណិនជីវិត ការអប់រំបំណិនជីវិតតាមមូលដ្ឋាន និងអាទិភាពនៃការអប់រំនៅសតវត្សរ៍ទី២១ ការអភិវឌ្ឍបំណិនជីវិត (ឬបំណិនទន់) ការគ្រប់គ្រងតាមសាលារៀន និងថាតើពាក្យ និងបញ្ញត្តិទាំងនេះត្រូវបានប្រើប្រាស់ និងយល់ក្នុងបរិបទនៃការអប់រំនៅកម្ពុជា និងមានអន្តរកម្មរវាងគ្នាទៅវិញទៅមកដូចម្តេច។ បញ្ញត្តិទាំងនេះភាគច្រើនបានបង្ហាញរួចហើយដល់អ្នកចូលរួមទាំងអស់ក្នុងអំឡុងពេលវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកដែលពួកគេធ្លាប់បានចូលរួមពីមុនមក។ អ្នកចូលរួមទាំងអស់នឹងត្រូវបានលើកទឹកចិត្តឱ្យចែករំលែកចំណេះដឹងដែលមានស្រាប់ និងឆ្លុះបញ្ចាំងពីសារៈសំខាន់នៃការបង្រៀនបំណិនជីវិតនៅក្នុងសាលារៀន។

### បញ្ញត្តិគន្លឹះទី១៖ ការអប់រំបំណិនជីវិត តើការអប់រំបំណិនជីវិតគឺជាអ្វី?

**សកម្មភាព ធ្វើការជាដៃគូរយៈពេល ២០នាទី៖** ឯកសារ ១.១៖ *ការបង្រៀនបំណិនជីវិត*។

សូមអានសេចក្តីប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា ហើយឆ្លើយនឹងសំណួរដូចខាងក្រោម។

**ដកស្រង់ពីអត្ថបទ៖**

"ក្រសួងអប់រំរៀបចំផែនការការអប់រំបំណិនជីវិត" ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ (ប្រភព៖ ខ្មែរថែម Khmer Time)។

"ក្រសួងអប់រំ យុវជន និងកីឡា មានគោលបំណងបង្រៀនកម្មវិធីបំណិនជីវិតដែលអាចជួយឱ្យយុវជនវ័យក្មេងទទួលបានគោលដៅក្នុងការអនុវត្តជាក់ស្តែងដើម្បីធ្វើឱ្យជីវិតទាន់សម័យជោគជ័យនៅក្នុងសតវត្សរ៍ទី២១។

[...] បំណិនជីវិតពិតជាមានសារៈសំខាន់សម្រាប់ដោះស្រាយបញ្ហាដែលប្រឈមមុខជាមួយគ្រួសារជាប្រចាំ និងបញ្ហាប្រឈមប្រចាំថ្ងៃដែលកើតឡើងនៅក្នុងសង្គម និងកន្លែងធ្វើការងារ។

[...] ការសិក្សាបំណិនជីវិតអាចធ្វើឱ្យជីវិតរបស់សិស្សប្រសើរឡើង រួមទាំងសុខភាពផ្លូវកាយ និងផ្លូវចិត្ត។ បំណិនទន់អាចជួយឱ្យយុវជនបានយល់ដឹងកាន់តែប្រសើរឡើងលើការទទួលខុសត្រូវសង្គម អភិវឌ្ឍន៍តុល្យភាពអារម្មណ៍ និងការគ្រប់គ្រងក៏ដូចជាទំនុកចិត្តលើខ្លួនឯង។

## សំណួរពិភាក្សា

- បើតាមទស្សនៈរបស់អ្នក តើអ្វីទៅជាការអប់រំបំណិនជីវិត?
- ហេតុអ្វីបានជាអ្នកគិតថា ក្រសួងអប់រំ ត្រូវលើកទឹកចិត្តដល់សាលារៀនឱ្យបង្រៀនកម្មវិធីបំណិនជីវិត ឬបំណិនទន់?
- បើតាមទស្សនៈរបស់អ្នក តើកម្មវិធីបំណិនជីវិតអាចជួយដល់យុវជនបានយ៉ាងដូចម្តេចខ្លះ?

សូមពិភាក្សាជាដៃគូនូវសំណួរខាងលើ អ្នកសម្របសម្រួលត្រូវតែសង្ខេបចំណុចសំខាន់ៗ និងផ្តល់និយមន័យទូទៅនៃការអប់រំផ្អែកលើបំណិនជីវិត (នៅក្នុងប្រអប់ខាងក្រោម)។

**និយមន័យ៖** "**ការអប់រំផ្អែកលើបំណិនជីវិត** គឺជាទម្រង់មួយនៃការអប់រំដែលផ្តោតលើការសាបព្រោះបំណិនជីវិតបុគ្គល (*បំណិនទន់ ឬបំណិនសតវត្សរ៍ទី២១*) ដូចជាការស្វ័យឆ្លុះបញ្ចាំង កាគិតពិចារណាស៊ីជម្រៅ ការដោះស្រាយបញ្ហា និងបំណិនអន្តរបុគ្គល"។ ជាការពិត បំណិនជីវិតតាមមូលដ្ឋានកំណត់ចង្អោមមួយនៃ**កម្មវិធីបំណិនជីវិតស្នូលទាំងដប់ពីរ** ដោយប្រើប្រាស់គំរូការសិក្សាចំនួនបួនសមាសភាគ៖ "**រៀនដើម្បីចេះ** (សមាសភាគចំណេះដឹង) **រៀនដើម្បីធ្វើ** (សមាសភាគឧបករណ៍) **រៀនដើម្បីមានសីលធម៌ល្អ** (សមាសភាគបុគ្គល) និង**រៀនដើម្បីរស់នៅជាមួយគ្នា** (សមាសភាគសង្គម)។ កម្មវិធីបំណិនជីវិតស្នូលទាំងដប់ពីរគឺជាការសិក្សាពេញមួយជីវិត និងកសាងភស្តុតាងដែលបានបញ្ជាក់ពីសារៈខាន់ក្នុងការទទួលបានបំណិនចាប់តាំងពីក្មេង[1]។ យើងនឹងស្វែងយល់បន្ថែមទៀតនៅក្នុងមេរៀនដែលនិយាយពីបំណិនទន់ទាំងដប់ពីរនេះ។

អ្នកសម្របសម្រួលគួរកត់សម្គាល់លើតំណភ្ជាប់ជាមួយនឹងការអភិវឌ្ឍជំនាញទន់។ ការឆ្លុះបញ្ចាំងអំពីជំនាញទន់ណាមួយនឹងត្រូវពិនិត្យបន្ថែមទៀត។ បន្ទាប់មក អ្នកសម្របសម្រួលណែនាំសំណួរបំផុសគំនិតខាងក្រោម៖

[1] https://www.unicef.org/mena/life-skills-and-citizenship-education

## បញ្ញត្តិគន្លឹះទី២៖ បំណិនជីវិត បំណិនទន់ ឬបំណិនសតវត្សរ៍ទី២១

**សំណួរបំផុស (១៥នាទី)៖** តើអ្នកអាចប្រាប់ពី "បំណិនទន់" ណាមួយដែលអ្នកបានដឹងដែរឬទេ? គិតអំពីបំណិនទន់ទាំង១២ ដែលជាគោលដៅនៃការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន។ អ្នកសម្របសម្រួលគ្រាន់តែរៀបរាប់បន្តិចបន្តួច និងអមជាមួយអ្នកចូលរួមក្នុងការរៀបរាប់ពីបំណិនមួយ ឬពីរក្នុងអំឡុងពេលធ្វើសកម្មភាពនេះ។

**សកម្មភាព៖** សូមចែកតេស្តចុងគ្រា (Post Test) ដល់អ្នកចូលរួមទាំងអស់។ ណែនាំពួកគេឱ្យរំលឹកឡើងវិញពីបទពិសោធន៍ពីមុនមក ប៉ុន្តែជាបទពិសោធន៍ដែលបានមកពីការបណ្តុះបណ្តាលតាមអនឡាញដែលពួកគេបានរៀនចប់ (ប្រសិនបើមាន)។ សូមណែនាំឧទាហរណ៍បំណិនទន់គោលដៅមួយ ឬពីរពីបំណិនទន់ទាំង១២ នៃការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន ឧទាហរណ៍ ការគ្រប់គ្រងខ្លួនឯង និងការច្នៃប្រឌិត។ អ្នកសម្របសម្រួលក៏ត្រូវផ្តល់និយមន័យដំបូងនៃបំណិនទន់ផងដែរ៖

«... គឺជាអ្វីដែលចាំបាច់ដើម្បីសម្របខ្លួនទៅនឹងបរិបទជីវិតផ្សេងៗ ហើយមនុស្សអាចផ្ទេរប្រកបដោយសក្តានុភាពទៅលើផ្នែកផ្សេងៗគ្នានៃសង្គម វប្បធម៌ ឬការងារ។ បំណិនទន់រួមបញ្ចូលទាំងចំណេះដឹងបំណិនសង្គម និងអារម្មណ៍ ដែលអាចធ្វើឱ្យកុមារ និងក្មេងជំទង់បន្តការសិក្សាពេញមួយជីវិត ក្លាយជាពលរដ្ឋសកម្ម និងមានសមត្ថភាពពេញលេញ។ បំណិនទន់អាចដំណើរការជាមួយបំណិនផ្សេងៗទៀត (បំណិនមូលដ្ឋាន បំណិនការងារ និងបំណិនឌីជីថល) ហើយជួយពួកគេឱ្យមានទំនាក់ទំនង និងពង្រឹងគ្នាទៅវិញទៅមក»។

អ្នកសម្របសម្រួលចាប់ផ្តើមប្រមូលចម្លើយរបស់អ្នកចូលរួម ហើយរៀបចំចម្លើយផ្សេងៗគ្នា ចាត់បំណិនស្រដៀងៗគ្នាជាក្រុម និងបំបែកបំណិនរឹងចេញពីបំណិនទន់ ប្រសិនបើមាន។

អ្នកសម្របសម្រួលពន្យល់ថាពាក្យ "**ទន់**" ត្រូវបានប្រើដើម្បីផ្ទុយនឹងពាក្យ "**រឹង**" ដែលត្រូវបានប្រើដើម្បីកំណត់បំណិនមួយ។ ជាទូទៅ យើងនិយាយអំពីបំណិនទន់ នៅពេលណាយើងសំដៅលើសមត្ថភាពដែលទាក់ទងទៅនឹងលក្ខណៈរបស់មនុស្ស ចំណែកបំណិនរឹងគឺជាសមត្ថភាពបច្ចេកទេសដូចជាការជួសជុលម៉ូតូ ការងារកសិកម្ម ការជួសជុលកុំព្យូទ័រ ជាដើម។ មុននឹងចាប់ផ្តើមធ្វើការជាមួយនឹងបំណិនទន់ វាជារឿងសំខាន់ដែលគ្រូ និងសិស្សនឹងត្រូវយល់ច្បាស់អំពីអ្វីជាបំណិនទន់។

**(ជាជម្រើស)**

**បញ្ជីបំណិនរឹង ឬទន់ ដើម្បីជួយបញ្ជាក់ពីភាពខុសប្លែកគ្នារវាងបំណិនរឹង និងបំណិនទន់**

| **បំណិនរឹង ឬបំណិនទន់?** | **ចម្លើយត្រឹមត្រូវ** |
|---|---|
| សរសេរកម្មវិធីកុំព្យូទ័រ | បំណិនរឹង |
| ដោះស្រាយបញ្ហាជាមួយដៃគូ | បំណិនទន់ |
| ធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព | បំណិនទន់ |
| ដោះស្រាយបញ្ហា | បំណិនទន់ |
| ធ្វើបេងផ្ទះ | បំណិនរឹង |
| រចនាប្លង់ស្ពាន | បំណិនរឹង |
| ដំណើរការចុះបញ្ជីសាច់ប្រាក់ | បំណិនរឹង |

បន្ទាប់មកអ្នកសម្របសម្រួលលើកទឹកចិត្តឱ្យអ្នកចូលរួមគិតប្រសិនបើតាមទស្សនៈរបស់ពួកគេ បំណិនរឹងមានសារៈសំខាន់ជាងបំណិនទន់ ឬបំណិនទន់មានសារៈសំខាងជាបំណិនរឹង។

បន្ទាប់មកសួរអ្នកចូលរួម៖ "តើគេអាចប្រើប្រាស់បំណិនទន់ ដើម្បីធ្វើឱ្យបំណិនរឹងកាន់តែមានប្រសិទ្ធភាពបានដែរឬទេ"?

**ឧទាហរណ៍៖** គិតអំពីវិស្វករដែលរចនាប្លង់ស្ពាន៖ នាងមានចំណេះដឹងបច្ចេកទេសគ្រប់បែបយ៉ាងក្នុងការធ្វើកិច្ចការនេះ ប៉ុន្តែប្រសិនបើមានបញ្ហាដែលនឹកស្មានមិនដល់ តើបំណិនរឹងគ្រប់គ្រាន់ដែរឬទេ? ឬក៏បំណិនការច្នៃប្រឌិត ឬការដោះស្រាយបញ្ហាចាំបាច់ក្នុងការចូលរួមកែប្រែស្ថានភាពនោះ?

**ឧទាហរណ៍ផ្សេងទៀត៖** ដូចជាការធ្វើស្រែចំការ បើកសិករមិនដឹងពីបម្រែបម្រួលអាកាសធាតុ តើបំណិនរឹង (ចំណេះដឹងក្នុងការដាំដុះ) គ្រប់គ្រាន់ហើយឬនៅ?

## សេចក្ដីសន្និដ្ឋាន

បំណិនទាំងពីរមានសារៈសំខាន់ និងជាញឹកញាប់វាតែងតែបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមកដើម្បីធ្វើឱ្យមានប្រសិទ្ធភាពទាំងនៅសាលារៀន និងការងារនាពេលអនាគត ដូច្នេះបំណិនទាំងពីរចាំបាច់ត្រូវតែជាផ្នែកនៃការសិក្សានៅក្នុងថ្នាក់រៀន។ បំណិនរឹងមិនគ្រប់គ្រាន់ក្នុងការទប់ទល់នឹងបញ្ហាប្រឈមប្រចាំថ្ងៃបានទេ។ បំណិនទន់រួមចំណែកដល់ដំណើរការសិក្សាទាំងក្នុងប្រធានបទបំណិនជីវិតសង្គម និងបំណិនអាជីពងាយ ជាឧទាហរណ៍កសិករត្រូវការបំណិនទន់ច្រើនជាងត្រូវការអ្នកឯកទេសព័ត៌មានវិទ្យាម្នាក់។ ទាំងនេះនឹងអនុញ្ញាតឱ្យពួកគេទាំងពីរអាចទប់ទល់នឹងការផ្លាស់ប្តូរ បញ្ហាប្រឈម និងរៀបចំយុទ្ធសាស្ត្រការងាររបស់ពួកគេ។ សូមស្វែងយល់បន្ថែមនៅក្នុងករណីសិក្សាបន្ទាប់។

## ហេតុអ្វីបំណិនទន់មានសារៈសំខាន់?

**សំណួរបំផុស** (៥នាទី)៖ បច្ចុប្បន្ននេះវាជារឿងធម្មតាទេដែលឮថា បំណិនរឹងតែមួយមុខ មិនគ្រប់គ្រាន់សម្រាប់មនុស្សជំនាន់ថ្មី ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងជីវិតប្រចាំថ្ងៃ រួមទាំងកន្លែងធ្វើការ។ ហេតុអ្វីបានជាអ្នកគិតថាមនុស្សនិយាយដូច្នេះ?

**សកម្មភាព** ឯកសារ ១.២៖ ករណីសិក្សា ***សម្បត្តិ*** *និង* ***មករា***





- រយៈពេល (៣០នាទី)
- គំរូ៖ ដៃគូ

**សំណួរបំផុស (ដើម្បីពិភាក្សាជាមួយអ្នកចូលរួម)៖**

- តើ **មករា** ធ្វើអ្វីដើម្បីប្រឈមនឹងបញ្ហា?
- តើ **សម្បត្តិ** ធ្វើអ្វី?
- តើលទ្ធផលដូចម្ដេច?
- តើបំណិនអ្វីដែល **មករា** បានអនុវត្តដើម្បីព្យាយាមរកដំណោះស្រាយ?

**ចម្លើយរំពឹងទុក៖** បំណិនទន់ជួយឱ្យយល់ដឹង និងដោះស្រាយបញ្ហា បង្កើតគំនិតថ្មីៗ ចែករំលែកគំនិតយោបល់ជាមួយអ្នកដទៃប្រកបដោយប្រសិទ្ធភាព ស្វែងយល់ពីបញ្ហាប្រឈមថ្មីៗ និងស្វែងរកដំណោះស្រាយ។ ទន្ទឹមនឹងនេះ បំណិនទន់ជួយអ្នកការពារខ្លួនអ្នកពីបញ្ហាដែលអាចកើតមាន ធ្វើឱ្យប៉ះពាល់ដល់អ្នក និងមនុស្សជុំវិញ។ គ្រូបង្រៀននៅក្នុងសាលារៀនគួរតែអភិវឌ្ឍន៍បំណិនទាំងនេះដល់សិស្សដែលជួយឱ្យពួកគេចេះគិត និងឆ្លើយតបបានល្អដូច **មករា**។

**វាក្យសព្ទ "បំណិនទន់"** គឺជាពាក្យដែលប្រើច្រើនបំផុតនៅក្នុងឯកសារណែនាំអនុវត្តបំណិនជីវិតតាមមូលដ្ឋាន។ ដើម្បីឱ្យស្របជាមួយនឹងការបោះពុម្ពផ្សាយថ្មីៗ ដែលស្របទៅនឹងសំណុំបំណិនសតវត្សរ៍ទី២១ផងដែរ ឬគ្រាន់តែជាបំណិនជីវិត ឬបំណិនដែលអាចផ្ទេរបាន។ មនុស្សផ្សេងគ្នានឹងប្រើពាក្យផ្សេងគ្នា។

ចុងក្រោយ សូមទស្សនាវីដេអូដែលផលិតដោយអនុវិទ្យាល័យថ្មស ក្នុងខេត្តតាកែវ។ នាយកសាលាបានរៀបចំវីដេអូនេះ ដើម្បីព្យាយាមពន្យល់ដល់សាលារៀនផ្សេងទៀតអំពីឱកាសដែលសិស្សរបស់គាត់មាននៅពេលនេះ តាមរយៈប្រធានបទការអប់រំបំណិនជីវិតតាមមូលដ្ឋាន ដើម្បីអភិវឌ្ឍ និងអនុវត្តបំណិនទន់។

(ពេលវេលាសម្រាប់សកម្មភាព៖ ២០នាទី)

**វីដេអូទី១.១** បំណិនទន់នៅអនុវិទ្យាល័យថ្មស

**សំណួរបំផុស (ដើម្បីពិភាក្សាជាមួយអ្នកចូលរួម)៖** អ្នកសម្របសម្រួលសរសេរសំណួរនៅលើក្ដារខៀន ឬ ការធ្វើបទបង្ហាញដោយការបញ្ចាំងស្លាយ ហើយសូមអានមុនពេលមើលវីដេអូ។ ស្នើសុំឱ្យអ្នកចូលរួមធ្វើការកត់ត្រា ហើយបញ្ជាក់ថា អ្នកនឹងត្រូវពិភាក្សាបន្ទាប់ពីមើលវីដេអូនេះរួច។

- តើបំណិនទន់អ្វីខ្លះដែលគាត់បានលើកឡើងនៅក្នុងវីដេអូ?
- តើសកម្មភាពអ្វីខ្លះដែលជំរុញសិស្សឱ្យអភិវឌ្ឍន៍បំណិនទន់?
- ហេតុអ្វីបានជាវាមានសារៈសំខាន់សម្រាប់សិស្ស?
- តើអ្នកអាចនិយាយពីព័ត៌មានសំខាន់ៗណាមួយដែលគាត់បានចែករំលែកបានដែរឬទេ?

ចុងក្រោយ អ្នកសម្របសម្រួលចែកឯកសារ ១.៣៖ ស្ដីពីបំណិនទន់នៅក្នុងបំណិនជីវិតតាមមូលដ្ឋាន ដែលបានបញ្ជាក់ថា មុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានបានកំណត់គោលដៅដែលមាន១២ បំណិនទន់ ដូចដែលបញ្ជាក់ក្នុងកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋានឆ្នាំ២០១៨ ដែលដាក់ជាក្រុម ៤ ប្រភេទ៖

១. បំណិនសម្រាប់ការរៀនសូត្រ (ការច្នៃប្រឌិត ការរិះគិតពិចារណា ការដោះស្រាយបញ្ហា)
២. បំណិនសម្រាប់ការពង្រឹងអំណាចផ្ទាល់ខ្លួន (ការគ្រប់គ្រងខ្លួនឯង ភាពធន់ និងទំនាក់ទំនង)
៣. បំណិនសម្រាប់លទ្ធភាពរកការងារ (សហប្រតិបត្តិការ ការចរចា និងការសម្រេចចិត្ត)
៤. បំណិនសម្រាប់ភាពជាពលរដ្ឋ (ការគោរពពហុភាព សមានចិត្ត និងការចូលរួម)

ការធ្វើចំណាត់ថ្នាក់ទៅតាមប្រភេទដោយប្រើប្រាស់គំរូសិក្សាបួនសមាសភាគដែលជាប់ពាក់ព័ន្ធទៅនឹងសសរស្ដម្ភទាំង៤ របស់លោក **Delors** ដែលបានកំណត់ក្នុងឆ្នាំ១៩៩៦។ តើអ្នកចូលរួមចាំបានទេថា តើអ្វីជាសសរស្ដម្ភទាំង៤?

| **ក្រុមគោលដៅ បំណិនជីវិតតាមមូលដ្ឋាន** | **ចតុស្ដម្ភ** | **គំរូសិក្សាតាមសមាសភាគទាំង៤** |
|---|---|---|
| បំណិនសម្រាប់ការរៀនសូត្រ | **រៀនដើម្បីចេះ** | សមាសភាគពុទ្ធិ |
| បំណិនសម្រាប់ការពង្រឹងអំណាចផ្ទាល់ខ្លួន | **រៀនដើម្បីមានសីលធម៌ល្អ** | សមាសភាគបុគ្គលិកលក្ខណៈ |
| បំណិនសម្រាប់លទ្ធភាពរកការងារ | **រៀនដើម្បីធ្វើ** | សមាសភាគឧបករណ៍ |
| បំណិនសម្រាប់ភាពជាពលរដ្ឋ | **រៀនដើម្បីរួមរស់ជាមួយគ្នា** | សមាសភាគសង្គម |

**សេចក្ដីសន្និដ្ឋាន៖** គោលដៅចុងក្រោយនៃការអភិវឌ្ឍបំណិនទន់របស់សិស្សគឺធ្វើឱ្យកុមារ និងក្មេងជំទង់បន្តការសិក្សាពេញមួយជីវិត និងក្លាយជាពលរដ្ឋសកម្ម និងពលរដ្ឋប្រកបដោយផលិតភាព។ ឧទាហរណ៍៖ បំណិនសម្រាប់ការសិក្សានឹងអាចឱ្យសិស្សរៀនបង្កើតចំណេះដឹងដោយខ្លួនឯង ទីបំផុតពួកគេសម្រេចបាន **"រៀនពីរបៀបរៀន"** ដែលជាបំណិនសំខាន់បំផុតនៅក្នុងពិភពលោកដែលអាចមានការផ្លាស់ប្ដូរជាបន្តបន្ទាប់ ហើយជារឿយៗនោះយើងមិនអាចទាយទុកជាមុនបានឡើយ។ នៅពេលដែលគ្រូបង្រៀនអនុវត្តវិធីសាស្ត្រការសិក្សាបែបសកម្មនៅក្នុងថ្នាក់រៀន ដែលយើងនឹងស្វែងយល់បន្ថែមនៅក្នុងផ្នែកទី២។ វិធីសាស្ត្រនេះផ្ទាល់នឹងជួយគ្រូបង្រៀនក្នុងការលើកកម្ពស់ការសិក្សាបែបសកម្មរបស់សិស្ស និងធ្វើឱ្យសិស្សដឹកនាំការសិក្សា និងអនុវត្តបំណិនទន់ដូចជា ការប្រឈមមុខនឹងបញ្ហា ហើយព្យាយាមដោះស្រាយវា គិតអំពីដំណោះស្រាយដែលសមស្រប ធ្វើការសម្រេចចិត្ត ទំនាក់ទំនងជាមួយសមាជិកសហគមន៍ សហការជាក្រុមជាមួយមិត្តភក្ដិ។ នេះជាហេតុផលដែលការបង្រៀនបំណិនជីវិតតាមមូលដ្ឋានមានសារៈសំខាន់ វាបង្ហាញសិស្សនូវបទពិសោធន៍សិក្សាដែលអនុញ្ញាតឱ្យពួកគេអភិវឌ្ឍបំណិនរបស់ពួកគេ និងក្លាយជាបុគ្គលដែលអាចឆ្លើយតបទៅនឹងបញ្ហាប្រឈម ការផ្លាស់ប្ដូរ និងសកម្មនៅក្នុងសង្គម។




ព័ត៌មានបន្ថែមអំពីបំណិនទន់ និងវិធីជំរុញពួកគេក្នុងការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន អាចរកបាននៅក្នុងឯកសារ ក្រសួង. អយក (២០១៩) ឯកសារណែនាំអនុវត្តសម្រាប់បំណិនជីវិតតាមមូលដ្ឋាន ជំពូកទី៤ ពីទំព័រ២៨។

*អាចទាញយកនៅទីនេះ:* https://sala.moeys.gov.kh/library/00000347

*(សម្រាក)*

## បញ្ញត្តិគន្លឹះទី៣៖ បំណិនជីវិតតាមមូលដ្ឋាន

ដើម្បីណែនាំពីបញ្ញត្តិនៃការបង្រៀនបំណិនជីវិត និងការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន អ្នកសម្របសម្រួលសូមណែនាំសេចក្តីប្រកាសបន្ថែមមួយពីក្រសួងអប់រំ យុវជន និងកីឡានៅកម្ពុជា។

ជាក់ស្តែងកាលពីពេលថ្មីៗនេះ ក្រសួងអប់រំបានលើកឡើងនៅក្នុងសុន្ទរកថាផ្សេងៗថា គ្រូបង្រៀនទាំងអស់គួរតែជា**គ្រូបង្រៀនបំណិនជីវិត**។

សំណួរណែនាំសម្រាប់ការពិភាក្សា (១០នាទី)៖

- សំណួរទី១៖ តើអ្នកគិតថាគាត់ចង់មានន័យថាដូចម្តេច?
- សំណួរទី២៖ តាមទស្សនៈរបស់អ្នក តើគ្រូបង្រៀនគណិតវិទ្យា គ្រូមុខវិជ្ជាភាសាខ្មែរ ឬគ្រូមុខវិជ្ជាវិទ្យាសាស្ត្រអាចក្លាយជាគ្រូបង្រៀនបំណិនជីវិតបានដោយរបៀបណា? ហេតុអ្វីអាច? ហេតុអ្វីមិនអាច?

**ចម្លើយដែលរំពឹងទុក៖** អ្នកសម្របសម្រួលសង្ខេបនូវអ្វីដែលអ្នកចូលរួមលើកឡើង ហើយណែនាំពួកគេឱ្យសន្និដ្ឋានថា ក្រសួងអប់រំរំពឹងថាគ្រូបង្រៀនទាំងអស់ ដោយមិនគិតពីមុខវិជ្ជាដែលពួកគេបង្រៀន ពួកគេអាចធ្វើវាតាមវិធីរបស់ពួកគេ ដែលមិនត្រឹមតែបង្កើនចំណេះដឹងរបស់សិស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបំណិន និងអាកប្បកិរិយារបស់ពួកគេផងដែរ។ សិស្ស **"រៀនដើម្បីចេះ" "រៀនដើម្បីធ្វើ" រៀនដើម្បីមានសីលធម៌ល្អ" និង "រៀនដើម្បីរស់នៅជាមួយគ្នា"**។ គ្រូបង្រៀនត្រូវរៀបចំសិស្សមិនត្រឹមតែការសិក្សាមួយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឱ្យពួកគេអាចប្រឈមមុខ និងឆ្លើយតបទៅនឹងបញ្ហាប្រឈមក្នុងពិភពពិតដើម្បីអាចទទួលបានជោគជ័យក្នុងជីវិតជាមនុស្សពេញវ័យ។ នេះរួមបញ្ចូលទាំងសមត្ថភាពប្រព្រឹត្តដូចលោក **មករា** បានធ្វើដែរ។

របៀបដែលគ្រូបង្រៀនក្លាយជា "**គ្រូបង្រៀនបំណិនជីវិត**" នឹងត្រូវបានពិភាក្សានៅក្នុងផ្នែកទី២ នៃវគ្គបណ្តុះបណ្តាលនេះ នៅពេលដែលយើងនឹងពិនិត្យមើលការអនុវត្តការបង្រៀននៅក្នុងថ្នាក់រៀន។

អ្នកសម្របសម្រួលបន្តធ្វើការណែនាំពាក្យគន្លឹះបន្ទាប់គឺ **បំណិនជីវិតតាមមូលដ្ឋាន**។ ក្នុងវគ្គបណ្តុះបណ្តាលនេះ ជាការពិតអ្នកចូលរួមនឹងផ្តោតលើការបង្រៀន និងរៀនបំណិនជីវិតតាមមូលដ្ឋាន ដែលជាឧទាហរណ៍គំរូល្អនៃការអប់រំបំណិនជីវិត ដើម្បីលើកកម្ពស់បំណិនសិស្ស និងការអភិវឌ្ឍអាកប្បកិរិយា។

សូមបញ្ជាក់ជាមុនសិនថា បំណិនជីវិតតាមមូលដ្ឋានជាអ្វី។

**សំណួរណែនាំសម្រាប់អ្នកសម្របសម្រួល (១៥នាទី)**

- តើវាជាមុខវិជ្ជាដែរឬទេ?
- តើវាជាកាតព្វកិច្ចដែរឬទេ?
- តើកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ត្រូវបានបង្រៀននៅថ្នាក់ទីប៉ុន្មាន?
- តើពាក្យ "**តាមមូលដ្ឋាន**" សំដៅលើអ្វី?

**ចម្លើយរំពឹងទុក៖** បំណិនជីវិតតាមមូលដ្ឋាន គឺជាមុខវិជ្ជាសិក្សាគោល។ ក្របខណ្ឌកម្មវិធីសិក្សាឆ្នាំ២០១៥ បែងចែក២ម៉ោងក្នុងមួយសប្ដាហ៍សម្រាប់កម្រិតបឋមសិក្សា (ថ្នាក់ទី៤ ដល់ថ្នាក់ទី៦) ខណៈ១ម៉ោងក្នុងមួយសប្ដាហ៍សម្រាប់ថ្នាក់ទី៧ ដល់ទី៩។ វិសាលភាពនៃបំណិនជីវិតតាមមូលដ្ឋានគឺដើម្បីលើកទឹកចិត្តសិស្សឱ្យស្វែងយល់ពីបញ្ហាពិតពពិត និងផលប៉ះពាល់នៅក្នុងមូលដ្ឋានរបស់ពួកគេ និងស្វែងរកដំណោះស្រាយដែលសមស្រប។

យោង**ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៩** យើងសំដៅលើប្រធានបទដែលសិស្សត្រូវបានណែនាំឱ្យបង្កើតគម្រោង រុករក និងរៀនពីបរិបទក្នុងតំបន់របស់ពួកគេ ដោយមានឯកសារយោងជាក់លាក់ចំពោះបំណិនជីវិតផ្នែកអាជីពងាយ និងបំណិនសង្គម។ វាមានគោលបំណងផ្សារភ្ជាប់សិស្សទៅនឹងពិតពពិត **ដែលអនុវត្តចំណេះដឹងដែលពួកគេបានរៀនពីមុខវិជ្ជាផ្សេងៗ និងអភិវឌ្ឍបំណិនតាមរយៈការសិក្សាបែបសកម្ម និងគម្រោងសហគមន៍** ដែលនឹងជួយពួកគេឱ្យចេះប្រឈមមុខនឹងបញ្ហាប្រឈមក្នុងជីវិតប្រចាំថ្ងៃដោយផ្សារភ្ជាប់ទ្រឹស្ដីជាមួយនឹងការអនុវត្ត។

បន្ទាប់មក អ្នកសម្របសម្រួលចែក ឯកសារ ១.៤៖ *ការអប់រំបំណិនជីវិតនៅកម្ពុជា* ហើយស្នើឱ្យអ្នកចូលរួមរំលឹកឡើងវិញនូវនិយមន័យនៃការអប់រំបំណិនជីវិត។ បន្ទាប់មកទៀត សូមឱ្យអ្នកចូលរួមមើលឯកសារណែនាំអនុវត្ត ហើយពិភាក្សាជាដៃគូ ពីរបៀបដែលពួកគេគិតថា មុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានទាក់ទងនឹងការអប់រំបំណិនជីវិត។




បន្ទាប់មក ដឹកនាំការពិភាក្សាដោយណែនាំអំពីធាតុសំខាន់ៗដែលបង្ហាញក្នុងដ្យាក្រាមខាងលើ ដោយសួរថាតើវាពាក់ព័ន្ធយ៉ាងណាទៅនឹងការអប់រំបំណិនជីវិត។ ព្យាយាមមិនបង្ហាញព័ត៌មាននេះដោយផ្ទាល់ទៅកាន់អ្នកចូលរួមទេប៉ុន្តែដើម្បីឈានដល់ការធ្វើសេចក្តីសន្និដ្ឋានគឺត្រូវផ្អែកលើសំណួរ និងចម្លើយ។ អ្នកសម្របសម្រួលគួរតែអង្កេតឱ្យបានច្បាស់ថាតើអ្នកចូលរួមប៉ុន្មាននាក់បានអនុវត្តរួច ហើយនៅក្នុងសាលារៀនរបស់ពួកគេដែលទាក់ទងនឹងក្លឹបសិក្សា ឬសកម្មភាពក្រៅកម្មវិធីសិក្សា (ចំណុចទី៣) ការអប់រំបំណិនជីវិតតាមមូលដ្ឋាន គឺជាឧទាហរណ៍នៃការអប់រំបំណិនជីវិត។ បំណិនជីវិតតាមមូលដ្ឋាន ផ្តោតលើការបណ្តុះបំណិនទន់របស់សិស្ស *ពីព្រោះសិស្សនឹងត្រូវបានណែនាំឱ្យឈ្វេងយល់លើប្រធានបទនៅក្នុងសហគមន៍មូលដ្ឋានដែលប៉ះពាល់ដល់ពួកគេ និងព្យាយាមស្វែងរកដំណោះស្រាយ។*

**ហេតុអ្វីការបង្រៀនបំណិនជីវិតតាមមូលដ្ឋានមានសារៈសំខាន់?**

អ្នកសម្របសម្រួលត្រូវពន្យល់ថា ឥឡូវនេះយើងនឹងមើលវីដេអូរបស់សាលារៀនមួយនៅខេត្តសៀមរាប។ ពួកគេនឹងឮពីនាយកសាលា និងគ្រូបង្រៀន ដែលពន្យល់ពីទស្សនៈរបស់ពួកគេ ហេតុអ្វីបានជាបំណិនជីវិតតាមមូលដ្ឋានមានសារៈសំខាន់ដល់សិស្ស និងការផ្តល់យោបល់មួយចំនួនលើការអនុវត្ត។

តើសិស្សអាចធ្វើអ្វីបានអំឡុងពេលសិក្សាបំណិនជីវិតតាមមូលដ្ឋាន?

សូមចាប់ផ្តើមស្វែងរកអ្វីដែលសិស្សអាចធ្វើបាននៅសាលារៀនដែលអនុវត្តមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាននៅសាលារៀនដូចគ្នា។

**វីដេអូទី១.២** សិស្សមកពីសាលារៀនដានរ៉ុន៖

https://www.youtube.com/watch?v=-ub7FAewxd8&t=855s (ពីនាទី0:00ទៅនាទី១៣:០៥)

សំណួរបំផុសសម្រាប់ការឆ្លុះបញ្ចាំងលើខ្លឹមសារវីដេអូ៖

- តើពួកគេស្រាវជ្រាវលើប្រធានបទអ្វី?
- ហេតុអ្វីបានជាពួកគេស្រាវជ្រាវប្រធានបទនេះ?
- តើពួកគេធ្វើអ្វីដើម្បីស្វែងរកព័ត៌មាន?
- តើសិស្សបង្ហាញបំណិនអ្វីខ្លះនៅក្នុងវីដេអូនេះ? (ឧ. តើគេមានទំនុកចិត្តដែរឬទេ? តើពួកគេប្រាស្រ័យទាក់ទងគ្នាយ៉ាងណា? តើពួកគេសហការគ្នាដោយរបៀបណា?។ល។)
- តើអ្នកគិតថាសិស្សក្នុងសាលារៀនរបស់អ្នកអាចធ្វើដូចនេះបានដែរឬទេ?

**វីដេអូទី១.៣** នាយកសាលា និងគ្រូបង្រៀនពីអនុវិទ្យាល័យដានរ៉ុន៖ ហេតុអ្វីបានជាមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានមានសារៈសំខាន់? (ពីនាទី៖ ១៣:០៦)

សំណួរបំផុស

- ហេតុអ្វីបានជាបំណិនជីវិតតាមមូលដ្ឋានមានសារៈសំខាន់សម្រាប់នាយកសាលា?
- តើការផ្តល់យោបល់សំខាន់អ្វីខ្លះពីគ្រូបង្រៀន?

សូមមើលបន្ថែមទៀតនូវអ្វីដែលសិស្សអាចសម្រេចបានការសិក្សាបំណិនជីវិតតាមរយៈគម្រោងគំនិតផ្តួចផ្តើមដើងឯកនៃការផ្លាស់ប្តូររបស់អង្គការភ្លែនអន្តរជាតិនៅកម្ពុជា។

**ជើងឯកនៃការផ្លាស់ប្តូរ(CoC) គំរូឬស្ត្រីវ័យក្មេងក្នុងការដឹកនាំកម្មវិធីសមភាពយេនឌ័រ និងសិទ្ធិកុមារី អង្គការភ្លែនអន្តរជាតិកម្ពុជា**




ឧទាហរណ៍ដ៏ល្អមួយនៃគំនិតផ្តួចផ្តើមបំណិនជីវិតដែលកំពុងមានផលជះដល់កុមារ និងយុវជននៅកម្ពុជាគឺជាមេរៀន ជើងឯកនៃការផ្លាស់ប្តូរ (CoC) ដែលជាផ្នែកមួយនៃកម្មវិធីភាពជាអ្នកដឹកនាំស្ត្រីវ័យក្មេងរបស់អង្គការភ្លែនអន្តរជាតិ។ កម្មវិធីនេះលើកទឹកចិត្តកុមារា និងកុមារីឱ្យរិភាគយ៉ាងស៊ីជម្រៅលើបទដ្ឋានសង្គម និងចូលរួមយ៉ាងសកម្មក្នុងការតស៊ូមតិដើម្បីសមភាពយេនឌ័រក្នុងសង្គមកម្ពុជា ដោយផ្តួចផ្តើមឱ្យមានយុវជនដឹកនាំចលនាសង្គមដែលប្រឈមនឹងបទដ្ឋានសង្គម និងទទួលបានការគាំទ្រពីសង្គមទាំងមូលចំពោះសមភាពយេនឌ័រ និងសិទ្ធិកុមារី។

**ចូរស្តាប់អ្នកចូលរួមមួយចំនួន៖**

**កែវ** ជាយុវជនមានអាយុ ១៩ឆ្នាំ មកពីខេត្តសៀមរាប និយាយថា៖

*"ការផ្លាស់ប្តូរដ៏សំខាន់បំផុតរបស់ខ្ញុំគឺសមត្ថភាពដឹកនាំរបស់ខ្ញុំ ពីព្រោះខ្ញុំបានរៀនពីរបៀបដឹកនាំប្រកបដោយប្រសិទ្ធភាព។"*

ចៅសង្កាត់រងម្នាក់មកពីខេត្តរតនគិរី មានប្រសាសន៍ថា៖

*"យុវជនមានភាពក្លាហាន និងឆ្លាតជាងមុន ដោយសារការចូលរួមក្នុងកិច្ចប្រជុំ និងចែករំលែកនូវវឌ្ឍនភាពសកម្មភាពរបស់ពួកគេជាមួយក្លឹបកុមារ ឬយុវជន។ ជាងនេះទៀត កុមារខ្លះបានបោះបង់ការសិក្សាឥឡូវបានចូលរៀនវិញហើយ"* ។

**ឧត្តម** មានអាយុ ១៦ឆ្នាំ ជាមនុស្សម្នាក់មកពីគម្រោង គំនិតផ្តួចផ្តើមកម្មវិធីភាពជាអ្នកដឹកនាំស្ត្រីចាប់តាំងពីឆ្នាំ២០១៩ នៅខេត្តស្ទឹងត្រែង និយាយថា៖

*"ខ្ញុំចង់ធ្វើជាគំរូសម្រាប់ក្មេងស្រីដទៃទៀតក្នុងសហគមន៍របស់ខ្ញុំ ហើយសង្ឃឹមថាខ្ញុំនឹងជំរុញពួកគេតាមរយៈការខិតខំប្រឹងប្រែងរបស់ខ្ញុំ និងការចូលរួមក្នុងការអភិវឌ្ឍសង្គម និងសហគមន៍របស់ខ្ញុំ"។*




អ្នកសម្របសម្រួល៖ ឱ្យអ្នកចូលរួមចែករំលែកចំណាប់អារម្មណ៍របស់ពួកគេលើឧត្តមានុវត្តដែលបានធ្វើកន្លងមក។

## ធនធានដែលមានស្រាប់ដើម្បីណែនាំការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន

ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយដៃគូអភិវឌ្ឍ បាននឹងកំពុងបង្កើតធនធានយ៉ាងច្រើនគួរឱ្យកត់សម្គាល់ដើម្បីគាំទ្រដល់ការអនុវត្តលើមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន។ រួមមានប្រភេទធនធានបានផលិតចែកជាក្រុម ៣ផ្សេងៗគ្នា៖

១. គោលនយោបាយ

២. ឯកសារណែនាំអនុវត្ត

៣. ការគាំទ្រផ្នែកធនធានសម្ភារ

អ្នកត្រូវបានគេណែនាំពីឯកសារទាំងអស់ក្នុងអំឡុងពេលសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក និងចូរធ្វើការរំលឹកឡើងវិញ៖

**សកម្មភាព (៣០នាទី)៖** តើអ្នកស្គាល់បានប៉ុន្មាន? តើអ្នកបានអានប៉ុន្មាន?

https://forms.gle/5wVjBaWadqXkivx86

រាល់ឯកសារទាំងអស់គឺទាក់ទិនទៅនឹងកម្រិតសាលារៀនដោយមានគោលបំណងផ្សេងៗគ្នា៖

- **គោលនយោបាយ និងនីតិវិធី៖** ដើម្បីផ្តល់ភាពជាផ្លូវការនៃមុខវិជ្ជាដល់ស្ថាប័នពាក់ព័ន្ធ និងផ្តល់នូវលទ្ធផលសិក្សាច្បាស់លាស់ ពេលវេលានៃការបង្រៀន វិសាលភាព និងនីតិវិធីទូទៅ។
- **ឯកសារណែនាំអនុវត្ត៖** ផ្តល់ឯកសារយោងលើដំណើរការអនុវត្ត។ ឯកសារណែនាំទាំងពីរដែលមាននាពេលបច្ចុប្បន្ននេះពន្យល់ពីអ្វី និងរបៀបធ្វើវា។ ឯកសារទាំងនេះតំណាងឱ្យឯកសារយោងសម្រាប់គ្រូបង្រៀន និងនាយកសាលា ដើម្បីគាំទ្រការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន ជាពិសេសចំពោះសាលារៀនដែលទើបចាប់ផ្តើមអនុវត្ត។




- **ការគាំទ្រផ្នែកធនធានសម្ភារ៖** វាមានភាពផ្សេងៗគ្នានៃសៀវភៅណែនាំ ធនធានលើអ៊ីនធឺណិត សៀវភៅណែនាំវីដេអូ កម្មវិធីដែលត្រូវបានអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡា ដែលផ្តល់ខ្លឹមសារ និងរចនាសម្ព័ន្ធការបង្រៀនដែលបានផ្តល់យោបល់សម្រាប់មុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានដែលពាក់ព័ន្ធមួយចំនួនចាប់ពីអក្ខរកម្មឌីជីថល រហូតដល់សុខភាពបន្តពូជផ្លូវភេទ និងបម្រែបម្រួលអាកាសធាតុ។ល។ ធនធាននេះអាចប្រើប្រាស់បានច្រើនយ៉ាងអាស្រ័យលើតម្រូវការរបស់សាលារៀន។ វាត្រូវបានស្នើឱ្យប្រើប្រាស់សៀវភៅណែនាំបែបនេះដើម្បីទទួលបានព័ត៌មានដំបូងអំពីប្រធានបទ ហើយបញ្ចូលសៀវភៅណែនាំបែបនេះនៅក្នុងការអនុវត្តគម្រោង ព្រោះយើងនឹងស្វែងយល់បន្ថែមនៅមេរៀនបន្ទាប់។ វាជារឿងសំខាន់ដែលសាលារៀនមានលទ្ធភាពប្រើប្រាស់ធនធានបែបនេះ ជាពិសេសសម្រាប់ប្រធានបទដែល

ព័ត៌មានទូទៅគឺវាពិបាកក្នុងការចូលស្វែងរកនៅក្នុងសហគមន៍ ឬសាលារៀន។ ក្នុងអំឡុងពេលបណ្តុះបណ្តាលនេះយើងនឹងចែករំលែកព័ត៌មានបន្ថែមអំពីរបៀបកំណត់ទីតាំងធនធានជំនួយសំខាន់ៗដែលមាននាពេលបច្ចុប្បន្ន។

លោកគ្រូ អ្នកគ្រូ និងនាយកសាលាទាំងអស់ក៏មានលទ្ធភាពចូលរៀនតាមប្រព័ន្ធអនឡាញ ស្តីពីការអប់រំបំណិនជីវិតតាមមូលដ្ឋាន និងវគ្គបណ្តុះបណ្តាលបំណិនផ្សេងៗទៀត ដែលត្រូវបានរៀបចំឡើងដោយនាយកដ្ឋានទទួលបន្ទុករបស់ក្រសួងអប់រំ យុវជន និងកីឡា VOD និង DCD ក្នុងការសម្របសម្រួលជាមួយនាយកដ្ឋានព័ត៌មានវិទ្យា (DIT)។

**ប្រអប់ផ្តល់អនុសាសន៍៖** ត្រូវប្រាកដថា បុគ្គលិកសាលារៀនទាំងអស់មានសិទ្ធិចូលប្រើប្រាស់ឯកសារ ក៏ប៉ុន្តែត្រូវលើកទឹកចិត្តដល់លោកគ្រូ អ្នកគ្រូ សម្រាប់ពេលវេលាជាក់លាក់មួយក្នុងការចរចា និងពិនិត្យមើលគោលការណ៍ណែនាំ។ សូមរំលឹកផងដែរថា គួរតែបែងចែកពេលវេលាជាក់លាក់ដល់គ្រូបង្រៀនថ្មីៗ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការពិភាក្សា (ឧ. ក្នុងអំឡុងពេលប្រជុំថ្ងៃព្រហស្បតិ៍/សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន។ល។ វាមានសារៈសំខាន់ជាពិសេសសម្រាប់បុគ្គលិកដែលទើបជ្រើសរើសថ្មី សម្រាប់គ្រូកិច្ចសន្យា និងគ្រូក្របខណ្ឌ។ ឯកសារនេះផ្តល់ឱ្យគ្រូនូវឧទាហរណ៍ និងការណែនាំសម្រាប់ការអនុវត្ត។

**បញ្ចប់មេរៀនទី១**

# មេរៀនទី២៖ ដំណើរការជ្រើសរើសប្រធានបទ

*រយៈពេលបណ្តុះបណ្តាល៖* ៥ម៉ោង(បន្ថែម១០ម៉ោងសម្រាប់ស្វ័យសិក្សា ហាត់សម និងអនុវត្ត)

**សកម្មភាពអ្នកសម្របសម្រួលត្រៀម៖**

- ពិនិត្យមើលស្លាយទាំងអស់សម្រាប់មេរៀនរួមទាំងវត្ថុបំណងសិក្សា
- ថតចម្លងឯកសារចែកដូចខាងក្រោម

**ធនធាន និងសម្ភារៈ**

- ស្លាយ (PPT) កុំព្យូទ័រ ម៉ាស៊ីនបញ្ចាំងស្លាយ
- ក្រដាស A4 & ប៊ិក
- ថតចម្លង**ឯកសារចែក ២.១៖** *កម្មវិធីសិក្សាដែលបានចរចាកនៅម្រិតសាលារៀន*
- ថតចម្លង**ឯកសារចែក ២.២៖** *ការជ្រើសរើសប្រធានបទ និងឯកសារចែក*
- ថតចម្លង**ឯកសារចែក ២.៣៖** *ការកំណត់បញ្ហា*
- ថតចម្លង**ឯកសារចែក ២.៤៖** *ប្រធានបទ និងការរំពឹងទុកនៃការសិក្សា*
- ថតចម្លង**ឯកសារចែក ២.៥៖** *កម្មវិធីបំណែងចែកកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន ឧទាហរណ៍លើប្រធានបទ*
- រៀបចំតំណភ្ជាប់តាមអ៊ីនធឺណិតនៅក្នុងឧបករណ៍វាស់ស្ទង់ (ឬកម្មវិធីអនឡាញ**ស្រដៀង**គ្នាផ្សេងទៀត) សម្រាប់សំណួរ "**តើសហគមន៍មានបញ្ហាអ្វី?** (ជាជម្រើស)
- ថតចម្លងសៀវភៅឯកសារយោងសម្រាប់ប្រធានបទបំណិនជីវិតតាមមូលដ្ឋាន និងកម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋាន

**វត្ថុបំណងសិក្សា៖**

នៅទីបញ្ចប់មេរៀនទី២នេះ អ្នកចូលរួមនឹងអាច៖

- ពិពណ៌នាអំពីដំណើរការជ្រើសរើសប្រធានបទ
- កំណត់ប្រភេទប្រធានបទផ្សេងៗគ្នា ហើយវាមានភាពពាក់ព័ន្ធជាសកល និងតាមមូលដ្ឋាន
- ពន្យល់ពីរបៀបកំណត់បញ្ហានៅក្នុងសហគមន៍
- ពន្យល់អ្នកពាក់ព័ន្ធសំខាន់ៗដែលចូលរួមលើការជ្រើសរើសប្រធានបទ និងតួនាទីរបស់ពួកគេ

ការឆ្លុះបញ្ចាំង និងការអនុវត្តទ្រឹស្តីផ្សារភ្ជាប់ទៅនឹងការងារជាក់ស្តែង៖ អ្នកចូលរួមនឹងមាន៖

- ឆ្លុះបញ្ចាំងពីបញ្ហាប្រឈមដែលអាចកើតមាននៅក្នុងដំណើរការជ្រើសរើសប្រធានបទ
- វាយតម្លៃលើដំណោះស្រាយដែលសមស្រប ដើម្បីជួយសម្រួលដល់ដំណើរការជ្រើសរើស

ប្រធានបទ

- រៀបចំផែនការប្រធានបទដែលសមស្រប ដើម្បីពិចារណាក្នុងការអនុវត្តនៅតាមសាលារៀនរបស់ពួកគេ

### ឯកសារ និងកិច្ចការអាន៖

● ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) កសារណែនាំអនុវត្តបំណិនជីវិតតាមមូលដ្ឋាន ជំពូកទី៣ វគ្គទី៣.១ "ការជ្រើសរើសប្រធានបទ"

# ផែនការបង្រៀន-មេរៀនទី២

## ពិនិត្យមើលគោលបំណងមេរៀន

បិទក្រដាសផ្ទាំងធំលើក្ដារខៀន ដែលសង្ខេបលទ្ធផលសិក្សាសម្រាប់ម៉ូឌុលនេះ។ ពន្យល់ពីលទ្ធផលសិក្សាដែលនេះគឺជាអ្វីដែលអ្នកចូលរួមគួរតែអាចធ្វើបាននៅពេលបញ្ចប់ម៉ូឌុល។

## កម្មវិធីសិក្សាដែលបានចរចាកម្រិតសាលារៀន

ចាប់ផ្ដើមមេរៀននេះដោយចែកឯកសារ ២.១៖ *ការពន្យល់និយមន័យកម្មវិធីសិក្សាដែលបានចរចានៅកម្រិតសាលារៀន*។ សូមមើលពាក្យគន្លឹះទាំងអស់នេះ៖ (១) **នៅកម្រិតសាលារៀន** (២) **ដែលបានចរចា** (៣) **កម្មវិធីសិក្សា**។

**សំណួរបំផុស** (១០នាទី)៖ តើអ្នកគិតថា អ្វីទៅជាកម្មវិធីសិក្សាដែលបានចរចានៅកម្រិតសាលារៀន?

**សកម្មភាព** (៣០នាទី)៖

**សកម្មភាពទី១៖** រៀបចំក្រដាសផ្ទាំងធំ រួចសរសេរកម្មវិធីសិក្សាដែលបានចរចានៅកម្រិតសាលារៀននៅចំកណ្ដាលក្រដាសផ្ទាំងធំ និងចែកក្រដាស់ស្អិតពណ៌ដល់អ្នកចូលរួម។ ស្នើឱ្យអ្នកចូលរួមសរសេរពី ៣ ទៅ ៥ ពាក្យ ឬគំនិតទៅនឹងពាក្យ (ពាក្យនីមួយៗទាក់ទងទៅនឹង "កម្មវិធីសិក្សាដែលបានចរចាកម្រិតសាលារៀន")។ បង្ហើតជាឧទាហរណ៍មួយចំនួន៖

- ការចរចា → ការពិភាក្សា និងការប្រឹក្សា
- កម្រិតសាលារៀន → ការផ្ដល់សិទ្ធិអំណាច និងការសម្រេចចិត្តតាមមូលដ្ឋាន។

**សកម្មភាពទី២៖** រៀបចំពាក្យជាក្រុម ក្រោមពាក្យគន្លឹះនីមួយៗនៃកម្មវិធីសិក្សាដែលបានចរចានៅកម្រិតសាលារៀន។

**សកម្មភាពទី៣៖** អានចម្លើយមួយចំនួន រួចគូសបញ្ជាក់ពីចម្លើយដែលស្រដៀងគ្នា និងសុំឱ្យអ្នកចូលរួមចែករំលែកការយល់ដឹងរបស់ពួកគេ។

លក្ខណៈសំខាន់ៗនៃកម្មវិធីសិក្សាដែលបានចរចានៅកម្រិតសាលារៀន ដែលបានពិភាក្សាគួរតែបញ្ចូល៖

- កម្មវិធីសិក្សាដែលបានចរចាកនៅម្រិតសាលារៀនសំដៅលើវិធីសាស្ត្រផ្តល់សិទ្ធិអំណាចដល់ថ្នាក់ក្រោមដែលចូលរួមធ្វើការសម្រេចចិត្តរបស់សាលារៀនអំពីកម្មវិធីដែលឆ្លើយតបទៅនឹងតម្រូវការសិក្សារបស់សិស្ស។

- ដំណើរការធ្វើការសម្រេចចិត្តរួមគ្នា (មានអ្នកពាក់ព័ន្ធចូលរួមផ្សេងៗ) និងគណនេយ្យភាពចំពោះការអប់រំរបស់កូនពួកគេ។

- វាតំណាងឱ្យជម្រើសមួយចំពោះការសម្រេចចិត្ត "ពីលើចុះក្រោម" ឬកម្មវិធីសិក្សាមជ្ឈការ។

    - ដោយសារហេតុផលនេះហើយ បំណិនជីវិតតាមមូលដ្ឋានត្រូវបានលើកឡើងជាញឹកញាប់ថាជាគំរូដ៏ល្អនៃការគ្រប់គ្រងតាមសាលារៀន។

- វាអនុវត្តតាមគោលការណ៍ និងដំណើរការលម្អិតដោយរដ្ឋាភិបាលថ្នាក់ជាតិ ដែលគ្រូបង្រៀនអាចសម្របខ្លួន និងមានភាពច្នៃប្រឌិតទៅនឹងតម្រូវការរបស់សិស្សរបស់ពួកគេ (ទាក់ទងនឹងដំណើរការជ្រើសរើសប្រធានបទ វិធីសាស្ត្រនៃការបង្រៀន និងការវាយតម្លៃ)។
- នៅកម្ពុជា ពាក្យ "ចរចា" ត្រូវបានបន្ថែមដើម្បីពង្រឹងបញ្ញត្តិដែលភាគីពាក់ព័ន្ធផ្សេងៗគ្នា រួមទាំងសិស្ស នាយកសាលា គ្រូបង្រៀន អ្នកតំណាងសហគមន៍ និងអាជ្ញាធរមូលដ្ឋានរួមចំណែកក្នុងការជ្រើសរើសប្រធានបទ ជ្រើសរើសការអភិវឌ្ឍកម្មវិធីសិក្សាតាមសាលារៀនដែលបានរៀបចំជាធម្មតាក្នុងអំឡុងពេលធ្វើផែនការកែលម្អសាលារៀនសម្រាប់ឆ្នាំសិក្សាបន្ទាប់។

**ការគ្រប់គ្រងតាមសាលារៀននៅកម្ពុជា** (SBM)**៖** ការគ្រប់គ្រងតាមសាលារៀននៅកម្ពុជាគឺជាវិធីសាស្ត្រវិមជ្ឈការមួយសម្រាប់អភិបាលកិច្ចសាលារៀន និងការធ្វើសេចក្តីសម្រេចក្នុងគោលបំណងលើកកម្ពស់គុណភាពអប់រំ និងការចូលរួមរបស់សហគមន៍។ វាផ្តល់ឱ្យសាលារៀននូវស្វ័យភាពនៅក្នុងផ្នែកដូចជា ការរៀបចំថវិកា និងការអភិវឌ្ឍកម្មវិធីសិក្សា។ សាលារៀនបង្កើតផែនការកែលម្អសាលារៀន **(SIPs)** ដោយចរចាជាមួយសហគមន៍។ គណៈកម្មការគ្រប់គ្រងសាលារៀនដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំការសម្រេចចិត្ត។ សរុបសេចក្តីមក **ការគ្រប់គ្រងតាមសាលារៀននៅកម្ពុជា** (SBM) មានគោលបំណងផ្តល់សិទ្ធិអំណាចដល់សាលារៀន លើកកម្ពស់លទ្ធផលនៃការអប់រំ និងជំរុញការចូលរួមរបស់សហគមន៍ដែលមានចែងនៅក្នុងការអប់រំបំណិនជីវិតតាមមូលដ្ឋាន។

**ស្តង់ដាសាលារៀនគំរូ** នៅដើមឆ្នាំ២០២៤ ក្រសួងអប់រំ យុវជន និងកីឡា បានប្រកាសឱ្យប្រើប្រាស់នូវស្តង់ដាសាលារៀនគំរូ។ ក្រសួងអប់រំ បានកំណត់ស្តង់ដា៥ ដើម្បីអន្តរាគមន៍ដោយមានសូចនាករកំណត់ដែលសាលារៀនត្រូវសម្រេចឱ្យបានដើម្បីក្លាយជាសាលារៀនគំរូ។ សាលារៀនចូលរួមក្នុងកម្មវិធីនេះតាមការស្ម័គ្រចិត្ត។ នៅក្នុងស្តង់ដាទី២ "គុណភាពនៃការសិក្សា" ក៏មានសូចនាករដែលសំដៅទៅលើការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន( សូចនាករ ២.៦ នៅកម្រិតបឋមសិក្សា "ភាគរយនៃថ្នាក់ទី៤ ដល់ ទី៦ រៀនបំណិនជីវិតតាមមូលដ្ឋាន" យ៉ាងហោចណាស់ឱ្យបាន ៧០%។



| | | | | | | | |
|---|---|---|---|---|---|---|---|
| ២.៦ | ភាគរយថ្នាក់ទី៤-៦បានបង្រៀនមេរៀន បំណិនជីវិតមូលដ្ឋាន | - របាយការណ៍បុគ្គលិកស្ដីពីការបង្រៀនបំណិនជីវិតមូលដ្ឋានរបស់សាលារៀន<br>- បំណែងចែកកាលវិភាគ និងមេរៀនដែលត្រូវបង្រៀនសិស្ស<br>- មានបញ្ចូលពិន្ទុបំណិនជីវិតមូលដ្ឋាន ក្នុងបញ្ជីពិន្ទុសៀវភៅតាមដានការសិក្សា និងសៀវភៅសិក្ខាគារិកជាដើម<br>- ការបញ្ជាក់ពីសិស្សានុសិស្ស និងអ្នកពាក់ព័ន្ធផ្សេងទៀត | ≤៥០% | >៥០% | >៧០% | >៨៥% | ≤៩៥% |

របៀបដែលបំណិនជីវិតតាមមូលដ្ឋានចូលរួមចំណែកក្នុងការកសាងសាលារៀនគំរូ៖

| **ស្តង់ដាសាលារៀនគំរូ** | **កម្មវិធីបំណិនជីវិតតាមមូលដ្ឋានចូលរួមចំណែក** |
|---|---|
| **ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស** | ការអភិវឌ្ឍបំណិនសតវត្សរ៍ទី២១ គឺជាអាទិភាពក្នុងដំណើរការសិក្សាបំណិនជីវិតតាមមូលដ្ឋាន។ |
| **ស្តង់ដាទី២៖ ដំណើរការបង្រៀន និងរៀន** | ការលើកកម្ពស់ការងារគម្រោងរបស់សិស្ស ដោយប្រើវិធីសាស្ត្រការសិក្សាអាស្រ័យលើបញ្ហា ដែលជាផ្នែកមួយនៃទស្សនវិជ្ជាការសិក្សាបែបស្ថាបនានិយម គឺជាគោលការណ៍សំខាន់ក្នុងការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន។ |
| **ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍** | ប្រសិទ្ធភាពនៃបំណិនជីវិតតាមមូលដ្ឋានអាស្រ័យលើការផ្សារភ្ជាប់សិស្ស និងគណៈគ្រប់គ្រងសាលារៀនដើម្បីទំនាក់ទំនងជាមួយសហគមន៍។ ការចូលរួមរបស់សហគមន៍ គឺជាផ្នែកមួយនៃដំណើរការសិក្សាមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន ដែលសិស្សអង្កេតបញ្ហាដែលមាននៅក្នុងសហគមន៍ និងស្វែងរកដំណោះស្រាយដែលសមស្រប។ |
| **ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន** | ការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន គឺអាស្រ័យលើអភិបាលកិច្ចល្អ និងការបង្កើតប្រព័ន្ធអេកូគរុកោសល្យប្រកបដោយប្រសិទ្ធភាពនៅក្នុងសាលារៀន។ |
| **ស្តង់ដាទី៥៖ គណនេយ្យភាព** | អភិបាលកិច្ចល្អ និងគណនេយ្យភាពចំពោះសិស្ស ឪពុកម្តាយ និងសហគមន៍ត្រូវបានលើកកម្ពស់ និងជាផ្នែកមួយដ៏សំខាន់នៃការបណ្តុះបណ្តាលបំណិនជីវិតតាមមូលដ្ឋានជាមួយសាលារៀន។ |

# ដំណើរការជ្រើសរើសប្រធានបទ

អ្នកសម្របសម្រួលចែកឯកសារ ២.២៖ *ការជ្រើសរើសប្រធានបទ និងពន្យល់* ពីសកម្មភាពបន្ទាប់របស់អនុវិទ្យាល័យ **ចាន់ ស** ខេត្តសៀមរាប។ អនុវិទ្យាល័យ **ចាន់ ស** គឺជាសាលារៀនដំបូងគេដែលចូលរួមនៅក្នុងការអនុវត្តបំណិនជីវិតតាមមូលដ្ឋានដើមឆ្នាំសិក្សា២០១៥-១៦។ មិនយូរប៉ុន្មានវាបានក្លាយជាសាលារៀនគំរូសម្រាប់សាលារៀនផ្សេងទៀត ហើយបានចាប់ផ្តើមផលិតវីដេអូដើម្បីគាំទ្រដល់សាលារៀនផ្សេងទៀតក្នុងការអនុវត្ត ដូចជាវីដេអូដែលយើងនឹងឃើញនៅពេលនេះ។

**សកម្មភាពណែនាំ**

- **ជំហានទី១** សូមអានសំណួរខាងក្រោមមុនពេលមើលវីដេអូ វានឹងជួយអ្នកឱ្យយល់អំពីបញ្ញត្តិសំខាន់ៗដែលបានពន្យល់។
- **ជំហានទី២** មើលវីដេអូអំពីដំណើរការជ្រើសរើសប្រធានបទ។
- **ជំហានទី៣** ពិភាក្សាក្នុងក្រុម ហើយឆ្លើយសំណួរនៅក្នុងឯកសារចែកជូន។
- **ជំហានទី៤** ចែករំលែកចម្លើយរបស់អ្នកនៅក្នុងក្រុម។

**មើលវីដេអូទី២.១** ពីសាលារៀនក្នុងការជ្រើសរើសប្រធានបទ (៣០ នាទី)៖
https://www.youtube.com/watch?v=b6G7Q8piIAo

**ការកំណត់បញ្ហា**

ភាពខុសគ្នាចម្បងរវាងបំណិនជីវិតតាមមូលដ្ឋាន និងមុខវិជ្ជាផ្សេងទៀតគឺបំណិនជីវិតតាមមូលដ្ឋាន មិនមានសៀវភៅសិក្សាគោលទេ៖ ដូច្នេះសៀវភៅសិក្សាគោលមិនមែនជាចំណុចចាប់ផ្តើមនោះទេ។ ផ្ទុយទៅវិញសាលារៀន **បង្កើតគម្រោងដោយចាប់ផ្តើមពីការកំណត់បញ្ហា** នៅក្នុងកម្រិតសាលារៀន ឬសហគមន៍។

ការកំណត់អត្តសញ្ញាណបញ្ហាគឺជាដំណើរការដែលចាប់ផ្តើមពីចំណាប់អារម្មណ៍របស់សិស្ស និងសេណារីយ៉ូក្នុងពិភពពិតនៅក្នុងសហគមន៍។ ដោយផ្អែកលើគំនិតផ្សេងគ្នាដែលបានស្នើឡើង សាលារៀននឹងជ្រើសរើសប្រធានបទដោយប្រើលក្ខណៈវិនិច្ឆ័យជាច្រើន។ **ទីមួយ** សាលារៀននឹងត្រូវកំណត់បញ្ហាដែលពាក់ព័ន្ធ **ទីពីរ** ពួកគេនឹងត្រូវពិចារណាពីធនធាន និងព័ត៌មានដែលមាននៅក្នុងសាលារៀន និងក្នុងសហគមន៍ ដើម្បីអង្កេតបញ្ហានេះ។ ប្រសិនបើបញ្ហាត្រូវបានជ្រើសរើសត្រឹមត្រូវ ដែលបញ្ជាក់ថាវាពាក់ព័ន្ធ នោះនឹងមានព័ត៌មានដែលត្រូវប្រមូលជានិច្ច។ សម្រាប់ហេតុផលនេះ ដូចដែលយើងបានឃើញភាគីផ្សេងគ្នាចូលរួមនៅក្នុងដំណើរការនេះ។

**សំណួរបំផុស៖** អ្នកសម្របសម្រួលឱ្យអ្នកចូលរួមគិតអំពី "**តើសហគមន៍មានបញ្ហាអ្វី?** អ្នកចូលរួមត្រូវបានលើកទឹកចិត្តឱ្យគិតអំពីសាលារៀន និងសហគមន៍របស់ពួកគេ។

ប្រើប្រាស់កម្មវិធី Mentimeter App ដើម្បីធ្វើការបំផុសគំនិតនេះជាផ្នែកមួយនៃការបង្ហាញដល់អ្នកចូលរួមពីរបៀបបញ្ច្រាបព័ត៌មានវិទ្យា ICT ក្នុងដំណើរការបង្រៀន និងរៀន។ (ជាជម្រើស៖ ផ្តល់ក្រដាសពណ៌ស្អិតដល់អ្នកចូលរួមដើម្បីសុំឱ្យពួកគេសរសេរជម្រើសឱ្យបាន ៣ ហើយបិទបង្ហាញវានៅក្នុងក្រដាសផ្ទាំងធំ)




ការសន្និដ្ឋានដែលសមស្រប (សម្រាប់អ្នកសម្របសម្រួល)។ មានបញ្ហាជាច្រើនដែលសិស្សអាចអង្កេតក្នុងសហគមន៍ ហើយវាមានឥទ្ធិពលដល់ជីវិតរបស់ពួកគេ។ បញ្ហាខ្លះកើតឡើងញឹកញាប់ ខ្លះតែម្តងគត់ ខ្លះពិបាកអង្កេត និងទៀតខ្លះអាចមានគ្រោះថ្នាក់ ប៉ុន្តែភាគច្រើនយើងត្រូវស្វែងរកបញ្ហាដែលអ្នកពាក់ព័ន្ធទាំងអស់ឱ្យឯកភាពគ្នាសម្រាប់កម្រិតថ្នាក់ ឬថ្នាក់រៀននីមួយៗ។ ជាចុងក្រោយ យើងអាចសួរខ្លួនឯងថា តើមានស្ថានភាពដែលយើងមិនចង់ឱ្យមាននៅក្នុងសហគមន៍ ឬសាលារៀនរបស់យើង និងវិធីដែលយើងមិនចង់ឱ្យសិស្សក្លាយជាបែបនោះ។ **ឧទាហរណ៍៖** អំពើហិង្សាក្នុងសាលារៀន ឬការបៀតបៀន ឬក្មេងទំនើង។ សូមមើលឧទាហរណ៍មួយចំនួនខាងក្រោមនៃបញ្ហាពីផ្នែកម្ខាង និងឱកាសផ្នែកម្ខាងទៀត "អ្វីដែលយើងចង់មាន ឬក្លាយជា" នៅក្នុងជួរឈរផ្សេងទៀត។

*រូបភាពទី១ បញ្ហាដែលអាចកើតមាន និងឱកាស*

ជាជាងកំណត់គោលដៅសម្រាប់បញ្ជីបញ្ហាពេញលេញ អ្នកសម្របសម្រួលត្រូវពន្យល់ថា សាលារៀនអាចពិចារណាប្រើប្រាស់លក្ខណៈវិនិច្ឆ័យមួយចំនួនដែលមានរាយដូចខាងក្រោមនៅពេលកំណត់បញ្ហាក្នុងសហគមន៍៖

**លក្ខណៈវិនិច្ឆ័យ**



- បញ្ហាកើតឡើងញឹកញាប់ (ញឹកញាប់)
- បញ្ហាកើតមានមួយរយៈ (រយៈពេល)

- បញ្ហាប៉ះពាល់ដល់មនុស្សជាច្រើន ជាពិសេសសិស្ស (វិសាលភាព ឬទំហំ)
- បញ្ហាគឺមានសុវត្ថិភាពសម្រាប់សិស្សក្នុងការអង្កេត (សុវត្ថិភាព)
- បញ្ហាត្រូវបានគេយល់ថាជាបញ្ហា(**ការយល់ឃើញ**)[2]

លក្ខណៈវិនិច្ឆ័យចុងក្រោយនេះ ការយល់ឃើញ គឺជាកត្តាសំខាន់មួយ ហើយក៏អាចជួយបង្ហាញពីការត្រៀមខ្លួនសម្រាប់ការដោះស្រាយបញ្ហាក្នុងសហគមន៍ផងដែរ។ អ្វីដែលត្រូវបានគេមើលឃើញថាជាបញ្ហា អាចខុសគ្នាពីកន្លែងមួយទៅកន្លែងមួយ និងពីក្រុមមួយទៅក្រុមក្នុងសហគមន៍តែមួយ។ ទោះបីជាមិនមាននិយមន័យផ្លូវការនៃបញ្ហាសហគមន៍ក៏ដោយ ក៏ឧទាហរណ៍ និងលក្ខណៈវិនិច្ឆ័យខាងលើអាចផ្តល់ឱ្យសាលារៀនក្នុងការកំណត់អត្តសញ្ញាណបាន។

អ្នកសម្របសម្រួលចែកឯកសារ ២.៣៖ កំណត់បញ្ហា និងពន្យល់ពីតួនាទី។ អ្នកចូលរួមត្រូវធ្វើការងារជាក្រុមដែលមានសមាជិកពី ៤ ទៅ ៥នាក់។ វិសាលភាពនៃសកម្មភាពគឺសម្រាប់អ្នកចូលរួមធ្វើការឆ្លុះបញ្ចាំងពីអ្វីដែលជាប្រធានបទដែលអាចកើតមានឡើង និងរបៀបដែលប្រធានបទត្រូវបានជ្រើសរើសដោយចេតនា។ (**ពេលវេលាណែនាំ៖ ៤៥នាទី**)៖

**ទិសដៅ និងតួនាទី៖** នាយកសាលាមានតួនាទីដឹកនាំការសន្ទនា និងធានាថាបញ្ហាដែលបានស្នើឡើងអនុវត្តតាមលក្ខណៈវិនិច្ឆ័យដែលបានផ្តល់ ហើយចុងក្រោយត្រូវកំណត់ពីការរួមចំណែកពីភាគីពាក់ព័ន្ធនីមួយៗ។

សមាជិកផ្សេងទៀតមានបញ្ជីបញ្ហាដែលពួកគេអាចស្នើឡើង និងព្យាយាមតស៊ូមតិ។ ប្រសិនបើត្រូវបានជ្រើសរើស ពួកគេក៏មានលក្ខណៈពិសេសផងដែរ ដែលប្រធានបទដែលពួកបានចូលរួមចំណែក។ ប្រធានបទចុងក្រោយនឹងត្រូវបានជ្រើសរើសដោយការបោះឆ្នោត ប៉ុន្តែអ្នកចូលរួមត្រូវតែប្រាកដថាប្រធានបទដែលបានជ្រើសរើសគឺ**ពាក់ព័ន្ធសម្រាប់ជីវិតរបស់សិស្ស និងផលប្រយោជន៍របស់ពួកគេ**។ អ្នកសម្របសម្រួលត្រូវលើកទឹកចិត្តឱ្យអ្នកចូលរួមគិតអំពីការចូលរួមរបស់កុមារក្នុងការជ្រើសរើសប្រធានបទ។

**សំណួរឆ្លុះបញ្ចាំង** អ្នកសម្របសម្រួលគាំទ្រការសង្ខេបពីសកម្មភាពដែលណែនាំអ្នកចូលរួមឱ្យឆ្លុះបញ្ចាំងពីផ្នែកសំខាន់ៗមួយចំនួននៃសកម្មភាពដូចជា៖

[2] https://www.youthlead.org/resources/analyzing-community-problems

- តើអ្វីទៅដែលប្រព្រឹត្តទៅបានល្អ?
- តើអ្វីជាបញ្ហាប្រឈមចម្បង? តើអ្នកបានដោះស្រាយវាដោយរបៀបណា?
- តើអ្នកអាចធ្វើវាបាននៅក្នុងសាលារៀនរបស់អ្នកបានដែរឬទេ? តើនឹងមានបញ្ហាប្រឈមអ្វីខ្លះ? តើអ្នកនឹងដោះស្រាយវាដោយរបៀបណា?

## ប្រភេទប្រធានបទ

នៅពេលគិតអំពីប្រធានបទ ចំណាត់ថ្នាក់ដំបូងដែលអាចពិចារណាបាន គឺរវាងប្រធានបទពាក់ព័ន្ធជា**សកល** និងក្នុង**មូលដ្ឋាន។**

អ្នកសម្របសម្រួលសួរអ្នកចូលរួមថា ប្រសិនបើពួកគេអាចគិតពីឧទាហរណ៍មួយនៃប្រធានបទជាសកល និងមួយទៀតសម្រាប់ប្រធានបទពាក់ព័ន្ធក្នុងមូលដ្ឋាន។

តើអ្វីទៅជាទំនាក់ទំនងរវាងប្រធានបទដែលពាក់ព័ន្ធជាសកល និងពាក់ព័ន្ធក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក?

*(សម្រាប់អ្នកសម្របសម្រួល)*

- ឧទាហរណ៍នៃប្រធានបទពាក់ព័ន្ធជាសកល៖ ការប្រែប្រួលអាកាសធាតុ បញ្ហាយេនឌ័រ សិទ្ធិកុមារ សុខភាពផ្លូវចិត្ត សុខភាពបន្តពូជផ្លូវភេទ អក្ខរកម្មឌីជីថល...
- ប្រធានបទពាក់ព័ន្ធក្នុងមូលដ្ឋាន៖ ការធ្វើចំណាកស្រុកខ្ពស់របស់យុវជននៅក្នុងភូមិ ករណីគ្រុនឈាមច្រើននៅក្នុងភូមិ ទឹកជំនន់ប៉ះពាល់ដល់ជីវភាពសហគមន៍។ល។

នៅក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន សិស្សត្រូវបានលើកទឹកចិត្តឱ្យអង្កេតប្រធានបទដែលពាក់ព័ន្ធសម្រាប់ជីវិតរបស់ពួកគេ។ ចាប់តាំងពីការបង្កើតដំបូងនៃបំណិនជីវិតតាមមូលដ្ឋាន នៅក្នុងប្រទេសកម្ពុជា ការផ្ដោតការយកចិត្តទុកដាក់លើបំណិនជីវិតតាមមូលដ្ឋាន បានផ្លាស់ប្ដូរបន្តិចម្ដងៗពីបំណិនអាជីពងាយ ដើម្បីរួមបញ្ចូលប្រធានបទបំណិនសង្គម។

អ្នកសម្របសម្រួលសួរអ្នកចូលរួម៖ ហេតុអ្វីបានជាអ្នកគិតថារឿងនេះវាកើតឡើង?

***ចម្លើយរំពឹងទុក៖*** ដំបូងឡើយ បំណិនជីវិតតាមមូលដ្ឋាន មានបំណងជាការបណ្ដុះបណ្ដាលបុរេវិជ្ជាជីវៈដែលកុមារកំពុងរៀនបំណិនបច្ចេកទេស ដែលពួកគេអាចប្រើប្រាស់នៅផ្ទះដើម្បីជួយគ្រួសាររបស់ពួកគេ ជាពិសេសទាក់ទងនឹងវិស័យកសិកម្ម។ បន្តិចម្ដងៗ អាទិភាពនៃការអប់រំកំពុងផ្លាស់ប្ដូរទៅបញ្ហាបំពេញបន្ថែមផ្សេងទៀត ដែលប៉ះពាល់ដល់ជីវិតរបស់សិស្ស និងនាំទៅរកការសម្រេចចិត្តដែលមាន

ព័ត៌មានបន្ថែមទៀតនាពេលអនាគត។ ប្រធានបទពាក់ព័ន្ធសង្គមបានចាប់ផ្តើមរួមមាន ច្បាប់ចរាចរណ៍ ការប្រើប្រាស់គ្រឿងញៀន សុខភាពបន្តពូជ មេរោគអេដស៍ ការថែទាំសុខភាពបឋម ការធ្វើចំណាក ស្រុក បរិស្ថាន ឬការសេពគ្រឿងស្រវឹង និងមួយចំនួនទៀត។

បន្ទាប់មក អ្នកសម្របសម្រួលបន្ថែមថា គោលការណ៍ណែនាំបំណិនជីវិតតាមមូលដ្ឋានឆ្នាំ ២០១៩ ក៏បានណែនាំគំរូពីរផ្សេងគ្នាផងដែរគឺ ប្រធានបទបំណិនសង្គម និងបំណិនអាជីពងាយ ហើយ មានប្រធានបទជាច្រើនដែលអាចជ្រើសរើសបានទាំងផ្នែកបំណិនសង្គម និងបំណិនអាជីពងាយ។

អ្នកសម្របសម្រួលចែក ឯកសារ ២.៤៖ "*ប្រធានបទ និងការរំពឹងនៃលទ្ធផលសិក្សា*" ឱ្យអ្នកចូលរួមធ្វើការជាក្រុមមានគ្នាពី ៤ ទៅ ៥នាក់ ត្រូវមានក្រដាសផ្ទាំងធំ និងហ្វឺត។ អ្នកសម្រប សម្រួលពន្យល់ដល់អ្នកចូលរួមថា ឥឡូវនេះពួកគេនឹងធ្វើការងារជាក្រុម ដើម្បីឆ្លុះបញ្ចាំងពីទំនាក់ទំនង រវាងប្រភេទប្រធានបទ និងលទ្ធផលសិក្សាដែលរំពឹងទុករបស់សិស្ស (២០នាទី)។

នៅចុងបញ្ចប់នៃសកម្មភាព អ្នកសម្របសម្រួលណែនាំអ្នកចូលរួមឱ្យឆ្លុះបញ្ចាំងពី សកម្មភាព ដោយប្រើសំណួរឆ្លុះបញ្ចាំងដូចខាងក្រោម (ជាឯកសារយោងសម្រាប់អ្នកសម្របសម្រួល ដែលអាចបន្ថែមសំណួរបន្ថែមទៀតដោយអាស្រ័យលើលទ្ធផលការងាររបស់អ្នកចូលរួម)៖

- តើអ្នកយល់ថាវាងាយស្រួលក្នុងការកំណត់ប្រធានបទក្នុងចំណោមគំរូទាំងពីរនេះដែរឬទេ?
- តើមានភាពខុសគ្នាអ្វីខ្លះទាក់ទងនឹងលទ្ធផលសិក្សារំពឹងទុក?

**សេចក្តីសន្និដ្ឋាន៖** ការជ្រើសរើស និងការអង្កេតទាំងប្រធានបទបំណិនសង្គម និងបំណិនអាជីពងាយគឺ មានសារៈសំខាន់។ សិស្សទទួលបានចំណេះដឹងផ្សេងៗគ្នា តាមរយៈការរៀន និងការអនុវត្តបំណិនស្រ ដៀងគ្នាក្នុងដំណើរការសិក្សា ប៉ុន្តែពួកគេក៏អភិវឌ្ឍបំណិនបច្ចេកទេសមួយចំនួនទៀត ព្រមទាំងមាន សមត្ថភាពទាក់ទងនឹង "បំណិនសហគ្រិន" ផងដែរ ដូចជាការធ្វើផែនការ ការធ្វើផែនការថវិកា ឬ ផលិតផលទីផ្សារ ឬការសរសេរប្រវត្តិរូបសង្ខេប ជាដើម។

អ្នកសម្របសម្រួលបន្តពន្យល់ថា ការឆ្ពោះទៅមុខក្នុងប៉ុន្មានឆ្នាំមកនេះ ការសង្កត់ធ្ងន់ជា ទូទៅត្រូវបានផ្តល់ទៅឱ្យការជ្រើសរើសប្រធានបទដែលផ្តល់ឱកាសដល់សិស្សក្នុងការអង្កេតបញ្ហា ឬ ឱកាសបង្កើតគម្រោងមួយនៅក្នុងសហគមន៍របស់ពួកគេ (ស្វែងរកដំណោះស្រាយ ឬការកសាង ផលិតផល)។

អ្នកសម្របសម្រួលសួរអ្នកចូលរួម៖ ហេតុអ្វីបានជាអ្នកគិតថារឿងនេះកើតឡើង?

**ចម្លើយរំពឹងទុក៖** ផ្តល់ឱកាសឱ្យសិស្សចូលរួមក្នុងការងារគម្រោងដែលអនុញ្ញាតឱ្យពួកគេស្វែងយល់ពីបញ្ហានៅក្នុងសហគមន៍ បង្កើតការសិក្សាយ៉ាងសកម្ម ជំរុញការសិក្សាបែបឯករាជ្យ ថែមទាំងផ្តល់ឱកាសឱ្យមានការសិក្សាបែបសហការជាមួយអ្នកដទៃ និងអនុវត្តបំណិនផ្សេងៗ រួមទាំងបំណិនការគិតពិចារណាស៊ីជម្រៅ មើលបញ្ហាឱ្យបានស៊ីជម្រៅដើម្បីស្វែងរកដំណោះស្រាយ ឬរៀនធ្វើការសម្រេចចិត្ត ឬរៀនទំនាក់ទំនងជាមួយមនុស្សផ្សេងៗគ្នា។ ការសិក្សាទាំងអស់នេះនឹងអាចអនុវត្តបាន ហើយមានការពាក់ព័ន្ធក្នុងជីវិតនាពេលអនាគត។

## បញ្ជីប្រធានបទ ឬព័ត៌មានកម្មវិធីសិក្សាលម្អិត

សាលារៀនមួយចំនួនប្រហែលជាពិបាកកំណត់ប្រធានបទផ្សេងៗគ្នានៅក្នុងឆ្នាំសិក្សានីមួយៗ។ សម្រាប់គោលបំណងនេះតារាងរៀបចំប្រធានបទតាមលំដាប់បំណិនជីវិតតាមមូលដ្ឋានត្រូវបានរៀបចំ តារាងលំដាក់ថ្នាក់នេះរួមបញ្ចូលទាំងឧទាហរណ៍នៃប្រធានបទ ដោយបានបែងចែករវាងប្រធានបទបំណិនសង្គម និងបំណិនអាជីពងាយ។ វាបានផ្តល់នូវឧទាហរណ៍នៃបញ្ហាដើម្បីអង្កេត និងមានធនធានដែលអាចផ្តល់ព័ត៌មានដំបូងដល់សិស្ស និងគាំទ្រគ្រូក្នុងការដឹកនាំការរៀបចំការងារគម្រោង។

អ្នកសម្របសម្រួលចែកឯកសារដែលបានដកស្រង់ចេញពីប្រធានបទ **កម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋានសម្រាប់ថ្នាក់ទី ៤-៦ និង ៧-៩** (ឯកសារ ២.៥ ឧទាហរណ៍ប្រធានបទកម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋាន) ដែលមានការគូសផែនទីចង្អុលប្រាប់អំពីប្រធានបទដែលត្រូវបានអង្កេតក្នុងកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន និងជាផ្នែកមួយនៃខ្លឹមសារប្រធានបទផ្សេងទៀត។ មុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានអាចផ្តល់ពេលវេលាដើម្បីអង្កេតពីរបៀបដែលបញ្ហាទាំងនេះកើតឡើងនៅក្នុងសហគមន៍។ សាលារៀនក៏អាចប្រើប្រាស់បំណិនជីវិតតាមមូលដ្ឋាន ដើម្បីស្វែងយល់ពីស្ថានភាពជាក់ស្តែងនៃប្រធានបទដែលសិស្សសិក្សាទ្រឹស្តីនៅក្នុងកម្មវិធីសិក្សានៃមុខវិជ្ជាផ្សេងទៀត ដែលជាធម្មតាមាននៅក្នុងមុខវិជ្ជាសិក្សាសង្គមវិទ្យា វិទ្យាសាស្ត្រ គណិតវិទ្យា ឬកម្មវិធីសិក្សាសុខភាព។ ជាឧទាហរណ៍ សិស្សានុសិស្សទាំងបឋម និងមធ្យមសិក្សា សិក្សាពីច្បាប់ចរាចរណ៍ ប្រធានបទសុខភាព ឬសុខភាពផ្លូវចិត្ត ដើម្បីលើកឡើងតិចតួចនៅក្នុងការសិក្សាសង្គម ប៉ុន្តែពួកគេមិនបានអង្កេតការអនុវត្តរបស់វានៅក្នុងសហគមន៍ និងមិត្តភក្តិរបស់ពួកគេទេ។

***សកម្មភាព៖*** អ្នកសម្របសម្រួលពន្យល់ថា វីដេអូនេះគឺជាឧទាហរណ៍នៃការអនុវត្តចំណេះដឹងកម្មវិធីសិក្សាសុខភាពនៅក្នុងសេណារីយ៉ូពិតនៃសហគមន៍មូលដ្ឋាន តាមរយៈមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន។

## វីដេអូ ទី២.២ ជំងឺគ្រុនឈាម

**សំណួរបំផុស (វីដេអូឈ្នះបញ្ហាំង)៖**

- តើសិស្សបានអង្កេតប្រធានបទដោយរបៀបណា?
- តើប្រភពនៃព័ត៌មានត្រូវបានប្រើប្រាស់អ្វីខ្លះ?
- តើអ្នកគិតថាសិស្សរបស់អ្នកនឹងអាចធ្វើកិច្ចការនេះបានដែរឬទេ?
- បើតាមទស្សនៈរបស់អ្នក ប្រសិនបើធ្វើសកម្មភាពបែបនេះ តើសិស្សរៀនអ្វីខ្លះទាក់ទងនឹងបំណិនទន់?

## ឧត្តមានុវត្ត និងគន្លឹះសម្រាប់ការជ្រើសរើសប្រធានបទ

ជាចុងក្រោយ អ្នកសម្របសម្រួលបង្ហាញដល់អ្នកចូលរួមនូវសៀវភៅយោងសម្រាប់បំណិនជីវិតតាមមូលដ្ឋាន ដែលរួមមានធនធានពាក់ព័ន្ធដែលមាននៅកម្ពុជាសម្រាប់ប្រធានបទជាក់លាក់ចំនួន៥ ដូចជា**ការប្រែប្រួលអាកាសធាតុ សមភាពយេនឌ័រ សុខភាពបន្តពូជ អក្ខរកម្មឌីជីថល និងការគ្រប់គ្រងភាពតានតឹង**។ ប្រធានបទទាំង ៥ នេះត្រូវបានគេកំណត់ថាជាប្រធានបទពាក់ព័ន្ធទូទៅជាសកល និងក្នុងតំបន់សម្រាប់សិស្ស ប៉ុន្តែពួកគេពិបាកក្នុងការស្វែងរកព័ត៌មាន។ នៅក្នុងឯកសារនេះសាលារៀននឹងរកឃើញបញ្ជីសម្ភារផ្សេងៗដែលមានជាភាសាខ្មែរសម្រាប់ប្រធានបទបំណិនអាជីពងាយ និងបំណិនសង្គម ដែលអាចធ្វើការប្រឹក្សាបាន។ ផ្តល់ពេលវេលាដល់អ្នកចូលរួមដើម្បីមើលឯកសារ។ បើអាចធ្វើបានសូមចែកឯកសារថតចម្លងមួយ ឬយ៉ាងហោចណាស់ឯកសារជាសុហ្វសម្រាប់អ្នកចូលរួមម្នាក់ៗ ហើយអាចរកបាននៅលើគេហទំព័ររបស់ក្រសួងអប់រំ។

**បញ្ចប់មេរៀនទី២**

# ៥ មេរៀន

**សេចក្តីសង្ខេប៖ ផ្នែកទី២** ផ្តោតលើរបៀបបង្រៀនមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន ដោយមានការណែនាំពីទ្រឹស្តីស្ថាបនានិយម និងទំនាក់ទំនងរបស់វាជាមួយវិធីសាស្ត្ររៀនអាស្រ័យលើបញ្ហា។ អ្នកអប់រំនឹងយល់ពីរបៀបអនុវត្តវិធីសាស្ត្រសិក្សាអាស្រ័យលើបញ្ហាជាមួយសិស្សក្នុងមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន ដោយចាប់ផ្តើមជាទូទៅពីបញ្ហាជីវិតពិតនៅក្នុងសហគមន៍ និងសាលារៀន ។ អ្នកចូលរួមនឹងយល់ពីទំនាក់ទំនងរវាងបញ្ហា និងការអប់រំបំណិនជីវិតតាមមូលដ្ឋាន ហើយនឹងប្រៀបធៀបជាមួយវិធីសាស្ត្រប្រពៃណីបន្ថែមទៀតដើម្បីវិភាគពីអត្ថប្រយោជន៍ និងបញ្ហាប្រឈមរបស់វា។ តាមរយៈករណីសិក្សាដែលបានជ្រើសរើសដោយបំណងប្រាថ្នា អ្នកចូលរួមនឹងវិភាគការអនុវត្តការរៀនអាស្រ័យលើបញ្ហានៅក្នុងថ្នាក់រៀនបំណិនជីវិតតាមមូលដ្ឋាន។ ការប្រើប្រាស់ព័ត៌មានវិទ្យា (ICT) ក្នុងការបង្រៀន និងរៀនរបស់កម្មវិធីបំណិនជីវិតតាមមូលដ្ឋាននឹងត្រូវបានបង្ហាញ។ អ្នកចូលរួមនឹងត្រូវណែនាំឱ្យកំណត់នូវភាពស៊ីសង្វាក់គ្នាដែលមាននៅក្នុងប្រធានបទបំណិនជីវិតតាមមូលដ្ឋាន និងគំនិតផ្តួចផ្តើមរបស់ក្រសួងអប់រំ យុវជន និងកីឡា នៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលលើកកម្ពស់ការចូលរួមយ៉ាងសកម្មរបស់យុវជន និងការស្ម័គ្រចិត្ត។ ជាចុងក្រោយ មេរៀនទី៧ នឹងអនុញ្ញាតឱ្យអ្នកចូលរួមឆ្លុះបញ្ចាំងអំពីដំណើរការវាយតម្លៃ និងឧបករណ៍ដែលសមស្របបំផុតដើម្បីប្រើប្រាស់ក្នុងប្រធានបទបំណិនជីវិតតាមមូលដ្ឋាន។



# មេរៀនទី៣៖ ទ្រឹស្តីការសិក្សាបែបស្ថាបនានិយម ការសិក្សាបែបគម្រោង និងការអប់រំបំណិនជីវិតតាមមូលដ្ឋាន

**ពេលវេលាមេរៀន៖** បង្រៀន៥ម៉ោង (បន្ថែម១០ម៉ោងស្វ័យសិក្សា ហាត់សម និងអនុវត្ត)

**សកម្មភាពអ្នកសម្របសម្រួលគួរត្រៀម៖**

- សរសេរវត្ថុបំណងសិក្សានៅលើក្រដាសផ្ទាំងធំដើម្បីណែនាំមេរៀន
- គូរដ្យាក្រាមដែលបង្ហាញនៅក្នុងឯកសារ ៣.២ នៅលើក្រដាសផ្ទាំងធំ
- គូរលើក្រដាសផ្ទាំងធំនូវដំណើការ ៦ដំណាក់កាល (ឯកសារ ៣.៦) និងក្រដាសផ្ទាំងធំបំណិនទន់ (ឯកសារ ៣.៨)
- ថតចម្លងឯកសារចែកទាំងអស់ដូចមានក្នុងបញ្ជីខាងក្រោម

**ធនធាន និងសម្ភារៈ**

- លទ្ធផលសិក្សានៅលើសន្លឹកក្រដាសផ្ទាំងធំដើម្បីណែនាំមេរៀន
- ក្រដាសផ្ទាំងធំ ហ្វឺត ស្កុតបិត
- ឯកសារថតចម្លងដ្យាក្រាមដែលគូរដោយដៃ ដែលបង្ហាញក្នុងឯកសារ ៣.២
- ថតចម្លងឯកសារចែក ៣.១៖ ការសិក្សាបែបស្ថាបនានិយម និងការសិក្សាបែបគម្រោង
- ថតចម្លងឯកសារចែក ៣.២៖ ការសិក្សាបែបស្ថាបនានិយម និងវិធីសាស្ត្រពាក់ព័ន្ធការសិក្សាបែបស្ថាបនានិយម
- ថតចម្លងឯកសារចែក ៣.៣៖ ឧទាហរណ៍នៃការសិក្សាបែបគម្រោង
- ថតចម្លងឯកសារចែក ៣.៤៖ ការសិក្សាអាស្រ័យលើគម្រោង និងអាស្រ័យលើបញ្ហា
- ថតចម្លងឯកសារចែក ៣.៥៖ ដំណើរការទាំង ៦ដំណាក់កាល
- ថតចម្លងឯកសារចែក ៣.៦៖ ក្រដាសផ្ទាំងធំដំណើរការ ៦ដំណាក់កាល
- ថតចម្លងឯកសារចែក ៣.៧៖ ក្រដាសផ្ទាំងធំពីបំណិនទន់
- ថតចម្លងឯកសារចែក ៣.៨៖ ការយល់ដឹងអំពីបំណិនទន់
- នៅពេលបញ្ចប់មេរៀនទី៣ អ្នកចូលរួមនឹងអាច៖
  ១. កំណត់គោលការណ៍សំខាន់ៗមួយចំនួននៃការសិក្សាបែបស្ថាបនានិយម និងរបៀបដែលវាទាក់ទងទៅនឹងការងារគម្រោង ជាពិសេស ការសិក្សាអាស្រ័យលើបញ្ហា។
  ២. កំណត់ការសិក្សាបែបរគម្រោងទាក់ទងនឹងលក្ខណៈសំខាន់ៗរបស់វា ព្រមទាំងទម្រង់ផ្សេងៗមួយចំនួនដែលអាចទទួលយកបាន (ឧ. វិធីសាស្ត្រការសិក្សាអាស្រ័យលើគម្រោង ការសិក្សាអាស្រ័យលើបញ្ហា។ល។)

៣. កំណត់គុណសម្បត្តិ និងគុណវិបត្តិនៃការអនុវត្តប្រភេទផ្សេងៗនៃគម្រោង
៤. ពន្យល់ពីរបៀបដែលការសិក្សាអាស្រ័យលើបញ្ហាគឺសាកសមបំផុតសម្រាប់ការលើកកម្ពស់ការអប់រំបំណិនជីវិតតាមមូលដ្ឋាន
៥. ពិពណ៌នាអំពីដំណើរការទាំង ៦ដំណាក់កាលនៃការសិក្សាអាស្រ័យលើបញ្ហាដែលបានអនុវត្តចំពោះការបង្រៀនកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន
៦. កំណត់អត្ថប្រយោជន៍នៃការសិក្សាអាស្រ័យលើបញ្ហាសម្រាប់សិស្ស និងសហគមន៍

## ឯកសារ និងកិច្ចការអាន៖

- *ក្រសួងអប់រំ យុវជន និងកីឡា (២០២០)៖ ឯកសារការបណ្តុះបណ្តាលការសិក្សាបែបស្ថាបនានិយម៖* ឯកសារនេះផ្តល់មូលដ្ឋានគ្រឹះបន្ថែមលើគោលការណ៍សំខាន់ៗនៃការសិក្សាបែបស្ថាបនានិយម និងបច្ចេកទេសជាក់លាក់ដែលអាចអនុវត្តបាននៅក្នុងថ្នាក់រៀននៅកម្ពុជា។

  តំណភ្ជាប់៖ https://www.kapekh.org/files/report_file/166-en.pdf
- ក្រសួងអប់រំ យុវជន និងកីឡា (២០២៣)៖ ការងារគម្រោង៖ ឯកសារនេះផ្តល់ការឆ្លុះបញ្ចាំងស៊ីជម្រៅស្តីពីអ្វីទៅជាការងារគម្រោង របៀបដែលវាពាក់ព័ន្ធទ្រឹស្តី និងការសិក្សាបែបស្ថាបនានិយម។ វាបង្ហាញពីគុណសម្បត្តិ និងគុណវិបត្តិនៃភាពផ្សេងៗគ្នានៃវិធីសាស្ត្រការសិក្សាបែបស្ថាបនានិយម តួនាទីថ្មីរបស់គ្រូបង្រៀន និងវិធីសាស្ត្រក្នុងវាយតម្លៃការងារគម្រោង។

  តំណភ្ជាប់៖ https://www.kapekh.org/files/report_file/395-en.pdf

# ផែនការបណ្តុះបណ្តាល-មេរៀនទី៣

## គោលបំណងសិក្សា

**ពិនិត្យមើលគោលបំណងមេរៀន**

បិទក្រដាសផ្ទាំងធំ ឬស្លាយលើក្តារខៀន ដែលសង្ខេបពីវត្ថុបំណងសម្រាប់ម៉ូឌុលនេះ។ ពន្យល់ពីវត្ថុបំណង និងអ្វីដែលអ្នកចូលរួមអាចធ្វើបាននៅពេលបញ្ចប់ម៉ូឌុល។ បន្ទាប់ ពន្យល់ពីវត្ថុបំណងសម្រាប់មេរៀននេះ។

## តើការសិក្សាបែបស្ថាបនានិយមជាអ្វី ហើយការសិក្សាបែបគម្រោងមានទំនាក់ទំនងយ៉ាងដូចម្តេចជាមួយការសិក្សាបែបស្ថាបនានិយម?

**សេចក្តីផ្តើម៖** សាលារៀនជាច្រើនក្នុងប្រទេសកម្ពុជាបានអនុវត្តការអប់រំបំណិនជីវិតតាមមូលដ្ឋានដោយស្វ័យភាព ឬដោយមានការជួយជ្រោមជ្រែងពីដៃគូអភិវឌ្ឍន៍ រួមជាមួយក្រសួងអប់រំ យុវជន និងកីឡាដោយបានបង្កើតធនធានសម្ភារជាច្រើនដើម្បីគាំទ្រដល់ការអនុវត្តរបស់សាលារៀន។ ធនធានសម្ភារទាំងនេះបានគ្របដណ្តប់លើចំណាប់អារម្មណ៍នៃប្រធានបទផ្សេងៗគ្នា និងវិធីសាស្ត្រផ្សេងៗក្នុងការអនុវត្ត។ ដូចដែលយើងបានសិក្សារួចមកហើយ សាលារៀននីមួយៗមានសេរីភាពក្នុងការសម្រេចចិត្តជ្រើសរើសប្រធានបទណាមួយមកសិក្សា។ ម្យ៉ាងវិញទៀត គោលបំណងនៃសៀវភៅណែនាំនេះគឺធ្វើឱ្យមានភាពស៊ីសង្វាក់គ្នាលើរបៀបនៃការបង្រៀនការអប់រំបំណិនជីវិតតាមមូលដ្ឋាន ដើម្បីធានាលើការលើកកម្ពស់វិធីសាស្ត្រសិក្សាបែបសកម្ម និងការសិក្សាបែបគម្រោងក្នុងក្របខណ្ឌនៃការបង្រៀន និងរៀនបំណិនជីវិតតាមមូលដ្ឋាន។

### វិធីសាស្ត្រក្នុងការអប់រំដែលលើកកម្ពស់ការសិក្សាបែបសកម្ម

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រសួងអប់រំ យុវជន និងកីឡា កំពុងខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការលើកកម្ពស់គុណភាពនៃប្រព័ន្ធអប់រំទូទៅក្នុងប្រទេស ដោយជំរុញឱ្យសាលារៀនមានការច្នៃប្រឌិតលើការអនុវត្តការបង្រៀន និងរៀននៅក្នុងថ្នាក់ដើម្បីលើកកម្ពស់គុណភាពអប់រំ និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់សិស្សទាំងអស់។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការយកចិត្តទុកដាក់ជាក់លាក់ត្រូវបានផ្តល់ការកែលម្អវិធីសាស្ត្របង្រៀនឆ្ពោះទៅរកវិធីសាស្ត្រសិក្សាបែបសកម្ម ដោយណែនាំពីការសិក្សាបែបស្ថាបនានិយម និងការសិក្សាបែបគម្រោងនៅក្នុងរបៀបវារៈជាតិ។ អ្នកសម្របសម្រួលបន្តបង្ហាញសៀវភៅណែនាំ និងចែករំលែកតំណភ្ជាប់ទៅកាន់ឯកសារដើម្បីឱ្យអ្នកចូលរួមយល់ដឹងកាន់តែស៊ីជម្រៅអំពីប្រធានបទដែលនឹងត្រូវណែនាំនៅពេលនេះ និងពន្យល់ពីរបៀប

ដែលការសិក្សាបែបស្ថាបនានិយម និងការសិក្សាបែបគម្រោងមានទំនាក់ទំនងជាមួយនឹងការបង្រៀន និងរៀនការអប់រំបំណិនជីវិតតាមមូលដ្ឋាន៖






**ព្យុះគំនិត៖** អ្នកសម្របសម្រួលបន្តសួរអ្នកចូលរួម តើពួកគេធ្លាប់បានឮដែរឬទេពី "ការសិក្សាបែបស្ថាបនានិយម" ឬ "ការសិក្សាបែបគម្រោង"?

អ្នកសម្របសម្រួលណែនាំការបំផុសគំនិតពីរបីនាទីដល់អ្នកចូលរួម និងត្រូវដឹងថាមានអ្នកចូលរួមប៉ុន្មាននាក់ធ្លាប់ស្គាល់ពី "ការសិក្សាបែបស្ថាបនានិយម" ឬ "ការសិក្សាបែបគម្រោង"។ បន្ទាប់មក អ្នកសម្របសម្រួលចែក ឯកសារ ៣.១ ការសិក្សាបែបស្ថាបនានិយម និងការសិក្សាបែបគម្រោង ដោយមានបង្ហាញពីនិយមន័យ "ការសិក្សាបែបស្ថាបនានិយម" ឬ "ការសិក្សាបែបគម្រោង"?

អ្នកសម្របសម្រួលចាប់ផ្តើមពន្យល់ថា ការសិក្សាបែបស្ថាបនានិយម គឺជាវិធីសាស្ត្រដ៏លេចធ្លោបំផុតមួយក្នុងការបង្រៀន និងរៀននៅក្នុងសតវត្សរ៍ទី២១នេះ ដោយសារតែវាបានផ្តោតលើ "ការបង្កើតចំណេះដឹង" និង "ការរៀនពីរបៀបរៀន"។ ការសិក្សាបែបស្ថាបនានិយមគឺជាទស្សនៈវិជ្ជាបង្រៀន ខណៈដែលការសិក្សាបែបគម្រោង ត្រូវបានកំណត់ថាជាវិធីសាស្ត្របង្រៀន ដែលរួមមានសិស្សសកម្ម និងការសហការគ្នាក្នុងសកម្មភាពគម្រោង ជាមួយនឹងវិសាលភាពនៃការដោះស្រាយបញ្ហាស្មុគស្មាញ ការបង្កើតគំនិត ការបង្កើតរបស់គំរូ និងការដោះស្រាយបញ្ហាសាមញ្ញៗ។

បន្ទាប់មក អ្នកសម្របសម្រួលស្នើសុំឱ្យអ្នកចូលរួមចែករំលែកចម្លើយរបស់ពួកគេទាក់ទងនឹងសំណួរដែលមាននៅក្នុងឯកសារចែក៖

តាមគំនិតរបស់អ្នក "តើការសិក្សាបែបស្ថាបនានិយម និងការសិក្សាបែបគម្រោង មានទំនាក់ទំនងគ្នាយ៉ាងដូចម្តេច?"

### សេចក្តីសន្និដ្ឋាន (សម្រាប់អ្នកសម្របសម្រួល)

- ពិតណាស់ ការសិក្សាបែបស្ថាបនានិយម និងវិធីសាស្ត្រការសិក្សាបែបគម្រោង គឺមានភាពស្រដៀងគ្នាជាច្រើនរួមមាន សិស្សធ្វើការឆ្លុះបញ្ចាំង សិស្សធ្វើការស្រាវជ្រាវ និងការបង្កើតផលិតផល ដូចជាការងារគម្រោង។
- ទោះយ៉ាងណាក៏ដោយ ការសិក្សាបែបស្ថាបនានិយមគឺជាក្របខណ្ឌទស្សនវិជ្ជាអប់រំទូលំទូលាយមួយដែលមានធាតុផ្សំជាច្រើន ដូចជាសិស្សអាចកំណត់ពីសារៈសំខាន់នៃភាពជាក់ស្តែងដោយដោយខ្លួនឯង ដែលមិនមែនពិពណ៌នាអំពីការសិក្សាបែបគម្រោងមួយមុខនោះទេ។
- សរុបសេចក្តីមក ការសិក្សាបែបស្ថាបនានិយមគឺជាក្របខណ្ឌទស្សនវិជ្ជាអប់រំមួយដែលបានគ្រប់ដណ្តប់លើវិធីសាស្ត្រការសិក្សាបែបគម្រោង ក៏ដូចជាវិធីសាស្ត្រផ្សេងៗទៀត។

| | |
|---|---|
| អ្នកសម្របសម្រួលបន្តបង្ហាញក្រាហ្វិកពី **ឯកសារ ៣.២ "ការសិក្សាបែបស្ថាបនានិយម និងវិធីសាស្ត្រពាក់ព័ន្ធនឹងកាសិក្សាបែបស្ថាបនានិយម"** ដែលពន្យល់ពីទំនាក់ទំនងនេះ។ អ្នកសម្របសម្រួលបង្ហាញពីរបៀបដែលការសិក្សាបែបស្ថាបនានិយម គឺជាក្របខណ្ឌទស្សនៈវិជ្ជាអប់រំទូលំទូលាយ ខណៈដែលមានវិធីសាស្ត្របង្រៀនជាច្រើនបានប្រើប្រាស់គោលការណ៍ការសិក្សាបែបស្ថាបនានិយម និងការសិក្សាបែបគម្រោង (មូលដ្ឋាន) ដូចជាការសិក្សាអាស្រ័យលើបញ្ហា និងការសិក្សាអាស្រ័យលើគម្រោង។ |   *រូបភាពទី២ ការសិក្សាបែបស្ថាបនានិយម និងវិធីសាស្ត្រពាក់ព័ន្ធការសិក្សាបែបស្ថាបនានិយម* |

អ្នកសម្របសម្រួលចែក**ឯកសារចែកទី៣.៣** ឧទាហរណ៍នៃការងារគម្រោង និងសួរទៅអ្នកចូលរួម៖ "តើមានវិធីសាស្ត្រការសិក្សាបែបគម្រោងច្រើនជាងមួយប្រភេទមែនដែរឬទេ?"

ចម្លើយសម្រាប់អ្នកសម្របសម្រួល បាទ ឬចាស។ វិធីសាស្ត្រការសិក្សាបែបគម្រោង មានភាពខុសប្លែកគ្នាក្នុងទម្រង់ជាច្រើនប្រភេទ។ ដូចដែលបានកត់សម្គាល់ខាងលើ ពេលខ្លះគេសំដៅថាវិធីសាស្ត្រការសិក្សាបែបគម្រោងគឺជា "ការសិក្សាបែបគម្រោង (មូលដ្ឋាន)"។ អ្នកផ្សេងទៀតនិយាយអំពី "ការសិក្សាអាស្រ័យលើគម្រោង" ខណៈអ្នកខ្លះផ្សេងទៀតចូលចិត្តនិយាយអំពី "ការសិក្សាអាស្រ័យលើបញ្ហា"។ ទាំងអស់នេះពាក់ព័ន្ធនឹងការប្រើប្រាស់ការសិក្សាបែបគម្រោងដើម្បីរៀបចំរចនាសម្ព័ន្ធសិក្សា។

អ្នកចូលរួមធ្វើការជាក្រុមតូចៗដើម្បីអានសៀវភៅណែនាំ និងធ្វើលំហាត់ដែលបានដាក់ឱ្យ។ អ្នកសម្របសម្រួល សម្របសម្រួលការពិភាក្សាជាមួយអ្នកចូលរួមលើប្រភេទផ្សេងគ្នានៃការសិក្សាបែប

គម្រោង ដោយបញ្ជាក់លើវិធីសាស្ត្រទាំង៣ ដែលត្រូវបានចាត់ទុកថាជាឧទាហរណ៍នៃការសិក្សាបែបស្ថាបនានិយម។ ទាំងអស់នេះគឺជាការបង្កើតគម្រោង។



ខណៈដែលវិធីសាស្ត្របង្រៀននីមួយៗប្រើប្រាស់គោលការណ៍ការសិក្សាបែបស្ថាបនានិយម មានភាពខុសប្លែកគ្នាក្នុងវិធីផ្សេងៗ ប៉ុន្តែពួកវាតែងតែចែករំលែកនូវបច្ចេកទេសដូចគ្នាមួយចំនួនដូចជា ការរៀនបែបសកម្ម បែបសហការ ការសិក្សាបែបគម្រោង និងការសិក្សាស្រាវជ្រាវរបស់សិស្ស។

បន្ទាប់មក អ្នកសម្របសម្រួលសួរអ្នកចូលរួមថា៖ តើអ្វីដែលអ្នកបានរៀនកន្លងមកទាក់ទងនឹងការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន ហើយបើតាមគំនិតរបស់អ្នក ហេតុអ្វីបានជាវិធីសាស្ត្របង្រៀនការសិក្សាអាស្រ័យលើបញ្ហាត្រូវបានចាត់ទុកថាសមស្របបំផុតសម្រាប់ការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន?

បង្ហាញក្រាហ្វិចម្តងទៀតពីឯកសារចែក ៣.២ ហើយបង្ហាញថាមួយណាជាវិធីសាស្ត្របង្រៀន (ការសិក្សាអាសស្រ័យលើបញ្ហា) និងការពិតដែលត្រូវបានភ្ជាប់ជាមួយគម្រោងដែលមានគោលបំណង (គម្រោងដែលមានគោលបំណង និងហេតុផល៖  ១. ស្វែងរកដំណោះស្រាយចំពោះបញ្ហា ឬការបង្កើតផលិតផល។ គម្រោងទាំងពីរនេះនៅតែបន្តបន្ទាប់ពីសកម្មភាពបានបញ្ចប់)។ វិធីសាស្ត្របង្រៀនការសិក្សាអាស្រ័យលើបញ្ហាគឺធ្វើឱ្យយើងយល់ពីដំណើរការនៃការសិក្សា ហើយអំឡុងពេលនៃដំណើរការនេះសិស្សនឹងអភិវឌ្ឍន៍ចំណេះដឹង និងបំណិនបានល្អ។

អ្នកសម្របសម្រួលបង្ហាញក្រដាសផ្ទាំងធំជាមួយការសិក្សាតាមបែបគម្រោង និងគោលការណ៍គន្លឹះនៃការសិក្សាអាស្រ័យលើបញ្ហា (ឯកសារ ៣.៤ ការសិក្សាអាស្រ័យលើបញ្ហា និងការសិក្សាតាមបែបគម្រោង)។ ស្នើឱ្យអ្នកចូលរួមកំណត់គោលការណ៍សំខាន់ៗនៃការសិក្សាអាស្រ័យលើបញ្ហាដែលរួមមាន៖

អ្នកសម្របសម្រួលបង្ហាញក្រដាសផ្ទាំងធំស្តីពីគោលការណ៍គន្លឹះនៃការសិក្សាអាស្រ័យលើគម្រោង និងការសិក្សាអាស្រ័យលើបញ្ហា (ឯកសារចែក ៣.៤ ការសិក្សាអាស្រ័យលើគម្រោង និងការសិក្សាអាស្រ័យលើបញ្ហា)។ អ្នកសម្របសម្រួលស្នើឱ្យអ្នកចូលរួមធ្វើការកំណត់ពីគោលការណ៍សំខាន់ៗនៃការសិក្សាអាស្រ័យលើបញ្ហា ដែលរួមមានដូចខាងក្រោម៖

- ចរិកលក្ខណៈនៃកិច្ចការ៖ ផ្តោតលើការស្វែងរកដំណោះស្រាយលើសេណារីយ៉ូក្នុងពិភពពិត។
- រចនាសម្ព័ន្ធ និងដំណើរការ៖ មានភាពបត់បែន ផ្តោតលើការសិក្សាស្រាវជ្រាវបែបសកម្ម ការសាកសួរការឆ្លុះបញ្ចាំង និងការអភិវឌ្ឍបំណិន។

- កិច្ចសហការ៖ ផ្ដោតលើការស្វែងរកដំណោះស្រាយជាក្រុម។
- ការវាយតម្លៃ៖ ផ្ដោតលើការអនុវត្តបំណិនដើម្បីស្វែងរកដំណោះស្រាយ និងការសហការ (មិនផ្ដោតលើផលិតផលចុងក្រោយ)។

**សេចក្ដីសន្និដ្ឋាន** (សម្រាប់អ្នកសម្របសម្រួល)៖ គោលការណ៍ទាំងអស់នេះត្រូវគ្នាជាមួយនឹងវិសាលភាពប្រធានបទបំណិនជីវិតតាមមូលដ្ឋាន៖

- វាផ្ដោតលើសេណារីយ៉ូពិភពពិត។
- មានរចនាសម្ព័ន្ធដែលអាចបត់បែនបាន ហើយវិសាលភាពគឺស្វែងរកដំណោះស្រាយ និងលើកកម្ពស់ការសិក្សាបែបសកម្មរបស់សិស្ស និងការអភិវឌ្ឍបំណិនទន់។
- ការផ្ដោតសំខាន់គឺទៅលើដំណើរការច្រើនជាងផលិតផលចុងក្រោយ។
- ការសហការគឺជាគន្លឹះ។
- ការវាយតម្លៃគឺនៅលើការអនុវត្តបំណិន ជាជាងគុណភាពផលិតផលចុងក្រោយ។

ចុងក្រោយ យើងចាប់ផ្ដើមលើកឡើងថា ការអប់រំបំណិនជីវិតតាមមូលដ្ឋានជួយសិស្សឱ្យអភិវឌ្ឍបំណិនដែលនឹងជួយពួកគេឱ្យកាន់តែមានទំនុកចិត្ត ប៉ុន្តែក៏ជាពលរដ្ឋមានទំនួលខុសត្រូវ និងត្រៀមខ្លួនប្រឈមមុខនឹងបញ្ហានាពេលអនាគត។ មកស្ដាប់ពីកាបកស្រាយពួកគេ។ អ្នកសម្របសម្រួលណែនាំវីដេអូបន្ទាប់ពីអនុវិទ្យាល័យ ហ៊ុនសែន រលួស ក្នុងខេត្តសៀមរាប។ អនុវិទ្យាល័យ ហ៊ុនសែន រលួសជាសាលារៀនគំរូសម្រាប់ការអនុវត្តការអប់រំបំណិនជីវិតតាមមូលដ្ឋាន និងជាឯកសារយោងសម្រាប់សាលារៀនទាំងអស់ក្នុងខេត្តសៀមរាប។

**វីដេអូទី៣.១ វីដេអូចុងក្រោយ ការផ្លាស់ប្ដូររបស់សិស្ស៖ ហេតុអ្វីត្រូវសិក្សាបំណិនជីវិតតាមមូលដ្ឋាន** https://www.youtube.com/watch?v=sPjdk39ND9s&t=84s

**សំណួរបំផុស**

- តើសិស្សចូលចិត្តអ្វីជាងគេអំពីមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន?
- តើអ្វីជាធាតុសំខាន់ៗក្នុងសាលារៀន ដែលអនុញ្ញាតឱ្យសិស្សទទួលបានការផ្លាស់ប្ដូរបែបនេះ?
- តើអ្នករកឃើញគុណភាពអ្វីខ្លះរបស់សិស្សនៅក្នុងវីដេអូ? គិតអំពីបំណិនទន់។
- តើភាពជាអ្នកដឹកនាំល្អក្នុងសាលារៀន មានសារៈសំខាន់យ៉ាងណាដើម្បីសម្រេចបានលទ្ធផលបែបនេះ? ហេតុអ្វី?

បន្ទាប់មក យើងចាប់ផ្ដើមស្វែងយល់ពីរបៀបដែលគ្រូអាចណែនាំសិស្សរៀនពីការអប់រំបំណិនជីវិតតាមមូលដ្ឋាន ក្រោមក្របខណ្ឌនៃ**វិធីសាស្ត្រការសិក្សាអាស្រ័យលើបញ្ហា**។ ដើម្បីជាការគាំទ្រដល់ការអនុវត្តក្នុងសាលារៀន យើងមានក្របខណ្ឌឯកសារយោងមួយត្រូវបានពន្យល់ និងប្រើប្រាស់ដោយសាលារៀនជាច្រើនរួចមកហើយ ដែលបានផ្ដល់នូវដំណើរការទាំង ៦ដំណាក់កាល៖ ដំណើរការមានភាពបត់បែន ហើយគ្រូអាចសម្រេចចិត្តជាមួយសិស្សពីរបៀបរៀបចំដំណាក់កាលនីមួយៗ។ យើងនឹងពិនិត្យមើលឧទាហរណ៍ និងករណីសិក្សាជាក់ស្ដែងមួយចំនួនទាំងឧត្តមានុវត្ត និងបញ្ហាប្រឈមដែលសាលារៀនបានជួបប្រទះនាពេលកន្លងមក និងផលជះដែលសិស្សកំពុងទទួលបានពីការសិក្សានេះ។

## *ម៉ោងសម្រាក*

# ការសិក្សាអាស្រ័យលើបញ្ហា និងដំណើការទាំង ៦ដំណាក់កាល

**សកម្មភាព (២០នាទី)៖** អ្នកសម្របសម្រួលស្នើឱ្យអ្នកចូលរួមគិតអំពីបញ្ហាដែលពួកគេបានជួបប្រទះកាលពីពេលកន្លងមក ហើយព្យាយាមរំលឹកឡើងវិញនូវអ្វីដែលពួកគេបានធ្វើដើម្បីដោះស្រាយ។ គិតអំពីជំហាន និងសកម្មភាពផ្សេងៗដែលអ្នកបានធ្វើដើម្បីជាដំណោះស្រាយ។

**គំរូ៖** ស្នើឱ្យអ្នកចូលរួមធ្វើការជាដៃគូ ឬក្រុមតូចៗពី ៣-៤នាក់ (អាស្រ័យលើចំនួនអ្នកចូលរួមសរុប)។ ចែកក្រដាសពណ៌ស្អិត (Sticker Note) និងទុកពេលឱ្យអ្នកចូលរួមពី ១០-១៥នាទី ដើម្បីធ្វើការពិភាក្សា និងសរសេរសកម្មភាព។

ពន្យល់អ្នកចូលរួមឱ្យជ្រើសរើសបញ្ហាដែលពួកគេបានជួបប្រទះកាលពីពេលកន្លងមក។ សរសេរសកម្មភាពដែលពួកគេបានធ្វើក្នុងបញ្ជី និងចុងក្រោយអនុញ្ញាតឱ្យពួកគេស្វែងរកដំណោះស្រាយចំពោះបញ្ហា។ ក្រដាសពណ៌ស្អិតមួយ (One sticker Note) សរសេរសកម្មភាពតែមួយប៉ុណ្ណោះ។

ក្នុងពេលជាមួយគ្នានេះ អ្នកសម្របសម្រួលគូសតារាងលើក្រដាសផ្ទាំងធំ ឬតារាងមួយនៅលើក្ដារខៀនដែលនឹងត្រូវប្រើសម្រាប់ដាក់ជាក្រុមនៃចម្លើយរបស់អ្នកចូលរួម (សូមមើលរូបខាងក្រោម) ដោយប្រើគោលការណ៍ទាំង ៦ដំណាក់កាល នៃការអនុវត្តការអប់រំបំណិនជីវិតតាមមូលដ្ឋាន ដែលនឹងពិភាក្សាបន្ថែមទៀតក្នុងកំឡុងពេលបណ្ដុះបណ្ដាល។

| ការយល់ដឹងពីបញ្ហា | ការប្រមូលព័ត៌មាន | ការវិភាគព័ត៌មាន | ស្វែករងដំណោះស្រាយនិងផែនការ | ការអនុវត្តផែនការ | ការឆ្លុះបញ្ចាំង និងវាយតម្លៃ |
|---|---|---|---|---|---|
|  |  |  |  |  |  |

**ចម្លើយរំពឹងទុក៖**

១. កំណត់បញ្ហា

២. ប្រមូលព័ត៌មាន

៣. បង្កើតដំណោះស្រាយប្រកបសក្តានុភាព

៤. វាយតម្លៃជម្រើស

៥. ធ្វើការសម្រេចចិត្តលើអ្វីដែលត្រូវដោះស្រាយ

៦. អនុវត្តដំណោះស្រាយ

៧. វាយតម្លៃលទ្ធផល

**សេចក្តីសន្និដ្ឋាន (សម្រាប់អ្នកសម្របសម្រួល)៖** យើងម្នាក់ៗប្រឈមមុខនឹងបញ្ហាតាមរបៀបផ្សេងៗគ្នា ប៉ុន្តែមានជំហាន ឬគោលការណ៍ទូទៅមួយចំនួនដែលយើងទាំងអស់គ្នាមានទំនោរធ្វើតាមជាពិសេសនៅពេលដែលយើងដោះស្រាយបញ្ហាដោយជោគជ័យ។ នេះគឺជាដំណើរការដែលយើងនឹងអនុវត្តតាមសម្រាប់ការបង្រៀនបំណិនជីវិតតាមមូលដ្ឋានជាមួយសិស្ស ហើយវាត្រូវបានសង្ខេបទាំងប្រាំមួយដំណាក់កាលដែលបានសរសេរនៅលើក្រដាសផ្ទាំងធំ។

**សកម្មភាព (៤០នាទី)៖** អ្នកសម្របសម្រួលចែកឯកសារ ៣.៥៖ ដំណើរការទាំង៦ដំណាក់កាល៖ ត្រូវពន្យល់ថាសកម្មភាពនេះ អ្នកចូលរួមនឹងអនុវត្តវិធីសាស្ត្រសហការពីរនៃការពិភាក្សាជាក្រុម៖ ហៅថា **Jigsaw** និង **Placemat**។ ពួកគេអាចប្រើវិធីសាស្ត្រទាំងនេះនាពេលអនាគតជាមួយសិស្សរបស់ពួកគេផងដែរ។ អ្នកសម្របសម្រួលពន្យល់យ៉ាងខ្លីអំពីវិធីសាស្ត្រមុនពេលចាប់ផ្តើមធ្វើសកម្មភាព៖

**វិធីសាស្ត្រ Jigsaw** គឺជាវិធីសាស្ត្រការសិក្សាដែលសិស្សធ្វើការរួមគ្នាជាក្រុមតូចៗ។ ១. វាចាប់ផ្តើមជាមួយសិស្សដែលធ្វើការជាក្រុម ដែលយើងហៅថា "ក្រុមដើម" ដែលសិស្សម្នាក់ៗក្លាយជាអ្នកជំនាញក្នុងផ្នែកមួយដ៏ជាក់លាក់លើការវិភាគប្រធានបទ ហើយមានភារកិច្ចជាក់លាក់ (ឧទាហរណ៍




អានផ្នែកនៃរឿង និងពន្យល់ទៅកាន់សមាជិកម្នាក់ទៀត។ សមាជិកនៃក្រុមនោះនឹងមានផ្នែកផ្សេងៗដើម្បីអាន និងពន្យល់ផងដែរ)។ ២. បន្ទាប់មក ក្រុមថ្មីត្រូវបានបង្កើតឡើងក្នុងចំណោមអ្នកជំនាញនៃក្រុមនីមួយៗដែលយើងដាក់ឈ្មោះថា "ក្រុមអ្នកជំនាញ"។ ក្នុងដំណាក់កាលនេះ អ្នកជំនាញមកពីគ្រប់ក្រុមនីមួយៗជួបប្រជុំគ្នាចែករំលែកការយល់ដឹងអំពីផ្នែកដែលពួកគេទទួលខុសត្រូវ និងបញ្ជាក់បន្ថែមការយល់ដឹងពីអ្នកផ្សេងទៀតដែលទទួលខុសត្រូវចំពោះផ្នែកដូចគ្នា។ ៣. ចុងក្រោយ អ្នកជំនាញម្នាក់ៗត្រឡប់ទៅ

"ក្រុមដើម" វិញ ហើយចែករំលែកការយល់ដឹងចុងក្រោយលើផ្នែករបស់គេ កែលម្អបន្ទាប់ពីការប្រឈមមុខជាមួយអ្នកជំនាញផ្សេងទៀត។ វិធីសាស្ត្រនេះលើកកម្ពស់ការសិក្សាបែបសហការ ការសិក្សាបែបសកម្ម និងការអភិវឌ្ឍបំណិនសំខាន់ៗ។
ព័ត៌មានបន្ថែមអាចរកបាននៅក្នុងឯកសារបណ្តុះបណ្តាលការសិក្សាបែបស្ថាបនានិយម (ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២០ ទំព័រ៥៨)។ https://www.kapekh.org/files/report_file/166-en.pdf




**វិធីសាស្ត្រ Placemat** គឺជាបច្ចេកទេសសិក្សារួមគ្នា ដែលសិស្សធ្វើការជាក្រុមតូចៗ។ ពួកគេបំផុសគំនិតរៀងខ្លួនៗ បន្ទាប់មកចែករំលែក និងពិភាក្សាអំពីគំនិតនោះនៅលើផ្នែកដែលទទួលខុសត្រូវនោះ។ ពួកគេសហការគ្នាសំយោគគំនិតរបស់ពួកគេ និងឈានដល់ការសន្និដ្ឋានជាក្រុម។ វិធីសាស្ត្រនេះជំរុញឱ្យមានការចូលរួមយ៉ាងសកម្ម ការគិតពិចារណាស៊ីជម្រៅ និងការកសាងចំណេះដឹង។

បច្ចេកទេស **Placemat** អាចប្រើបានជាមួយសំណួរជាច្រើនប្រភេទ និងការជំរុញ ឬសម្រាប់គោលដៅសិក្សាដ៏ធំទូលាយ ដូ. • ដើម្បីលើកទឹកចិត្តសិស្សឱ្យចែករំលែកគំនិត និងឈានដល់ការមូលមតិគ្នាអំពីប្រធានបទ ឬគំនិត • ដើម្បីរំលឹកបុរេពុទ្ធិនៃប្រធានបទក្នុងចំនោមសិស្ស • ដើម្បីជួយសិស្សឱ្យចែករំលែកបច្ចេកទេសដោះស្រាយបញ្ហា • ដើម្បីកត់ត្រាតាមក្រុមអំឡុងពេលមើលវីដេអូ ឬធ្វើបទបង្ហាញផ្ទាល់មាត់ • ដើម្បីសង្ខេបមេរៀនបន្ទាប់ពីថ្នាក់រៀន និងត្រូវប្រើជាការរំលឹកឡើងវិញសម្រាប់មេរៀនបន្ទាប់។

បន្ទាប់មក អ្នកសម្របសម្រួលត្រូវណែនាំពីវីដេអូបន្ទាប់។ វីដេអូនេះផលិតឡើងដោយអនុវិទ្យាល័យអរញ្ញរង្សី ខេត្តសៀមរាប ដើម្បីពន្យល់ពីដំណើរការទាំង ៦ដំណាក់កាលដល់សាលារៀនដទៃទៀត។ សាលារៀននេះបានចាប់ផ្តើមអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋានក្នុងឆ្នាំ២០១៥ ហើយមិនយូរប៉ុន្មានសាលារៀននេះបានក្លាយជាសាលារៀនគំរូសម្រាប់សាលារៀនទាំងអស់នៅក្នុងខេត្ត។
សម្រាប់ហេតុផលនេះ មន្ទីរអប់រំខេត្ត បានស្នើឱ្យសាលារៀននេះជួយដល់សាលារៀនផ្សេងទៀតក្នុងការចាប់ផ្តើមការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន។ សូមណែនាំអ្នកចូលរួមឱ្យអានសេចក្តីណែនាំនៅឯកសារចែក។ បញ្ជាក់តាមតម្រូវការ និងណែនាំអ្នកចូលរួមឱ្យយល់ពីដំណើរការ។

## វីដេអូទី៣.២ អនុវិទ្យាល័យអរញ្ញរង្សី គោលការណ៍ទាំង ៦ដំណាក់កាល៖

https://www.youtube.com/watch?v=Y2Vu6mnxt20

នៅពេលបញ្ចប់សកម្មភាព អ្នកសម្របសម្រួលចំណាយពេល ៥នាទី ដើម្បីធ្វើការឆ្លុះបញ្ចាំងជាមួយអ្នកចូលរួមអំពីវិធីសាស្ត្រសិក្សាដែលប្រើក្នុងសកម្មភាព៖

- តើអ្នកបានរៀន ឬធ្វើការឆ្លុះបញ្ចាំងពីផ្នែកដែលអ្នកទទួលខុសត្រូវប៉ុន្មានដង?
- តើអ្នកមានអារម្មណ៍ថាក្នុងអំឡុងពេលដំណើរការការយល់ដឹងរបស់អ្នកបានប្រសើរឡើងក្នុងដំណាក់ផ្សេងគ្នាមែនដែរឬទេ? ហេតុអ្វី?
- តើអ្នកអាចអនុវត្តវិធីសាស្ត្រទាំងនេះក្នុងដំណើរការសិក្សាផ្សេងទៀតដោយរបៀបណា?

**សេចក្តីសន្និដ្ឋាន (សម្រាប់អ្នកសម្របសម្រួល)៖** អ្នកសម្របសម្រួលណែនាំអ្នកចូលរួមឱ្យយល់ថាវិធីសាស្ត្រទាំងនេះពិតជាមានប្រយោជន៍នៅក្នុងថ្នាក់រៀន ហើយអាចប្រើបានក្នុងស្ថានភាពជាច្រើនដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមយ៉ាងសកម្ម ការសហការ និងធ្វើឱ្យសិស្សមានការគិតពិចារណាស៊ីជម្រៅ។ វាធ្វើឱ្យសិស្សបង្ហាញពីគំនិតផ្ទាល់ខ្លួនរបស់ពួកគេខណៈដែលការលើកកម្ពស់គំនិតស្របគ្នានៅក្នុងក្រុមផងដែរ។ តាមរយៈការបង្ហាញដោយមើលឃើញនូវគំនិតរបស់ពួកគេរួមគ្នា សិស្សអាចមើលឃើញទំនាក់ទំនង និងភាពខុសគ្នានៃការគិតរបស់ពួកគេ ដែលនាំទៅដល់ការយល់ដឹងកាន់តែស៊ីជម្រៅ និងការកសាងចំណេះដឹង។

### ដំណើរការ ៦ដំណាក់កាល និងការអភិវឌ្ឍបំណិនទន់

អ្នកសម្របសម្រួលចែកឯកសារទី៣.៦ ប៉ុស្ទ័ដំណើរការ ៦ដំណាក់កាល៖ ឱ្យអ្នកចូលរួមមើល និងអានឱ្យលឺៗសម្រាប់ដំណាក់កាលនីមួយៗ។ សូមពន្យល់ថា សម្រាប់ដំណាក់កាលនីមួយៗក្នុងផ្នែកខាងលើបង្ហាញពីបំណិនទន់ដែលសិស្សនឹងប្រើ។

**សកម្មភាព (៤៥នាទី)** គំរូ៖ ឱ្យអ្នកចូលរួមធ្វើការងារជាដៃគូ ឬក្រុមដែលមានសមាជិក ៣នាក់។ ចែកឱ្យដៃគូនីមួយៗនូវនិយមន័យ និងការពិពណ៌នាអំពីបំណិនទន់១ក្នុងចំណោម១២បំណិនទន់ដែលពួកគេបានរៀនរួចមកហើយនៅក្នុងវគ្គសិក្សាតាមអនឡាញ (អ្នកសម្របសម្រួលអាចថតចម្លងវាចេញពីឯកសារណែនាំឆ្នាំ២០១៩)។ ត្រូវប្រាកដថា បំណិនទន់ទាំង១២ ត្រូវបានចែកឱ្យទៅតាមក្រុម ប្រសិនបើអ្នកមានអ្នកចូលរួមតិចជាង ២៤នាក់ (តិចជាង១២ដៃគូ) សូមផ្តល់បំណិនទន់ចំនួន២ ដល់ក្រុមដែលមានគ្នា ៣នាក់។ មុននឹងចាប់ផ្តើមសកម្មភាព សូមពិនិត្យមើលថាតើអ្នកចូលរួមត្រូវការរំលឹកឡើងវិញបន្តិចពីបំណិនទន់ទាំង១២ដែរឬទេ។ បង្ហាញពួកគេនូវឯកសារ ១.៣៖ បំណិនទន់ និងមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន និងធ្វើការជាមួយគ្នាលើបំណិនជាមួយអ្នកចូលរួម។

ពន្យល់ថាមានទំនាក់ទំនងផ្ទាល់រវាងសកម្មភាពដែលសិស្សចូលរួម និងការអភិវឌ្ឍបំណិន។ ឧទាហរណ៍៖

- រៀបចំការដដែកដេញដោលរបស់សាលារៀន៖ ជំរុញឱ្យមានការអភិវឌ្ឍបំណិនទំនាក់ទំនង និងបំណិនគ្រប់គ្រងខ្លួនឯងផងដែរ។
- លើកកម្ពស់ការសិក្សាបែបស្រាវជ្រាវរបស់សិស្ស៖ ជំរុញការគិតពិចារណាស៊ីជម្រៅ ឬបំណិនដោះស្រាយបញ្ហា ព្រោះសិស្សត្រូវគិតពីកន្លែងដែលត្រូវស្វែងរកព័ត៌មាន តើព័ត៌មានណាដែលពាក់ព័ន្ធនឹងការយល់ដឹង។

បង្ហាញរូបភាពខាងក្រោម ហើយពន្យល់ថា ទោះបីជាប្រភេទនៃប្រធានបទត្រូវបានអង្កេតក៏ដោយ សិស្សក៏អាចអភិវឌ្ឍបំណិនទន់ក្នុងដំណើរការសិក្សាបានដែរ៖ **ទាំងអស់នេះគឺអាស្រ័យលើរបៀបដែលសិស្សត្រូវបានណែនាំឱ្យសិក្សា។**




**សម្រាប់អ្នកសម្របសម្រួល៖** ពិពណ៌នារូបភាព និងបង្ហាញពីទំនាក់ទំនងរវាងប្រភេទនៃសកម្មភាពដែលបានស្នើឡើង និងការអភិវឌ្ឍបំណិនទន់នៅក្នុងសកម្មភាពសួនជីវៈចម្រុះ៖ គ្រប់គ្រងពេលវេលា និងកិច្ចការរបស់អ្នក (បំណិនគ្រប់គ្រងខ្លួនឯង) ការប្រាស្រ័យទាក់ទងជាមួយមិត្តភ័ក្តិ និងអ្នកជំនាញក្នុងសហគមន៍ ដើម្បីទទួលបានព័ត៌មានអំពីរបៀបធ្វើសួនជីវៈចម្រុះ (បំណិនទំនាក់ទំនង) សម្រេចចិត្តពីរបៀបរៀបចំសួន (ការសម្រេចចិត្ត ឬបំណិនចរចា) ។ល។

**បញ្ចប់មេរៀនទី៣**

# មេរៀនទី៤៖ គំរូអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន៖ ការអនុវត្ត ៦ដំណាក់កាល

**រយៈពេលបណ្តុះបណ្តាល៖** បង្រៀន៥ម៉ោង (បន្ថែម១០ម៉ោងស្វ័យសិក្សា ហាត់សម និងអនុវត្ត)

## សកម្មភាពអ្នកសម្របសម្រួលគួរត្រៀម៖

- ពិនិត្យមើលស្លាយទាំងអស់ពីស្លាយ (PPT) សម្រាប់មេរៀន រួមទាំងគោលបំណងសិក្សា
- ថតចម្លងឯកសារចែកទាំងអស់ដូចដែលបានរាយបញ្ជីខាងក្រោម
- បោះពុម្ពផែនការមេរៀនរបស់គ្រូ
- ក្រដាសផ្ទាំងធំ និងហ្វឺត

## ធនធាន និងសម្ភារៈ៖

- ស្លាយ (PPT) កុំព្យូទ័រ ម៉ាស៊ីនបញ្ចាំងស្លាយ
- ថតចម្លងក្រដាសកិច្ចការ ឬគម្រោងអនុវត្ត (ផ្នែកទន់ ឬរឹង) សកម្មភាពទាំងអស់
- ក្រដាស A4 និងប៊ិក
- ថតចម្លងសេចក្តីណែនាំសម្រាប់ការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន (ឆ្នាំ២០១៨ និង២០១៩)
- ថតចម្លង**ឯកសារចែក ៤.១៖** *ដើមឈើបញ្ហា និងដើមឈើវត្ថុបំណង*
- ថតចម្លង**ឯកសារចែក ៤.២៖** *ការកំណត់សកម្មភាព*
- ថតចម្លង**ឯកសារចែក ៤.៣៖** *ការបង្កើតក្រុមការងារគម្រោងប្រកបដោយប្រសិទ្ធភាព និងសមតុល្យ*

## វត្ថុបំណងសិក្សា៖

នៅពេលបញ្ចប់មេរៀនទី៤ អ្នកចូលរួមនឹងអាច៖

- ពន្យល់ពីសកម្មភាពដើម្បីអនុវត្តប្រធានបទបំណិនជីវិតតាមមូលដ្ឋានសម្រាប់ដំណាក់កាលនៃដំណើរការនីមួយៗ
- បែងចែកឱ្យដាច់រវាងការងារជាក្រុម (Group) និងក្រុមការងារ (Team)
- ពិពណ៌នាអំពីតួនាទីបីប្រភេទនៃក្រុមការងារ និងពន្យល់ពីមូលហេតុសំខាន់ក្នុងការដែលសិស្សម្នាក់ ឬច្រើននាក់បានដើរតួយ៉ាងតិចមួយនៅក្នុងប្រភេទនីមួយៗ
- អ្នកចូលរួមយល់អំពីតួនាទីទាំងប្រាំបួនប្រភេទនៅក្នុងក្រុមមួយ

ការឆ្លុះបញ្ចាំង និងការអនុវត្តទ្រឹស្តីនៅកន្លែងធ្វើការ៖ អ្នកចូលរួមនឹង៖

- ឆ្លុះបញ្ចាំងពីប្រភេទនៃសកម្មភាពដែលសាលារៀនអាចអនុវត្តបានក្នុងអំឡុងពេលបង្រៀនបំណិនជីវិតតាមមូលដ្ឋាន
- ឆ្លុះបញ្ចាំងលើឧបករណ៍ និងឧទាហរណ៍ផ្សេងៗដែលអាចអនុវត្តបានសម្រាប់ដំណាក់កាលនីមួយៗ
- ឆ្លុះបញ្ចាំងពីរបៀបជ្រើសរើសសកម្មភាពដោយផ្អែកលើធនធានដែលមាន និងក្រុមគោលដៅ
- ឆ្លុះបញ្ចាំងពីការអនុវត្តការសិក្សាអាស្រ័យលើបញ្ហានៅក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋានតាមរយៈឧត្តមានុវត្ត
- ឆ្លុះបញ្ចាំងពីបញ្ហាប្រឈមដែលអាចកើតមាននៅក្នុងដំណោះស្រាយ
- ស្វែងយល់ថាតើសិស្សណាដែលសមស្របក្នុងការដើរតួណាមួយ

## ឯកសារ និងកិច្ចការអាន៖

- (ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៩) សេចក្តីណែនាំការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន ជំពូកទី៤។ បំណិនទន់៖ សេចក្តីណែនាំសម្រាប់ការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន (ទំព័រទី២៨ ដល់ទំព័រទី៥០)។
- (ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៩) សេចក្តីណែនាំសម្រាប់ការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន៖ កិច្ចតែងការមេរៀន ទំព័រទី៥១ ដល់ទំព័រទី៥២ ការអនុវត្ត ៦ដំណាក់កាលឧទាហរណ៍៖ ទំព័រទី១១១ ដល់ទំព័រទី១៤១។

# ផែនការបណ្តុះបណ្តាល-មេរៀនទី៤

## ដំណើរការទាំង ៦ដំណាក់កាលៈ ឧត្តមានុវត្តពីសាលារៀន

### គោលបំណងសិក្សា

ពិនិត្យមើលគោលបំណងសិក្សា

បិទក្រដាសផ្ទាំងធំលើក្តារខៀន ដែលសង្ខេបលទ្ធផលសិក្សាសម្រាប់ម៉ូឌុលនេះ។ ពន្យល់ពីលទ្ធផលសិក្សា ហើយនេះគឺជាអ្វីដែលអ្នកចូលរួមគួរតែអាចធ្វើបាននៅពេលបញ្ចប់ម៉ូឌុល។

### ធនធានដែលពាក់ព័ន្ធ

**សេចក្តីណែនាំ៖** អ្នកសម្របសម្រួលចាប់ផ្តើមមេរៀនដោយការចង្អុលបង្ហាញពីធនធានឯកសារសំខាន់ៗមានសម្រាប់សាលារៀន ដើម្បីចរចាក្នុងការធ្វើជាឯកសារយោងដល់ការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន។

| ១ | ២ |
|---|---|
|   |   |
| ឯកសារណែនាំការអប់រំបំណិនជីវិតតាមមូលដ្ឋាន (សៀវភៅពណ៌បៃតង) ឆ្នាំ២០១៨ https://sala.moeys.gov.kh/library/00000358 | ឯកសារណែនាំការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន (ឆ្នាំ២០១៩) https://sala.moeys.gov.kh/library/00000347 |

ទី១ មានសេចក្តីណែនាំពីរ ពន្យល់៖

១. (សៀវភៅពណ៌បៃតង ឆ្នាំ២០១៨) របៀបអនុវត្តបំណិនជីវិតតាមមូលដ្ឋាននៅក្នុងសាលារៀន និងមានការគាំទ្ររបស់អាជ្ញាធរមូលដ្ឋាន។

២. (សេចក្តីណែនាំ ឆ្នាំ២០១៩) **ណែនាំបញ្ញត្តិបំណិនជីវិតតាមមូលដ្ឋានសំខាន់ៗ (រួមទាំងនិយមន័យ និងសកម្មភាពបំណិនទន់ ដើម្បីគាំទ្រដល់ការអភិវឌ្ឍ**របស់ពួកគេនៅក្នុងថ្នាក់រៀនជាមួយសិស្ស) ផ្តល់ជាឧទាហរណ៍ពីសកម្មភាពអនុវត្ត (៦ដំណាក់កាល) និងរួមបញ្ចូលឧបករណ៍វាយតម្លៃទាំងអស់ដែលសាលារៀនត្រូវបានលើកទឹកចិត្តឱ្យប្រើដើម្បីវាយតម្លៃសិស្សក្នុងអំឡុងពេលបង្រៀនកម្មវិធីបំណិនជីវិត។

## សកម្មភាព (៤០នាទី)៖ ការវិភាគសេចក្តីណែនាំសម្រាប់ការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន (ឆ្នាំ២០១៩)

- រៀបចំអ្នកចូលរួមជាក្រុមដែលមានគ្នា ៤នាក់។
- ចែកឯកសារតាមជំពូកដល់សមាជិកក្រុមនីមួយៗ (ជំពូកទី៤ ដល់ទី៧)។ ផ្តល់ពេលចំនួន ២០នាទីដល់អ្នកចូលរួមម្នាក់ៗឱ្យអានឯកសារដោយសង្ខេប។
- បន្ទាប់មក សុំឱ្យអ្នកចូលរួមដូរក្រុមឡើងវិញ លើកនេះដាក់ជាក្រុមតាមជំពូកដែលបានអាន។ ដូច្នេះយើងនឹងមានក្រុមចំនួន៤៖ មួយក្រុមធ្វើកិច្ចការនៅជំពូកទី៤ មួយក្រុមធ្វើកិច្ចការនៅជំពូកទី៥ មួយក្រុមធ្វើកិច្ចការនៅជំពូកទី៦ និងមួយក្រុមធ្វើកិច្ចការនៅជំពូកទី៧។ ទុកពេលឱ្យពួកគេចំនួន ២០នាទី ដើម្បីពិភាក្សាក្នុងក្រុមថ្មីអំពីអ្វីដែលជាខ្លឹមសារសំខាន់នៃជំពូកនីមួយៗ ហើយត្រៀមខ្លួនដើម្បីបង្ហាញដល់ក្រុមធំ។ ចែកក្រដាសផ្ទាំងធំ និងហ្វឺត ដើម្បីសង្ខេបចំណុចសំខាន់ៗនៃបទបង្ហាញរបស់ពួកគេ។

សាលារៀនប្រហែលនឹងអាចប្រើប្រាស់ធនធានទាំងអស់នេះរាល់ពេលដែលពួកគេត្រូវការដើម្បីបញ្ជាក់ដំណាក់កាលនីមួយ ឬទទួលបានគំនិតពីរបៀបនៃការចាប់ផ្តើមសកម្មភាព។ ប្រសិនបើសាលារៀនមានតែសៀវភៅណែនាំបំណិនជីវិត (សៀវភៅពណ៌បៃតង) ឆ្នាំ២០១៨ សូមពន្យល់ថាខ្លឹមសារមានភាពស្រដៀងគ្នារវាងឯកសារណែនាំទាំង២នេះ ប៉ុន្តែឯកសារណែនាំឆ្នាំ២០១៩ គ្របដណ្តប់ខ្លឹមសារបន្ថែម ជាពិសេសបំណិនទន់ និងឧទាហរណ៍បន្ថែមដើម្បីគាំទ្រដល់ការអនុវត្ត។

ទី២ ក្រសួងអប់រំ យុវជន និងកីឡា បានបញ្ចប់ឯកសារយោងសម្រាប់ការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន ដែលរួមមានធនធានសម្ភារ (វីដេអូ សៀវភៅណែនាំ កម្មវិធី បទបង្ហាញ) សម្រាប់ប្រធានបទជាច្រើនពាក់ព័ន្ធបំណិនសង្គម និងបំណិនអាជីពងាយ ដែលសាលារៀនអាចប្រើប្រាស់បានដើម្បីយល់ពីប្រធានបទ និងទទួលបានគំនិតអ្វីមួយ និងរបៀបអង្កេតលើប្រធានបទ។ ការផ្តោតជាក់លាក់ត្រូវបានផ្តល់នូវប្រធានបទពាក់ព័ន្ធជាសកលចំនួន៥ សម្រាប់សិស្សអាចអង្កេតកម្មវិធីរបស់ខ្លួននៅក្នុងបរិបទក្នុងមូលដ្ឋានដែលរួមមាន៖

- សមភាពយេនឌ័រ
- សុខភាពបន្តពូជ
- សុខភាពផ្លូវចិត្ត
- អក្ខរកម្មឌីជីថល
- បម្រែបម្រួលអាកាសធាតុ
- ប្រធានបទបំណិនសង្គម និងបំណិនអាជីពងាយផ្សេងទៀត។




អ្នកសម្របសម្រួលចែករំលែកឯកសារថតចម្លងមួយចំនួននៃឯកសារយោងសម្រាប់អ្នកចូលរួមដើម្បីពិគ្រោះយោបល់។ ធនធានសម្ភារនេះត្រូវបានផលិតឡើងដោយក្រសួងអប់រំ យុវជន និងកីឡា អង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍផ្សេងៗទៀតជាច្រើនឆ្នាំកន្លងមក ហើយសម្ភារថ្មីបន្តផលិត។ ក្រសួងអប់រំនឹងដាក់ឯកសារទាំងអស់នៅលើគេហទំព័រ៖ *(https://sala.moeys.gov.kh/)*

**ទី៣** ក្រសួងអប់រំ យុវជន និងកីឡា បានផលិតនូវផែនការមេរៀនគំរូបំណិនជីវិតតាមមូលដ្ឋានដែលមានសារៈប្រយោជន៍ដល់សាលារៀនដែលទើបចាប់ផ្តើមអនុវត្តបំណិនជីវិតតាមមូលដ្ឋាន។ ផែនការមេរៀនទាំងនេះត្រូវបានរៀបចំឡើងសម្រាប់រយៈពេល ១ឆមាស ដែលសិស្សនឹងប្រើដើម្បីស្រាវជ្រាវប្រធានបទដែលបានជ្រើសរើស និងរៀបចំផែនការផ្សព្វផ្សាយដើម្បីបង្ហាញលទ្ធផល និងសកម្មភាពបន្ថែមទៀតជាមួយមិត្តភក្តិ និងសហគមន៍ *(អ្នកសម្របសម្រួលបោះពុម្ព ចែកផែនការមេរៀនមួយចំនួន និងចែករំលែកតំណភ្ជាប់សម្រាប់ទាញយកឯកសារដល់អ្នកចូលរួមនៅចុងបញ្ចប់មេរៀន)*។ សូមបង្ហាញផែនការមេរៀនមួយ និងពន្យល់ពីរបៀបរៀបចំរចនាសម្ព័ន្ធ។

មុនពេលចាប់ផ្តើមមើលដំណាក់កាលនីមួយៗ អ្នកសម្របសម្រួលត្រូវណែនាំវីដេអូដែលផលិតដោយអង្គការ Action Aid ដោយសហការជាមួយនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈនៃក្រសួងអប់រំ យុវជន និងកីឡា។

**វីដេអូទី៤.១** ចំណងជើង៖ បំណិនជីវិតតាមមូលដ្ឋាន មិនមែនគ្រាន់តែជាមុខវិជ្ជា៖ https://www.youtube.com/watch?v=lb4dE_a96iI (នៅនាទីទី៨.១២)

**សំណួរបំផុស** (១៥នាទី)

- នៅក្នុងវីដេអូតើលោកគ្រូ **សុខ លី** យល់ឃើញដូចម្ដេចពីអត្ថប្រយោជន៍នៃការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន? តើអ្វីធ្វើឱ្យគាត់មានអារម្មណ៍រីករាយចំពោះការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន? (ចម្លើយ៖ មានអារម្មណ៍ថាមានមោទនភាព ឃើញភាពប្រសើរឡើងនៃបំណិន និងចរិយាសម្បទារបស់សិស្ស រៀនស្វែងរកការគាំទ្រពីអ្នកដទៃ គាំទ្រការងារជាក្រុមតាមរយៈបច្ចេកទេសបង្រៀនថ្មី)
- កាលពីមុន តើអ្វីខ្លះជាបញ្ហាប្រឈមសំខាន់ៗដែលអ្នកគ្រូ **ហ៊ុន ថាវី** ជួបប្រទះក្នុងការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន? តើនាងយកឈ្នះដោយរបៀបណា? (ចម្លើយ៖ នាងមិនអាចយល់ពីរបៀបអនុវត្តល្អបានទេ ប៉ុន្តែគ្រូផ្សេងទៀតបានគាំទ្រគាត់ ហើយឥឡូវនេះគាត់បានយល់ច្បាស់ហើយ)
- តើអត្ថប្រយោជន៍អ្វីខ្លះនៃការបង្រៀន និងរៀនបំណិនជីវិតតាមមូលដ្ឋានសម្រាប់លោក **ម៉ុក វី** សមាជិកគណៈកម្មការគ្រប់គ្រងសាលារៀន? (ចម្លើយ៖ គ្រូបង្រៀន និងសហគមន៍ធ្វើការរួមគ្នា សិស្សកាន់តែសកម្ម ក្លាហានជាងមុន និងអាចរៀបចំការងារគម្រោងដោយខ្លួនឯងបាន)
- មានអត្ថប្រយោជន៍អ្វីខ្លះដល់ **ឈាង នីសា** ជាសិស្សថ្នាក់ទី៦ នៅក្នុងវីដេអូ? (ចម្លើយ៖ នាងអាចបង្កើតគម្រោងសំណួរ បំផុសគំនិត ធ្វើការជាក្រុម)
- ហេតុអ្វីបានជាអ្នកគិតថាចំណងជើងវីដេអូ បំណិនជីវិតតាមមូលដ្ឋានមិនមែនគ្រាន់តែជាមុខវិជ្ជាមួយនោះទេ?

អ្នកសម្របសម្រួលដោយដកស្រង់ពីវីដេអូលោក **ម៉ុក វី** បានលើកទឹកចិត្តដល់អ្នកចូលរួម "កុំមើលស្រាលកម្មវិធីនេះ" ដើម្បីផលប្រយោជន៍ដល់សិស្សានុសិស្ស និងសាលារៀនចំណោះទូទៅ។

ឥឡូវនេះ យើងចាប់ផ្ដើមឈ្វេងយល់ពីការអនុវត្តដំណាក់កាលនីមួយៗឱ្យបានលម្អិតបន្ថែមទៀត ដើម្បីការយល់ដឹងកាន់តែស៊ីជម្រៅ។ យើងនឹងពិនិត្យមើលឧទាហរណ៍ពីសាលារៀន ហើយយើងនឹងឮពីសិស្ស គ្រូ និងនាយកសាលាអំពីការឧត្តមានុវត្ត ដើម្បីមើលពីរបៀបដែលដំណើរការនេះត្រូវបានអនុវត្តនៅសាលារៀនពិតប្រាកដ។

## ដំណើរការ ៦ដំណាក់កាល៖ ឧទាហរណ៍ជាក់ស្ដែង

ក្នុងពេលស្ទាបស្ទង់មតិដែលធ្វើឡើងជាមួយសាលារៀនគំរូថ្មីៗនេះ សាលារៀនដែលអនុវត្តដំណើរការ ៦ដំណាក់កាលនៅចុងឆ្នាំ២០២៣ ដោយសាលារៀនត្រូវបានសួរថា តើដំណាក់នីមួយៗមានការលំបាកយ៉ាងណា? ខាងក្រោមនេះជាចម្លើយ៖




សាលារៀនភាគច្រើនយល់ថាដំណើរការ ៦ដំណាក់កាល "ធម្មតា" ឬ "ពិបាកខ្លះដែរ" មានឧបសគ្គតិចតួចប៉ុណ្ណោះ ឬងាយស្រួលណាស់។ ដំណាក់កាលទី៣ ត្រូវបានគេយល់ថាមានការលំបាកបំផុតសម្រាប់គ្រូបង្រៀន ហើយហេតុផលនេះ យើងនឹងផ្តោតជាពិសេសលើជំហាននេះ ខណៈការផ្តល់នូវទិដ្ឋភាពទូទៅ និងឧទាហរណ៍មួយចំនួនសម្រាប់អ្នកដទៃ។

## ដំណាក់កាលទី១៖ ការស្វែងយល់ពីប្រធានបទ

**អ្វី?** សិស្សត្រូវចាប់ផ្តើមស្វែងយល់ពីប្រធានបទ ឬបញ្ហាដែលពួកគេនឹងអង្កេតនៅក្នុងសហគមន៍របស់ពួកគេ។

**ដូចម្តេច?** **ការបំផុសគំនិត៖** អ្នកសម្របសម្រួលសួរអ្នកចូលរួមថា តើពួកគេអាចរៀបរាប់ពីប្រភពព័ត៌មាន និងសកម្មភាពដែលពាក់ព័ន្ធ ឬបច្ចេកទេសដែលសិស្ស និងគ្រូអាចប្រើប្រាស់ក្នុងដំណាក់កាលទី១បានដែរឬទេ? ពេលសួរសំណួរនេះ អ្នកសម្របសម្រួលរៀបចំតារាងខាងក្រោម៖

| **ធនធាន** | **សកម្មភាព និងឧបករណ៍** |
|---|---|
| សិស្ស | ពិនិត្យមើលចំណេះដឹងដែលមានស្រាប់។ ប្រើប្រាស់ព្យុះគំនិត ផែនទីគំនិត និងប្រើប្រាស់ឧបករណ៍ដូចជា Mentimeter App និង Callpoint App។ |
| បណ្ណាល័យ | អ្នកអាចចាប់ផ្តើមពីបណ្ណាល័យ |

| | |
|---|---|
| ឯកសារផ្លូវការរបស់ក្រសួងអប់រំមាននៅសាលារៀន | ប្រឹក្សាសៀវភៅឯកសារយោង ឆ្នាំ២០២៤ ដែលផលិតដោយក្រសួងអប់រំ យុវជន និងកីឡា ឬធនធានផ្សេងទៀតដែលផលិតដោយអង្គការក្រៅរដ្ឋាភិបាល ដែលអាចរកបាននៅក្នុងការិយាល័យនាយក។ |
| អ៊ីនធឺណិត | ប្រឹក្សាលើគេហទំព័រក្រសួងអប់រំ ដើម្បីស្វែងរកធនធានបន្ថែម ឬនៅក្នុងបណ្តាញ YouTube៖ https://www.youtube.com/channel/UChj-XAo5wFRjZtXgTExKwQQ |
| ធនធានមនុស្ស (ឧ. នាយកសាលា គ្រូបង្រៀន មិត្តភក្តិ ឪពុកម្តាយ អ្នកជំនាញនៅមូលដ្ឋាន) | ជួបប្រជុំជាមួយអ្នកដែលមានចំណេះដឹងស្តីពីប្រធានបទអ្វីមួយដែលសិស្សនឹងអង្កេត។ គ្រូអាចរៀបចំការធ្វើបទបង្ហាញដល់សិស្សនៅសាលារៀនជាមុនដើម្បីណែនាំប្រធានបទដល់សិស្ស ឬអញ្ជើញអ្នកជំនាញពីសហគមន៍។ |

អ្នកសម្របសម្រួលបន្ថែមថានៅក្នុងដំណាក់កាលទី១ សិស្សចាប់ផ្តើមយល់ពីបញ្ហាដោយខ្លួនឯង ឧទាហរណ៍ ជំងឺគ្រុនចាញ់។ ក្នុងដំណាក់កាលដំបូង ចំណុចសំខាន់គឺត្រូវស្វែងយល់ពីព័ត៌មានមូលដ្ឋាន រួមមាន៖ តើវាជាអ្វី ឆ្លងរបៀបណា ផលប៉ះពាល់ និងវិធីព្យាបាលដូចម្តេចនៅក្នុងដំណាក់កាលដំបូងនេះ?

បន្ទាប់មក អ្នកសម្របសម្រួលណែនាំពីវីដេអូនៅអនុវិទ្យាល័យអញ្ចោះរង្សី ខេត្តសៀមរាប។ អ្នកចូលរួមបានមើលវីដេអូនេះរួចហើយនៅក្នុងមេរៀនមុន ប៉ុន្តែឥឡូវនេះយើងនឹងផ្តោតបញ្ចាំងបន្ថែមទៀតពីសកម្មភាពនីមួយៗ។ សូមទស្សនា និងស្តាប់ការបកស្រាយពីដំណាក់កាលទី១ លើការអនុវត្តនៅក្នុងអនុវិទ្យាល័យ អញ្ចោះរង្សី។

**សកម្មភាព (១០នាទី)** **វីដេអូទី៤.២៖** https://youtu.be/Y2Vu6mnxt20 (វីដេអូចាប់ពីការណែនាំទូទៅ បន្ទាប់មកព័ត៌មានជាក់លាក់នៅជំហានទី១ ផ្តើមនៅនាទីទី**២:៤៣** ដល់ទី **៣:៥៤**)។

**សំណួរសម្រាប់ពិភាក្សា៖**

- តើមានបច្ចេកទេសអ្វីខ្លះដែលបានរៀបរាប់នៅក្នុងវីដេអូនេះ?
- តើអ្នកអាចគិតពីវិធីផ្សេងទៀតនៃការរៀបចំដំណាក់កាលដំបូងនេះបានដែរឬទេ?
- តើបញ្ហាប្រឈមអ្វីខ្លះដែលអ្នកគិតថាអ្នកអាចនឹងជួបនៅក្នុងដំណាក់កាលដំបូងនេះ?

### សកម្មភាពគ្រូ៖ សកម្មភាពគន្លឹះ

**គន្លឹះទី១៖ គ្រប់គ្រងការប្រើប្រាស់ទូរស័ព្ទក្នុងថ្នាក់រៀន៖** កំណត់ការប្រើប្រាស់ទូរស័ព្ទនៅក្នុងថ្នាក់រៀនរបស់អ្នកដើម្បីធានាថាមិនរំខានដល់ដំណើរការការសិក្សា។ គិតអំពីវិធីការពារសិស្សប្រកបដោយប្រសិទ្ធភាព មិនមែនរំខានពួកគេទេ ប៉ុន្តែនៅពេលជាមួយគ្នានោះ សូមប្រើទូរស័ព្ទជាប្រភពក្នុងការស្វែងរកព័ត៌មានដ៏មានប្រយោជន៍សម្រាប់ការស្រាវជ្រាវ។

**គន្លឹះទី២៖ ត្រូវប្រាកដថាព័ត៌មានអាចទុកចិត្តបាន៖** ណែនាំសិស្សរបស់អ្នកឱ្យផ្ទៀងផ្ទាត់ព័ត៌មានដែលពួកគេប្រមូលបាន ជាពិសេសពីគេហទំព័រ និងបណ្ដាញសង្គម (**Facebook, TikTok** ។ល។)។ ឧទាហរណ៍ ព័ត៌មានមិនពិតអំពីការប្រែប្រួលអាកាសធាតុ ជាឧទាហរណ៍រួមមាន៖

- *អាកាសធាតុមិនដែលល្អប្រសើរទេ។*
- *ការប្រែប្រួលអាកាសធាតុមានការកើនឡើងយ៉ាងឆាប់រហ័ស មិនមែនសុទ្ធតែបណ្ដាលមកពីសកម្មភាពរបស់មនុស្សទេ។*
- *ថាមពលកកើតឡើងវិញមិនដំណើរការទេ។*

វីដេអូទី៤.៣៖ ធ្វើដូចម្ដេចដើម្បីដឹងថាគេហទំព័រព័ត៌មានណាមួយដែលអាចជឿទុកចិត្តបាន? ក្រសួងអប់រំ យុវជន និងកីឡា៖
https://www.facebook.com/moeys.gov.kh/videos/1611219236302723/



- ដើម្បីស្វែងយល់បន្ថែមអំពីវិធីជួយសិស្សរបស់អ្នកឱ្យដឹងពីព័ត៌មានក្លែងក្លាយ សូមមើលឯកសារណែនាំអនុវត្តបំណិនជីវិតតាមមូលដ្ឋាន (ឆ្នាំ២០១៩) ឧបសម្ព័ន្ធទី៤.១។
- គំនិតបន្ថែមលើការអនុវត្តដំណាក់កាលទី១ អាចរកមើលនៅទំព័រ១១១ ដល់ ១១៦ នៃសេចក្ដីណែនាំនេះ។ អ្នកនឹងរកឃើញព័ត៌មានអំពីរបៀបធ្វើផែនទីគំនិត ចំណេះដឹងដែលមានស្រាប់ ពិនិត្យមើលព័ត៌មានដែលត្រឹមត្រូវ ដើម្បីចាប់ផ្ដើមរៀបចំចំណេះដឹងដែលមានស្រាប់។

## ដំណាក់កាលទី២៖ ការប្រមូលព័ត៌មាន

អ្វី? ប្រមូលព័ត៌មាននៅក្នុងសាលារៀន និងពីសហគមន៍ដែលទាក់ទងនឹងប្រធានបទដែលសិស្សកំពុងអង្កេត។ សិស្សនឹងត្រូវណែនាំឱ្យធ្វើបទសម្ភាសន៍ ជួបជាមួយអ្នកជំនាញនៅមូលដ្ឋាន និងសមាជិកសហគមន៍ ដើម្បីស្វែងយល់ពីផលប៉ះពាល់នៃបញ្ហានៅក្នុងសហគមន៍របស់ពួកគេ។ ភាពស្មុគស្មាញនៃកម្រងសំណួរអាស្រ័យលើកម្រិតថ្នាក់ និងសមត្ថភាពរបស់សិស្ស។

ដូចម្ដេច? វីដេអូទី៤.២ សូមស្ដាប់វីដេអូនៅអនុវិទ្យាល័យអញ្ញវង្សី ដោយពន្យល់ពីដំណាក់កាលទី២។ វីដេអូ៖ https://youtu.be/Y2Vu6mnxt20 (ពីនាទីទី៣:៥៥ ដល់ទី៦.១៧)

**សំណួរបំផុស**

- តើសិស្សធ្វើអ្វីខ្លះដើម្បីប្រមូលព័ត៌មាន?
- តើសិស្សជួបនរណាខ្លះ?
- តើអ្នកគិតថា អាចមានមធ្យោបាយផ្សេងសម្រាប់ប្រមូលព័ត៌មានដែរឬទេ?

**គន្លឹះសម្រាប់គ្រូ៖ សូមរៀបចំការហៅតាមប្រព័ន្ធអនឡាញ**



បច្ចុប្បន្ននេះ វាជារឿងធម្មតាក្នុងការរៀបចំការប្រជុំការងារតាមអនឡាញ។ វិធីនេះមានគុណសម្បត្តិដោយមិនទាមទារការចំណាយច្រើនលើកន្លែងប្រជុំ ជាពិសេសនៅពេលអ្នកត្រូវការរៀបចំការប្រជុំសិស្សទាំងអស់ជាមួយអ្នកជំនាញនៅមូលដ្ឋាន។ នៅពេលអ្នកជំនាញនៅតាមមូលដ្ឋានមិននៅក្នុងសហគមន៍ ប៉ុន្តែសិស្សមានចំណាប់អារម្មណ៍ជជែកជាមួយអ្នកពាក់ព័ន្ធបាន ឧទាហរណ៍ ជាមួយអ្នកជំនាញដែលនៅទីក្រុងផ្សេងគ្នា ការប្រជុំតាមអនឡាញពិតជាអាចធ្វើទៅបាន។ នៅក្នុងមេរៀនទី៥ យើងនឹងឃើញលម្អិតបន្ថែមទៀត ប៉ុន្តែមានមធ្យោបាយផ្សេងៗក្នុងការរៀបចំការប្រជុំ ដោយប្រើទម្រង់ផ្សេងគ្នារួមមាន តាមតេឡេក្រាមជាដើម។ អ្វីដែលសាមញ្ញគឺ Google Drive (អ្នកត្រូវការគណនេយ្យមួយដើម្បីបង្កើតតំណភ្ជាប់) ឬ skype។

**គន្លឹះសម្រាប់គ្រូ៖**

- ត្រៀមឱ្យសិស្សរបស់អ្នកហាត់សមមុនពេលធ្វើការសម្ភាសជាក់ស្ដែង។ សូមឱ្យគេអនុវត្តសួរសំណួរ ដោយបែងចែកការទទួលខុសត្រូវរវាងសិស្ស (អ្នកដែលសួរសំណួរ អ្នកដែលកត់ត្រាចម្លើយ និងអ្នកដែលធានាថាសំណួរទាំងអស់ត្រូវបានសួរ ជាដើម។ល។)
- សូមអញ្ជើញអ្នកជំនាញនៅមូលដ្ឋាន ដោយសរសេរលិខិតអញ្ជើញជាផ្លូវការ។ សូមពន្យល់ឱ្យបានច្បាស់ពីសកម្មភាពអ្វី និងមូលហេតុអ្វីបានជាវត្តមានរបស់ពួកគាត់មានតម្លៃសម្រាប់សិស្ស។ ពិនិត្យពីរបីថ្ងៃមុន ដើម្បីប្រាកដថាពួកគាត់អាចមកសាលារៀន ឬជួបសិស្សទៅតាមការគ្រោងទុក។

| | |
|---|---|
|  | ព័ត៌មានលម្អិតបន្ថែមស្ដីពីការអនុវត្តដំណាក់កាលទី២ អាចរកមើលបាននៅក្នុងសេចក្ដីណែនាំសម្រាប់ការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ពីទំព័រទី ១១៧ ដល់ទី១២០។ ព័ត៌មានស្ដីពីកន្លឹះទំនាក់ទំនង មិនផ្ទាល់មាត់ ហើយទំនាក់ទំនងផ្ទាល់មាត់អាចរកមើលបាននៅទំព័រទី១៣៨។ |

## ដំណាក់កាលទី៣៖ ការវិភាគព័ត៌មាន




**អ្វី?** សិស្សរៀនវិភាគព័ត៌មានដែលប្រមូលបាននៅក្នុងដំណាក់កាលទី២ រៀបចំវាដោយផ្អែកលើទំនាក់ទំនង ផលប៉ះពាល់ដើម្បីកំណត់ពីឫសគល់បញ្ហា និងកំណត់ដំណោះស្រាយសមស្រប។

**ហេតុអ្វី?** មានមធ្យោបាយជាច្រើនដើម្បីវិភាគព័ត៌មានសិស្សដែលប្រមូលបាននៅក្នុងដំណាក់កាលទី២។ នៅក្នុងដំណាក់កាលនេះ សិស្សនឹងមានឱកាសឆ្លុះបញ្ចាំងព័ត៌មាន វិភាគផលប៉ះពាល់ ព័ត៌មានក្រុមដែលរៀបរាប់ពីបញ្ហា និងចាប់ផ្ដើមយល់ដឹងពីឫសគល់បញ្ហា។

អ្នកសម្របសម្រួលសួរអ្នកចូលរួម ប្រសិនបើពួកគេដឹងពីច្ចេកទេស ឬឧបករណ៍ណាមួយសម្រាប់គោលបំណងនេះ តើពួកគេបានធ្លាប់បាលលីពីដើមឈើបញ្ហា សម្រាប់ជាឧទាហរណ៍? ឬបច្ចេកទេកគ្រោងឆ្អឹងត្រីឬទេ?

អ្នកសម្របសម្រួលណែនាំសកម្មភាពបន្ទាប់ដោយបង្ហាញពីរូបដើមឈើបញ្ហានៅក្នុងផ្ទាំងប៉ុស្ទ័រ (ឯកសារ ៤.១) និងចាប់ផ្ដើមពន្យល់ថា ដើមឈើបញ្ហាគឺជាឧបករណ៍មួយដែលជួយអ្នកឱ្យបែងចែកពីភាពខុសគ្នា និងរៀបចំ **ហេតុ និងផលនៃបញ្ហា**។ អ្នកសម្របសម្រួលបង្កើតឧទាហរណ៍មួយ៖ **កង្វះកិច្ចសហការរវាងសាលារៀន និងសហគមន៍។**

អ្នកសម្របសម្រួលចាប់ផ្ដើមធ្វើព្យុះគំនិតជាមួយអ្នកចូលរួម៖

- "តើអ្វីទៅដែលជាមូលហេតុនៃបញ្ហានេះ?" (*ចម្លើយ៖* កង្វះបណ្ដាញទំនាក់ទំនង កង្វះការយល់ដឹងអំពីសារៈប្រយោជន៍នៃកិច្ចសហការគ្នា ទស្សនៈអាចជឿទុកចិត្តបាន ឬអវិជ្ជមានធនធានមានកម្រិត កង្វះភាពជាអ្នកដឹកនាំ។)

- តើអ្វីទៅជាផលប៉ះពាល់នៃមូលហេតុទាំងនេះលើកង្វះខាតនៃកិច្ចសហការគ្នា? (***ចម្លើយ៖*** ការចូលរួមរបស់សហគមន៍មានកម្រិត បាត់បង់ឱកាសសម្រាប់ការសិក្សា កាត់បន្ថយការគាំទ្រសិស្ស ភាពជាម្ចាស់ការរបស់សហគមន៍មានកម្រិត ការប្រើធនធានមិនមានប្រសិទ្ធភាព)។

អ្នកសម្របសម្រួលសរសេរពីហេតុ និងផលនៅក្នុងក្រដាសផ្ទាំងធំ។ នៅពេលបញ្ចប់ បង្ហាញវាដល់អ្នកចូលរួមពីវិធីប្រមូលព័ត៌មាន។ ពួកគេអាចមើលឃើញទាំងអស់គ្នានូវមូលហេតុនៃបញ្ហានៅខាងក្រោម និងផលនៃបញ្ហានៅខាងលើ។ រាល់ហេតុនីមួយៗមានផលយ៉ាងតិចមួយ ដើម្បីបញ្ចូលក្នុងផ្នែកខាងលើ។

*នៅដំណាក់កាលទី២៖* អ្នកសម្របសម្រួលបំពេញដើមឈើវត្ថុបំណង បន្ទាប់មកដើមឈើបញ្ហា ហើយបំប្លែងមូលហេតុទៅជាសកម្មភាពដើម្បីដោះស្រាយបញ្ហាប្រកបដោយភាពវិជ្ជមាន គម្រោងប្រែក្លាយនៅក្នុងគោលបំណង ហើយផលគឺជាផលនៃសកម្មភាពវិជ្ជមានមានរាយមុខបញ្ជីខាងក្រោម។

អ្នកសម្របសម្រួលសួរ៖ តើសកម្មភាពអ្វីដែលខ្ញុំអាចធ្វើដើម្បីដោះស្រាយបញ្ហានីមួយៗ តើផលដូចម្តេច? (***ចម្លើយ៖*** ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ ដំណោះស្រាយរួមមាន ការកែលម្អបណ្តាញទំនាក់ទំនង បង្កើនការយល់ដឹង ដោះដ្រាយការមិនជឿជាក់ វិភាជធនធាន និងជំរុញការគាំទ្រភាពជាអ្នកដឹកនាំ។ តាមរយៈការអនុវត្តដំណោះស្រាយទាំងនេះ សាលារៀន និងសហគមន៍អាចលើកកម្ពស់កិច្ចសហការគ្នា និងតម្កល់ផលប្រយោជន៍ដល់សិស្ស និងសហគមន៍ទាំងមូល។

## ឧទាហរណ៍សម្រាប់អ្នកសម្របសម្រួល






**ទំនាក់ទំនងហេតុ-ផលប៉ះពាល់៖** ឧបករណ៍ដើមឈើបញ្ហាអនុញ្ញាតឱ្យសិស្សរៀន និងអនុវត្តប្រកបដោយហេតុផលស្ដីពីមូលហេតុ - ផលប៉ះពាល់ ដែលសំខាន់ដើម្បីយល់ដឹងពីស្ថានភាព និងព្យាយាមដោះស្រាយ។ វាគឺជាធាតុមួយដ៏សំខាន់នៃបំណិនការគិតពិចារណាស៊ីជម្រៅ (ដំណើរការវិភាគ) ព្រមទាំងបំណិនដោះស្រាយបញ្ហា និងវិភាគបញ្ហា។ នៅពេលធ្វើការជាមួយសិស្ស មុនពេលចាប់ផ្ដើមដើមឈើបញ្ហា សូមធ្វើលំហាត់សាមញ្ញៗខ្លះស្ដីពីទំនាក់ទំនងហេតុ និងផលប៉ះពាល់។ អ្នកចូលរួមអាចស្វែងរកការពន្យល់បន្ថែមស្ដីពីហេតុ និងផលប៉ះពាល់នៅក្នុងសេចក្ដីណែនាំសម្រាប់ការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន (ឆ្នាំ២០១៩) ទំព័រទី៣៣។

**សកម្មភាព (៣០នាទី)៖** បន្ទាប់មក អ្នកសម្របសម្រួលចែកឯកសារ ៤.១៖ ការអនុវត្តឧបករណ៍ដើមឈើបញ្ហា៖ អ្នកសម្របសម្រួលណែនាំសកម្មភាព ដោយត្រូវធានាថាអ្នកចូលរួមទាំងអស់យល់ដឹងពីសេចក្ដីណែនាំ។

នៅចុងបញ្ចប់នៃសកម្មភាព សូមចំណាយពេលបន្តិចដើម្បីឆ្លុះបញ្ចាំងជាមួយអ្នកចូលរួម។ នៅពេលធ្វើវារួច សូមគូសបញ្ជាក់ពីរបៀបធ្វើការឆ្លុះបញ្ចាំងនៅចុងបញ្ចប់នៃដំណាក់កាល

នីមួយៗដែលមានសារៈសំខាន់សម្រាប់សិស្សក្នុងការរៀបចំដំណើរការទាំងចំណេះដឹង និងបំណិនដែលពួកគេកំពុងអនុវត្ត។ ខាងក្រោមនេះគឺជាឧទាហរណ៍នៃការឆ្លុះបញ្ចាំងដែលអ្នកសម្របសម្រួលលើកទឹកចិត្តឱ្យអ្នកចូលរួមឆ្លើយ ហើយត្រូវចងចាំថាត្រូវប្រើជាមួយសិស្សជានិច្ច នៅក្នុងដំណើរការសិក្សាណាមួយដែលពួកគេកំពុងចូលរួម។ វាជាប្រភេទនៃការវាយតម្លៃក្រៅផ្លូវការផងដែរ ដើម្បីជួយអ្នកពិនិត្យមើលពីរបៀបដែលសិស្សកំពុងរៀន។

**សំណួរឆ្លុះបញ្ចាំង៖**

1. តើអ្នកមានសកម្មភាពពិបាកធ្វើដែរឬទេ? ហេតុអ្វី?
2. តើអ្នកបានធ្វើសកម្មភាពអ្វីខ្លះដើម្បីស្វែងរកដំណោះស្រាយ?
3. តើអ្នកចូលចិត្តធ្វើការជាក្រុមទេ? ហេតុអ្វី? តើវាពិបាកទេ?
4. តើអ្នកអាចកែលម្អអ្វីខ្លះនាពេលអនាគត?

**សេចក្ដីសន្និដ្ឋាន (សម្រាប់អ្នកសម្របសម្រួល)៖** ឧបករណ៍ដើមឈើបញ្ហាផ្ដល់នូវវិធីសាស្ត្ររចនាសម្ព័ន្ធដើម្បីកំណត់អត្តសញ្ញាណឫសគល់នៃបញ្ហាគ្រោះថ្នាក់ចរាចរណ៍ និងបង្កើតគោលដៅដំណោះស្រាយសម្រាប់ការបង្ការគ្រោះថ្នាក់។ តាមរយៈការប្រើប្រាស់ឧបករណ៍នេះ សិស្សានុសិស្សអាចកំណត់អត្តសញ្ញាណមូលហេតុជាក់លាក់តាមមូលដ្ឋានដែលបង្កឱ្យមានអត្រាគ្រោះថ្នាក់ខ្ពស់នៅក្នុងមូលដ្ឋាន និងកំណត់សកម្មភាពដែលអាចអនុវត្តបានសម្រាប់ការកែលម្អសុវត្ថិភាពចរាចរណ៍ និងកាត់បន្ថយចំនួនគ្រោះថ្នាក់។



គំនិតបន្ថែមលើការអនុវត្តដំណាក់កាលទី៣ អាចរកបាននៅក្នុងឯកសារណែនាំ (ឆ្នាំ២០១៩) ដោយចាប់ផ្ដើមពីទំព័រទី១២១ ដល់ទី១២៦។ វាពន្យល់ពីរបៀបប្រើប្រាស់ឧបករណ៍ផ្សេងទៀតផងដែរ ដូចជាដ្យាក្រាមគ្រោងឆ្អឹងត្រី ឬ ៥ហេតុអ្វី (៥ Why) ដែលអ្នកចូលរួមអាចប្រើជាមួយសិស្សក្នុងថ្នាក់រៀនដើម្បីវិភាគមូលហេតុនៃបញ្ហា។




## ដំណាក់កាលទី៤៖ ការអភិវឌ្ឍផែនការគៀងគរ ឬផែនការអាជីវកម្ម

អ្នកសម្របសម្រួលពន្យល់ថា នៅដំណាក់កាលនេះ សិស្សត្រូវសម្រេចចិត្តពីអ្វីដែលត្រូវធ្វើនៅដំណាក់កាលបន្ទាប់ជាមួយនឹងព័ត៌មានទាំងអស់ដែលពួកគេប្រមូលបាន ដើម្បីធ្វើសកម្មភាពដោយយោងទៅលើបញ្ហាដែលពួកគេបានវិភាគ។ អ្នកសម្របសម្រួលបន្តទៅដំណាក់កាលបន្ទាប់ដែលជាគន្លឹះក្នុងការបណ្ដុះកូនសិស្សនូវតម្លៃនៃភាពជាពលរដ្ឋសកម្ម និងការទទួលខុសត្រូវ ព្រមទាំងលើក

កម្ពស់ការស្ម័គ្រចិត្ត។ នៅដំណាក់កាលនេះ ការសហការគ្នាជាមួយគំនិតផ្តួចផ្តើមផ្សេងទៀតអាចស្វែងយល់បាន ដើម្បីពង្រឹងសមត្ថភាពក្នុងការធ្វើសកម្មភាព និងមានផលជះដោយការភ្ជាប់ និងការជួយសហគមន៍ (ផ្នែកនេះនឹងអាចស្វែងយល់យ៉ាងលម្អិតនៅក្នុងមេរៀនទី៦)។

**អ្វី?** សិស្សនឹងរៀនពីរបៀបកំណត់ដំណោះស្រាយសមស្របបំផុតសម្រាប់បញ្ហា និងរបៀបរៀបចំផែនការដើម្បីប្រតិបត្តិសកម្មភាពផ្សព្វផ្សាយ។ ពួកគេនឹងរៀនកំណត់ធនធាន និងបែងចែកទំនួលខុសត្រូវក្នុងក្រុម។

**ហេតុអ្វី?** អ្នកសម្របសម្រួលសុំឱ្យអ្នកចូលរួមត្រឡប់ទៅក្រុមដើមដែលពួកគេបានពិភាក្សាលើបញ្ហា ឬសកម្មភាពដើមឈើវត្ថុបំណង ឯកសារចែក ៤.១ និង ឯកសារចែក ៤.២ *កំណត់សកម្មភាព។* មើលដើមឈើវត្ថុបំណង និងពន្យល់ថាពួកគេត្រូវមើលសកម្មភាពដែលបានស្នើឡើងនៅក្នុងដើមឈើវត្ថុបំណង ហើយឆ្លើយតបទៅនឹងសំណួរដែលបានណែនាំខាងក្រោម៖

**សំណួរណែនាំ** (ការពិភាក្សាលើសកម្មភាព ឯកសារចែក ៤.២)។

- អ្នកត្រូវតែជ្រើសរើសសកម្មភាពមួយបន្ថែមទៀតឱ្យសិស្សអនុវត្ត៖ តើសកម្មភាពអ្វីដែលអ្នកនឹងណែនាំសិស្សឱ្យធ្វើ? ជ្រើសរើសសកម្មភាពមួយសម្រាប់សិស្សបឋមសិក្សា និងសកម្មភាពមួយសម្រាប់សិស្សអនុវិទ្យាល័យ។
- តើអ្នកនឹងអនុវត្តលក្ខខណ្ឌអ្វីខ្លះ?
- តើអ្វីអាចជាដែនកំណត់ ឬបញ្ហាប្រឈម?

បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញឧទាហរណ៍ពីរនៃសកម្មភាពដែលអាចអនុវត្តបាន មួយមកពីកម្មវិធីស្ត្រីវ័យក្មេងក្នុងការដឹកនាំរបស់អង្គការប្លែនអន្តរជាតិ ហើយមួយទៀតពីសាលារៀនជំនាន់ថ្មី។




**ឧទាហរណ៍ទី១៖ ការចូលរួមរបស់យុវជននៅក្នុងកម្មវិធីស្ត្រីវ័យក្មេងក្នុងការដឹកនាំ**

របស់អង្គការប្លែនអន្តរជាតិនៅកម្ពុជា បន្តពង្រឹងសមត្ថភាព និងលើកទឹកចិត្តឱ្យមានការចូលរួមរបស់មនុស្សជំនាន់ថ្មីទាំងនេះ ក្នុងការអភិវឌ្ឍសហគមន៍ និងដោះស្រាយបញ្ហាសមភាពយេនឌ័រ។ សកម្មភាពទាំងនេះកើតឡើងនៅក្នុងក្លឹបសិក្សានានាក្នុងសហគមន៍ ហើយអាចក្លាយជាសកម្មភាពយ៉ាងងាយស្រួលជាផ្នែកនៃការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន ដែលបំផុសតួនាទីសកម្មរបស់សិស្សនៅក្នុងសហគមន៍ និងសហគមន៍មូលដ្ឋាន (ឃុំ) របស់ពួកគេ។

## វីដេអូទី៤.៣ ការចូលរួមរបស់យុវជននៅក្នុងកម្មវិធីស្ត្រីវ័យក្មេងក្នុងការដឹកនាំ

**មើលវីដេអូ** (រយៈពេល៖ ៣:៥១ នាទី)។

https://www.youtube.com/watch?v=xXdhzwAx2To

**សំណួរបំផុស**

តើពួកគេរៀនពីអ្វីខ្លះដើម្បីអាចតស៊ូមតិបាន?

តើសិស្សធ្វើសកម្មភាពអ្វីខ្លះ ដើម្បីតស៊ូមតិសម្រាប់សមភាពយេនឌ័រ?

តើអ្វីជាវិសាលភាពនៃគម្រោងសំឡេងជួង?

តើអ្នកណាចូលរួម?

## ឧទាហរណ៍ទី២៖ ទិវាជួបជុំឪពុកម្ដាយនៅសាលារៀនជំនាន់ថ្មី ឆ្នាំ២០២៣

អ្នកសម្របសម្រួលពន្យល់ថា សាលារៀនជំនាន់ថ្មីរៀបចំកម្មវិធីពិព័រណ៍ស្នាដៃសិស្សជារៀងរាល់ឆ្នាំ។ សិស្សានុសិស្សបង្ហាញលទ្ធផលស្នាដៃរបស់ពួកគេដោយមោទកភាពនៅក្នុងសាលារៀន ជូនចំពោះឪពុកម្ដាយ អាជ្ញាធរមូលដ្ឋាន និងសហគមន៍ដែលមកទស្សនា។ រូបភាពខាងក្រោមបង្ហាញពីការតាំងពិព័រណ៍ស្នាដៃសិស្សឆ្នាំ២០២៣ នៅវិទ្យាល័យ ជា ស៊ីម ព្រែកអញ្ចាញ សម្រាប់មាតាបិតា សហគមន៍ និងសិស្សានុសិស្សទាំងអស់បានចូលរួម និងជួបជុំគ្នាដើម្បីបង្ហាញស្នាដៃរបស់ពួកគេក្នុងឆ្នាំសិក្សា។ ស្នាដៃរបស់ពួកគេរួមមានឯកសារស្រាវជ្រាវ ការបង្កើតផលិតផលធម្មជាតិ និងការអភិវឌ្ឍផែនការអាជីវកម្មដែលពាក់ព័ន្ធសម្រាប់ផលិតផលធម្មជាតិដូចជាសាប៊ូកក់សក់ ឬសាប៊ូបោកខោអាវ ការអភិវឌ្ឍកម្មវិធី (Apps) ជាដើម។





**សំណួរបំផុស៖**

ហេតុអ្វីបានជាសាលារៀនរៀបចំពិព័រណ៍ស្នាដៃសិស្ស?

តើសកម្មភាពនេះអាចស្របទៅនឹងសកម្មភាពបំណិនជីវិតតាមមូលដ្ឋានដូចម្ដេចខ្លះ?

តើអ្នកត្រូវការធនធានអ្វីខ្លះ?

តើអ្នកធ្លាប់រៀបចំព្រឹត្តិការណ៍ស្រដៀងគ្នានៅក្នុងសាលារៀនរបស់អ្នកដែរឬទេ?

**ចំណាំទី១៖** នេះគឺជាឱកាសដ៏ល្អមួយដើម្បីឱ្យសហគមន៍ចូលរួមនៅក្នុងសាលារៀនរបស់អ្នក ដូចដែលយើងនឹងពិភាក្សាបន្ថែមទៀតនៅក្នុងមេរៀនទី៨ នៃវគ្គបណ្ដុះបណ្ដាលនេះ។

**ចំណាំទី២៖** ប្រសិនបើអ្នកកំពុងអនុវត្តក្លឹបសរសេរកូដនៅក្នុងសាលារៀនរបស់អ្នក ការអភិវឌ្ឍកម្មវិធី ឬកម្មវិធីក៏អាចឱ្យឧបករណ៍ដែលអាចធ្វើទៅបានសម្រាប់ផែនការផ្សព្វផ្សាយផងដែរ។
ឧទាហរណ៍៖
សាលារៀនជំនាន់ថ្មី ឧទាហរណ៍ទី១៖ ក្រុមសិស្សបង្កើតកម្មវិធីដែលអាចកំណត់ដឹងពីសំណើមនៅក្នុងដី។ នៅពេលដែលដីស្ងួត កម្មវិធីនេះធ្វើសកម្មភាពដល់ឧបករណ៍បញ្ចេញទឹកដើម្បីធានាថារុក្ខជាតិក្នុងសួនច្បារមានទឹកគ្រប់គ្រាន់ដើម្បីដុះលូតលាស់។
https://www.facebook.com/NGSAction/videos/540970754473055

អ្នកសម្របសម្រួលសំយោគការចង់ចាំរបស់អ្នកចូលរួមថា សហគមន៍ និងអាជ្ញាធរមូលដ្ឋានអាចចូលរួមចំណែកជាធនធានសម្ភារ និងហិរញ្ញវត្ថុ ដើម្បីជួយដល់សកម្មភាពសិស្ស ដូចដែលយើងបានឃើញពីឧត្តមានុវត្តរបស់សាលារៀនល្អសដែលមានច្រើននៅក្នុងផ្នែកនេះ៖

| **សមាជិកសហគមន៍ចូលរួមថវិកា និងសម្ភារសម្រាប់យុទ្ធនាការបរិស្ថាន** | **ការអំពាវនាវការជួយគាំទ្រពីសប្បុរសជន** |
|---|---|
|   |   |

## ដំណាក់កាលទី៥៖ ការអនុវត្តផែនការ

**អ្វី?** សិស្សអនុវត្តផែនការដោយផ្អែកលើដំណោះស្រាយដែលពួកគេបានជ្រើសរើស ដោយមានការចូលរួមពីសហគមន៍ក្នុងការផ្សព្វផ្សាយ ដើម្បីជូនដំណឹងដល់ពួកគេអំពីដំណោះស្រាយដែលអាចកំណត់បាន។

**ហេតុអ្វី?** អ្នកសម្របសម្រួលណែនាំឧទាហរណ៍បន្ទាប់ ពីអនុវិទ្យាល័យ ហ៊ុន សែន រលួស ជំនួសវិញ។ អ្នកចូលរួមនឹងមើលវីដេអូពីមធ្យោបាយផ្សេងៗនៃសកម្មភាពរបស់សិស្ស។ មើលដោយប្រុងប្រយ័ត្ន ហើយត្រៀមខ្លួនឆ្លើយតបទៅនឹងសំណួរខាងក្រោម (ឱ្យអ្នកចូលរួមសរសេរ)៖

**វីដេអូទី៤.៤ ការការពារភពផែនដី គឺការពារជីវិតរបស់យើង** (ពីអនុវិទ្យាល័យ ហ៊ុន សែន រលួស)

https://www.youtube.com/watch?v=hUxnBmSIupE

**សំណួរបំផុស៖**

- តើសិស្សដោះស្រាយបញ្ហាអ្វីខ្លះ?
- តើមានសកម្មភាពសំខាន់ៗអ្វីខ្លះ?
- តាមទស្សនៈរបស់អ្នក ហេតុអ្វីបានជាសាលារៀនសម្រេចចិត្តរៀបចំសកម្មភាពបែបនេះ?
    - តើនរណាជាគោលដៅចុងក្រោយ?
- តើអ្នកគិតថាអ្នកអាចធ្វើបែបនេះនៅក្នុងសាលារៀនរបស់អ្នកដែរឬទេ?

ចុងក្រោយ យើងនឹងចាប់ផ្តើមពិនិត្យមើលភាពស៊ីសង្វាក់គ្នាមួយចំនួនដែលសាលារៀនអាចស្វែងយល់នៅដំណាក់កាលនេះ។ តាមពិតទៅ វាមានសារៈសំខាន់ណាស់សម្រាប់សាលារៀនផងដែរក្នុងការមើលទៅពិភពខាងក្រៅ ហើយស្វែងរកឱកាសដែលអាចអនុញ្ញាតឱ្យសិស្សមានបទពិសោធន៍កាន់តែច្រើន ពង្រីកចំណេះដឹងរបស់ពួកគេ និងអនុវត្តនូវអ្វីដែលបានរៀនក្នុងអំឡុងពេលរៀនមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន។ យើងនឹងស្វែងយល់បន្ថែមនៅក្នុងមេរៀនទី៦ ប៉ុន្តែសូមចាប់ផ្តើមមើលការរួមផ្សំដែលអាចធ្វើបានទាំងនេះ។ ចំពោះបញ្ហានេះ អ្នកសម្របសម្រួលណែនាំវីដេអូបន្ទាប់។ ការសហការដោយមានគំនិតផ្តួចផ្តើមផ្សេងទៀត (សូមមើលវីដេអូរបស់ក្មេងស្រី)។

**កំណត់យុទ្ធសាស្ត្រសម្រាប់ទស្សនិកជននៃទិសដៅនាពេលអនាគត៖** ជួយសិស្សរបស់អ្នកឱ្យគិតអំពី ថាតើទស្សនិកជនគោលដៅសម្រាប់សកម្មភាពផ្សព្វផ្សាយរបស់ពួកគេនឹងត្រូវធ្វើដូចម្តេច។ នៅពេលដែលយើងចង់តស៊ូមតិសម្រាប់ការផ្លាស់ប្តូរឥរិយាសម្បទារបស់មនុស្ស ឬដើម្បីជូនដំណឹងដល់សហគមន៍ឱ្យបានទូលំទូលាយ វាតែងតែមានយុទ្ធសាស្ត្រក្នុងការរួមបញ្ចូលការប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន ឧទាហរណ៍តំណាងឃុំ



*រូបភាពទី១៖ អង្គការ UNICEF នៅកម្ពុជា/២០២៣/សេង តារាវត្តី*

ឬសង្កាត់ ដែលនៅជិតបំផុតជាមួយសហគមន៍ និងជាប់ឆ្នោតតាមកាលកំណត់។ ខាងក្រោមនេះ យើងបង្ហាញឧទាហរណ៍មួយនៅសាលារៀន**ត្រែង** ដែលសិស្សបានអង្កេតលើការគ្រប់គ្រងសំរាម ពួកគេសម្រេចចិត្តតស៊ូមតិដើម្បីសុំអន្តរាគមន៍ពីក្រុមប្រឹក្សាឃុំ ឬសង្កាត់។ សិស្សថ្នាក់ទី៨ នៃអនុ

វិទ្យាល័យ**ថ្មីតាព្រហ្ម** ក្នុងខេត្តស្ទឹងត្រែង បង្ហាញដំណោះស្រាយចំពោះបញ្ហាគ្រប់គ្រងសំរាមដែលប្រឈមមុខនឹងមន្ត្រីសាលាឃុំ ឬសង្កាត់ មានការតស៊ូមតិដោយមានការជួយជ្រោមជ្រែងពីនាយកសាលា (រូបភាពខាងស្តាំ) ដើម្បីឱ្យក្រុមប្រឹក្សាឃុំ ឬសង្កាត់សាងសង់ឡដុតសំរាមនៅលើកោះក្បែរនោះគឺកោះជ្រោម។

*លោក ឡាយ ឈុន ជំទុកទី១ ឃុំអូររ៉ាំង ដែលសារភាពកំហុសខ្លួនឯងថាបានចោលសំរាមពាសវាលពាសកាលដូចជាកន្ទុយបារី ប៉ុន្តែមិនបានដឹងថាវាពុលដល់បរិស្ថាន គាត់បាននិយាយថា "វាដូចជាការដាស់តឿនមួយ"។ លោកសង្ឃឹមថាពួកគេនឹងអាចទុកថវិកាដែលត្រូវការសម្រាប់សាងសង់ឡដុតនៅឆ្នាំក្រោយ។*

*ប្រភព៖* *https://www.unicef.org/cambodia/stories/students-empowered-take-action-against-rubbish*



នៅក្នុងទំព័រទី១៣៧-១៣៨ ឯកសារណែនាំអនុវត្តបំណិនជីវិតតាមមូលដ្ឋានឆ្នាំ២០១៩ ផ្តល់យោបល់ និងការណែនាំអំពីការអនុវត្តផែនការ និងវិធីជួយសិស្សក្នុងការរៀបចំព្រឹត្តិការណ៍ ឬសកម្មភាពដែលបានសម្រេចចិត្ត។

## ដំណាក់កាលទី៦៖ ការឆ្លុះបញ្ចាំង និងការវាយតម្លៃ

**អ្វី?** លើកទឹកចិត្តសិស្សឱ្យឆ្លុះបញ្ចាំងពីបទពិសោធន៍សិក្សារួមក្នុងការអនុវត្តសកម្មភាព និងការអភិវឌ្ឍបំណិន។

**ហេតុអ្វី?** គ្រូបង្រៀនអាចប្រើឧបករណ៍ណាមួយដែលបានស្នើឡើងសម្រាប់ការវាយតម្លៃជាផ្លូវការ និងក្រៅផ្លូវការដែលមាននៅក្នុងឯកសារណែនាំអនុវត្តឆ្នាំ២០១៩។ មេរៀនទី៧ នឹងផ្តោតលើដំណើរការ និងឧបករណ៍វាយតម្លៃដែលយើងនឹងចាប់ផ្តើមឆ្លុះបញ្ចាំងពីសារៈសំខាន់ និងពេលវេលា។ សូមស្តាប់ពីសាលារៀនមួយចំនួន៖

### ការឆ្លុះបញ្ចាំងលើដំណើរការទូទៅ

ការឆ្លុះបញ្ចាំងគឺជាបំណិនដ៏សំខាន់ដែលជួយបុគ្គលគ្រប់រូបឱ្យជៀសផុតពីកំហុសដដែលៗនាពេលអនាគត។ វាលើកទឹកចិត្តឱ្យមានការគិត និងការវិភាគឱ្យបានហ្មត់ចត់ និងជួយឱ្យមានគំនិត និងដំណោះស្រាយល្អៗសម្រាប់ជីវិតប្រចាំថ្ងៃ។ គ្រូត្រូវបញ្ចូលការឆ្លុះបញ្ចាំង៖

- នៅចុងបញ្ចប់នៃមេរៀននីមួយៗ (ជាពាក្យសំដី) ឧទាហរណ៍៖

    - តើអ្នកជួបសកម្មភាពលំបាកអ្វីខ្លះសម្រាប់ថ្ងៃនេះដែរឬទេ ?
    - តើអ្នកបានធ្វើអ្វីខ្លះដើម្បីដោះស្រាយបញ្ហា ?
    - តើអ្នកសប្បាយចិត្តនឹងលទ្ធផលថ្ងៃនេះដែរឬទេ ?
- ចុងបញ្ចប់នៃដំណាក់កាលនីមួយៗ ត្រូវឆ្លុះបញ្ចាំងពីដំណើរការបំណិនគោលដៅ (ផ្ទាល់មាត់) ឧទាហរណ៍៖
    - ឆ្លុះបញ្ចាំងពីរបៀបអនុវត្តសកម្មភាព តើយើងបានរៀនអ្វីខ្លះ។ល។?
    - គិតអំពីរបៀបកែលម្អសកម្មភាពនេះនៅពេលក្រោយ។
- ចុងបញ្ចប់នៃឆមាស (ជាពាក្យសំដី ឬសរសេរ)៖ ដើម្បីពិនិត្យមើលចំណេះដឹងដែលទទួលបានឡើងវិញ ប៉ុន្តែជាពិសេសការកែលម្អការអនុវត្តបំណិនទន់ និងសមត្ថភាពគោល។
    - ទម្រង់អង្កេត
    - ការធ្វើតេស្តសរសេរ
    - កម្រងស្នាដៃ
    - ។ល។

អ្នកសម្របសម្រួលសួរអ្នកចូលរួម៖ ហេតុអ្វីបានជាវាសំខាន់ក្នុងការលើកទឹកចិត្តឱ្យមានការឆ្លុះបញ្ចាំងជាបន្តបន្ទាប់?

**ចម្លើយ៖ ការឆ្លុះបញ្ចាំងលើដំណើរការគឺជាផ្នែកមួយដ៏សំខាន់ ដែលសិស្សរៀនតាមរយៈសកម្មភាពសិក្សាអាស្រ័យលើបញ្ហា។ ជួនកាល ការឆ្លុះបញ្ចាំងនេះបង្កើតផលច្រើន ឬច្រើនជាងការដែលធ្វើគម្រោងខ្លួនឯងទៅទៀត។ ការឆ្លុះបញ្ចាំងនេះរួមបញ្ចូលទាំងការគិតអំពីរបៀបដែលសិស្សបានធ្វើការជាក្រុម ឬរបៀបដែលពួកគេស៊ូទ្រាំនឹងបញ្ហាប្រឈមក្នុងអំឡុងពេលដំណើរការ។ នៅពេលអនាគត ការវិភាគបែប Meta នេះទំនងជាបានផល។**

| | |
|---|---|
|  | ពីទំព័រទី១៣៩-១៤១ ផ្តល់ជាគំនិតសម្រាប់ការឆ្លុះបញ្ចាំងចុងក្រោយជាមួយសិស្ស និងការរៀបចំរបាយការណ៍ចុងក្រោយសង្ខេបមួយពីការងារដែលបានធ្វើតាមថ្នាក់ និងការឆ្លុះបញ្ចាំងចុងក្រោយសម្រាប់ការកែលម្អនាពេលអនាគត។ ការពិពណ៌នាលម្អិតនៃដំណើរការវាយតម្លៃ និងឧបករណ៍ដែលមានស្រាប់ ត្រូវបានកំណត់នៅក្នុងជំពូកទី៧ នៃឯកសារណែនាំអនុវត្ត។  **ព័ត៌មានលម្អិតនឹងត្រូវបានផ្តល់ជូននៅក្នុងមេរៀនទី៧ នៃឯកសារបណ្តុះបណ្តាលនេះ។** |

# ការរៀបចំប្រកបដោយប្រសិទ្ធភាពនៃការធ្វើការជាក្រុមនៅក្នុងការអនុវត្តគម្រោង

## ការបែងចែកភាពខុសគ្នារវាងក្រុម និងធីម




ចុងក្រោយ មុនពេលបញ្ចប់មេរៀន យើងនឹងមើលលម្អិតលើរបៀបរៀបចំក្រុមឱ្យមានប្រសិទ្ធភាព។

សូមអ្នកចូលរួមធ្វើការជាក្រុម។ សរសេរពាក្យ "ក្រុម" នៅផ្នែកខាងឆ្វេងក្តារខៀន និងពាក្យ "ធីម" នៅផ្នែកខាងស្តាំ និងគូសបន្ទាត់កណ្តាលបែងចែកក្តារខៀនជាពីរ។ ចែកក្រដាសស្អិតក័រឱ្យក្រុមនីមួយៗដោយមួយក្រុមទទួលបានដុំក្រដាសមានពណ៌ផ្សេងៗគ្នា។ ប្រាប់អ្នកចូលរួមរកភាពដូចគ្នា និងខុសគ្នារវាងក្រុម និងធីម។ ក្រុមអ្នកចូលរួមពិភាក្សា និងសរសេរចម្លើយលើក្រដាសស្អិតក័រមួយសន្លឹក ឧទាហរណ៍៖ "ក្រុម ជាការប្រមូលមនុស្សដែល.....ហើយធីម ជាទូទៅដំណើរការដោយ.....”។ ក្រដាសស្អិតក័រនីមួយៗមានល្បះមួយអំពីក្រុម និងធីម មិនមែនទាំងពីរលើក្រដាសតែមួយទេ។ បន្ទាប់ពីពិភាក្សាប្រហែល ១០ ទៅ ១៥នាទី ពួកគេត្រូវយកក្រដាសស្អិតក័រទាំងអស់សរសេរពី **ក្រុម** មកបិទខាងឆ្វេង និងក្រដាសសរសេរពី **ធីម** ទៅបិទនៅខាងស្តាំ។ បើពេលវេលាមិនគ្រប់គ្រាន់ អ្នកសម្របសម្រួលអាចបន្ថែមបាន។ ក្តារខៀនបិទក្រដាសហើយមានទម្រង់ដូចនឹងរូបភាពខាងស្តាំ។

អានល្បះលើក្រដាសនីមួយៗឱ្យឮៗសម្រាប់ **ក្រុម។** ប្រសិនបើល្បះមិនសូវច្បាស់ សូមក្រុមអ្នកចូលរួមដែលត្រូវនឹងពណ៌ក្រដាសស្អិតក័រធ្វើការពន្យល់។ ធ្វើដូចគ្នាដែរចំពោះ"**ធីម**"។

សួរអ្នកចូលរួមថាតើពួកគេមានអ្វីជាការសង្កេតឃើញបន្ថែមទៀតដែលពួកគេបានលឺ?

ឯកសារចែកទី៤.៣៖ *ការបង្កើតក្រុមអនុវត្តការសិក្សាបែបគម្រោងប្រកបដោយប្រសិទ្ធភាព និងតុល្យភាព។*

អ្នកសម្របសម្រួល និងអ្នកចូលរួមអានជាមួយគ្នានូវអ្វីដែលមានក្នុងឯកសារចែកជូន៤.៣។ អ្នកសម្របសម្រួលអាចស្នើឱ្យអ្នកចូលរួមម្នាក់អានឮៗ មួយជួរម្តងៗ។ បន្ទាប់មកទៀត ឱ្យអ្នកចូលរួមម្នាក់អានល្បះចាប់ផ្តើមដោយ "វាប្រាកដណាស់ថា.....” ។ ពន្យល់ទៅអ្នកចូលរួមថា ផ្នែកបន្ទាប់នឹងនិយាយពីការបង្កើតក្រុមដែលមានប្រសិទ្ធភាព និងតួនាទីចាំបាច់ដើម្បីឱ្យក្រុមមួយធ្វើការជាមួយគ្នាបានល្អពេលអនុវត្តគម្រោងណាមួយនៅសាលារៀន។ ស្នើឱ្យគ្រូទុកពេល ៥នាទីដល់អ្នកចូលរួមសរសេរពីបទពិសោធន៍ពេលធ្វើការជាមួយក្រុមសិស្ស អាចជាការអនុវត្តការសិក្សាបែបគម្រោងណាមួយដែលដំណើរការមិន

ស្ទួល្អ ឧទាហរណ៍៖ សិស្សមិនអាចបញ្ចប់ការងារទាន់ពេល លទ្ធផលមិនសូវល្អ សមាជិកក្រុមមិនសូវសហការគ្នាជាដើម។ ឱ្យពួកគេពិចារណាពី៖

- អ្វីជាបញ្ហាប្រឈមដែលសមាជិកក្រុមជួបប្រទះពេលអនុវត្តគម្រោង?
- អ្វីទៅជាប្រភពនៃបញ្ហាប្រឈមទាំងអស់នោះ?

ជ្រើសរើសអ្នកស្ម័គ្រចិត្តពីរ ឬបីនាក់ដើម្បីចែករំលែករឿងរ៉ាវរបស់ពួកគេ។ ស្តាប់ករណីសិក្សាខាងក្រោម៖

- សិស្សក្នុងឧទាហរណ៍ដែលបានផ្តល់ឱ្យមានមុខងារជាការងារក្រុម មិនមែនជាការងារធីម។
- បញ្ហានេះទាក់ទងនឹងសិស្សចម្រុះដែលមិនសូវល្អ ពោលគឺក្រុមមិនដំណើរការល្អ ដោយសារពួកគេខ្វះសមាជិកណាមួយ ឬច្រើនដែលផ្តោតលើសកម្មភាព តម្រង់ទិស ឬផ្តោតលើមនុស្ស។

សួរទៅអ្នកចូលរួមថាតើពួកគេបានកត់សម្គាល់ឃើញគំរូណាមួយនៅក្នុងឧទាហរណ៍ដែលបរាជ័យ។ អ្នកសម្របសម្រួលធ្វើការសង្កេតផ្ទាល់ខ្លួនពីចំណុចទាំង ២ ខាងលើ(គឺភាពខុសគ្នារវាងក្រុម និងធីម និងការបាត់តួនាទីទទួលខុសត្រូវ)។ ប្រើប្រាស់ចំណុចទាំងអស់នេះដើម្បីជួយដល់ការពិភាក្សាបន្ទាប់អំពីតួនាទីធីម។

## តួនាទីរបស់ធីម

អ្នកសម្របសម្រួលពន្យល់ដោយពាក្យរបស់គាត់ផ្ទាល់អំពីខ្លឹមសារនៅក្នុងកថាខណ្ឌដែលចាប់ផ្តើមដោយពាក្យ "គ្រូទាំងអស.....″ នៅឯកសារចែក ៤.៣។

សួរអ្នកចូលរួម "តើមានអ្នកចង់សាកល្បងពន្យល់ពីភាពខុសគ្នារវាងអ្នកផ្តោតលើសកម្មភាព អ្នកផ្តោតលើគំនិត និងអ្នកផ្តោតលើមនុស្សដែរឬទេ?″

បន្ទាប់មក ពន្យល់លម្អិតពីតួនាទីសមាជិកធីមនីមួយៗដូចខាងក្រោម៖

- អ្នកអនុវត្ត៖ អ្នកអនុវត្តចូលចិត្តអនុវត្តសកម្មភាព និងធ្វើឱ្យគំនិតក្លាយជាការពិត។ ពួកគេជាមនុស្សមានវិន័យក្នុងការរៀបចំសម្ភារផ្សេងៗឱ្យមានរបៀបរៀបរយ ហើយពួកគេក៏ជាអ្នកជួយគាំទ្រសមាជិកក្រុមផ្សេងៗទៀតផងដែរ។
- អ្នកជំរុញ៖ អ្នកជំរុញក៏ជាអ្នកអនុវត្តសកម្មភាពដែរ។ ពួកគេជំរុញការងារក្រុម និងលើកទឹកចិត្តសមាជិកក្រុមដើម្បីឱ្យមានដំណើរការទៅមុខ។ ពេលក្រុមជួបបញ្ហាអ្វីមួយ អ្នកជំរុញនេះដោះស្រាយបញ្ហាទាំងនោះភ្លាមៗ។ ពួកគេភាគច្រើនជាអ្នកដឹកនាំ ឬអ្នកគ្រប់គ្រងចាត់ចែង។
- អ្នកបញ្ចប់៖ អ្នកបញ្ចប់ផ្តោតការយកចិត្តទុកដាក់ទៅលើការលម្អិតការងារតូចៗ និងភាគច្រើនធ្វើការដោយឯករាជ្យ។ ពួកគេជាអ្នកធានាថាលទ្ធផលសម្រេចបានមានគុណភាពអតិបរមា និងលើកទឹកចិត្តសមាជិកក្រុមឱ្យប្រឹងប្រែងទាំងអស់គ្នា។

- អ្នកពិនិត្យតាមដាន៖ អ្នកពិនិត្យតាមដានជាមនុស្សពូកែខាងធ្វើផែនការយុទ្ធសាស្ត្រ និងភាគច្រើនជាអ្នកចេះដឹងច្រើន។ ពួកគេគិតពីគំនិតណាមួយយ៉ាងល្អិតល្អន់ ហើយបើគំនិតនោះល្អ និងអាចសម្រេចទៅបានពួកគេនឹងជំរុញភ្លាម។
- អ្នកនវានុវត្តន៍៖ អ្នកនវានុវត្តន៍ជាមនុស្សមានភាពច្នៃប្រឌិតខ្ពស់។ ភាគច្រើនពួកគេជាអ្នកផ្ដើមគំនិតណាមួយ ហើយដឹកនាំគំនិតនោះទៅចែកចាយក្នុងក្រុម។
- អ្នកមានឯកទេស៖ អ្នកមានឯកទេសមានចំណេះដឹងជ្រៅជ្រះលើផ្នែកណាមួយ។ ពួកគាត់ចូលចិត្តការចែករំលែកគំនិតរបស់អ្នកដទៃ ពួកនេះចូលចិត្តធ្វើការតែឯងជាងធ្វើការជាក្រុម។ ពួកគេនាំជំនាញដ៏មានតម្លៃផ្សេងៗមកជួយការងារក្រុម។
- អ្នកអង្កេត៖ អ្នកអង្កេតចូលចិត្តរកឱកាសថ្មីៗ។ ពួកគេពូកែខាងទំនាក់ទំនងជាមួយមនុស្សជុំវិញខ្លួន ដូច្នេះជាទូទៅពួកគេអាចធ្វើរឿងមួយចំនួនមានប្រសិទ្ធភាពដូចជា ផ្នែកលក់ និងការធ្វើទីផ្សារជាដើម។
- អ្នកគាំទ្រធីម៖ អ្នកគាំទ្រធីម ធ្វើការចុះសម្រុងជាមួយសមាជិកផ្សេងទៀត ពូកែសម្របខ្លួន និងជាអ្នកស្ដាប់ដ៏ពូកែ។ ពួកគេពូកែដោះស្រាយបញ្ហាទំនាស់ក្នុងក្រុម ដោយធ្វើឱ្យអ្នកដទៃស្ងប់អារម្មណ៍ និងមានសន្តិភាពផ្លូវចិត្ត។
- អ្នកសម្របសម្រួល៖ អ្នកសម្របសម្រួលពូកែលើកទឹកចិត្តក្រុមឱ្យសហការគ្នា និងពូកែខាងលើកទឹកចិត្តសមាជិកទាំងអស់សម្រេចគោលដៅ។ ពួកគេជាមនុស្សពូកែខាងទំនាក់ទំនងជាងគេ និងទទួលបានទំនុកចិត្តច្រើនពីសមាជិកក្រុមផ្សេងទៀត។

សុំឱ្យអ្នកចូលរួមត្រឡប់ទៅធ្វើការក្រុមវិញ និងឆ្លុះបញ្ចាំងពីមូលហេតុពួកគេធ្វើការជាមួយគ្នាក្នុងសកម្មភាពពីមុននេះគឺសកម្មភាពកំណត់ក្រុម និងធីម ដោយប្រើក្រដាសស្ទីកគ័រ។ ពួកគេអាចពិភាក្សាដោយផ្អែកលើសំណួរនៅក្នុងឯកសារចែក៖

### សំណួរពិភាក្សា

- តើអ្នកអាចមើលឃើញពីអន្តរកម្មខ្លីៗដែលមនុស្សផ្សេងគ្នាដើរតួនាទីខុសគ្នាដែរឬទេ?
- តើក្រុមសហការគ្នាបានល្អតាមមធ្យោបាយណា? តើមធ្យោបាយនោះអាចពន្យល់ដោយប្រើប្រាស់ព័ត៌មានបានសិក្សាពីតួនាទីសមាជិកធីមដែរឬទេ?
- តើអ្នកបានជួបបញ្ហាប្រឈមដែរឬទេ? ហេតុអ្វី? តើបញ្ហាប្រឈមទាំងនោះមានបញ្ហាណាមួយត្រូវបានពន្យល់ដោយព័ត៌មានពីតួនាទីសមាជិកធីមដែរឬទេ?

ខណៈពេលពួកគេស្ថិតក្នុងក្រុមតូចៗរបស់ពួកគេ សូមជជែកអំពីឧទាហរណ៍នៃបញ្ហាធីម។ ប្រើប្រាស់ខ្លឹមសារពី**ឯកសារចែក ៤.៣**។ ធីម ដែលបង្កើតឡើងដោយសមាជិកមានសមត្ថភាពស្រដៀងគ្នាអាចចុះសម្រុងគ្នាបានល្អ ប៉ុន្តែលទ្ធផលអាចមិនជោគជ័យ។ ធីមមួយមានតែសមាជិកជាប្រភេទអ្នកផ្ដោតលើគំនិតតែម្យ៉ាង ដូចនេះពួកគេមិនអាចជំរុញគំនិតនោះទៅជាផលិតផលមានគុណភាពខ្ពស់បានទេ។ ឧទាហរណ៍ ការកំណត់រចនាសម្ព័ន្ធក្រុមខាងក្រោមអាចមានបញ្ហាសម្រាប់សិស្ស៖

- ប្រភេទតែមួយ៖ ប្រសិនបើសិស្សដែលផ្ដោតលើការគិតតែមួយនៅក្នុងក្រុម ជាឧទាហរណ៍ពួកគេប្រហែលជាមិនអាចនាំយកគំនិតរួមគ្នារបស់ពួកគេ ដើម្បីឆ្ពោះទៅមុខតាមរបៀបរៀបចំត្រឹមត្រូវនោះទេ។ ពួកគេប្រហែលជាខ្វះការប្រាស្រ័យទាក់ទង និងការគិតស៊ីជម្រៅផងដែរ។
- ការបាត់តួនាទីណាមួយ៖ បើក្រុមមួយមិនមានសមាជិកណាម្នាក់ទទួលតួនាទីជាអ្នកបញ្ចប់នោះទេក្រុមនោះអាចមានគំនិតបង្កើតផលិតផលអស្ចារ្យណាមួយ ដោយមានស្មារតីសហការក្រុមល្អ សមាជិកមានសក្ដានុពល ប៉ុន្តែផលិតផលផលិតបានមានគុណភាពមិនសូវល្អព្រោះមិនមានតួនាទីអ្នកបញ្ចប់ និងអ្នកត្រួតពិនិត្យគុណភាពផលិតផលសម្រេច"។

សូមឱ្យអ្នកចូលរួមត្រឡប់ទៅមើលឧទាហរណ៍ពីបរាជ័យនៃការងារសិស្សជាក្រុមហើយពិភាក្សាគ្នាពីសំណួរខាងក្រោម៖

## សំណួរពិភាក្សា

- តើឧទាហរណ៍ណាមួយបង្ហាញពីបញ្ហាប្រឈមទាក់ទងនឹងតួនាទីក្រុម?
- តើលក្ខណៈនៃបញ្ហាប្រឈមនោះមានអ្វីខ្លះ?

## សំណួរឆ្លុះបញ្ចាំងលក្ខណៈបុគ្គល

- ផ្អែកលើអ្វីដែលអ្នកដឹងពីសមាជិកសិស្សនៃធីមតើផ្នែកណាខ្លះនៃគម្រោងដែលមានភាពងាយស្រួលសម្រាប់ពួកគេ? តើសកម្មភាពប្រភេទណាខ្លះដែលពួកគេទំនងជាអាចអនុវត្តបានល្អ?
- ស្រដៀងគ្នានេះដែរ តើសកម្មភាពណាខ្លះដែលប្រឈមសម្រាប់សមាជិកធីម? ហេតុអ្វីបានជាអ្នកគិតថាវាជាបញ្ហាប្រឈម? ហើយតើសមាជិកធីមធ្វើដូចម្ដេចដើម្បីកាត់បន្ថយបញ្ហានោះ?
- តើគ្រូគួរធ្វើអ្វីខ្លះដើម្បីធានាបាននូវមុខងារត្រឹមត្រូវរបស់ធីម? បើដូច្នេះតើគាត់គួរធ្វើអ្វី? បើមិនដូច្នេះទេហេតុអ្វីបានជាអ្នកគិតថាគ្រូគួរមានវិធីដោះស្រាយ?

សង្ខេបសំណួរនៅក្នុងក្រុមធំដែលសួរអ្នកចូលរួមសម្រាប់គំនិតរបស់ពួកគេនីមួយៗ។ បន្ថែមការឆ្លុះបញ្ចាំង ឬមតិកែលម្អផ្ទាល់ខ្លួនរបស់អ្នកតាមការចង់បាន។

គ្រូអាច៖

- ទទួលបានចំណេះដឹងជិតស្និទ្ធអំពីភាពខ្លាំង ចំណាប់អារម្មណ៍ និងបុគ្គលិកលក្ខណៈរបស់សិស្ស។
- ត្រូវមានយុទ្ធសាស្ត្រនៅពេលបង្កើតក្រុមសិស្សសម្រាប់ការងារគម្រោង។
- ត្រូវប្រាកដថាក្រុមនីមួយៗមានសិស្សយ៉ាងតិចម្នាក់ដែលអាចដើរតួនាទី ឬតួនាទីនៅក្នុងប្រភេទសំខាន់ៗទាំងបីរួមមានសកម្មភាពតម្រង់ទិសគំនិត និងតម្រង់ទិសមនុស្ស។

ពន្យល់អ្នកចូលរួមពីអត្ថន័យនៃ "គម្រោងបណ្ដុះបំណិន (stretch project)" ។ អ្នកសម្របសម្រួលអាចប្រើប្រាស់ខ្លឹមសារខាងក្រោម ឬប្រើប្រាស់ពាក្យសម្ដីផ្ទាល់ខ្លួន។

**"គម្រោងបណ្ដុះបំណិន (stretch project)"**

"សិស្សអភិវឌ្ឍខ្លួនតាមមធ្យោបាយផ្សេងៗគ្នាជាច្រើន។ គ្រូបង្រៀនត្រូវកត់ចំណាំចំណុចនេះ។ សិស្សម្នាក់ប្រហែលមិនមែនជាអ្នកអង្កេតដ៏ពូកែ តែគេអាចជាអ្នកពូកែទំនាក់ទំនងក្នុងសង្គមជាក់ស្ដែង។ សិស្សម្នាក់ទៀតប្រហែលមិនមានទំនុកចិត្តធ្វើជាអ្នកអនុវត្តដ៏ពូកែ តែគេក៏មានបំណិនផ្នែកនេះខ្លះដែរ។ គ្រូត្រូវមានភាពឆ្លាតវៃក្នុងការតម្រង់ទិសពួកគេឱ្យត្រូវបំណិន និងតួនាទីក្នុងក្រុម ដើម្បីជំរុញការលូតលាស់ និងបង្កើតការសិក្សាបែបគម្រោងបណ្ដុះបំណិនដែលជាឱកាសសម្រាប់ពួកគេអភិវឌ្ឍខ្លួន។"

**បញ្ចប់មេរៀនទី៤**

# មេរៀនទី៥៖ វិធីបញ្ចូល ICT នៅក្នុងដំណើរការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន

**រយៈពេលមេរៀន៖** ៦ម៉ោង ៣០នាទី (បន្ថែម ១០ម៉ោងស្វ័យសិក្សា ការហាត់សម និងការអនុវត្ត)

**សកម្មភាពអ្នកសម្របសម្រួលគួរត្រៀម៖**

- ត្រូវធានាថាសម្ភារទាំងអស់បានរៀបចំរួចជាស្រេច រួមមានឯកសារចែក ស្លាយធ្វើបទបង្ហាញ និងសម្ភារចាំបាច់ផ្សេងៗទៀត
- រៀបចំទីកន្លែងបណ្ដុះបណ្ដាលសម្រាប់សកម្មភាពក្រុម និងការពិភាក្សា
- ថតចម្លងឯកសារចែកទាំងអស់មានក្នុងបញ្ជីខាងក្រោម

**ធនធាន និងសម្ភារ៖**

- ស្លាយមេរៀន កុំព្យូទ័រដោយមានភ្ជាប់អ៊ិនធឺណិត ម៉ាស៊ីនបញ្ចាំងស្លាយ ផ្ទាំងស្លាយ
- ក្រដាស A4 និងប៊ិក
- ស្កុតបិទ
- ក្ដារខៀន ឬក្រដាសផ្ទាំងធំ និងហ្វឺត
- ថតចម្លង**ឯកសារចែក ៥.១**៖ កសាងប្រអប់ឧបករណ៍ ICT របស់អ្នក៖ ស្វែងរកផ្នែកឧបករណ៍ផ្សេងៗ
- ថតចម្លង**ឯកសារចែក ៥.២**៖ ការបញ្ចូល ICT ទៅក្នុងជំហានទាំង៦ ដំណាក់កាលនៃការអប់រំបំណិនជីវិតតាមមូលដ្ឋាន
- ថតចម្លង**ឯកសារចែក ៥.៣**៖ បំណិន និងគុណវុឌ្ឍិសម្រាប់អាជីព ICT នៅកម្ពុជា
- ថតចម្លង**ឯកសារចែក ៥.៤**៖ គន្លឹះសម្រាប់ការបញ្ចូល ICT ដោយជោគជ័យនៅក្នុងបំណិនជីវិតតាមមូលដ្ឋាន
- វីដេអូបង្ហាញពីការប្រើប្រាស់ ICT នៅសាលារៀននៅកម្ពុជា

**វត្ថុបំណងសិក្សា៖**

ពេលបញ្ចប់មេរៀនទី៥ អ្នកចូលរួមនឹងអាច៖

- ឈ្វេងយល់ពីសារៈសំខាន់ និងអត្ថប្រយោជន៍នៃការរួមបញ្ចូល ICT ទៅក្នុងការអប់រំបំណិនជីវិតនៅកម្ពុជា
- ពន្យល់ពីរបៀបបញ្ចូលឧបករណ៍ ICT ឥតគិតថ្លៃផ្សេងៗទៅក្នុងដំណាក់កាលនីមួយៗនៃដំណើរការអនុវត្តការអប់រំបំណិនជីវិត
- ឆ្លុះបញ្ចាំងពីឧទាហរណ៍ជាក់ស្ដែងនៃការធ្វើសមាហរណកម្ម ICT ប្រកបដោយជោគជ័យក្នុងការអប់រំបំណិនជីវិតនៅកម្ពុជា
- អនុវត្តយុទ្ធសាស្ត្រដើម្បីធានាការអនុវត្តជោគជ័យនៃឧបករណ៍ ICT នៅក្នុងកម្មវិធីការអប់រំបំណិនជីវិតតាមមូលដ្ឋានរបស់ពួកគេ

- ឈ្វេងយល់អំពីអាជីព ICT ផ្សេងៗ និងសំណុំជំនាញដែលត្រូវគ្នា

ឯកសារ និងកិច្ចការអាន៖

- ដំណោះស្រាយបច្ចេកវិទ្យាឌីជីថលសម្រាប់លើកកម្ពស់ការអប់រំបំណិនជីវិតតាមមូលដ្ឋាន-សាលាឌីជីថល (moeys.gov.kh)
- គំរូមេរៀនការអប់រំបំណិនជីវិតតាមមូលដ្ឋាន ( https://kapekh.org/files/report_file/407-en.pdf0

## ផែនការមេរៀន-មេរៀនទី៥

### សេចក្ដីផ្ដើម និងការកំណត់ជំហាន ( ១ម៉ោង )

អ្នកសម្របសម្រួលស្វាគមន៍អ្នកចូលរួមដោយបង្ហាញពីគោលបំណងរបស់មេរៀនទី៥ និងការបណ្ដុះបណ្ដាល។ អ្នកសម្របសម្រួលពន្យល់យ៉ាងសង្ខេបនូវបញ្ញត្តិនៃ ICT និងតួនាទីរបស់វាក្នុងការលើកកម្ពស់ការអប់រំ។ ICT មកពីពាក្យពេញថា បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។ វាសំដៅលើឧបករណ៍ និងបច្ចេកវិទ្យាប្រើដើម្បីបង្កើត រក្សាទុក គ្រប់គ្រង ចែករំលែក និងចូលប្រើប្រាស់ព័ត៌មាន។ នៅក្នុងវិស័យអប់រំ ICT ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការសិក្សារួមមាន៖

- ***ការធ្វើឱ្យការសិក្សាមានភាពទាក់ទាញ និងអន្តរកម្ម៖*** *ឧបករណ៍ ICT ដូចជាល្បែងសិក្សា ការបង្ហាញជាក់ស្ដែង និងធនធានពហុព័ត៌មានអាចធ្វើឱ្យការសិក្សាមានភាពសប្បាយរីករាយ និងទាញការយកចិត្តទុកដាក់របស់សិស្សបាន។*
- ***ការផ្ដល់ការចូលប្រើប្រាស់ព័ត៌មានបានយ៉ាងទំលំទូលាយ៖*** *អ៊ិនធឺណិតអនុញ្ញាតិឱ្យសិស្សចូលប្រើប្រាស់ព័ត៌មានជាច្រើនលើសពីសៀវភៅសិក្សាគោល ការលើកកម្ពស់ការសិក្សា និងបំណិនស្រាវជ្រាវបែបឯករាជ្យ ។*
- ***ការសម្របសម្រួលការសហការ និងការទំនាក់ទំនង៖*** *វេទិការ និងឧបករណ៍អនឡាញអាចជួយឱ្យសិស្សភ្ជាប់ទំនាក់ទំនងជាមួយមិត្តភក្តិ និងអ្នកអប់រំពីជុំវិញពិភពលោក ការជម្រុញការងារក្រុម និងបំណិនទំនាក់ទំនង។*
- ***ការលើកកម្ពស់ការសិក្សាតាមបែបបុគ្គល៖*** *ICT អនុញ្ញាតឱ្យមានបទពិសោធន៍សិក្សាជាលក្ខណៈបុគ្គលដោយផ្ដល់ឱ្យនូវរបៀប និងជំហាននៃការសិក្សាផ្សេងៗគ្នា។ សិស្សអាចចូលប្រើប្រាស់ធនធាន និងសកម្មភាពដែលតម្រូវតាមតម្រូវការជាក់លាក់របស់ពួកគេ។*
- ***ការអភិវឌ្ឍបំណិនអក្ខរកម្មឌីជីថល៖*** *នៅពេលដែលបច្ចេកវិទ្យាត្រូវបានបញ្ចូលទៅក្នុងសង្គមកាន់តែខ្លាំង ការរៀបចំឱ្យសិស្សមានបំណិនអក្ខរកម្មឌីជីថលគឺជាការចាំបាច់ណាស់។ ICT នៅក្នុងការអប់រំជួយសិស្សឱ្យមានភាពងាយស្រួលក្នុងការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការរៀន និងការទំនាក់ទំនង។*

សរុបសេចក្តីមក ICT អាចបំប្លែងការអប់រំពីវិធីសាស្ត្រគ្រូមជ្ឈមណ្ឌលទៅជាសិស្សមជ្ឈមណ្ឌលបានកាន់តែច្រើន ដោយការផ្តល់សិទ្ធិអំណាចដល់សិស្សឱ្យក្លាយជាអ្នកចូលរួមយ៉ាងសកម្មនៅក្នុងដំណើរសិក្សារបស់ពួកគេ។

### ការចែករំលែកបទពិសោធន៍ ICT នៅក្នុងថ្នាក់រៀននៅកម្ពុជា

អ្នកសម្របសម្រួលសួរអ្នកចូលរួមឱ្យចែករំលែកបទពិសោធន៍របស់ពួកគេជាមួយការប្រើប្រាស់ ICT នៅក្នុងថ្នាក់រៀនរបស់ពួកគេ។ ចាប់ផ្តើមដោយសួរសំណួរទៅកាន់អ្នកចូលរួមទាំងអស់៖

"ចូរគិតពីបទពិសោធន៍របស់អ្នក (ប្រសិនបើមាន) ដោយប្រើប្រាស់ឧបករណ៍ ICT នៅក្នុងថ្នាក់រៀន។ តើមានមធ្យោបាយណាខ្លះដែលអាចបញ្ចូលបច្ចេកវិទ្យាទៅក្នុងមេរៀនរបស់អ្នក?"

អ្នកសម្របសម្រួលផ្តល់ឱ្យអ្នកចូលរួមនូវក្រដាសបិទតូចៗ (sticky note) ហើយឱ្យពួកគេសរសេរនៅលើក្រដាសបិទតូចៗនីមួយៗដោយមានឧទាហរណ៍ជាក់លាក់ ពីវិធីដែលពួកគេប្រើប្រាស់ ICT នៅក្នុងថ្នាក់រៀន (ឬជាឧទាហរណ៍ដែលពួកគេមានសាក្សីពីសហការី) ណែនាំអ្នកចូលរួមឱ្យឡើងមកបិទក្រដាសបិទតូចៗដែលពួកគេបានសរសេរនៅលើក្តារខៀនខាងក្រោមចំណងជើងពីរ៖ **ភាពជោគជ័យ និងបញ្ហាប្រឈម**

អ្នកសម្របសម្រួល សម្របសម្រួលការពិភាក្សាក្រុមជុំវិញឧទាហរណ៍ដែលបានបិទនៅលើក្តារខៀន។

- សម្រាប់ "ភាពជោគជ័យ"៖ ស្វែងរកអ្វីដែលធ្វើឱ្យការបញ្ចូល ICT មានប្រសិទ្ធភាព (ឧ. ឧបករណ៍ជាក់លាក់ដែលបានប្រើប្រាស់ ប្រធានបទមេរៀន ការចូលរួមរបស់សិស្ស)។
- សម្រាប់ "បញ្ហាប្រឈម"៖ ពិភាក្សាដំណោះស្រាយដែលមានសក្តានុពល ឬយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងបរិបទសាលារៀននៅកម្ពុជា (ឧ.ការចូលប្រើអ៊ិនធឺណិតនៅមានកម្រិត កង្វះការបណ្តុះបណ្តាលគ្រូ ការពិចារណាសម្រាប់សាលារៀននៅតាមទីជនបទ)។

| **ភាពជោគជ័យ៖** ឧទាហរណ៍ដែលការបញ្ចូល ICT មានប្រសិទ្ធភាព | **បញ្ហាប្រឈម៖** ឧទាហរណ៍ដែលការបញ្ចូល ICT មានការលំបាក |
| --- | --- |
| | |

**សេចក្តីសន្និដ្ឋាន៖** នៅក្នុងវគ្គនេះ អ្នកចូលរួមនឹងចែករំលែកពីបទពិសោធន៍របស់ខ្លួនជាមួយនឹងការបញ្ចូល ICT ទាំងផលវិជ្ជមាន និងអវិជ្ជមាន។ ការពិភាក្សានេះនឹងជំរុញឱ្យមានគំនិត និងបង្កើតយុទ្ធសាស្រ្តសម្រាប់ការបញ្ចូល ICT ប្រកបដោយប្រសិទ្ធភាពនៅក្នុងថ្នាក់រៀននៅកម្ពុជា។ ហើយអ្នកចូលរួមនឹងទទួលបានការយល់ដឹងអំពីបរិបទជាក់លាក់ និងបញ្ហាប្រឈមដែលសាលារៀននៅកម្ពុជាជួបប្រទះនៅពេលបញ្ចូលបច្ចេកវិទ្យា។

## បញ្ហាប្រឈម និងឱកាសនៃការបញ្ចូល ICT នៅក្នុងការអប់រំបំណិនជីវិតតាមមូលដ្ឋាននៅកម្ពុជា ( ១ម៉ោង )

យោងតាម "ការចែករំលែកបទពិសោធន៍ ICT ក្នុងថ្នាក់រៀននៅកម្ពុជា" ការតាមដាននេះ បង្ហាញឱ្យកាន់តែស៊ីជម្រៅទៅលើបញ្ហាប្រឈម និងឱកាសនៃការបញ្ចូល ICT ក្នុងការអប់រំបំណិនជីវិតតាមមូលដ្ឋាននៅកម្ពុជា។ អ្នកសម្របសម្រួលសង្ខេបដោយខ្លីនូវចំណុចសំខាន់ៗពីសកម្មភាពមុន ដោយលើកឡើងពីភាពជោគជ័យ និងបញ្ហាប្រឈមដែលបានកំណត់ជាមួយការបញ្ចូល ICT។

បន្ទាប់មក អ្នកសម្របសម្រួលផ្លាស់ប្តូរការផ្តោតអារម្មណ៍ទៅជាការពិភាក្សាដ៏ទូលំទូលាយវិញ ដោយសួរសំណួរភ្លាមៗ៖

"ការពិចារណាបរិបទសាលារៀននៅកម្ពុជា និងការអប់រំបំណិនជីវិតតាមមូលដ្ឋានជាពិសេស តើអ្វីជាបញ្ហាប្រឈមដ៏ធំជាងគេបំផុត ដែលពួកយើងប្រឈមមុខនៅពេលបញ្ចូលឧបករណ៍ ICT នោះ ?"

អ្នកសម្របសម្រួលផ្តល់ឱ្យអ្នកចូលរួមនូវហ្វឹត និងណែនាំពួកគេឱ្យប្រមូលគំនិតពីបញ្ហាប្រឈមនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។ លើកទឹកចិត្តឱ្យមានការចូលរួមយ៉ាងសកម្ម ដោយឱ្យអ្នកចូលរួមចូលរួមផ្តល់ និងកសាងគំនិតជាមួយគ្នាទៅវិញទៅមក។ ប្រើហ្វឹតមានពណ៌ផ្សេងគ្នា ដើម្បីបែងចែកភាពខុសគ្នារវាងការរួមចំណែករបស់អ្នកចូលរួម។ នៅពេលដែលបញ្ជីបញ្ហាប្រឈមត្រូវបានបង្កើតឡើងរួចហើយ អ្នកសម្របសម្រួលប្តូរការចាប់អារម្មណ៍ទៅរកឱកាសវិញម្តងដោយសួរ៖

"ទោះបីជាមានបញ្ហាប្រឈមខ្លះក្តី តើមានឱកាសអ្វីអាចឱ្យមានការបញ្ចូល ICT ចូលទៅក្នុងការអប់រំបំណិនជីវិតតាមមូលដ្ឋាននៅកម្ពុជា ?"

អ្នកសម្របសម្រួលធ្វើការរំលឹកឡើងវិញនូវដំណើរការបំផុសគំនិត ដោយលើកនេះផ្តោតលើឱកាសសម្រាប់ការបញ្ចូល ICT នៅក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន។ អ្នកចូលរួមអាចប្រើហ្វឹតពណ៌ថ្មីដើម្បីបែងចែកគំនិតរបស់ពួកគេ។

អ្នកសម្របសម្រួលសម្របសម្រួលការពិភាក្សាជាក្រុមជុំវិញបញ្ហាប្រឈម និងឱកាសដែលបានរាយបញ្ជីនៅលើក្ដារខៀន។ ស្វែងរកដំណោះស្រាយ ឬយុទ្ធសាស្ត្រដែលមានសក្ដានុពល ដើម្បីដោះស្រាយលើបញ្ហាប្រឈមដែលបានកំណត់ (ពិចារណារកដំណោះស្រាយដែលបានពិភាក្សានៅក្នុងសកម្មភាពមុន)។ បន្ទាប់មកពិភាក្សាអំពីឱកាសជាក់លាក់ដែលអាចប្រើប្រាស់បាន ដើម្បីលើកកម្ពស់ការអប់រំបំណិនជីវិតតាមមូលដ្ឋាន (ឧ. ការកែលម្អការចូលរួមរបស់សិស្ស ការលើកកម្ពស់កិច្ចសហការក្នុងការផ្សព្វផ្សាយដល់សហគមន៍)។

**សេចក្ដីសន្និដ្ឋាន៖** ក្នុងសកម្មភាពនេះ អ្នកចូលរួមនឹងទទួលបានការយល់ដឹងកាន់តែស៊ីជម្រៅអំពីបញ្ហាប្រឈមជាក់លាក់ និងឱកាសនៃការបញ្ចូល ICT ក្នុងការអប់រំបំណិនជីវិតតាមមូលដ្ឋាននៅកម្ពុជា។ ការពិភាក្សានឹងលើកទឹកចិត្តឱ្យអ្នកចូលរួមគិតប្រកបដោយភាពច្នៃប្រឌិតអំពីការជំនះលើបញ្ហាប្រឈម និងការប្រើប្រាស់បច្ចេកវិទ្យាឱ្យអស់ពីលទ្ធភាព។ ហើយសកម្មភាពនេះនឹងកំណត់ដំណាក់កាលសម្រាប់វគ្គបណ្ដុះបណ្ដាលដែលនៅសល់ ហើយអ្នកចូលរួមនឹងស្វែងយល់បន្ថែមអំពីយុទ្ធសាស្ត្រជាក់ស្ដែងសម្រាប់ការបញ្ចូល ICT នៅក្នុងដំណាក់កាលនីមួយៗនៃដំណើរការបំណិនជីវិតតាមមូលដ្ឋាន។

### ការកសាងប្រអប់ឧបករណ៍ ICT របស់អ្នក៖ ស្វែងរកផ្នែកឧបករណ៍ផ្សេងៗគ្នា ICT (៣០នាទី)

អ្នកសម្របសម្រួលចាប់ផ្ដើមណែនាំថាក្នុងវគ្គនេះ អ្នកចូលរួមនឹងរៀនអំពីប្រភេទផ្សេងៗនៃឧបករណ៍ ICT ដែលអាចបញ្ចូលទៅក្នុងមេរៀនទូទៅ ដើម្បីបង្កើនការរៀនសូត្រ និងការចូលរួមរបស់សិស្ស។




អ្នកសម្របសម្រួលបែងចែកអ្នកចូលរួមជាក្រុមតូចៗ ដោយចាត់ក្រុមនីមួយៗនូវប្រភេទមួយពីផែនទីគំនិតប្រអប់ឧបករណ៍ ICT។ ចាត់ចែងក្រុមនីមួយៗដើម្បីស្រាវជ្រាវ និងពិភាក្សាអំពីឧបករណ៍ជាក់លាក់នៅក្នុងប្រភេទដែលបានកំណត់របស់ពួកគេ។ លើកទឹកចិត្តពួកគេឱ្យពិចារណា៖

o ចំណុចខ្លាំង និងចំណុចខ្សោយនៃឧបករណ៍ផ្សេងៗ

o កម្មវិធីសក្តានុពលក្នុងការអប់រំបំណិនជីវិតតាមមូលដ្ឋាន

o ភាពស្និទ្ធស្នាលក្នុងការប្រើប្រាស់ និងភាពងាយស្រួលសម្រាប់សិស្សានុសិស្ស

បន្ទាប់មក អ្នកសម្របសម្រួលសុំឱ្យក្រុមនីមួយៗបង្ហាញការរកឃើញរបស់ពួកគេទៅកាន់ទស្សនិកជនកាន់តែច្រើន ចែករំលែកឧទាហរណ៍ និងជំរុញការពិភាក្សា។



### ការកសាងប្រអប់ឧបករណ៍ ICT៖ ស្វែងរកវិធីដែលទាក់ទាញ ( ១ម៉ោង )

អ្នកសម្របសម្រួលយោងលើ**ឯកសារ ៥.១**៖ ការកសាងប្រអប់ឧបករណ៍ ICT របស់អ្នក៖ ស្វែងរកប្រភេទឧបករណ៍ផ្សេងៗ (**ចែកឯកសារ ៥.១**) និងឱ្យអ្នកចូលរួមបើកមើលហើយអានវា។ អ្នកសម្របសម្រួលពិនិត្យមើលផ្នែកនីមួយៗម្តងមួយៗ និងសង្កត់ធ្ងន់លើចំណុចគន្លឹះៗ៖

- ពន្យល់ត្រួសៗពីគោលបំណងនៃផ្នែកនីមួយៗ (ឧ.រៀបចំឧបករណ៍សម្រាប់បង្កើតរូបភាព)
- រៀបរាប់ពីឧបករណ៍ជាឧទាហរណ៍ដែលចុះបញ្ជីនៅក្នុងផ្នែកនោះ
- លើកទឹកចិត្តអ្នកចូលរួមឱ្យសួរសំណួរបញ្ជាក់ស្ដីពីផ្នែកជាក់លាក់ ឬឧបករណ៍ណាមួយ

### ការស្វែងរកតាមគេហទំព័រ៖

អ្នកសម្របសម្រួលបែងចែកអ្នកចូលរួមជាក្រុមតូចៗ (អ្នកចូលរួម ៤ ទៅ ៥នាក់ក្នុងមួយក្រុម)។ រៀបចំផ្នែកឧបករណ៍ ICT ជាក់លាក់ដល់ក្រុមនីមួយៗ (ត្រូវធានាថាមិនមានការត្រួតស៊ីគ្នាដើម្បីជៀសវាងការច្រំដែល)។ បន្ទាប់មកអ្នកសម្របសម្រួលណែនាំទៅក្រុមនីមួយៗដើម្បីជ្រើសរើសឧបករណ៍គំរូមួយដែលមាននៅក្នុងបញ្ជីក្នុងផ្នែកដែលបានរៀបចំឱ្យពីឯកសារចែក។ (ម៉្យាងទៀតប្រសិនបើមានឧបករណ៍ជាក់លាក់ដែលអ្នកសម្របសម្រួលចង់ឱ្យពួកគេស្វែងរក គេអាចចាត់តាំងវាដោយផ្ទាល់)។ អ្នកសម្របសម្រួលទុកពេលឱ្យពួកគេមួយចំនួន (ប្រហែល ៥-៧នាទី) ដើម្បីស្វែងរកឧបករណ៍ដែលបានជ្រើសរើសដោយប្រើកម្មវិធីស្វែងរកតាមអ៊ីនធឺណិត។ អ្នកសម្របសម្រួលលើកទឹកចិត្តពួកគេឱ្យ៖

- ចូលមើលឧបករណ៍របស់គេហទំព័រ ឬធនធានផ្លូវការ
- រកមើលលក្ខណៈ និងមុខងារដែលមាន
- ស្វែងរកវីដេអូបង្រៀន ឬវីដេអូណែនាំ (ប្រសិនបើមាន)

### ការជម្រុញការរុករក (ជម្រើស)៖

អាស្រ័យលើពេលវេលា និងធនធានដែលមាន អ្នកសម្របសម្រួលពិចារណាផ្ដល់នូវជំហានរុករកតាមជម្រើសមួយ៖

- ប្រសិនបើឧបករណ៍ខ្លះផ្ដល់គណនីដោយឥតគិតថ្លៃបណ្ដោះអាសន្ន ឬមុខងារមូលដ្ឋានមួយចំនួនដោយមិនចាំបាច់ចុះឈ្មោះ អ្នកសម្របសម្រួលអាចព្យាយាមបង្កើតគម្រោងគំរូ ឬសកម្មភាពនៅក្នុងឧបករណ៍។
- នេះអាចផ្ដល់ប្រយោជន៍ជាពិសេសសម្រាប់ផ្នែកមួយចំនួនដូចជាឧបករណ៍ដែលរៀបចំការបង្កើតឯកសារ ឬឧបករណ៍វាស់វែង។

### ការចែករំលែក និងការពិភាក្សាក្រុម៖

អ្នកសម្របសម្រួលមានក្រុមចែករំលែកឧបករណ៍ដែលជ្រើសរើសរបស់ពួកគេ និងលទ្ធផលសំខាន់ៗពីការរុករកនោះ។ អ្នកសម្របសម្រួលលើកទឹកចិត្តពួកគេឱ្យពិភាក្សា៖

- តើអ្វីជាចំណាប់អារម្មណ៍ដំបូងរបស់ពួកគេចំពោះឧបករណ៍?
- តើលក្ខណៈ និងមុខងារសំខាន់ៗអ្វីខ្លះដែលពួកគេបានរកឃើញ?
- តើពួកគេអាចស្រមៃដោយប្រើឧបករណ៍នេះសម្រាប់ការអប់រំបំណិនជីវិតតាមមូលដ្ឋានបានដែរឬទេ? បានយ៉ាងដូចម្ដេច?

សម្របសម្រួលការពិភាក្សានៅក្នុងថ្នាក់នូវការធ្វើបទបង្ហាញបន្តបន្ទាប់ ដោយអនុញ្ញាតឱ្យអ្នកចូលរួមសួរសំណួរ និងចែករំលែកការយល់ឃើញផ្ទាល់ខ្លួនលើឧបករណ៍ដែលបានរុករកនោះ។

**សេចក្ដីសន្និដ្ឋាន៖ អ្នកសម្របសម្រួលសង្ខេបខ្លីៗនូវចំណុចសំខាន់ៗដែលបានពិភាក្សាអំឡុងពេលធ្វើសកម្មភាពរុករក។ លើកទឹកចិត្តអ្នកចូលរួមឱ្យបន្តរុករកឧបករណ៍** ICT ផ្សេងៗទៀតក្រៅពីវគ្គនេះ។ ហើយអ្នកសម្របសម្រួលត្រូវរំលឹកពួកគេពីឯកសារចែកដែលជាឯកសារយោងណែនាំសម្រាប់ផ្នែកឧបករណ៍ ICT ជាច្រើនទៀត។ ការរុករកដែលគួឱ្យទាក់ទាញនេះអនុញ្ញាតឱ្យអ្នកចូលរួមស្វែងរកកាន់តែស៊ីជម្រៅលើឧបករណ៍ជាក់លាក់នៅក្នុងផ្នែកដែលបានរៀបរាប់។ ដោយបញ្ចូលគ្នានូវការរុករកតាមគេហទំព័រជាមួយសកម្មភាពលើកកម្ពស់ការសិក្សាតាមជម្រើស និងការពិភាក្សាក្រុម វិធីសាស្ត្រនេះជម្រុញការសិក្សាបែបសកម្ម និងជួយអ្នកចូលរួមឱ្យធ្វើការសម្រេចចិត្តត្រឹមត្រូវលើការបញ្ចូលឧបករណ៍ ICT ទៅក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន។



### ការបញ្ចូល ICT ទៅក្នុងដំណាក់កាលទាំង៦ របស់បំណិនជីវិតតាមមូលដ្ឋាន (១ម៉ោង)

វគ្គនេះនឹងស្វែងរកការបញ្ចូលឧបករណ៍ព័ត៌មានវិទ្យា និងបច្ចេកវិទ្យាទំនាក់ទំនង (ICT) ឱ្យមានប្រសិទ្ធភាពទៅក្នុងដំណាក់កាលនីមួយៗនៃដំណើរការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន។

អ្នកសម្របសម្រួលរំលឹកត្រួសៗដល់អ្នកចូលរួមនូវដំណាក់កាលទាំង៦ រួមបញ្ចូលទាំងការអនុវត្ត (ឧ. ការប្រើប្រាស់រូបភាព ឬស្រងពួកវាដាក់លើក្ដារខៀន) ដែលពួកគេបានរៀននៅក្នុងមេរៀនទី៤។ អ្នកសម្របសម្រួលអាចសួរអ្នកស្ម័គ្រចិត្តពីរបីនាក់ឱ្យសង្ខេបដំណាក់កាលនីមួយៗតាមពាក្យផ្ទាល់ខ្លួនគេ ដើម្បីធានាថាអ្នកទាំងអស់គ្នាមានការយល់ដឹងដូចគ្នា។

អ្នកសម្របសម្រួលពន្យល់ថា ការបញ្ចូល ICT លើកកម្ពស់ទិដ្ឋភាពជាច្រើននៃបំណិនជីវិតតាមមូលដ្ឋានដោយការធ្វើឱ្យមានប្រសិទ្ធភាពកាន់តែច្រើន មានការចូលរួម និងមានទិន្នន័យច្បាស់លាស់។

បន្ទាប់មកណែនាំខ្លីៗនូវបញ្ញត្តិនៃការបញ្ចូល ICT សម្រាប់ដំណាក់កាលនីមួយៗ សង្កត់ធ្ងន់ពីអត្ថប្រយោជន៍ដែលមានសក្តានុពលដោយសំដៅលើ ឯកសារ ៥.២ ជាឧទាហរណ៍ជាក់លាក់។

អ្នកសម្របសម្រួលចែកឯកសារ ៥.២៖ "ការបញ្ចូល ICT ទៅក្នុងដំណាក់កាលទាំង៦ នៃបំណិនជីវិតតាមមូលដ្ឋាន"។ បន្ទាប់មកផ្តល់ឱ្យអ្នកចូលរួមនូវពេលវេលាមួយចំនួនដើម្បីរុករកឧបករណ៍ ICT ដែលបានស្នើឡើងសម្រាប់ដំណាក់កាលនៃបំណិនជីវិតតាមមូលដ្ឋាននៅក្នុងឯកសារ។ លើកទឹកចិត្តពួកគេឱ្យពិចារណាលើឧបករណ៍បន្ថែមដែលពួកគេស្គាល់។

អ្នសម្របសម្រួលបែងចែកអ្នកចូលរួមជាក្រុមតូចៗ (ប្រហែល៤-៥នាក់)។ ដាក់កិច្ចការលើដំណាក់កាលបំណិនជីវិតតាមមូលដ្ឋានជាក់លាក់ (ឧ.ដំណាក់កាលទី១៖ ការស្វែងយល់ពីប្រធានបទ) ដល់ក្រុមនីមួយៗ។ អ្នកសម្របសម្រួលណែនាំក្រុមនីមួយៗឱ្យពិភាក្សា និងប្រមូលគំនិតលើឧបករណ៍ ICT ដែលមានសក្តានុពល ពួកគេអាចប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពសម្រាប់ដំណាក់កាលដែលពួកគេបានចាត់ចែងនៃដំណើរការបំណិនជីវិតតាមមូលដ្ឋាន។ អ្នកសម្របសម្រួលលើកទឹកចិត្តពួកគេឱ្យពិចារណាកត្តាមួយចំនួនដូចជា៖

- អាយុ និងកម្រិតអក្ខរកម្មឌីជីថលនៃក្រុមគោលដៅ។
- វត្ថុបំណងមេរៀនច្បាស់លាស់សម្រាប់ដំណាក់កាលនោះ។
- ធនធាន និងលទ្ធភាពនៃការចូលប្រើប្រាស់ដែលអាចមាន។

អ្នកសម្របសម្រួលមានក្រុមនីមួយៗធ្វើបទបង្ហាញឧបករណ៍ដែលបានជ្រើសរើសរបស់ខ្លួន និងវិធីដែលពួកគេបញ្ចូលឧបករណ៍ទាំងនោះទៅក្នុងដំណាក់កាលបំណិនជីវិតតាមមូលដ្ឋានដែលដាក់កិច្ចការឱ្យធ្វើ។ លើកទឹកចិត្តពួកគេឱ្យផ្តល់ឧទាហរណ៍ច្បាស់លាស់នៃរបៀបដែលឧបករណ៍អាចប្រើប្រាស់បាន (ឧ. ការបង្កើតតេស្តតាមអនឡាញដើម្បីវាស់វែងបុរេពុទ្ធិនៅដំណាក់កាលទី១)។ អ្នកសម្របសម្រួលសម្របសម្រួលការពិភាក្សាក្រុមធំដោយតាមលំដាប់លំដោយនៃការធ្វើបទបង្ហាញនីមួយៗ។

- លើកទឹកចិត្តឱ្យសួរសំណួរ ផ្តល់ព័ត៌មានត្រឡប់ និងស្នើយោបល់ពីអ្នកចូលរួមផ្សេងៗទៀត។
- ពិភាក្សាពីភាពខ្លាំង និងខ្សោយនៃឧបករណ៍ដែលបានស្នើ និងស្វែងរកជម្រើសរើសផ្សេងៗ។



## ការបញ្ចូលឧបករណ៍ ICT ផ្សេងៗគ្នាទៅក្នុងគំរូមេរៀនការអប់រំបំណិនជីវិតតាមមូលដ្ឋានក្នុងពិភពពិត (១ ម៉ោង)

អ្នកសម្របសម្រួលនិយាយថា វគ្គនេះផ្តល់ឱ្យអ្នកចូលរួមនូវឱកាសមួយដើម្បីស្វែងយល់ពីការអនុវត្តជាក់ស្តែងនៃឧបករណ៍ ICT នៅក្នុងគំរូមេរៀនការអប់រំបំណិនជីវិតាមមូលដ្ឋាន។ តាមរយៈការងារជា

ក្រុម និងការបំផុសគំនិត អ្នកចូលរួមនឹងទទួលបានបទពិសោធន៍ជាក់ស្តែងក្នុងការជ្រើសរើស និងរួមបញ្ចូលឧបករណ៍ ICT ដែលសមស្របដើម្បីបង្កើនលទ្ធផលសិក្សា។

មុនពេលសកម្មភាពនេះ អ្នកសម្របសម្រួលសំដៅដល់អ្នកចូលរួមក្នុងការចែកជូន**ឯកសារ ៥.១**៖ "ការកសាងប្រអប់ឧបករណ៍ ICT របស់អ្នក៖ការរុករកប្រភេទឧបករណ៍ផ្សេងៗ"(ដែលបានចែកជូនពីមុន) ហើយផ្តល់ឯកសារថតចម្លងគំរូមេរៀនការអប់រំបំណិនជីវិតាមមូលដ្ឋាន ឬសុំឱ្យពួកគេមើលមេរៀនតាមរយៈតំណភ្ជាប់នេះ៖ https: //kapekh.org/files/report_file/407-en.pdf សម្រាប់ការងារក្រុម។

អ្នកសម្របសម្រួលផ្តល់ក្រដាសគំនូសតាង ឬហ្វឺតក្តារខៀនសម្រាប់បទបង្ហាញជាក្រុមផងដែរ។

អ្នកសម្របសម្រួលណែនាំយ៉ាងខ្លីអំពីសកម្មភាព និងគោលបំណងរបស់វា (ការរួមបញ្ចូលឧបករណ៍ ICT ទៅក្នុងមេរៀនការអប់រំបំណិនជីវិតាមមូលដ្ឋានក្នុងពិភពពិត) ហើយបន្ទាប់មកបង្ហាញគំរូមេរៀនការអប់រំបំណិនជីវិតាមមូលដ្ឋានក្នុងពិភពពិតដែលបានរៀបចំទុកជាមុននៅក្នុងតំណភ្ជាប់ខាងលើ ហើយត្រូវប្រាកដថាគំរូមេរៀនបង្ហាញយ៉ាងច្បាស់អំពីគោលបំណងសិក្សា ខ្លឹមសារគោល និងសកម្មភាពដែលបានគ្រោងទុក។

**(ការងារជាក្រុម) ការរួមបញ្ចូលឧបករណ៍ ICT (២៥នាទី)៖**

អ្នកសម្របសម្រួលបែងចែកអ្នកចូលរួមជាក្រុមតូចៗ (ចំនួនអ្នកចូលរួម ៤-៥នាក់)។ ផ្តល់ឱ្យក្រុមនីមួយៗនូវឯកសារថតចម្លងគំរូមេរៀនការអប់រំបំណិនជីវិតាមមូលដ្ឋាន(សូមមើលតំណភ្ជាប់ខាងលើ) និង**ឯកសារចែក ៥.១** "ការកសាងប្រអប់ឧបករណ៍ ICT របស់អ្នក"។

អ្នកសម្របសម្រួលណែនាំក្រុមនីមួយៗឱ្យ៖

- ពិនិត្យដោយប្រុងប្រយ័ត្ននូវគំរូមេរៀនការអប់រំបំណិនជីវិតាមមូលដ្ឋានដែលបានផ្តល់ជូនដោយផ្តោតលើគោលបំណងសិក្សា និងសកម្មភាពដែលបានគ្រោងទុកនៅតាមដំណាក់កាលនីមួយៗ។

- យោងទៅលើសៀវភៅណែនាំឧបករណ៍ ICT ដើម្បីបំផុសគំនិតឧបករណ៍ ICT ដ៏មានសក្តានុពលពីប្រភេទផ្សេងៗដែលអាចត្រូវបានដាក់បញ្ចូលទៅក្នុងដំណាក់កាលផ្សេងៗគ្នានៃមេរៀន។

- ពិភាក្សាអំពីរបៀបដែលឧបករណ៍ ICT នីមួយៗដែលបានជ្រើសរើសនឹងជួយបង្កើនបទពិសោធន៍សិក្សា និងគាំទ្រសិស្សក្នុងការសម្រេចគោលបំណងមេរៀន។

- ពិចារណាលើកត្តាមួយចំនួនដូចជា អាយុសិស្ស ជំនាញអក្ខរកម្មឌីជីថល និងធនធានដែលមាននៅពេលជ្រើសរើសឧបករណ៍។

**បទបង្ហាញក្រុមតូច និងការពិភាក្សាក្រុមធំ (៣០នាទី)៖**

បន្ទាប់ពីបញ្ចប់ការងារក្រុមតូច អ្នកសម្របសម្រួលប្រាប់ថាក្រុមនីមួយៗមានពេល ៥-៧នាទីដើម្បីបង្ហាញឧបករណ៍ ICT ដែលបានជ្រើសរើសរបស់ពួកគេ និងផែនការរួមបញ្ចូលរបស់ពួកគេសម្រាប់គំរូមេរៀនការអប់រំបំណិនជីវិតាមមូលដ្ឋាន។ អ្នកសម្របសម្រួលលើកទឹកចិត្តពួកគេឱ្យប្រើក្រដាសគំនូសតាង ឬក្តារខៀន ដើម្បីបង្ហាញឱ្យឃើញនូវគំនិតរបស់ពួកគេ (ឧ. តារាងបង្ហាញជំហានមេរៀនឧបករណ៍ ICT ដែលត្រូវគ្នា និងរបៀបដែលពួកគេបង្កើនការរៀនសូត្រ)។

បន្ទាប់ពីការធ្វើបទបង្ហាញនីមួយៗ អ្នកសម្របសម្រួលសម្របសម្រួលដឹកនាំការពិភាក្សាក្រុមធំ ដើម្បីស្វែងយល់ពីយុទ្ធសាស្រ្តសមាហរណកម្ម ICT ដែលបានស្នើឡើង។ លើកទឹកចិត្តឱ្យមានសំណួរ មតិកែលម្អ និងការផ្តល់យោបល់ពីអ្នកចូលរួមផ្សេងទៀត។ ពិភាក្សាពីចំណុចខ្លាំង និងចំណុចខ្សោយនៃវិធីសាស្រ្តនីមួយៗដែលបានស្នើឡើង និងស្វែងរកឧបករណ៍ ICT ជំនួសដែលអាចប្រើប្រាស់បាន។

**សេចក្តីសន្និដ្ឋាន៖** អ្នកសម្របសម្រួលសង្ខេបចំណុចសំខាន់ៗដែលបានពិភាក្សាក្នុងអំឡុងពេលធ្វើសកម្មភាព។ សង្កត់ធ្ងន់លើសារៈសំខាន់នៃការពិចារណាបរិបទ (តម្រូវការរបស់សិស្ស ធនធាន) នៅពេលជ្រើសរើសឧបករណ៍ ICT។ លើកទឹកចិត្តឱ្យអ្នកចូលរួមបន្តស្វែងរកវិធីច្នៃប្រឌិតក្នុងការរួមបញ្ចូលឧបករណ៍ ICT ទៅក្នុងផែនការមេរៀនការអប់រំបំណិនជីវិតាមមូលដ្ឋានផ្ទាល់ខ្លួនរបស់ពួកគេ។

### ការបញ្ចូល ICT - ឧត្តមានុវត្តនៅកម្ពុជា (៣០នាទី)

វគ្គនេះស្វែងរកការអនុវត្តការបញ្ចូល ICT ប្រកបដោយភាពជោគជ័យសម្រាប់សាលារៀននៅកម្ពុជាសម្រាប់ការអប់រំបំណិនជីវិតតាមមូលដ្ឋាន។ ដោយស្វែងរកឧទាហរណ៍ក្នុងពិភពពិតជាក់ស្តែង អ្នកចូលរួមអាចទទួលបានការយល់ដឹងដ៏មានតម្លៃ និងទាក់ទាញសម្រាប់យុទ្ធសាស្រ្តបង្រៀនផ្ទាល់ខ្លួន។

**អ្នកសម្របសម្រួលណែនាំខ្លីៗពីសារៈសំខាន់នៃការសិក្សាពីឧទាហរណ៍ដែលជោគជ័យ។ រំលេចពីរបៀបដែលករណីសិក្សាអាចបង្ហាញវិធីសាស្រ្តនៃការបញ្ចូល** ICT ប្រកបដោយប្រសិទ្ធភាព និងទាក់ទាញឱ្យអ្នកចូលរួមទទួលយកវិធីទាំងនេះសម្រាប់បរិបទរបស់ពួកគេ។

បន្ទាប់មកអ្នកសម្របសម្រួលចាក់វីដេអូស្តីពីការអប់រំស្នែមចំនួន ៨នាទី ដែលផ្តោតលើទិដ្ឋភាពការបញ្ចូល ICT។ នេះជាតំណភ្ជាប់វីដេអូ៖ https://fb.watch/rM6mo6DU_i/?mibextid=jmPrMh ។ បន្ទាប់ពីមើលវីដេអូរួចហើយ ឈប់សិនដើម្បីធ្វើការឆ្លុះបញ្ចាំង។ អ្នកសម្របសម្រួលសម្របសម្រួលការពិភាក្សាពីការបង្ហាញជាឧទាហរណ៍ដោយបែងចែកអ្នកចូលរួមជាក្រុមតូចៗ (ជាគំនិតពី ៤-៥នាក់)។

អ្នកសម្របសម្រួលពិចារណាការបញ្ចូលឧបករណ៍អនឡាញដូចជា mentimeter ឬ Padlet សម្រាប់ការពិភាក្សាដែលមានអន្តរកម្ម និងការប្រមូលគំនិតក្នុងអំឡុងពេលធ្វើការការងារជាក្រុម។ អ្នកសម្របសម្រួលណែនាំក្រុមនីមួយៗឱ្យពិភាក្សាគ្នាលើសំណួរបន្តបន្ទាប់អាស្រ័យលើករណីដែលបានបង្ហាញ៖

| **ឧបករណ៍ ICT៖** តើឧបករណ៍ ICT ជាក់លាក់អ្វីដែលបានប្រើប្រាស់នៅក្នុងករណីសិក្សានេះ? | **ប្រធានបទបំណិនជីវិតតាមមូលដ្ឋាន៖** តើប្រធានបទបំណិនជីវិតតាមមូលដ្ឋានអ្វីត្រូវបានបង្ហាញតាមរយៈការបញ្ចូល ICT? | **អត្ថប្រយោជន៍ដែលបានសង្កេត៖** តើអ្វីជាលទ្ធផល ឬជាអត្ថប្រយោជន៍បែបវិជ្ជមានត្រូវបានសង្កេតឃើញពីការប្រើប្រាស់ឧបករណ៍ ICT? (ឧ. ពង្រឹងការសិក្សា បង្កើនការចូលរួមរបស់សិស្ស។) | **ការយកឈ្នះបញ្ហាប្រឈម៖** តើករណីសិក្សាបានរៀបរាប់បញ្ហាប្រឈមអ្វីខ្លះដែលជួបប្រទះពេលបញ្ចូលឧបករណ៍ ICT? តើពួកគេដោះស្រាយវាយ៉ាងដូចម្តេច? |
|---|---|---|---|
| | | | |

អ្នកសម្របសម្រួលលើកទឹកចិត្តអ្នកចូលរួមឱ្យចែករំលែកគំនិតយោបល់ ការយល់ឃើញ និងបទពិសោធន៍ដែលពាក់ព័ន្ធនឹងចំណុចពិភាក្សា។

## ការឆ្លុះបញ្ចាំង និងចែករំលែក៖

អ្នកសម្របសម្រួលសួរ៖

- សួរអ្នកចូលរួមឱ្យឆ្លុះបញ្ចាំងពីរបៀបដែលបង្ហាញជាឧទាហរណ៍អាចទាក់ទាញយុទ្ធសាស្ត្របញ្ចូលរបស់ពួកគេផ្ទាល់នៅក្នុងការអប់រំបំណិនជីវិតតាមមូលដ្ឋាន។
- ឱ្យក្រុមនីមួយៗចែករំលែកទស្សនៈ និងគំនិតយោបល់សំខាន់ៗសម្រាប់ទទួលយកការអនុវត្តដែលបានសង្កេតទៅកាន់បរិបទជាក់លាក់។
- សម្របសម្រួលការពិភាក្សាក្រុមធំដើម្បីស្វែងរកសាច់រឿង និងបញ្ហាប្រឈមដូចគ្នា។
- លើកទឹកចិត្តឱ្យអ្នកចូលរួមសួរសំណួរ និងចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនជាមួយការបញ្ចូលឧបករណ៍ ICT ។

**គន្លឹះបន្ថែម (ជម្រើស)៖** ប្រសិនបើអាច អញ្ជើញអ្នកអប់រំកម្ពុជាម្នាក់ដែលមានបទពិសោធន៍ជាវាគ្មិន ចែករំលែកបទពិសោធន៍ការបញ្ចូល ICT ទៅក្នុងមេរៀនបំណិនជីវិតតាមមូលដ្ឋានដោយជោគជ័យ។

**សេចក្តីសន្និដ្ឋាន៖** ដោយការបញ្ចូលបទបង្ហាញជាវីដេអូ ករណីសិក្សា និងការពិភាក្សាក្រុម ផ្នែកនេះផ្តល់វិធីដែលងាយយល់ និងទាក់ទាញសម្រាប់អ្នកចូលរួមដើម្បីសិក្សាពីការអនុវត្តការបញ្ចូល ICT ដោយជោគជ័យនៅកម្ពុជា។ ការផ្តោតលើការឆ្លុះបញ្ចាំង និងចែករំលែកអនុញ្ញាតឱ្យពួកគេទទួលយកការអនុវត្តទាំងនេះទៅក្នុងបរិបទរបស់ពួកគេ និងលើកកម្ពស់យុទ្ធសាស្ត្រការសិក្សាបំណិនជីវិតតាមមូលដ្ឋាន។

## ស្វែងយល់ពីអាជីព ICT នៅកម្ពុជា (១ម៉ោង)

វគ្គនេះមានគោលបំណងបំផុសទឹកចិត្តអ្នកសិក្សាបំណិនជីវិតតាមមូលដ្ឋានដោយបង្ហាញពីឱកាសការងារដ៏គួរឱ្យចាប់អារម្មណ៍នៅក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) ដែលកំពុងរីកចម្រើនឥតឈប់ឈរនៅក្នុងប្រទេសកម្ពុជា។ តាមរយៈការស្វែងយល់ពីវិជ្ជាជីវៈ ICT ផ្សេងៗគ្នា និងជំនាញដែលពួកគេត្រូវការ អ្នកចូលរួមអាចទទួលបានការយល់ដឹងដ៏មានតម្លៃចំពោះអាជីពនាពេលអនាគតដ៏មានសក្តានុពល។

អ្នកសម្របសម្រួលចាប់ផ្តើមដោយសុំឱ្យអ្នកចូលរួមចែករំលែកគំនិតដំបូងរបស់ពួកគេលើអាជីព ICT។ ហើយបន្ទាប់មកពិភាក្សាដោយសង្ខេបពីសារៈសំខាន់នៃ ICT ដែលកំពុងកើនឡើងក្នុងវិស័យផ្សេងៗក្នុងប្រទេសកម្ពុជា និងការកើនឡើងនៃតម្រូវការសម្រាប់អ្នកជំនាញដែលមានវិជ្ជាជីវៈ។

អ្នកសម្របសម្រួលប្រើរូបភាពដើម្បីបង្ហាញពីអាជីព ICT ជាច្រើនដែលទាក់ទងនឹងបរិបទកម្ពុជា។ ពិចារណារួមទាំងឧទាហរណ៍ដូចខាងក្រោម៖

| | | |
|---|---|---|
| អ្នកបង្កើតគេហទំព័រ និងអ្នករចនា<br>Web Developers & Designers | អ្នកបង្កើត និងសរសេរកម្មវិធី<br>Software Developers & Programmers | អ្នកគ្រប់គ្រងបណ្តាញ និងអ្នកជំនួយការជំនាញផ្នែកព័ត៌មានវិទ្យា<br>Network Administrators & IT Support Specialists |
| អ្នករចនាក្រាហ្វិក និងអ្នកឯកទេសពហុព័ត៌មាន<br>Graphic Designers & Multimedia Specialists | ប្រព័ន្ធផ្សព្វផ្សាយសង្គម និងអ្នកជំនាញទីផ្សារមាតិកា<br>Social Media & Content Marketing Specialists | អ្នកវិភាគទិន្នន័យ និងអ្នកឯកទេសសុវត្ថិភាពអ៊ីនធឺណិត<br>Data Analysts & Cybersecurity Specialists |

អ្នកសម្របសម្រួលពន្យល់យ៉ាងខ្លីអំពីជំនាញ និងគុណវុឌ្ឍិសំខាន់ៗដែលត្រូវការសម្រាប់អាជីពនីមួយៗដែលបានបង្ហាញ។ នេះរួមបញ្ចូលជំនាញបច្ចេកទេស (កម្មវិធីសរសេរកូដ ជំនាញផ្នែកសូហ្វែ) បំណិនទន់ (ការទំនាក់ទំនង ការដោះស្រាយបញ្ហា) និងជំនាញអក្ខរកម្មឌីជីថល។

បន្ទាប់មកអ្នកសម្របសម្រួលចែកចាយ**ឯកសារ ៥.៣៖** ការរាយបញ្ជីអាជីព ICT ផ្សេងៗ និងសំណុំជំនាញដែលត្រូវគ្នា។ អ្នកសម្របសម្រួលស្នើឱ្យអ្នកចូលរួមពិនិត្យមើលបញ្ជី និងកំណត់អត្តសញ្ញាណអាជីពដែលស្របតាមជំនាញ និងចំណាប់អារម្មណ៍ដែលមានស្រាប់របស់ពួកគេ។

ជាចុងក្រោយ អ្នកសម្របសម្រួលលើកទឹកចិត្តអ្នកចូលរួមឱ្យស្វែងរកធនធានបន្ថែម (ធនធានដូចជាគេហទំព័រ សេវាប្រឹក្សាអាជីព) ដើម្បីស្វែងយល់បន្ថែមអំពីជំនាញ ICT ជាក់លាក់ និងគន្លងអាជីពតាមរយៈតំណភ្ជាប់ខាងក្រោម៖

- ដំណោះស្រាយបច្ចេកវិទ្យាសម្រាប់ការអប់រំបំណិនជីវិតតាមមូលដ្ឋាន។ តំណភ្ជាប់៖ ដំណោះស្រាយឌីជីថលសម្រាប់សិស្សានុសិស្ស សាលាឌីជីថល (moeys.gov.kh)
- App ប្រឹក្សាតាមអេឡិចត្រូនិក ហៅថា ត្រីវិស័យ (TreyVisay)៖ https://onelink.to/xrjebn
- អ្នកសរសេរកម្មវិធីសូហ្វែ៖ https://www.youtube.com/watch?v=MNKHfCqEQ4o
- អ្នករចនាក្រាហ្វិក៖ https://www.youtube.com/watch?v=16Fn-GL8teg
- សិល្បៈឌីជីថល (Digital Art)៖ https://www.youtube.com/watch?v=k2r6w7SGj7Q&list=PLy6V57dykHeNRxsvxqFURg6lfOUdPtb5F&index=8
- បណ្ដាញកុំព្យូទ័រ (Computer network)៖ https://www.youtube.com/watch?v=3eTt-IVnOaY
- វិស្វករបណ្ដាញ (Networking Designer)៖ https://www.youtube.com/watch?v=OicTWLeO08o



## គន្លឹះខ្លះៗសម្រាប់ការអនុវត្តដោយជោគជ័យ (៣០នាទី)

វគ្គនេះផ្ដល់ឧបករណ៍ដល់អ្នកចូលរួមជាមួយគន្លឹះ និងយុទ្ធសាស្ត្រខ្លះៗជាក់ស្ដែងសម្រាប់ការអនុវត្តឧបករណ៍ ICT ដោយជោគជ័យនៅក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋានរបស់ពួកគេ។ ដោយពិចារណាលើកក្ដាសំខាន់ៗ និងការលើកកម្ពស់ធនធានដែលមាន អ្នកចូលរួមត្រូវប្រាកដថាដំណើរការការបញ្ចូលមានភាពរលូន និងមានប្រសិទ្ធភាព។

អ្នកសម្របសម្រួលចាប់ផ្ដើមដោយការពិភាក្សាពីសារៈសំខាន់នៃការពិចារណាលើបរិបទនៅពេលធ្វើផែនការបញ្ចូល ICT។ ចំណុចនេះរួមបញ្ចូលទាំងកត្តាមួយចំនួនដូចជា៖

- ធនធានដែលសាលារៀនមាន (កុំព្យូទ័រ អ៊ីនធឺណិត ការគាំទ្របច្ចេកទេស)
- ការយល់ដឹងរបស់សិស្សចំពោះបច្ចេកវិទ្យា (អាយុ បំណិនអក្ខរកម្មឌីជីថល)
- តម្រូវការកម្មវិធីសិក្សា និងវត្ថុបំណងការសិក្សា

អ្នកសម្របសម្រួលក៏ត្រូវរំលេចលើតម្រូវការពិតប្រាកដដើម្បីជ្រើសរើសឧបករណ៍ ICT ដែលសាកសម សម្រាប់បរិបទ និងក្រុមគោលដៅជាក់លាក់។

អ្នកសម្របសម្រួលរំលេចពីតួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធសំខាន់ៗត្រូវជានាថាការបញ្ចូល ICT ដោយជោគជ័យ៖

- **រដ្ឋបាលសាលារៀន៖** ផ្តល់ភាពជាអ្នកដឹកនាំ វិភាជធនធាន និងគាំទ្រគ្រូបង្រៀនក្នុងការអនុវត្តឧបករណ៍ ICT។
- **គ្រូបង្រៀន៖** បញ្ចូលឧបករណ៍ ICT ទៅក្នុងកិច្ចតែងការបង្រៀន រៀបចំសកម្មភាព និងផ្តល់បច្ចេកទេសគាំទ្រសិស្ស។
- **សិស្ស៖** ចូលរួមឱ្យសកម្មក្នុងសកម្មភាពសិក្សាអាស្រ័យលើ ICT រៀបចំបំណិនអក្ខរកម្មឌីជីថល និងធ្វើភាពជាម្ចាស់ការនៃការសិក្សារបស់ខ្លួន។
- **ឪពុកម្តាយ ឬសហគមន៍៖** ផ្តល់ការលើកទឹកចិត្ត និងគាំទ្រនៅផ្ទះ សហការជាមួយគ្រូបង្រៀនក្នុងគំនិតផ្តួចផ្តើម ICT។

បន្ទាប់មក អ្នកសម្របសម្រួលរៀបរាប់ខ្លីៗពីធនធានគាំទ្របន្ថែមដែលមានសម្រាប់ការបញ្ចូល ICT៖

- **សេចក្តីណែនាំក្រសួងអប់រំ យុវជន និងកីឡា ស្តីពី ICT៖** ផ្តល់សេចក្តីណែនាំ និងឧត្តមានុវត្តសម្រាប់ការប្រើប្រាស់ ICT នៅក្នុងការអប់រំ (ពិចារណាផ្តល់តំណភ្ជាប់ ឬឯកសារយោងនៅក្នុងឯកសារចែក)។
- **សិក្ខាសាលា ICT ៖** ស្វែងរកឱកាសដើម្បីចូលរួមសិក្ខាសាលា ឬការបណ្តុះបណ្តាលផ្តល់ដោយក្រសួងអប់រំ យុវជន និងកីឡា ឬអង្គការផ្សេងៗទៀត។
- **ធនធានតាមអនឡាញ៖** គេហទំព័រ និងសហគមន៍តាមអនឡាញអាចផ្តល់គន្លឹះមានតម្លៃ ការបង្រៀន និងឧទាហរណ៍នៃការបញ្ចូល ICT នៅក្នុងការអប់រំ។

បន្ទាប់មកអ្នកសម្របសម្រួលចែករំលែក ឯកសារ ៥.៤៖ "គន្លឹះខ្លះៗសម្រាប់ការបញ្ចូល ICT ដោយជោគជ័យនៅក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន" សម្រាប់អ្នកចូលរួមពិនិត្យមើលឡើងវិញ និងចង់ចាំជាមួយគន្លឹះទាំងនោះដែលបានផ្តល់ឱ្យ។

ចុងក្រោយ អ្នកសម្របសម្រួលសម្របសម្រួលការពិភាក្សាដើម្បីដោះស្រាយកង្វល់ណាមួយ ឬសំណួររបស់អ្នកចូលរួមដែលអាចមានចំពោះការអនុវត្ត ICT នៅក្នុងសាលារៀនរបស់ពួកគ។ លើកទឹកចិត្តពួកគេឱ្យចែករំលែកបញ្ហាប្រឈមដែលពួកគេចូលរួម និងប្រមូលគំនិតដំណោះស្រាយទាំងអស់គ្នា។

**បញ្ចប់មេរៀនទី៥**

# ផែនការបង្រៀន-មេរៀនទី៦

## មេរៀនទី៦៖ ការបង្កើតភាពស៊ីសង្វាក់គ្នាសម្រាប់ធ្វើឱ្យការសិក្សាប្រសើរឡើង

## កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន និងការអនុវត្តរបស់ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការក្រៅរដ្ឋាភិបាលដែលមានស្រាប់

**រយៈពេលមេរៀន៖** បង្រៀន៥ ម៉ោង (បន្ថែម១០ ម៉ោងស្វ័យសិក្សា ហាត់សម និងអនុវត្ត)

**សកម្មភាពអ្នកសម្របសម្រួលគួរត្រៀម៖**

- ពិនិត្យមើលស្លាយទាំងអស់ (PPT) សម្រាប់មេរៀន រួមទាំងគោលបំណងសិក្សា
- ថតចម្លងឯកសារចែកទាំងអស់ដូចដែលបានរាយខាងក្រោម

**ធនធាន និងសម្ភារៈ**

- ស្លាយ (PPT) កុំព្យូទ័រ ម៉ាស៊ីនបញ្ចាំងស្លាយ
- ថតចម្លងឯកសារសកម្មភាពទាំងអស់ កិច្ចការ ឬគម្រោងអនុវត្ត (ផ្នែករឹង ឬផ្នែកទន់)
- ក្រដាស A4 និងប៊ិក
- ថតចម្លង**ឯកសារចែកទី៦.១** *និយមន័យ*
- ថតចម្លង**ឯកសារចែកទី៦.២** *កម្រិតផ្សេងៗ – ភាពដែលអាចធ្វើទៅបានផ្សេងៗ*
- ថតចម្លង**ឯកសារចែកទី៦.៣** *វីដេអូស្រីចិន និងសមិទ្ធិផលរបស់នាង*

**គោលបំណងសិក្សា៖**

ពេលបញ្ចប់មេរៀនទី៦ អ្នកចូលរួមនឹងអាច៖

- ពិពណ៌នាអំពីគំនិតផ្តួចផ្តើមដើម្បីបង្កើតការស៊ីសង្វាក់គ្នាជាមួយគម្រោងបំណិនជីវិតតាមមូលដ្ឋាន។
- ពន្យល់ពីការស៊ីសង្វាក់គ្នាដែលអាចកើតមានឡើងរវាងគំនិតផ្តួចផ្តើមផ្សេងៗគ្នានៅកម្ពុជា និងក្រៅប្រទេស និងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាននៅសាលារៀន ។
- ពិពណ៌នាពីឧទាហរណ៍នៃគំនិតផ្តួចផ្តើមផ្សេងៗនៅកម្រិតសាលារៀន កម្រិតមូលដ្ឋាន កម្រិតជាតិ និងអន្តរជាតិ។

ការឆ្លុះបញ្ចាំង និងការអនុវត្តទ្រឹស្តីផ្សារភ្ជាប់នឹងការអនុវត្តជាក់ស្តែងនៅកន្លែងធ្វើការ៖ អ្នកចូលរួមនឹងមាន៖

- ការឆ្លុះបញ្ចាំងពីរបៀបបង្កើតការស៊ីសង្វាក់គ្នារវាងការបង្រៀន និងរៀនបំណិនជីវិតតាមមូលដ្ឋាន និងគំនិតផ្តួចផ្តើមរបស់ក្រសួងអប់រំ ស្ថាប័នឯកជន និងដៃគូអភិវឌ្ឍនានា។

- ការឆ្លុះបញ្ចាំងពីរបៀបដែលសាលារៀនទទួលបានអត្ថប្រយោជន៍ដោយការបង្កើតការស៊ីសង្វាក់គ្នាជាមួយគំនិតផ្តួចផ្តើមដែលលើកកម្ពស់ការរៀនបំណិនជីវិតតាមមូលដ្ឋាន ដោយមើលលើឧត្តមានុវត្តដែលមានស្រាប់។

ឯកសារ និងកិច្ចការអាន៖

- ស្វែងរកទំព័រ VMC Facebook និងបណ្តាញ YouTube ហើយឆ្លុះបញ្ចាំងពីទំនាក់ទំនងជាមួយការបង្រៀនបំណិនជីវិតតាមមូលដ្ឋាននៅក្នុងសាលារៀនរបស់អ្នក។
  https://www.facebook.com/VMC2019/ ; https://www.youtube.com/@vmc7912

# ផែនការបណ្តុះបណ្តាល-មេរៀនទី៦

## ពិនិត្យមើលគោលបំណងមេរៀន

បិទក្រដាសផ្ទាំងធំលើក្តារខៀន  ដែលសង្ខេបលទ្ធផលសិក្សាសម្រាប់ម៉ូឌុលនេះ។  ពន្យល់ពីលទ្ធផលសិក្សា ហើយនេះគឺជាអ្វីដែលអ្នកចូលរួមគួរតែអាចធ្វើបាននៅពេលបញ្ចប់ម៉ូឌុល។

## និយមន័យ និងគំនិតផ្តួចផ្តើមសំខាន់ៗ

អ្នកសម្របសម្រួលចាប់ផ្តើមមេរៀនដោយពន្យល់ថា ក្នុងវគ្គសិក្សានេះ អ្នកចូលរួមនឹងស្វែងយល់ពីរបៀបបង្រៀនបំណិនជីវិតតាមមូលដ្ឋានដែលអាចឱ្យសិស្សរៀបចំបង្កើតគម្រោងដោយខ្លួនឯងបាន។

មេរៀននេះ យើងនឹងស្វែងយល់ពីគំនិតផ្តួចផ្តើមផ្សេងៗនៅតាមសាលារៀន តាមមូលដ្ឋាន ថ្នាក់ជាតិ ប៉ុន្តែក៏មានកម្រិតអន្តរជាតិផងដែរ ដែលអាចជួយឱ្យសាលារៀន និងសិស្សធ្វើការងាររបស់ពួកគេលើបំណិនជីវិតតាមមូលដ្ឋាន។ ជាការពិត ដូចដែលយើងនឹងរៀន មានគំនិតផ្តួចផ្តើមជាច្រើន ដែលរៀបចំឡើងដោយស្ថាប័នសាធារណៈ និងឯកជននានា ប៉ុន្តែក៏មានតាមសាលារៀនខ្លួនឯងផងដែរ ដែលអ្នកចូលរួមអាចប្រើប្រាស់ម្តងក្នុងសាលារៀនដើម្បីបង្កើនប្រសិទ្ធភាពសិក្សារបស់សិស្សរបស់ពួកគេនៅក្នុងប្រធានបទបំណិនជីវិតតាមមូលដ្ឋាន (ប៉ុន្តែក៏សម្រាប់មុខវិជ្ជាផ្សេងៗផងដែរ)។

ជំហានទី១ អ្នកសម្របសម្រួលចែក ឯកសារ ៦.១ *និយមន័យ*។ បញ្ជីឈ្មោះ និងស្ថាប័ន។ សកម្មភាពដំបូងនេះមានគោលបំណងពិនិត្យមើលចំណេះដឹងដែលមានស្រាប់របស់អ្នកចូលរួមអំពីពាក្យគន្លឹះ និងការពន្យល់លទ្ធផលដែលអ្នកសម្របសម្រួលនឹងផ្តល់ឱ្យមុនពេលឆ្ពោះទៅធ្វើការវិភាគ។

ជំហានទី២ អ្នកសម្របសម្រួលចែក ឯកសារ ៦.២។ កម្រិតផ្សេងៗគ្នា – លទ្ធភាពផ្សេងៗគ្នា និងសុំឱ្យអ្នកចូលរួមផ្គូរផ្គងកម្រិត ហើយស្នើឱ្យជ្រើសរើសគំនិតផ្តួចផ្តើមចំនួន៣ ដែលពួកគេនឹងពិចារណាណែនាំនៅក្នុងសាលារៀនរបស់ពួកគេ។

នៅពេលបញ្ចប់សកម្មភាព អ្នកសម្របសម្រួលស្នើឱ្យអ្នកចូលរួមពិភាក្សាជាដៃគូ ដែលជាអត្ថប្រយោជន៍នៃការភ្ជាប់សកម្មភាព ឬគំនិតផ្តួចផ្តើមទាំងនេះជាមួយនឹងការបង្រៀន និងរៀនបំណិនជីវិតតាមមូលដ្ឋាននៅក្នុងសាលារៀនរបស់ពួកគេ។

**ចម្លើយរំពឹងទុក (សម្រាប់អ្នកសម្របសម្រួល)៖**

- គាំទ្រដល់គម្រោងបំណិនជីវិតតាមមូលដ្ឋានរបស់សិស្ស (ដើម្បីជួយជាធនធានព័ត៌មាន)។
- បន្តផ្តល់ដំណោះស្រាយដែលបានកំណត់នៅក្នុងគម្រោងបំណិនជីវិតតាមមូលដ្ឋាន។
- អនុញ្ញាតឱ្យមានការបណ្តុះបណ្តាលបំណិនទន់បន្ថែមដល់សិស្ស (បំណិនទំនាក់ទំនង បំណិនគិតពិចារណា បំណិនចរចា)។
- អនុញ្ញាតឱ្យសិស្សឆ្លុះបញ្ចាំង និងពិភាក្សាគ្នាអំពីប្រធានបទដែលពួកគេកំពុងអង្កេត។
- វាផ្តល់ការទទួលស្គាល់ការងាររបស់ពួកគេ។

ដូចលំហាត់ដែលយើងបានធ្វើពីមុន គំនិតផ្តួចផ្តើមបែបនេះអាចកើតឡើងនៅកម្រិតសាលារៀនកម្រិតមូលដ្ឋាន ប៉ុន្តែក៏មានកម្រិតជាតិ និងអន្តរជាតិដែលអាចរៀបចំដោយ៖

- ក្រសួងអប់រំ ឬក្រសួងទទួលបន្ទុកផ្សេងទៀតអាស្រ័យលើប្រធានបទ (ឧ. ក្រសួងបរិស្ថាន)
- អាជីវកម្មឯកជន ឧទាហរណ៍ SMART AXIATA;
- ដៃគូអភិវឌ្ឍ៖ ឧទាហរណ៍ អង្គការយូនីសេហ្វ អង្គការយូណេស្កូ អង្គការក្លែនអន្តរជាតិ អង្គការ Save the Children ឬអង្គការទស្សនៈពិភពលោក ដើម្បីលើកឧទាហរណ៍មួយចំនួន។
- អង្គការអន្តររដ្ឋាភិបាលដូចជា SEAMEO ជាដើម។

ក្នុងរយៈពេលច្រើនឆ្នាំគំនិតផ្តួចផ្តើមទាំងនេះនឹងផ្លាស់ប្តូរ ហើយគំនិតផ្តួចផ្តើមថ្មីនឹងចាប់ផ្តើម អ្នកដទៃនឹងឈប់។ សាលារៀនត្រូវស្វែងរកគំនិតផ្តួចផ្តើមបែបនេះ និងត្រូវរក្សាខ្លួនឱ្យទាន់សម័យ និងសកម្ម។

អ្នកសម្របសម្រួលណែនាំវីដេអូរបស់សិស្សឈ្មោះ **ស្រី ចិន** មកពីអនុវិទ្យាល័យ ហ៊ុន សែន រលួស។ នាងនឹងប្រាប់យើងពីអ្វីដែលនាងសម្រេចបាន និងឧទាហរណ៍នៃគំនិតផ្តួចផ្តើមដែលនាងបានចូលរួមអរគុណចំពោះតួនាទីដ៏សកម្មរបស់សាលារៀនរបស់នាង។ អនុវិទ្យាល័យ ហ៊ុនសែន រលួស ជាសាលារៀនសាធារណៈមកពីខេត្តសៀមរាប ដែលបានចាប់ផ្តើមអនុវត្តបំណិនជីវិតតាមមូលដ្ឋានក្នុងឆ្នាំសិក្សា២០១៥-១៦។ អ្នកសម្របសម្រួលចែក ឯកសារ ៦.៣ ដោយមានសំណួរទាក់ទងនឹងវីដេអូ។ អ្នកចូលរួមនឹងមើលវីដេអូជាលក្ខណៈបុគ្គល ហើយបន្ទាប់ពួកគេនឹងធ្វើការជាក្រុមតូចៗពី៤ ទៅ ៥នាក់

ដើម្បីឆ្លើយតបទៅនឹងចម្លើយ និងចែករំលែកជាមួយក្រុមផ្សេងទៀត។ អានសំណួរជាមួយអ្នកចូលរួមមុនពេលចាក់វីដេអូ។

សកម្មភាព៖វីដេអូទី៦.១ **ស្រី ចិន** អនុវិទ្យាល័យហ៊ុនសែនរលួស(ប្រហែលជា២០-៣០នាទី)។
នៅក្នុងវីដេអូនេះ សិស្សអនុវិទ្យាល័យហ៊ុនសែនរលួសឈ្មោះ **ស្រី ចិន** នឹងពន្យល់ពីសកម្មភាពដែលនាងបានចូលរួមលើប្រធានបទបំណិនជីវិតតាមមូលដ្ឋាន។ ជាការពិត អរគុណចំពោះអ្វីដែលបានរៀនក្នុងអំឡុងពេលសិក្សាបំណិនជីវិតតាមមូលដ្ឋាន សាលារៀនបានស្វែងរកឱកាសបន្ថែមឱ្យសិស្ស ដែលអនុញ្ញាតឱ្យពួកគេទទួលបានបទពិសោធន៍ និងសម្រេចបានលទ្ធផលលើសពីការបង្រៀន និងរៀនតែមួយគត់នៃមុខវិជ្ជានៅសាលារៀន។

ឯកសារទី៦.៣ *វីដេអូ **ស្រី ចិន** និងសមិទ្ធិផលរបស់នាង*

- តើមានគំនិតផ្តួចផ្តើមអ្វីទៀតដែល **ស្រី ចិន** បានចូលរួម?
- តើអ្វីជាអត្ថប្រយោជន៍សម្រាប់នាងក្នុងការចូលរួមក្នុងគំនិតផ្តួចផ្តើមបែបនេះ?
- តើសាលារៀនមានអត្ថប្រយោជន៍អ្វីខ្លះ? ហើយសម្រាប់អាជ្ញាធរមូលដ្ឋាន?

នាយកអនុវិទ្យាល័យ ហ៊ុនសែន រលួស លោក **ម៉ី រឿម** បានប្រកាសថា៖
"កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន គឺជាការវិនិយោគប្រកបដោយនិរន្តរភាពលើកុមារកម្ពុជា យើងបានឃើញលទ្ធផលដំបូងនៃការវិនិយោគនេះ ក្នុងការទទួលជ័យជម្នះរបស់ក្រុមយើងក្នុងការប្រកួតប្រជែងការជជែកដេញដោលថ្នាក់ជាតិ។ កម្មវិធីនេះផ្តល់ឱកាសដល់សិស្សានុសិស្សក្នុងការអភិវឌ្ឍការស្រាវជ្រាវ ការគិតពិចារណាស៊ីជម្រៅ និងបំណិនអក្ខរកម្មព័ត៌មាន ក៏ដូចជាសមត្ថភាពរបស់ពួកគេក្នុងការធ្វើការជាក្រុម ដើម្បីបង្ហាញទឡ្ហីករណ៍ត្រឹមត្រូវ។

លោក **តាន់ វិច្ឆិកា រង្សី** ប្រធានការិយាល័យអប់រំមធ្យមសិក្សានៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប មានប្រសាសន៍ថា "ខ្ញុំចាំបានថា គ្រប់គ្នាក្នុងខេត្តរបស់យើង រួមទាំងអាជ្ញាធរស្រុកផងដែរ បានមើលការផ្សាយផ្ទាល់ការជជែកដេញដោលតាមហ្វេសប៊ុក ហាក់ដូចជាការប្រកួតបាល់ទាត់អញ្ចឹង"។ យើងទទួលបានការបំផុសគំនិតយ៉ាងច្រើនពីក្រុមរបស់ **ស្រី ចិន** និងជ័យជម្នះរបស់ពួកគេ"។
ប្រភព៖ https://www.unicef.org/cambodia/stories/how-local-life-skills-helped-student-win-national-debate-contest

## កម្មវិធីគំនិតផ្តួចផ្តើមនៅតាមសាលារៀន

មានវិធីផ្សេងគ្នាជាច្រើនដែលសាលារៀនរួមចំណែកក្នុងការធ្វើសកម្មភាពដែលលើកទឹកចិត្តសិស្សឱ្យអង្កេតបន្ថែម និងអភិវឌ្ឍគំនិតរបស់ពួកគេពីគម្រោងបំណិនជីវិតតាមមូលដ្ឋាន។ ថ្ងៃនេះយើងនឹងស្វែងយល់ពីឧត្តមានុវត្តមួយចំនួនពីសាលារៀន។

ដំបូងអ្នកសម្របសម្រួលសួរអ្នកចូលរួមថា តើនរណាមួយក្នុងចំណោមពួកគេរៀបចំការជជែកដេញដោលក្នុងសាលារៀន។ តើការជជែកដេញដោលរបស់សាលារៀនគឺជាអ្វី?

### ការជជែកដេញដោលនៅសាលារៀន

ការជជែកដេញដោលនៅសាលារៀនគឺជាឱកាសមួយសម្រាប់សិស្សានុសិស្សពិភាក្សាអំពីប្រធានបទសំខាន់ៗដែលពួកគេចាប់អារម្មណ៍ ចែករំលែក និងការពារទស្សនៈផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ។ វាអាចត្រូវបានដំណើរការជាផ្នែកនៃប្រធានបទថ្នាក់រៀនជាក់លាក់មួយ ឬនៅក្នុងព្រឹត្តិការណ៍សាលារៀន ដូចជាថ្ងៃបើកបើកបវេសនកាល ក៏ប៉ុន្តែជាផ្នែកនៃសកម្មភាពក្រៅកម្មវិធីសិក្សាផងដែរ ក្នុងទម្រង់ជាក្លឹបសិក្សា។
ទាក់ទងទៅនឹងការអប់រំបំណិនជីវិតតាមមូលដ្ឋាន សាលារៀនអាចពិចារណាក្នុងការជួយសិស្សឱ្យពង្រឹងការយល់ដឹងរបស់ពួកគេលើប្រធានបទនីមួយៗ ឬនៅផ្នែកចុងក្រោយនៃគម្រោង ដោយរៀបចំការជជែកដេញដោលនៅក្នុងសាលារៀនដើម្បីពិភាក្សាអំពីប្រធានបទនៃគម្រោងរបស់ពួកគេ។

ជំហានសំខាន់ៗក្នុងការរៀបចំការជជែកដេញដោលជា២ក្រុមស្តីពីបែបបទប្រពៃណី៖

1. បែងចែកអ្នកចូលរួមជាពីរ ធីម៖ ស្រប និងបដិសេធ។
2. ជ្រើសរើសប្រធានបទឱ្យបានច្បាស់លាស់ និងអាចពិភាក្សាបានសម្រាប់ការជជែកពិភាក្សា។ ឧទាហរណ៍៖ "តើយើងគួរហាមឃាត់ការលក់ដបជ័រដែលប្រើតែមួយដងពីគ្រប់ហាងបានដែរឬទេ?"
3. កំណត់ពេលវេលាសម្រាប់សុន្ទរកថាក្នុងន័យស្ថាបនា ជាធម្មតា ៥នាទីសម្រាប់ការបើកសុន្ទរកថា និង៣នាទីសម្រាប់ការបិទសុន្ទរកថា។
4. បែងចែកពេលវេលាសម្រាប់សុន្ទរកថាចោទសួរ ដោយអនុញ្ញាតឱ្យក្រុមនីមួយៗឆ្លើយតបទៅនឹងអំណះអំណាងរបស់ក្រុមបដិសេធ ដែលជាធម្មតាមានពេល២នាទីក្នុងមួយក្រុម។
5. ពិចារណាលើការបញ្ចូលរយៈពេលចោទសួរ ដែលវាគ្មិនអាចសាកសួរក្រុមបដិសេធ ដោយបែងចែកពេលវេលាជាក់លាក់មួយដូចជា ២នាទីសម្រាប់វាគ្មិនម្នាក់ៗ។

6. ទំនាក់ទំនងឱ្យបានច្បាស់លាស់នូវលក្ខណៈវិនិច្ឆ័យ ដើម្បីធ្វើការវិនិច្ឆ័យ រួមមានកត្តាមួយចំនួន ដូចជាការធ្វើទឡ្ហីករ ភស្តុតាង ការរៀបចំ និងភាពច្បាស់លាស់នៃការនិយាយ។
7. ពិចារណាឱ្យមានអ្នកសម្របសម្រួលអព្យាក្រឹតដើម្បីត្រួតពិនិត្យការជជែកដេញដោល គ្រប់គ្រងពេលវេលា និងសម្របសម្រួលដល់ការចោទសួរ។
8. លើកទឹកចិត្តឱ្យមានការចូលរួមរបស់ទស្សនិកជនតាមរយៈវគ្គសំណួរ និងចម្លើយ ឬរយៈពេលខ្លីសម្រាប់មតិយោបល់របស់ទស្សនិកជន។
9. ផ្តល់ឱកាសសម្រាប់ការពិភាក្សាជជែកដេញដោលចុងក្រោយ និងការឆ្លុះបញ្ចាំងក្នុងចំណោមអ្នកចូលរួម។

ដោយធ្វើតាមជំហានទាំងនេះ អ្នកអាចរៀបចំការជជែកដេញដោលជាពីរក្រុម ប្រកបដោយប្រសិទ្ធភាព ដោយផ្តល់ឱ្យអ្នកចូលរួមនូវវេទិកាដែលមានរចនាសម្ព័ន្ធមួយដើម្បីអភិវឌ្ឍការនិយាយជាសាធារណៈ ការគិតពិចារណាស៊ីជម្រៅ និងបំណិនបញ្ចុះបញ្ចូលរបស់ពួកគេ។

[...] អ្នកសិក្សាទទួលបានអត្ថប្រយោជន៍ជាពិសេសពីបំណិនជជែកដេញដោល ដើម្បីតស៊ូមតិសម្រាប់តម្រូវការ និងក្រុមគ្រួសាររបស់ពួកគេ ព្រមទាំងដើម្បីទប់ទល់នឹងការភ័យខ្លាចពិតប្រាកដនៃការបន្ទាបខ្លួននៅចំពោះមុខមិត្តភក្តិរបស់ពួកគេ។ ដោយតម្រូវឱ្យអ្នកជជែកដេញដោលធ្វើការស្រាវជ្រាវ និងជជែកដេញដោលពីបញ្ហានៃភាគីទាំងពីរ ពួកគេទំនងជាមិនសូវចាត់ទុកអ្នកដទៃថាជា "សត្រូវ" ហើយទំនងជានៅតែបើកចំហរ ដោយរៀនសួរសំណួរមុនធ្វើការវិនិច្ឆ័យ និងពន្យល់ពីចំណុចរបស់ពួកគេដើម្បីឱ្យមនុស្សគ្រប់គ្នាអាចយល់បាន (Litan, 2020) ។

**ក្លីបជជែកដេញដោល ការនិយាយជាសាធារណៈ (វិទ្យាល័យព្រះស៊ីសុវត្ថិ)៖**

សូមមើលឧទាហរណ៍ពីរបីនៃលទ្ធផលការជជែកជាសាធារណៈរបស់សិស្ស ដែលបានផលិត និងចែករំលែកដើម្បីទទួលបានជ័យលាភីនៅកម្រិតសាលារៀន។

- https://www.facebook.com/watch/?v=1724891107867539
- https://www.facebook.com/watch/?v=1980902435631740

ការបង្កើតការប្រកួតប្រជែងនៅក្នុងសាលារៀនដើម្បីលើកទឹកចិត្តសិស្សឱ្យអនុវត្តបំណិនទំនាក់ទំនងរបស់ពួកគេគឺត្រូវប្រើជាឧទាហរណ៍នៅក្នុងសាលារៀនជំនាន់ថ្មី។ សិស្សជាផ្នែកមួយនៃក្លឹប គឺតម្រូវឱ្យរៀបចំវីដេអូពីប្រធានបទដែលពួកគេជ្រើសរើស និងប្រកួតប្រជែងរវាងក្រុមពួកគេ។

## ក្រុមប្រឹក្សាកុមារ ឬយុវជន

យោងតាមក្រសួងអប់រំ យុវជន និងកីឡា ក្រុមប្រឹក្សាកុមារ ឬយុវជន គឺជាក្រុមប្រឹក្សាសិស្ស ដែលត្រូវបានបង្កើតឡើងដើម្បីពង្រឹងការចូលរួមរបស់កុមារ ឬយុវជននៅក្នុងសាលារៀន និងការយល់ដឹងពីភាពជាពលរដ្ឋ។ បំណិតជីវិតតាមមូលដ្ឋានគឺជាផ្នែកមួយនៃសមត្ថភាពរបស់ក្រុមប្រឹក្សាកុមារ ឬយុវជន។

អ្នកសម្របសម្រួលសួរអ្នកចូលរួមពីរបៀបដែលពួកគេគិតថា ក្រុមប្រឹក្សាកុមារ ឬយុវនអាចជួយសិស្សផ្សេងទៀតនៅក្នុងគម្រោងបំណិតជីវិតតាមមូលដ្ឋាន។

**វីដេអូទី៦.២** អ្នកសម្របសម្រួលណែនាំវីដេអូស្តីពីអនុវិទ្យាល័យ ហ៊ុនសែន រលួស និងក្រុមប្រឹក្សាកុមារ ឬយុវជន៖ https://www.facebook.com/share/v/i5jRGttggvH624rU/?mibextid=WC7FNe

**សំណួរបំផុស៖**

- តើក្រុមប្រឹក្សាកុមារ ឬយុវជនមានវិសាលភាពអ្វីខ្លះ?
- តើសកម្មភាពអ្វីខ្លះដែលសិស្សអាចធ្វើបាន?
- តើពួកគេរៀននៅពេលណា និងដោយរបៀបណា?
- ហេតុអ្វីបានជាក្រុមប្រឹក្សាកុមារ ឬយុវជនមានសារៈសំខាន់?

ជាចុងក្រោយ អ្នកសម្របសម្រួលបន្ថែមថាឧទាហរណ៍មួយទៀតនៃការចូលរួមដោយជោគជ័យរបស់ក្រុមប្រឹក្សាកុមារ ឬយុវជនគឺត្រូវបានផ្តល់ដោយអង្គការផ្លែនអន្តរជាតិ ក្រោមគម្រោងជើងឯក ដែលជាចំណែកមួយនៃកម្មវិធីស្ត្រីវ័យក្មេងក្នុងការអ្នកដឹកនាំ។

| |
|---|
| **គម្រោងជើងឯក**នៃអង្គការផ្លែនអន្តរជាតិ។ មូលនិធិជំនួយខ្នាតតូចមួយ (សម្រាប់ការផ្សព្វផ្សាយដល់មិត្តភក្តិ) ជាផ្នែកនៃកម្មវិធីស្ត្រីវ័យក្មេងក្នុងការអ្នកដឹកនាំ មូលនិធិជំនួយតូចៗត្រូវបានបែងចែកសម្រាប់ក្រុមប្រឹក្សាកុមារ ឬយុវជន និងក្លឹបនានា ដើម្បីរៀបចំសកម្មភាពសម្រាប់ការផ្សព្វផ្សាយដល់មិត្តភក្តិលើសមភាពយេនឌ័រ។ ដឹកនាំដោយកុមារ និងយុវជន សកម្មភាពនេះបានផ្សព្វផ្សាយដោយផ្ទាល់នូវសមភាពយេនឌ័រ និងបានផ្លាស់ប្តូរអាកប្បកិរិយា និងការអនុវត្តវិសមភាពយេនឌ័រមួយចំនួនរួមទាំងបទដ្ឋានយេនឌ័រ តួនាទី និងគំរូដែលបង្កគ្រោះថ្នាក់នៅក្នុងសហគមន៍របស់ពួកគេ។ ជាពិសេស ក្មេងស្រី ឬស្ត្រីពេញវ័យកាន់តែមានទំនុកចិត្តលើសមត្ថភាព និងភាពជាអ្នកដឹកនាំរបស់ពួក |

គេ និងក្មេងប្រុស ឬបុរសពេញវ័យកាន់តែច្រើនគាំទ្រសមភាពយេនឌ័រ ហើយឪពុកម្តាយ ឬអាណាព្យាបាលកាន់តែច្រើនយល់ និងគាំទ្រសិទ្ធិស្មើគ្នារវាងក្មេងស្រី និងក្មេងប្រុស។

លើសពីនេះ ទាំងក្មេងប្រុស និងក្មេងស្រីបានក្លាយជាអ្នកចូលរួមយ៉ាងសកម្មក្នុងការជួយដោះស្រាយបញ្ហាទាំងនេះបានមួយចំនួន។ "កុមារ ឬយុវជនដែលជាសមាជិកក្លឹ មានបុរេសកម្ម និងមានតម្លៃ


រូបភាពទី២ @ប្រភព៖អង្គការផ្លែនអន្តរជាតិ

ដល់សហគមន៍។ ឧទាហរណ៍ នៅពេលដែលពួកគេឃើញករណីអំពើហិង្សាក្នុងគ្រួសារកើតឡើង ឬមានកុមារបោះបង់ការសិក្សា ពួកគេជួយផ្សព្វផ្សាយព័ត៌មានដល់សហគមន៍របស់ពួកគេ និងសហការជាមួយអាជ្ញាធរឃុំ" (KII ជាមួយ CCWC)។

***សេចក្តីសន្និដ្ឋាន (សម្រាប់អ្នកសម្របសម្រួល)៖***

*ប្រភេទនៃសកម្មភាពទាំងនេះអាចផ្តួចផ្តើមឡើងនៅក្នុងសាលារៀនបានផងដែរ តាមរយៈក្រុមប្រឹក្សាកុមារ ឬយុវជនដែលបានចូលរួមក្នុងតួនាទីយ៉ាងសកម្មនៅក្នុងសហគមន៍ និងសាលារៀនដើម្បីលើកកម្ពស់អ្វីដែលបានរៀនធ្វើក្នុងអំឡុងពេលសិក្សាមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន។ កញ្ចប់ថវិកាតូចមួយអាចបែងចែកដោយសាលារៀនសម្រាប់សកម្មភាពរបស់ពួកគេ ដែលជាផ្នែកមួយនៃតួនាទីរបស់ពួកគេ ប៉ុន្តែសាលារៀនក៏អាចគាំទ្រសកម្មភាពរៃអង្គាសប្រាក់ជាមួយសហគមន៍ដើម្បីផ្តល់ការគាំទ្រដល់គំនិតផ្តួចផ្តើមទាំងនេះផងដែរ។*

អ្នកសម្របសម្រួលបញ្ជាក់ថាក្រុមប្រឹក្សាកុមារ ឬយុវជនអាចគាំទ្រសិស្សនៅក្នុងសាលារៀនឱ្យឆ្ពោះទៅមុខជាមួយនឹងគម្រោងរបស់ពួកគេ ជាឧទាហរណ៍ ពួកគេអាចជួយក្នុងការផ្សព្វផ្សាយដល់សហគមន៍ ឬជួយធ្វើការស្ទង់មតិនៅក្នុងសាលារៀន។ តួនាទីរបស់ក្រុមប្រឹក្សាកុមារ ឬយុវជន និងសមត្ថភាពរបស់គេក្នុងការផ្សព្វផ្សាយទៅដល់សហគមន៍ និងតម្រូវការរបស់សិស្សផ្សេងទៀត។ វាសមស្របឥតខ្ចោះជាមួយសកម្មភាពមួយចំនួនដែលបានរៀបចំនៅក្នុងមុខវិជ្ជាបំណិតជីវិតតាមមូលដ្ឋាន។ ពួកគេអាចជួយជាពិសេសក្នុងការផ្សព្វផ្សាយ និងការអនុវត្តដំណោះស្រាយដែលបានស្នើឡើងនៅក្នុងគម្រោងបំណិតជីវិតតាមមូលដ្ឋាន។ ជាឧទាហរណ៍ ប្រសិនបើពេលសិស្សសិក្សាមុខវិជ្ជាបំណិតជីវិតតាមមូលដ្ឋាន ដែលកំពុងអង្កេតគម្រោងកាកសំណល់ប្លាស្ទិកនៅក្នុងសាលារៀន ក្រុមប្រឹក្សាកុមារ ឬយុវជនអាចអនុវត្តនៅក្នុងសាលារៀននូវគម្រោងធំជាងនេះ ដើម្បីរៀបចំការគ្រប់គ្រង និងយុទ្ធនាការសំរាមនៅក្នុងសាលារៀន ឬសកម្មភាពមិត្តជួយមិត្តដើម្បីតស៊ូមតិក្នុងការថែរក្សាបរិស្ថានសាលារៀន ឱ្យបានស្អាតជានិច្ចពេញមួយឆ្នាំបន្ទាប់ពីគម្រោងបំណិតជីវិតតាមមូលដ្ឋានបានបញ្ចប់។ ជាមួយគ្នានេះ

ក្រុមប្រឹក្សាកុមារ ឬយុវជនមានលទ្ធភាពផ្សព្វផ្សាយព័ត៌មានទៅដល់សហគមន៍បន្ថែមទៀតដោយប្រើកញ្ចក់ថវិកាតិចតួចមួយដែលបានបម្រុងទុកសម្រាប់សកម្មភាពក្រុមប្រឹក្សាកុមារ ឬយុវជននៅក្នុងផែនការកែលម្អសាលារៀនជារៀងរាល់ឆ្នាំ។

## គំនិតផ្តួចផ្តើមថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ

**ការស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ** (VMC) គឺជាកម្មវិធីជាតិដ៏ធំបំផុតសម្រាប់ការស្ម័គ្រចិត្ត និងការផ្សព្វផ្សាយដល់សហគមន៍នៅកម្ពុជា។ វាជាកម្មវិធីរបស់នាយកដ្ឋានយុវជននៃក្រសួងអប់រំ យុវជន និងកីឡា។ នៅឆ្នាំ២០១៩ នាយកដ្ឋានយុវជននៃក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការអ្នកស្ម័គ្រចិត្តសហប្រជាជាតិប្រចាំនៅកម្ពុជា បានចាប់ផ្តើមកម្មវិធី VMC ដើម្បីបង្កើតឱកាសដល់យុវជនក្នុងមូលដ្ឋានដើម្បីស្វែងយល់ពីគំនិតផ្តួចផ្តើមថ្មីៗ ដោយចូលរួមក្នុងការកសាង និងអភិវឌ្ឍសហគមន៍ដែលពួកគេរស់នៅ។




www.vmcdyc.com ការស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ-VMC ការស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ-VMC

នៅឆ្នាំ២០២២ កម្មវិធីនេះបានពង្រីកទូទាំងប្រទេសគ្របដណ្តប់ ២៥រាជធានីខេត្ត គម្រោងយុវជនសរុបចំនួន៨៦ បានអនុវត្តន៍ និងមានយុវជនស្ម័គ្រចិត្តចំនួន ៥០៦នាក់ចូលរួមក្នុងគំនិតផ្តួចផ្តើមនេះ។ ឧទាហរណ៍មួយចំនួននៃគំនិតផ្តួចផ្តើមរបស់ពួកគេរួមមានគម្រោងស្តីពីបរិស្ថាន សុខភាព ទេសចរណ៍ ប៉ុន្តែក៏មានការអប់រំទៅសាលារៀនដើម្បីជួបជាមួយសិស្ស និងគៀងគរពួកគេឱ្យចូលរួមក្នុងគម្រោង។

**សកម្មភាព កម្មវិធីការស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ៖** ឧទាហរណ៍នៃកម្មវិធីការស្ម័គ្រចិត្តនៅក្នុងខេត្តរបស់អ្នក។

តំណភ្ជាប់៖ https://www.youtube.com/watch?v=IPNYYwiDiTQ&t=12s

## សំណួរឆ្លុះបញ្ចាំង

- តើអ្នកធ្លាប់បានឮពីកម្មវិធីនេះដែរឬទេ?
- អ្វីទៅជាការស៊ីសង្វាក់គ្នា ដែលអ្នកអាចបង្កើតបានរវាង VMC និងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាននៅក្នុងសាលារៀនរបស់អ្នក?

| |
|---|
| ក្រសួងអប់រំ យុវជន និងកីឡា កំពុងលើកកម្ពស់សកម្មភាពក្រៅកម្មវិធីសិក្សាយ៉ាងសកម្ម និងជាផ្នែកមួយនៃសកម្មភាពទាំងនេះ គម្រោងស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ (VMC) ត្រូវបានបញ្ចូលទៅក្នុងការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ។ មុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន និង VMC ចែករំលែកគោលការណ៍ទូទៅដូចជាការសិក្សាបែបសកម្ម ការលើកកម្ពស់អ្នកស្ម័គ្រចិត្ត និងការធ្វើសកម្មភាពនៅក្នុងសហគមន៍ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរជាវិជ្ជមាន។ តាមរយៈការណែនាំមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាននៅបឋម និងមធ្យមសិក្សា សិស្សានុសិស្សនឹងរៀបចំខ្លួនដើម្បីចូលរួមយ៉ាងសកម្មនៅក្នុងគំនិតផ្តួចផ្តើម VMC នៅពេលដែលពួកគេឈានដល់កម្រិតមធ្យមសិក្សាទុតិយភូមិ។<br>ដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូរដោយរលូន និងបង្កើនការយល់ដឹងរបស់សិស្សអំពីកម្មវិធី VMC វាមានអត្ថប្រយោជន៍ក្នុងការស្វែងរកការស៊ីសង្វាក់គ្នារវាងកម្មវិធីសូម្បីតែនៅមធ្យមសិក្សាបឋមភូមិក៏ដោយ។ ជាធម្មតា តាមស្រុកនីមួយៗយ៉ាងហោចណាស់មានវិទ្យាល័យមួយដែលគ្របដណ្តប់ពីថ្នាក់ទី៧ ដល់ទី១២ រួមនឹងអនុវិទ្យាល័យមួយចំនួន។ នៅកម្រិតមធ្យមសិក្សាបឋមភូមិ សិស្សចូលរួមក្នុងការសិក្សាអាស្រ័យលើបញ្ហាតាមរយៈកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន ដោយធ្វើការអង្កេតបញ្ហានៅក្នុងសហគមន៍។ នៅពេលពួកគេបន្តទៅរៀននៅថ្នាក់វិទ្យាល័យ ពួកគេបានប្តូរការផ្តោតអារម្មណ៍របស់ពួកគេទៅលើកម្មវិធី VMC និងការងារគម្រោង ដោយរៀនរៀបចំគម្រោង រៃអង្គាសថវិកា និងអនុវត្តក្នុងសហគមន៍។ រួមគ្នាសិស្សានុសិស្សមកពីមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិអាចសហការគ្នាដើម្បីតស៊ូមតិទៅរដ្ឋាភិបាលថ្នាក់ក្រោមជាតិបន្ទាប់ពីអនុវត្តគម្រោងសហគមន៍។ វិធីសាស្ត្ររួមមួយនេះបង្កើតប្រព័ន្ធអេកូសម្រាប់ការស្ម័គ្រចិត្ត និងការអភិវឌ្ឍបំណិននៅក្នុងស្រុកនីមួយៗ។ |
| |

---

គំនិតផ្តួចផ្តើមមួយទៀតដែលត្រូវបានផ្សព្វផ្សាយដោយក្រសួងអប់រំនៅថ្នាក់ជាតិ គឺ**កម្មវិធីជជែកដេញដោលយុវជនថ្នាក់ជាតិ**។

ការប្រកួតជជែកដេញដោលថ្នាក់ជាតិ គឺជាការប្រកួតប្រចាំឆ្នាំដ៏មានកិត្យានុភាព ដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា ទូទាំងខេត្តនីមួយៗក្នុងប្រទេសកម្ពុជា។ ក្រុមត្រូវបានវិនិច្ឆ័យលើការរៀបចំ និងភាពច្បាស់លាស់ ការនិយាយជាសាធារណៈ ការប្រើអំណះអំណាង និងការប្រើប្រាស់




ទម្រង់ការចោទសួរ និងរបៀបនៃការធ្វើបទបង្ហាញ។ ដូចដែលយើងបានដឹងពីអនុវិទ្យាល័យ ហ៊ុន សែន រលួស សិស្សមកពីសាលារៀនរដ្ឋអាចចូលរួម និងអាចឈ្នះបាន។

អ្នកសម្របសម្រួលណែនាំវីដេអូថ្មីដែលបង្ហាញពីក្រុមសិស្សស្រី ៤ នាក់មកពីវិទ្យាល័យ ហ៊ុន សែន ប្រាសាទបាគង ដែលបានចូលរួមកម្មវិធីជជែកដេញដោលថ្នាក់ជាតិក្នុងឆ្នាំ២០២៣។

***ឈឿម ស្រី ចិន*** *សិស្សថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុន សែន ប្រាសាទបាគង ខេត្តសៀមរាប ដែលទើបឈ្នះការប្រកួតជជែកដេញដោលថ្នាក់ជាតិនាពេលថ្មីៗនេះ បានលើកឡើងថា "កម្មវិធីបំណិនជីវិតតាមមូលដ្ឋានបានក្លាយជាថាមពលដ៏អស្ចារ្យរបស់យើងក្នុងការឈ្នះការជជែកដេញដោលជាមួយក្រុមរបស់នាងគឺ* ***ជួន ដានី*** *និង* ***ឡោះ លីន****"។*

ជាការពិតណាស់ សិស្សទាំងអស់បានចូលរួមកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន នៅពេលពួកគេរៀននៅអនុវិទ្យាល័យ ដែលបានរៀបចំពួកគេឱ្យត្រៀមខ្លួនរួចជាសម្រេចសម្រាប់ឱកាសបែបនេះនៅក្នុងកម្មវិធីជជែកដេញដោលយុវជនថ្នាក់ជាតិ។

### សកម្មភាព៖ បទពិសោធន៍ការជជែកដេញដោលយុវជនថ្នាក់ជាតិ។

https://www.facebook.com/NationalYouthDebate/videos/1326771974513521 (១០នាទី)

**សំណួរឆ្លុះបញ្ចាំង**

- តើអ្នកគិតថាបទពិសោធន៍នេះមានសារៈសំខាន់សម្រាប់សិស្សដែរឬទេ?
- តើអ្នកគិតថាអ្វីជាផលចំណេញដ៏សំខាន់បំផុតសម្រាប់សិស្ស?

---

អ្នកសម្របសម្រួលបន្តពន្យល់ថា ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយក្រសួង និងវិស័យឯកជនដទៃទៀតដើម្បីលើកកម្ពស់គំនិតផ្តួចផ្តើមស្រដៀងគ្នាផ្សេងទៀត ឧទាហរណ៍ជាមួយកម្មវិធីជជែកដេញដោលរបស់យុវជនស្តីពីកិច្ចពិភាក្សាលើបរិស្ថាន។ នៅក្នុងគំនិតផ្តួចផ្តើមនេះ ក្រុមហ៊ុន SMART AxiATA គាំទ្រកម្មវិធីជជែកដេញដោលរបស់យុវជនលើរឿងបរិស្ថាន ដែលត្រូវបានរៀបចំឡើងដោយក្រសួងបរិស្ថានសហការជាមួយក្រសួងអប់រំ និងការផ្តល់ហិរញ្ញប្បទានដោយក្រុមហ៊ុន SMART។

**ឧទាហរណ៍** ក្នុងកម្មវិធីជជែកដេញដោលយុវជនលើប្រធានបទបរិស្ថានឆ្នាំ២០២១ វិទ្យាល័យច្បារអំពៅ (ក្រុមស្រប) បានប្រកួតជាមួយវិទ្យាល័យ ហ៊ុន សែន ចម្លង (ក្រុមបដិសេធ) លើប្រធានបទ "ការប្រើប្រាស់ថង់ប្លាស្ទិកធ្វើឱ្យជីវិតកាន់តែងាយស្រួល"។

វិទ្យាល័យវត្តកោះ (ក្រុមស្រប) បានប្រកួតជាមួយវិទ្យាល័យឫស្សីកែវ (ក្រុមបដិសេធ) លើប្រធានបទ "ការបង្កើនតំបន់ការពារជាយន្តការដ៏ល្អក្នុងការការពារ និងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព"។

@ប្រភព៖ https://www.khmertimeskh.com/50927769/environment-youth-debate-2021/

## គំនិតផ្តួចផ្តើមអន្តរជាតិ

អ្នកសម្របសម្រួលចាប់ផ្តើមសួរអ្នកចូលរួមថាតើពួកគេស្គាល់ SEAMEO ដែរឬទេ។ សួរអ្នកចូលរួមថាតើពួកគេធ្លាប់បានឮអំពីអង្គភាពនេះដែរឬទេ ប្រសិនបើពួកគេដឹងថាវាជាអ្វី ហើយប្រសិនបើពួកគេធ្លាប់បានឮអំពីគំនិតផ្តួចផ្តើមដែលផ្សព្វផ្សាយដោយ SEAMEO។

SEAMEO គឺជាអង្គការអន្តររដ្ឋាភិបាលក្នុងតំបន់មួយត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៦៥ ក្នុងចំណោមរដ្ឋាភិបាលនៃប្រទេសអាស៊ីអាគ្នេយ៍ ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងតំបន់ក្នុងវិស័យអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ក្នុងតំបន់។

ជាបន្តបន្ទាប់ អ្នកសម្របសម្រួលពន្យល់ថា SEAMEO ជាអ្នករៀបចំគំនិតផ្តួចផ្តើមដ៏មានកិត្យានុភាពបំផុតសម្រាប់អាស៊ីអាគ្នេយ៍។ ប្រទេសកម្ពុជាគឺជាប្រទេសសមាជិកនៃ SEAMEO ហើយសាលារៀន និងយុវជនទាំងអស់ពីប្រទេសកម្ពុជាមានសិទ្ធិចូលរួមក្នុងការផ្តល់រង្វាន់ និងការប្រកួតប្រជែងដែលផ្សព្វផ្សាយដោយអង្គការនេះ។

កម្ពុជាក៏បានចូលរួមក្នុងគំនិតផ្តួចផ្តើមបែបនេះដែរ។ តើអ្នកគិតថាសាលារៀនកម្ពុជាណាមួយអាចនឹងឈ្នះ?

អ្នកសម្របសម្រួលបន្តដោយការពន្យល់អំពីគំនិតផ្តួចផ្តើម និងពានរង្វាន់ចំនួន៣ ពី SEAMEO គឺ៖ ការប្រកួតប្រជែងគម្រោង STEM (១) ពានរង្វាន់វីរបុរសសំណល់អាស៊ីអាគ្នេយ៍ (២) និងពានរង្វាន់ SEAMEO-Japan ESD (៣)។

| | |
|---|---|
| ការប្រគួតប្រជែងគម្រោង STEM | ការប្រកួតប្រជែងគម្រោង STEM ត្រូវបានធ្វើឡើង ដើម្បីជួយ និងលើកកម្ពស់បំណិនដោះស្រាយបញ្ហារបស់យុវជន ដោយប្រើប្រាស់ចំណេះដឹងរួមបញ្ចូលការអប់រំ STEM។ ប្រធានបទសម្រាប់ការប្រកួតប្រជែងដែលសិស្សអាស៊ីអាគ្នេយ៍អាចដាក់ពាក្យប្រគួតបានចែកចេញជាបីប្រភេទនៃបញ្ហាប្រឈមក្នុងជីវិតប្រចាំថ្ងៃ បញ្ហាប្រឈមក្នុងឧស្សាហកម្ម បញ្ហាប្រឈមសហគមន៍ និងសាលារៀន។<br>ការប្រកួតបានស្វាគមន៍សិស្សានុសិស្ស ឬធីមសិស្ស (ដោយមានការដឹកនាំពីគ្រូ) មកពីបណ្ដាលប្រទេសជាសមាជិក SEAMEO (សិស្សមានអាយុ ហូតដល់អាយុ ១៨ឆ្នាំ ពោលគឺថ្នាក់ទី ៦/៧-១២ រួមទាំងសិស្សមកពីការអប់រំក្រៅប្រព័ន្ធ សិស្សអប់រំវិជ្ជាជីវៈ បច្ចេកទេស និងសាកលវិទ្យាល័យ និស្សិត ឬកម្រិតបរិញ្ញាបត្រ) ដើម្បីដាក់ស្នើគម្រោងរបស់ពួកគេ។ វិទ្យាល័យព្រះស៊ីសុវត្ថិ ឈ្នះជ័យលាភីលេខ១ ជាមួយគម្រោងនេះ។ |
| ពានរង្វាន់វីរៈបុរសសំណល់អាស៊ីអាគ្នេយ៍នៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា។ | **បីប្រភេទ**<br>១. សាលារៀន<br>រឿងជោគជ័យនៃកម្មវិធី ឬសកម្មភាពគ្រប់គ្រងកាកសំណល់របស់សាលារៀនតាមរយៈវីដេអូឃ្លីបរយៈពេល ៥នាទី។<br>២. គ្រូបង្រៀន<br>រឿងជោគជ័យនៃសកម្មភាពថ្នាក់រៀនប្រកបដោយភាពច្នៃប្រឌិតរបស់អ្នកលើការគ្រប់គ្រងកាកសំណល់តាមរយៈវីដេអូឃ្លីបរយៈពេល ៣នាទី។<br>៣. សិស្ស |

| | |
|---|---|
| | គំនិត ឬដំណោះស្រាយលើវិធីកាត់បន្ថយកាកសំណល់ និងកែលម្អបរិស្ថានសាលារៀន ឬសហគមន៍<br>• ថ្នាក់ទី ៤-៥-៦៖ គូរដោយដៃដោយសិស្សម្នាក់ៗ<br>• ថ្នាក់ទី ៩-១០-១១៖ វីដេអូឃ្លីប ៣នាទីដោយសិស្សមួយក្រុម (សិស្ស ៣-៦នាក់ ឬធំម) |
| **ពានរង្វាន់** SEAMEO-Japan ESD<br>• ប្រធានបទ៖ ការលើកកម្ពស់ការអប់រំបរិស្ថានតាមរយៈការប្រើប្រាស់ថាមពលកកើតឡើងវិញ។<br>• គោលដៅ៖ សាលារៀនបឋមសិក្សា និងមធ្យមសិក្សា មកពីប្រទេសជាសមាជិក។<br>• សាលាធ្វើបទបង្ហាញពីកម្មវិធីរបស់ពួកគេ។<br>កម្មវិធី និងលក្ខខណ្ឌចូលរួម៖<br>https://www.seameo.org/Main_programme/414 |  |

អ្នកសម្របសម្រួលក៏ត្រូវពន្យល់ថា សាលារៀនកម្ពុជាក៏អាចជាផ្នែកមួយនៃបណ្តាញសាលារៀន SEAMEO ផងដែរ។ គម្រោងនេះមានគោលបំណងបម្រើជាវេទិកា "បណ្តាញចែករំលែក និងអភិវឌ្ឍ" ក្នុងចំណោមគ្រឹះស្ថានអប់រំសាធារណៈ និងឯកជននៅគ្រប់កម្រិតរួមមាន មត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សា អប់រំវិជ្ជាជីវៈ និងបច្ចេកទេស ពហុបច្ចេកទេស សាកលវិទ្យាល័យ ការអប់រំពិសេស និងការអប់រំក្រៅប្រព័ន្ធក្នុងប្រទេសអាស៊ីអាគ្នេយ៍ទាំង១១ (ប្រ៊ុយណេដារូសាឡឹម កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ ទីម័រខាងកើត និងវៀតណាម)។
គេរំពឹងថាបណ្តាញនេះអាចកសាង និងពង្រឹងកិច្ចសហប្រតិបត្តិការពហុភាគីលើវិស័យអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៅក្នុងពិភពលោកដែលផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។
នៅខែវិច្ឆិកា ឆ្នាំ២០២៣ ស្ថាប័នសរុបចំនួន៤០ មកពីប្រទេសកម្ពុជាបានចុះឈ្មោះក្នុងបណ្តាញនេះ រួមទាំងសាលារៀនឯកជន ប៉ុន្តែក៏មានសាលារៀន និងស្ថាប័នរដ្ឋផងដែរ។
https://www.seameo.org/img/Programmes_Projects/2020/SN2020/Countries7/KH_SSNNOV2023.pdf

ទីបំផុត បើក្រឡេកទៅមើលសាលារៀនជំនាន់ថ្មី ពួកគេបានចូលរួមកម្មវិធី Asean Cyberkids Camp និងទិវាប្រវត្តិសាស្ត្រធម្មជាតិសកល។ ទាំងនេះគ្រាន់តែជាឧទាហរណ៍នៃឱកាសជាច្រើនរបស់សាលារៀននៅកម្ពុជាទាំងនៅថ្នាក់ជាតិ និងនៅឆាកអន្តរជាតិក្នុងឆ្នាំកន្លងទៅ (រូបថតខាងក្រោម)។







## តម្រូវការផ្នែកធនធាន

តើធនធានប្រភេទណាខ្លះដែលត្រូវការជាផ្នែកនៃគំនិតផ្តួចផ្តើមទាំងនេះ? ចម្លើយជាវិជ្ជមានគឺថាធនធានហិរញ្ញវត្ថុដែលមានចំនួនតិចតួច និងសូមចងចាំថាអ្នកក៏អាចអំពាវនាវឱ្យមានការគាំទ្រពីសហគមន៍ដើម្បីគាំទ្រសិស្សរបស់អ្នកផងដែរ។

**ភាពជាអ្នកដឹកនាំ**របស់សាលារៀន គឺជាធនធានដ៏សំខាន់ពិតប្រាកដ ដែលអាចអនុញ្ញាតឱ្យសិស្សចាប់យកឱកាសទាំងនេះបាន និងជាផ្នែកមួយនៃកម្មវិធីទាំងនេះ។ ពួកគេតំណាងឱ្យឱកាសពិសេសដើម្បីសិក្សា ប្រកួតប្រជែងខ្លួនឯង និងរីករាយជាមួយបទពិសោធន៍ដ៏គួរឱ្យរំភើបទាំងនេះនៅក្នុងសាលារៀននៅថ្នាក់ជាតិ ឬសូម្បីតែនៅថ្នាក់អន្តរជាតិ។ ឧទាហរណ៍ក្នុងមេរៀននេះបង្ហាញថា វាអាចធ្វើទៅរួចបានដែលយើងមានឧទាហរណ៍ជាច្រើនពីសាលារៀនរដ្ឋរបស់កម្ពុជាដែលកំពុងចូលរួម និងបានឈ្នះពានរង្វាន់ផងដែរ។

ចូរយើងត្រលប់ទៅមើលក្រដាសផ្ទាំងធំនៃសកម្មភាព ឯកសារចែក ៦.២ វិញ។ អ្នកសម្របសម្រួលសួរអ្នកចូលរួម "តើអ្នកអាចផ្លាស់ប្តូរអ្វីមួយនៅក្នុងជម្រើសរបស់អ្នកដែរឬទេ បន្ទាប់ពីបានសិក្សាបន្ថែមអំពីគំនិតផ្តួចផ្តើមទាំងអស់នេះ ឬអ្នកនៅតែជ្រើសរើសដដែល"?

ផ្តល់ពេលវេលាដល់អ្នកចូលរួមដើម្បីត្រឡប់ទៅមើលក្រដាសផ្ទាំងធំ និងពិភាក្សាជាក្រុម។ ចុងក្រោយបែងចែកពេលវេលាសម្រាប់ពួកគេដើម្បីចែករំលែកការឆ្លុះបញ្ចាំងចុងក្រោយ (១៥នាទី)។

**បញ្ចប់មេរៀនទី៦**

# មេរៀនទី៧៖ វង្វាយតម្លៃគម្រោង និងការសិក្សាអាស្រ័យលើបញ្ហា

**រយៈពេលមេរៀន៖** បង្រៀន៥ម៉ោង (បន្ថែម១០ម៉ោងស្វ័យសិក្សា ហាត់សម និងអនុវត្ត)

**សកម្មភាពអ្នកសម្របសម្រួលគួរត្រៀម៖**

- សរសេរលទ្ធផលសិក្សានៃមេរៀននៅលើសន្លឹកក្រដាសប្រកាសដើម្បីណែនាំមេរៀន
- ថតចម្លងឯកសារចែកទាំងអស់ដូចដែលបានរាយខាងក្រោម

**ធនធាន និងសម្ភារៈ**

- លទ្ធផលសិក្សានៃមេរៀននៅលើសន្លឹកប៉ុស្ទ័រដើម្បីណែនាំមេរៀន
- ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត
- ថតចម្លង**ឯកសារចែក ៧.១៖** *ផ្នែកសំខាន់នៃវង្វាយតម្លៃកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន*
- ថតចម្លង**ឯកសារចែក ៧.២៖** *ការស្វែងយល់វិធីសាស្ត្រផ្សេងៗនៃវង្វាយតម្លៃ និងភាពសមរម្យសម្រាប់ផ្នែកផ្សេងៗនៃការសិក្សាបំណិនជីវិត*
- ថតចម្លង**ឯកសារចែក ៧.៣៖** *ការវាយតម្លៃខុសគ្នានៃការសិក្សាបែបប្រពៃណី និងការសិក្សាបែបគម្រោង*
- ថតចម្លង**ឯកសារចែក ៧.៤៖** *យុទ្ធសាស្ត្រវាយតម្លៃការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន*
- ថតចម្លង**ឯកសារចែក ៧.៥៖** *ឧទាហរណ៍ជាក់ស្តែងនៃយុទ្ធសាស្ត្រវាយតម្លៃដែលប្រើប្រាស់ដើម្បីវាយតម្លៃការសិក្សាបែបស្ថាបនានិយម និងបំណិនជីវិតតាមមូលដ្ឋាន*
- *ឯកសារថតចម្លង៖*
  a. សេចក្តីណែនាំអង្កេត ឧបសម្ព័ន្ធទី៧.២.២ (ទំព័រទី៩៩ - ១០១ នៃឯកសារណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៩)
  b. ស្វ័យវាយតម្លៃសិស្ស ឧបសម្ព័ន្ធទី៧.១.១ (ទំព័រទី៩៥ នៃសេចក្តីណែនាំក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៩)
  c. វង្វាយតម្លៃសមិទ្ធកម្ម ឧបសម្ព័ន្ធទី៧.១.១ (ទំព័រទី៩៥ នៃសេចក្តីណែនាំក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៩)

**គោលបំណងសិក្សា៖**

ពេលបញ្ចប់មេរៀនទី៧ អ្នកចូលរួមនឹងអាច៖

1. ពន្យល់ផ្នែកសំខាន់នៃការសិក្សាដើម្បីវាយតម្លៃនៅក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន (ឧ. វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា)
2. ការបរិយាយប្រភេទសំខាន់ៗនៃវង្វាយតម្លៃជាដំណាក់ និងបូកសរុប

3. ការកំណត់ទម្រង់វាស់វែងដូចនេះ (ឧ. តេស្តសរសេរ ស្វ័យវាយតម្លៃ) សមរម្យបំផុតសម្រាប់ទិដ្ឋភាពផ្សេងគ្នានៃក្របខណ្ឌការងារ KSA (ឧ. វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា)
4. ពន្យល់ពីការបង្កើនការវាយតម្លៃផ្តោតលើ "របៀប" កុមាររៀន (ផ្ទុយពី "អ្វី" ដែលពួកគេត្រូវរៀន) នៅក្នុងវគ្គសិក្សាបំណិនជីវិតតាមមូលដ្ឋានដែលពាក់ព័ន្ធនឹងគម្រោង និងការសិក្សាអាស្រ័យលើបញ្ហា
5. ពន្យល់ពីមូលហេតុដែលគម្រោង និងការសិក្សាអាស្រ័យលើបញ្ហា ត្រូវការយុទ្ធសាស្ត្រពិសេសសម្រាប់វាយតម្លៃការសិក្សាសិស្ស
6. កំណត់យុទ្ធសាស្ត្រសំខាន់ៗមួយចំនួនសម្រាប់ការវាយតម្លៃការសិក្សានៅក្នុងគម្រោង ឬបរិយាកាសសិក្សាអាស្រ័យលើបញ្ហា
7. ពិពណ៌នាអំពីលក្ខណៈសំខាន់ៗមួយចំនួននៃយុទ្ធសាស្ត្រវាយតម្លៃនីមួយៗ ដែលប្រើដើម្បីវាយតម្លៃគម្រោង ឬការសិក្សាអាស្រ័យលើបញ្ហា
8. ប្រៀបធៀប និងប្រៀបធៀបប្រកបដោយប្រសិទ្ធភាពនូវលក្ខណៈនៃយុទ្ធសាស្ត្រវាយតម្លៃផ្សេងៗគ្នាដែលប្រើដើម្បីវាយតម្លៃគម្រោង ឬការងារអាស្រ័យលើបញ្ហា ដោយប្រើតារាងពិសេសដែលបានរចនាឡើងសម្រាប់គោលបំណងនេះ

### ឯកសារ និងកិច្ចការអាន៖

- *គោលការណ៍នៃសៀវភៅណែនាំការវាយតម្លៃសិស្ស និងគ្រូ៖* សៀវភៅណែនាំនេះផ្តល់នូវសារបានបន្ថែមលើគោលការណ៍សំខាន់ៗនៃការវាយតម្លៃអប់រំ និងបច្ចេកទេសវាយតម្លៃជាក់លាក់ដែលនាំទៅដល់ការកែលម្អសុពលភាពទិន្នន័យ និងការបកស្រាយកាន់តែប្រសើរ។

  តំណភ្ជាប់៖ https://www.kapekh.org/files/report_file/362-en.pdf

  ក្រសួងអប់រំ យុវជន និងកីឡា(ឆ្នាំ២០១៩) ការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន។ ជំពូកទី៧៖

# ផែនការបណ្តុះបណ្តាល-មេរៀនទី៧

### ពិនិត្យមើលគោលបំណងសិក្សា

បិទក្រដាសផ្ទាំងធំលើក្តារខៀន ដែលសង្ខេបលទ្ធផលសិក្សាសម្រាប់ម៉ូឌុលនេះ។ ពន្យល់ពីលទ្ធផលសិក្សា ហើយនេះគឺជាអ្វីដែលអ្នកចូលរួមគួរតែអាចធ្វើបាននៅពេលបញ្ចប់ម៉ូឌុល។

## បញ្ញាត្តិគន្លឹះស្តីពីការវាយតម្លៃការសិក្សាបំណិនជីវិតតាមមូលដ្ឋាន

### ពិនិត្យឡើងវិញក្របខ័ណ្ឌវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា

អ្នកសម្របសម្រួលអាចចាប់ផ្តើមម៉ូឌុលនេះដោយពិនិត្យមើលការផ្តោតសំខាន់នៃការអប់រំបំណិនជីវិតតាមមូលដ្ឋាន លើការសិក្សាដែលលើសពីចំណេះដឹង ឬព័ត៌មាន។ នោះគឺមិនដូចមុខវិជ្ជាជាច្រើនដែលការផ្តោតសំខាន់គឺគ្រាន់តែលើការយល់ដឹងអំពីប្រធានបទផ្សេងៗនោះទេ បំណិនជីវិតតាមមូលដ្ឋានក៏ផ្តោតលើការទទួលបាន "បំណិន" ក៏ដូចជាប្រកាន់យកនៃ "ចរិយាសម្បទា" ឬ "តម្លៃ" មួយចំនួនដែលជួយលើកទឹកចិត្តអ្នកសិក្សា ដើម្បីអនុវត្តអ្វីដែលពួកគេបានសិក្សា។ ក្របខណ្ឌការងារ វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា ឬ KSA ប្រហែលជាអ្វីមួយដែលអ្នកចូលរួមបានឮពីមុនមក ប៉ុន្តែវាមានសារៈសំខាន់ក្នុងការត្រួតពិនិត្យក្របខណ្ឌនេះម្តងទៀតដើម្បីកំណត់ដំណាក់កាលសម្រាប់របៀបរៀបចំការវាយតម្លៃរបស់យើងនៅក្នុងថ្នាក់រៀនបំណិនជីវិតតាមមូលដ្ឋាន។

បន្ទាប់ពីការណែនាំខាងលើនៃក្របខ័ណ្ឌ KSA សូមបញ្ជូនឯកសារ ៧.១៖ *ផ្នែកសំខាន់ៗនៃការវាយតម្លៃបំណិនជីវិតតាមមូលដ្ឋាន*។ ពិនិត្យឡើងវិញនូវបញ្ញត្តិនៅក្នុងឯកសារចែកដោយគូរដ្យាក្រាមខាងក្រោមនៅលើក្តារខៀន ដើម្បីជួយពន្យល់ពីភាពខុសគ្នារវាងវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ប៉ុន្តែក៏អំពីរបៀបដែលត្រូវបានភ្ជាប់គ្នាទៅវិញទៅមកតាមរវិធីគាំទ្រការពង្រឹងគ្នាទៅវិញទៅមក។

***ដ្យាក្រាមដែលមានប្រយោជន៍ដើម្បីពន្យល់អន្តរភ្ជាប់រវាងវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា***



## ការប្រើប្រាស់ករណីសិក្សាដើម្បីអនុវត្តក្របខណ្ឌ KSA

បន្ទាប់ពីការពន្យល់ខាងលើ សូមចែកអ្នកចូលរួមទៅជាក្រុមតូចៗ ហើយសុំឱ្យពួកគេធ្វើលំហាត់នៅចុងបញ្ចប់នៃឯកសារចែក។ លំហាត់នេះតម្រូវឱ្យអ្នកចូលរួមកំណត់ថាតើវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាត្រូវបានទទួលដោយអ្នកសិក្សានៅក្នុងករណីសិក្សានីមួយៗដោយផ្អែកលើការពិពណ៌នាដែលបានផ្តល់ឱ្យ។ ផ្តល់ពេលឱ្យអ្នកចូលរួមប្រហែល ១៥នាទី ដើម្បីបញ្ចប់លំហាត់នេះនៅក្នុងក្រុម និងពិភាក្សាអំពីការវិភាគរបស់ពួកគេជាក្រុមធំនៅពេលធ្វើរួច។

នៅពេលពិនិត្យមើលលំហាត់ជាមួយក្រុមធំ អ្នកសម្របសម្រួលអាចប្រើតារាងចម្លើយដែលបានផ្តល់ជូនខាងក្រោម ដើម្បីជួយណែនាំការពិភាក្សា។ ក្នុងអំឡុងពេលនៃការពិភាក្សាជាបន្តបន្ទាប់ អ្នកសម្របសម្រួលគួរតែចង្អុលបង្ហាញថា ទោះបីជាក្នុងករណីសិសក្សារបស់សិស្សបានយល់ពីចំណេះដឹងពីប្រធានបទមួយក៏ដោយ ជារឿយៗពួកគេមិនបានអនុវត្តចំណេះដឹងនេះទេ ពីព្រោះពួកគេមិនគិតថាវាមានសារៈសំខាន់(ខ្វះការសម្របសម្រួលផ្ទៃក្នុង)ឬខ្វះខាតបំណិនដើម្បីអនុវត្តអ្វីដែលពួកគេបានរៀន។ ត្រូវប្រាកដថាដើម្បីចង្អុលបង្ហាញពីការទទួលបានបំណិនមិនល្អ និងការទទួលយកចរិយាសម្បទាថ្មីខ្សោយនឹងធ្វើឱ្យប៉ះពាល់ដល់ការសិក្សានៃខ្លឹមសារចំណេះដឹង។

### ចម្លើយសម្រាប់ការពិភាក្សាដែលបានណែនាំ

| **ករណីសិក្សា** | តើវិជ្ជាសម្បទាត្រូវបានយល់ច្បាស់ដែរឬទេ? | | តើបំណិនសម្បទាត្រូវបានទទួលដែរឬទេ? | | តើចរិយាសម្បទាត្រូវបានប្រកាន់យកដែរឬទេ? | |
|---|---|---|---|---|---|---|
| | ចាស/បាទ | ទេ | ចាស/បាទ | ទេ | ចាស/បាទ | ទេ |
| **ករណីសិក្សាទី១៖** វណ្ណៈ | x | | | x | | x |
| **ករណីសិក្សាទី២៖** ធីតា | x | | | x | x | |
| **ករណីសិក្សាទី៣៖** សុខា | x | | x | | x | |
| **ករណីសិក្សាទី៤៖** សុភា | x | | x | | | x |
| **ករណីសិក្សាទី៥៖** វណ្ណារ៉ា | | x | | x | x | |
| **ករណីសិក្សាទី៦៖** បូរ៉ា | | x | | x | | x |

ជាផ្នែកមួយនៃការពិភាក្សាខាងលើ អ្នកសម្របសម្រួលក៏អាចព្យាយាមបញ្ចូលសំណួរពិភាក្សាខាងក្រោមទៅក្នុងកិច្ចសន្ទនាផងដែរ។ ទាំងនេះគឺជាប្រធានបទសំខាន់ៗដែលអាចរកឃើញនៅក្នុងករណីសិក្សា។ ចម្លើយបន្ទាប់បន្សំមួយចំនួនត្រូវបានផ្តល់ជូនជាមួយនឹងសំណួរនីមួយៗ ដើម្បីជួយណែនាំអ្នកសម្របសម្រួល។

## សំណួរពិភាក្សា

1. តើអ្នកធ្លាប់ជួបសិស្សដែលហាក់ដូចជាយល់មេរៀនអំពីបញ្ហាសង្គមដ៏សំខាន់មួយ ប៉ុន្តែមិនដែលអនុវត្តចំណេះដឹងរបស់ពួកគេទេ? នៅពេលវង្វាយតម្លៃរបស់អ្នកបង្ហាញថា សិស្សមិនកំពុងរៀបចំតវិយាបថសំខាន់ៗអំពីប្រធានបទមួយ តើអ្នកអាចធ្វើអ្វីដើម្បីបង្វែរស្ថានភាពនេះ?
   ***ចម្លើយដែលបានណែនាំ៖*** ព្យាយាមបង្កើតជាឧទាហរណ៍មួយពីអត្ថន័យនៃការទទួលបានចរិយាសម្បទាដែលបានផ្តល់ឱ្យដោយមិត្តភក្តិ ដើម្បីបង្ហាញពីរបៀបដែលចរិយាសម្បទាជាទីចាប់អារម្មណ៍របស់សិស្ស។ល។
2. ពេលអ្នកពិចារណាវាងការទទួលវិជ្ជាសម្បទា និងការទទួលយកចរិយាសម្បទាជាប់ខ្លួន តើអ្នកគិតថាមួយណាសិស្សងាយនឹងធ្វើបានជាង? សូមពន្យល់ចម្លើយ
   ***ចម្លើយដែលបានណែនាំ៖*** ចំណេះដឹងតាមរយៈការសិក្សា (ដូចជាអង្គហេតុសាមញ្ញ និងព័ត៌មានមូលដ្ឋាន) ជាទូទៅគឺងាយស្រួលជាងការបង្កើត ឬពង្រឹងចរិយាសម្បទា និងភាពជឿជាក់ខាងក្នុង។ វិជ្ជាសម្បទាច្រើនតែជាសំណួរនៃការចងចាំ ឬយល់អ្វីមួយ។ ប៉ុន្តែការបង្កើតភាពជឿជាក់ពាក់ព័ន្ធនឹងការវិភាគបទពិសោធន៍ ទស្សនៈរបស់យើងអំពីពិភពលោក និងការកសាងចរិយាសម្បទាសមហេតុផលដែលស្របនឹងបទពិសោធន៍ទាំងនោះ។ ដូច្នេះការបង្កើតភាពជឿជាក់គឺជាដំណើរការស្មុគស្មាញជាងគេ។
3. ករណីសិក្សា យើងឃើញថា បំណិនគឺជាឧបករណ៍សំខាន់ដែលសិស្សប្រើប្រាស់ដើម្បីអនុវត្តចំណេះដឹងដែលខ្លួនរៀន។ តើអ្នកអាចកំណត់បានដោយរបៀបណា ថាតើសិស្សកំពុងទទួលបានបំណិនជាក់លាក់ដែរឬទេ? តើអ្នកគិតថាការធ្វើតេស្តសរសេរមានប្រយោជន៍សម្រាប់ការវាយតម្លៃបែបនេះដែរឬទេ?
   ***ចម្លើយដែលបានណែនាំ៖*** ការធ្វើតេស្តសរសេរជាធម្មតាមិនដំណើរការល្អក្នុងការវាយតម្លៃការទទួលបានបំណិនទេ (ទោះបីជាការធ្វើតេស្តបែបនេះអាចមានប្រយោជន៍ក្នុងករណីខ្លះក៏ដោយ)។ ជាទូទៅ ការវាយតម្លៃដែលមានប្រសិទ្ធភាពជាងនេះពាក់ព័ន្ធនឹងការបង្កើតភារកិច្ចជាក់ស្តែងសម្រាប់សិស្សអនុវត្ត និងបង្ហាញពីការទទួលបានបំណិនរបស់ពួកគេ។

## ការយល់ដឹងពីវិធីសាស្ត្រផ្សេងៗនៃវង្វាយតម្លៃ និងភាពស័ក្តិសមរបស់ពួកគេសម្រាប់ប្រភេទផ្សេងៗនៃការសិក្សាបំណិនជីវិត

អ្នកសម្របសម្រួលចាប់ផ្តើមវគ្គដោយសួរអ្នកចូលរួមថា តើពួកគេធ្លាប់បានឮអំពីវង្វាយតម្លៃតាមដំណាក់ និងវង្វាយតម្លៃបូកសរុបដែរឬទេ? អ្នកចូលរួមភាគច្រើនប្រហែលជាបានឮពីវិធីសាស្ត្រវាស់វែងទាំងនេះ ទោះបីជាពួកគេទំនងជាមិនទាន់យល់ច្បាស់អំពីអត្ថន័យក៏ដោយ។ សួរសំណួរសាកល្បងមួយចំនួនពីវិធីសាស្ត្រនីមួយៗទាក់ទងនឹង "គោលបំណង" នៃវិធីសាស្ត្រនីមួយៗ ដើម្បីឱ្យគេយល់ថាវង្វាយតម្លៃជាដំណាក់ផ្តោតលើគោលបំណងនៃការ "ដឹងពីអ្វី និងអ្នកណាដែលត្រូវបង្រៀនឡើងវិញ" ខណៈ

ដែលគោលបំណងនៃវង្វាយតម្លៃបូកសរុបមិនមែនជាការបង្រៀនឡើងវិញទេ ប៉ុន្តែគ្រាន់តែ"ដើម្បីបូកសរុបពីកម្រិតនៃការយល់ដឹងរបស់សិស្សម្នាក់ៗមុននឹងបន្តទៅវគ្គបន្ទាប់"។ ចែកឯកសារ ៧.២៖ ការយល់ដឹងពីវិធីសាស្ត្រនៃវង្វាយតម្លៃផ្សេងៗគ្នា និងភាពស័ក្តិសមរបស់ពួកគេសម្រាប់ប្រភេទផ្សេងៗនៃការរៀនបំណិនជីវិត។ ប្រើឯកសារនេះដើម្បីពិនិត្យមើលលក្ខណៈសំខាន់ៗមួយចំនួននៃវង្វាយតម្លៃតាមដំណាក់ និងវង្វាយតម្លៃបូកសរុប ព្រមទាំងសំណួរពិភាក្សាមួយចំនួនដែលនឹងជួយពង្រឹងគោលគំនិតសំខាន់ៗ។ ការឆ្លើយតបដែលបានស្នើឡើងសម្រាប់សំណួរពិភាក្សានីមួយៗនៅក្នុងឯកសារចែក ត្រូវបានផ្តល់ជូនខាងក្រោម ដើម្បីជួយអ្នកសម្របសម្រួលដឹកនាំការពិភាក្សាប្រកបដោយប្រសិទ្ធភាព។

## សំណួរពិភាក្សាដែលមានសារៈប្រយោជន៍

1. តើគ្រូធ្វើអ្វីបន្ទាប់ពីវង្វាយតម្លៃជាដំណាក់?
   ***ចម្លើយ៖*** បន្ទាប់ពីវង្វាយតម្លៃជាដំណាក់ គ្រូនឹងកំណត់ថាតើផ្នែកណាខ្លះនៃខ្លឹមសារដែលត្រូវបង្រៀនឡើងវិញ ឬសិស្សណាខ្លះដែលត្រូវការជំនួយពិសេស ដោយសារការយល់ដឹងរបស់ពួកគេខ្សោយ។ ពិន្ទុដែលបានមកពីវង្វាយតម្លៃជាដំណាក់មិនត្រូវបានកត់ត្រាទុកសម្រាប់ការសម្រេចចិត្តឡើងថ្នាក់នោះទេ ប៉ុន្តែដើម្បីធ្វើផែនការបង្រៀនឡើងវិញ។
2. ហេតុអ្វីបានជាអ្នកគិតថាការធ្វើតេស្តតាមដំណាក់គួរតែខ្លី?
   ***ចម្លើយ៖*** វង្វាយតម្លៃជាដំណាក់គឺខ្លីក្នុងន័យខ្លឹមសារ ពីព្រោះគ្រូបង្រៀនចង់ធ្វើឱ្យប្រាកដថាកូនសិស្សបានយល់ច្បាស់ពីបញ្ញត្តិសំខាន់ៗក្នុងមេរៀន មុនពេលបន្តទៅមេរៀនបន្ទាប់។ នេះបង្កើតបានជាមូលដ្ឋានគ្រឹះដ៏ល្អមួយសម្រាប់ការសិក្សានាពេលអនាគត។ ដូច្នេះវង្វាយតម្លៃជាដំណាក់គួរតែធ្វើជាបន្ត និងធ្វើឡើងដើម្បីអន្តរាគមន៍ជាប្រចាំ។
3. ហេតុអ្វីបានជាអ្នកគិតថាសំណួរវង្វាយតម្លៃជាដំណាក់គួរតែងាយស្រួល?
   ***ចម្លើយ៖*** គ្រូគ្រាន់តែចង់ដឹងថា តើសិស្សយល់ដឹងអំពីសមត្ថភាពគោលសំខាន់ៗដែលបានបង្រៀន ឬពិភាក្សាមុននឹងបន្តមេរៀនបន្ទាប់។ ដូច្នេះសំណួរគួរតែមានភាពងាយស្រួល។
4. តើវង្វាយតម្លៃជាដំណាក់ និងវង្វាយតម្លៃបូកសរុបមានគោលបំណងដូចគ្នាដែរឬទេ?
   ***ចម្លើយ៖*** ទេ ពួកវាមានគោលបំណងខុសគ្នាទាំងស្រុង។ គោលបំណងនៃវង្វាយតម្លៃជាដំណាក់គឺដើម្បីរៀបចំផែនការថាតើផ្នែកខ្លឹមសារអ្វីខ្លះ និងសិស្សណាខ្លះដែលត្រូវបង្រៀនឡើងវិញ ខណៈដែលគោលបំណងនៃវង្វាយតម្លៃបូកសរុបគឺដើម្បីកត់ត្រាលទ្ធផលសិក្សាចុងក្រោយ ដើម្បីធ្វើការសម្រេចចិត្តឱ្យ "ឡើងថ្នាក់"។
5. តើការធ្វើតេស្តបូកសរុបគួរតែអនុវត្តដោយការបង្រៀនឡើងវិញដែរឬទេ? ចូរពន្យល់ចម្លើយរបស់អ្នក។
   ***ចម្លើយ៖*** ទេ នៅពេលដែលបញ្ចប់វង្វាយតម្លៃបូកសរុប ជាធម្មតាគ្រូបង្រៀនមិនបង្រៀនខ្លឹមសារណាមួយឡើងវិញទេ ពីព្រោះគោលបំណងគឺដើម្បីធ្វើការសម្រេចចិត្តលើការឡើងថ្នាក់ដោយផ្អែកលើលទ្ធផលសិក្សាចុងក្រោយ។

បន្ទាប់ពីការពិភាក្សាអំពីវង្វាយតម្លៃជាដំណាក់ និងវង្វាយតម្លៃបូកសរុប សូមពិនិត្យមើលទម្រង់ការវាស់វែងផ្សេងៗដែលបានប្រើប្រាស់ជាញឹកញាប់សម្រាប់សិក្សាបំណិនជីវិតតាមមូលដ្ឋាន។ ទម្រង់ទាំងនេះត្រូវបានសង្ខេបនៅក្នុង ឯកសារ ៧.២។ បន្ទាប់ពីការពិនិត្យនិយមន័យនៃទម្រង់វង្វាយតម្លៃនីមួយៗឡើងវិញ សូមចែកអ្នកចូលរួមជាក្រុមតូចៗ ហើយសុំឱ្យពួកគេបំពេញលំហាត់នៅចុងបញ្ចប់នៃឯកសារនេះ។ នៅក្នុងលំហាត់នេះ អ្នកចូលរួមត្រូវតែបង្ហាញថា តើពួកគេគិតថាទម្រង់វង្វាយតម្លៃ (ឧទាហរណ៍ ការធ្វើតេស្តសរសេរ) គឺសមរម្យសម្រាប់ទិដ្ឋភាពនីមួយៗនៃក្របខណ្ឌ KSA ដោយសម្គាល់ "X" នៅក្នុងក្រឡោនឱ្យបានត្រឹមត្រូវ។ ពួកគេក៏អាចផ្តល់នូវយុត្តិកម្មសម្រាប់ការប្តេជ្ញាចិត្តរបស់ពួកគេនៅក្នុងក្រឡោនមតិយោបល់ផងដែរ។ ដូច្នេះ ក្រុមនីមួយៗគួរតែកត់ត្រាចម្លើយរបស់ពួកគេនៅលើក្រដាសផ្ទាំងធំដើម្បីឱ្យពួកគេអាចបង្ហាញដល់ក្រុមធំ។ ចម្លើយដែលបានណែនាំសម្រាប់លំហាត់នេះត្រូវបានផ្តល់ជូននៅក្នុងតារាងខាងក្រោមដើម្បីជួយអ្នកសម្របសម្រួលឱ្យដឹកនាំការពិភាក្សាប្រកបដោយប្រសិទ្ធភាព។ ប្រសិនបើចម្លើយរបស់អ្នកចូលរួមខុសពីចម្លើយដែលបានផ្តល់ខាងក្រោម អ្នកសម្របសម្រួលអាចទទួលយកចម្លើយផ្សេងៗវិញ ប្រសិនបើហេតុផលហាក់ដូចជាសមហេតុផល។

**ចម្លើយសម្រាប់លំហាត់នៅក្នុងឯកសារ ៧.២**

| ទម្រង់វង្វាយតម្លៃ | វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|---|
| តេស្តសរសេរ | x | | |
| ការអង្កេតគ្រូអំឡុងពេលបង្រៀន | x | x | x |
| អនុវត្តជាក់ស្តែង | x | x | x |
| ការវាយតម្លៃជាដៃគូ ឬជាក្រុម | x | x | |
| ស្វ័យវាយតម្លៃសិស្ស | x | | x |

## ពិភាក្សាជាក្រុមធំ

បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញក្រាហ្វិចដែលសង្ខេបពីការអនុវត្តរបស់ក្រុមគ្រូបង្រៀនចំនួន៨៦នាក់ មកពីសាលា ៣ប្រភេទ៖ សាលារៀនដែលអនុវត្តបំណិនជីវិតតាមមូលដ្ឋានតាមរយៈការគាំទ្រពីអង្គការយូនីសេហ្វ ឬមន្ទីរអប់រំ និងការិយាល័យអប់រំស្រុក សាលារៀនជំនាន់ថ្មី និងសាលារៀនដែលអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ដោយមានការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាល អង្គការរ៉ូមដូរីត។ សាលារៀនត្រូវបានវាយតម្លៃនៅចុងឆ្នាំ២០២៣ លើការអនុវត្តរបស់ពួកគេ ដោយយោងទៅលើការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន។

## តើក្រាហ្វិចនិយាយអំពីអ្វី ?




*រូបភាពទី៣ ង្វាយតម្លៃដើមគ្រាស្តីពីបំណិនជីវិតតាមមូលដ្ឋាន ២០២៣*

**ចម្លើយដែលបានណែនាំ៖** ក្រាហ្វិចបង្ហាញថា សាលារៀនភាគច្រើនដែលត្រូវបានសម្ភាស៍ដោយប្រើទាំងវង្វាយតម្លៃផ្លូវការ និងក្រៅផ្លូវការ ក្នុងនោះវង្វាយតម្លៃក្រៅផ្លូវការរួមមានការឆ្លុះបញ្ចាំង ការពិភាក្សា ការសង្កេត កម្រងសំណួរតូចៗ (វង្វាយតម្លៃជាដំណាក់)។ មានសាលារៀនតិចតួចប៉ុណ្ណោះដែលបញ្ចូលបំណិនទាំង១២ ទៅក្នុងសៀវភៅកត់ត្រាប្រចាំខែរបស់សិស្ស ប៉ុន្តែពួកគេមានទំនោរសង្កេតមើលការអភិវឌ្ឍបំណិនទន់របស់សិស្ស និងគាំទ្រវាល់បញ្ហាប្រឈមនានាក្នុងអំឡុងពេលដំណើរការ។ ទិន្នន័យនេះបង្ហាញថាសាលារៀនបានបញ្ចូលគ្នានូវឧបករណ៍ភាគច្រើនដែលបានកំណត់ និងពិភាក្សាក្នុងអំឡុងពេលសកម្មភាពពិភាក្សានៅលើឯកសារ ៧.២។

## ការវាយតម្លៃការសិក្សាបំណិនជីវិតតាមមូលដ្ឋាន

### ដំណើរការសិក្សាអាស្រ័យលើបញ្ហា

អ្នកសម្របសម្រួលគួរតែចាប់ផ្ដើមវគ្គនេះដោយពន្យល់ថា វគ្គសិក្សាបំណិនជីវិតជាច្រើន រួមទាំងមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន តម្រូវឱ្យសិស្សបង្កើតគម្រោងដោយប្រើការសិក្សាតាមបែបគម្រោង ឬការសិក្សាអាស្រ័យលើបញ្ហា (សូមមើលមេរៀនទី៣)។ ទោះជាយ៉ាងណាក៏ដោយ យើងដឹងហើយថា យុទ្ធសាស្ត្រវាយតម្លៃបែបប្រពៃណី (ឧទាហរណ៍ ការធ្វើតេស្ត ការធ្វើលំហាត់ខ្លីៗ ជាដើម។ល។) មិនបានផ្ដល់ឱ្យពួកគេត្រឹមត្រូវដើម្បីវាស់វែងការងារគម្រោង ពីព្រោះគ្រូបង្រៀនត្រូវការដឹងពីដំណើរការផ្ទៃក្នុងនៃការគិត ដែលសិស្សប្រើប្រាស់នៅពេលបង្កើតផលិតផលគម្រោង។ នោះគឺការយល់ដឹងពីរបៀបដែលសិស្សរកដំណោះស្រាយ ឬការសន្និដ្ឋានអំពីអ្វីមួយគឺមានសារៈសំខាន់ដូចជាផលិតផល ឬដំណោះស្រាយខ្លួនឯង។

## ការប្រៀបធៀបវិធីសាស្ត្រការសិក្សាតាមបែបប្រពៃណី និងការសិក្សាតាមបែបគម្រោង

បន្ទាប់ពីចាប់ផ្តើមជាមួយនឹងការពន្យល់ខាងលើ សូមចែកឯកសារ ៧.៣៖ *ភាពផ្ទុយគ្នានៃការវាយតម្លៃការសិក្សាបែបប្រពៃណី និងការសិក្សាតាមបែបគម្រោង* ដើម្បីជួយអ្នកចូលរួមឱ្យយល់អំពីភាពផ្ទុយគ្នារវាងវិធីសាស្ត្រការសិក្សាតាមបែបប្រពៃណី និងតាមបែបគម្រោង និងការពាក់ព័ន្ធ។ បន្ទាប់មក រៀបចំការពិភាក្សាជាក្រុមតូចៗដែលអ្នកចូលរួមពិនិត្យមើលរូបតុក្កតាដែលបានផ្តល់នៅក្នុងឯកសារ និងឆ្លើយសំណួរដែលមាននៅខាងក្រោមនៃទំព័រ។ ផ្តល់ពេលប្រហែល ១៥នាទីសម្រាប់ការពិភាក្សាជាក្រុមតូច។ បន្ទាប់មក ពិនិត្យមើលចម្លើយរបស់ក្រុមនីមួយៗជាក្រុមធំ ដើម្បីធានាថាអ្នកគ្រប់គ្នាបានយល់ពីរបៀបដែលការសិក្សាខុសគ្នានៅក្នុងបរិបទទាំងពីរ និងរបៀបដែលវានឹងប៉ះពាល់ដល់ការវាយតម្លៃរបស់សិស្សនៅក្នុងមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន ដែលសិស្សកំពុងស្វែងរកការដោះស្រាយបញ្ហា និងបង្កើតដំណោះស្រាយ។ ប្រើចម្លើយដែលបានផ្តល់ជូនខាងក្រោម ដើម្បីជួយណែនាំការពិភាក្សាជាក្រុមធំ៖

### សំណួរពិភាក្សា

1. **តើកម្រិតនៃការគិតមួយណាអនុវត្តក្នុងការវាយតម្លៃក្នុងរូបភាព"ក"? រូបភាព"ខ"? ប្រើប្រាស់ចំណេះដឹងតាមប្លុមតាក់សូណូមីដើម្បីឆ្លើយសំណួរនេះ**
   a. *រូបភាព ក ៖ ចងចាំ យល់ដឹង (អាចមាន អនុវត្ត ខ្លះ)*
   b. *រូបភាព ខ ៖ អនុវត្ត វិភាគ វាយតម្លៃ បង្កើតថ្មី*
2. **រកគុណសម្បត្តិ និងគុណវិបត្តិនៃបច្ចេកទេសវាយតម្លៃក្នុងរូបភាព "ក" និងរូបភាព "ខ"**
   a. *គុណសម្បត្តិក្នុងរូបភាព ក៖*
      i. *ងាយស្រួលវាយតម្លៃសិស្សដោយប្រើតេស្ត ឬសំណួរធម្មតា*
      ii. *ទាមទាឱ្យមានការវាយតម្លៃស៊ីគ្នានឹងក្របខណ្ឌវាយតម្លៃបែបប្រពៃណីដែលសាលារៀនភាគច្រើនបានអនុវត្តហើយ*
   b. *គុណវិបត្តិក្នុងរូបភាព ក៖*
      i. *សិស្សមិនសូវមានការប្រឹងប្រែងនឹងកិច្ចការគ្រូដាក់ឱ្យ*
      ii. *ការសិក្សាផ្តោតលើការគិតកម្រិតទាប*
      iii. *សិស្សមានឱកាសតិចតួចដើម្បីគិតស៊ីជម្រៅ ឬច្នៃប្រឌិត*
   c. *គុណសម្បត្តិក្នុងរូបភព ខ៖*
      i. *សិស្សមានការប្រឹងប្រែងនឹងកិច្ចការគ្រូដាក់ឱ្យ*
      ii. *ការសិក្សាជំរុញការគិតកម្រិតខ្ពស់*
      iii. *គ្រូយល់បានកាន់តែស៊ីជម្រៅពីវិធីគិតរបស់សិស្ស និងរបៀបដោះស្រាយបញ្ហា*

d. *គុណវិបត្តិក្នុងរូបភាព ខ៖*

i. *ការអនុវត្តវិធីវាយតម្លៃត្រូវការពេលវេលាច្រើន*

ii. *ត្រូវការវិធីថ្មីក្នុងការវាយតម្លៃដែលគ្រូភាគច្រើនមិនទាន់ចេះ*

iii. *មិនស៊ីគ្នាជាមួយក្របខណ្ឌវាយតម្លៃបែបប្រពៃណីប្រើក្នុងសាលាភាគច្រើន*

3. **ហេតុអ្វីបានអ្នកគិតថាគ្រូភាគច្រើនក្នុងប្រទេសកម្ពុជាមិនចង់ប្រើប្រាស់បច្ចេកទេសបង្រៀន និងវាយតម្លៃដែលអនុវត្តក្នុងរូបភាព "ខ" ?**

a. *គ្រូភាគច្រើនផ្តោតលើការបង្រៀនដើម្បីតែប្រឡង(តាមបែបប្រពៃណី)ដែលមិនសូវជំរុញការគិតបែបស៊ីជម្រៅដល់សិស្ស*

b. *គ្រូភាគច្រើនមិនចេះវិធីវាយតម្លៃគម្រោង និងវិធីស្រដៀងគ្នាថ្មីៗនេះ*

c. *គ្រូភាគច្រើនផ្តល់អាទិភាពលើការងារក្រៅម៉ោងបង្រៀន មិនមានពេលស្រាវជ្រាវ និងអនុវត្តវិធីបង្រៀន ឬវិធីវាយតម្លៃថ្មីៗ*

d. *។ល។*

បន្ទាប់ពីការពិភាក្សាខាងលើត្រូវបានបញ្ចប់សូមចែកឯកសារ ៧.៤៖ យុទ្ធសាស្ត្រវាយតម្លៃក្នុងបំណិនជីវិតតាមមូលដ្ឋាន ដើម្បីពិនិត្យមើលឡើងវិញនូវយុទ្ធសាស្ត្រវាយតម្លៃជាក់លាក់មួយចំនួនដែលប្រើប្រាស់ដោយអ្នកអប់រំ ដើម្បីវាស់វែងការសិក្សារបស់សិស្សនៅក្នុងការងារគម្រោង អនុវត្តចំពោះ**បរិយាកាសសិក្សាអាស្រ័យលើបញ្ហា**។ យុទ្ធសាស្ត្រទាំងនេះរួមមានដូចខាងក្រោម៖

- ការវាយតម្លៃបែបឌីណាមិក
- ការវាយតម្លៃបែបកម្រងស្នាដៃសិស្ស
- ការវាយតម្លៃបែបដំណើរការ
- ការវាយតម្លៃបែបក្រៅផ្លូវការ

ពិនិត្យមើលលក្ខណៈពិសេសនៃបច្ចេកទេសវាស់វែងក្នុងឯកសារចែក។ ពេលពិនិត្យត្រូវកត់សម្គាល់ចំណុចទាំងអស់ខាងក្រោម៖

- បច្ចេកទេសទាំងនេះ ត្រូវការអន្តរកម្មខ្លាំងរវាងសិស្ស និងសិស្ស និងក្នុងក្រុម
- អន្តរកម្មទាំងនេះអាចជាការសម្ភាស ការពិភាក្សាក្រៅផ្លូវការ និងការសង្កេតអាកប្បកិរិយាសិស្ស
- ផ្តោតការយកចិត្តទុកដាក់លើដំណើរការរៀន ដូចផលិតផល និងដំណោះស្រាយផងដែរ
- មានចំណុចជាន់គ្នាខ្លះទៅលើលក្ខណៈពិសេសនៃបច្ចេកទេសវាយតម្លៃទាំងនេះ

បច្ចេកទេសទាំងនេះ អាចបំពេញបន្ថែមទៅលើក្របខណ្ឌការវាយតម្លៃផ្លូវការដោយមានព័ត៌មានបន្ថែមច្រើនពីសកម្មភាពរៀនរបស់សិស្ស។

បន្ទាប់មក អ្នកសម្របសម្រួលពន្យល់បន្ថែមពីចំណុចខាងលើដោយផ្តល់ឧទាហរណ៍ពីបច្ចេកទេសវាយតម្លៃផ្សេងៗក្នុង ឯកសារ ៧.៤។ សម្រាប់គោលបំណងនេះ សូមចែកឯកសារ ៧.៥៖

*ឧទាហរណ៍ជាក់ស្តែងនៃយុទ្ធសាស្ត្រវាយតម្លៃដែលប្រើដើម្បីវាស់វែងការសិក្សាតាមបែបស្ថាបនានិយម និងបំណិនជីវិតតាមមូលដ្ឋាន*។ ប្រើឯកសារនេះដើម្បីពិនិត្យមើលឧទាហរណ៍នីមួយៗដែលបានផ្តល់ជាមធ្យោបាយដើម្បីលើកជាឧទាហរណ៍ពីការពន្យល់ដែលបានផ្តល់ពីមុន។

បន្ទាប់ពីពន្យល់ចប់ ឱ្យអ្នកចូលរួមធ្វើការពិភាក្សាក្រុម និងបំពេញលំហាត់ក្នុង **ឯកសារ ៧.៥**។ ផ្តល់ពេលប្រហែល ៣០នាទីសម្រាប់ការពិភាក្សា និងបំពេញតារាង។ ចែកក្រដាសផ្ទាំងធំឱ្យក្រុមនីមួយៗដើម្បីកត់ត្រាចម្លើយ។ ឆ្លងកាត់ឧទាហរណ៍នៃឧបករណ៍ ដែលត្រូវបានរៀបចំឡើងសម្រាប់វង្វាយតម្លៃបែបដំណាក់ ប៉ុន្តែក៏មានវង្វាយតម្លៃបូកសរុបនៃបំណិនជីវិតតាមមូលដ្ឋានផងដែរ។

ពេលក្រុមទាំងអស់បំពេញតារាងរួចរាល់ហើយ សូមឱ្យពួកគេបិទក្រដាសចម្លើយលើជញ្ជាំងដើម្បីប្រៀបធៀប។ ប្រើប្រាស់ចម្លើយក្នុងតារាងខាងក្រោមជាជំនួយក្នុងការពិភាក្សាដើម្បីរកចំណុចរួមនៃចម្លើយក្រុមទាំងអស់ដើម្បីឱ្យអ្នកចូលរួមចាប់បាននូវគោលគំនិតសំខាន់ៗពីលំហាត់អនុវត្តមួយនេះ។

| លក្ខណៈពិសេស | ការវាយតម្លៃបែបឌីណាមិក | ការវាយតម្លៃបែបកម្រងស្នាដៃសិស្ស | ការវាយតម្លៃបែបដំណើរការ | ការវាយតម្លៃបែបក្រៅផ្លូវការ |
|---|---|---|---|---|
| ពេលវេលា<br>(ឧ.មុនពេល អំឡុងពេល ក្រោយពេលបញ្ចប់កិច្ចការ ជាប្រចាំ) | ជាប្រចាំ | ក្រោយពេលបញ្ចប់កិច្ចការ | ជាប្រចាំ | ជាប្រចាំ |
| ការផ្តោតលើគុណភាពផលិតផល<br>(ឧ. ទាប មធ្យម ខ្ពស់) | មធ្យម | ខ្ពស់ | ទាប | មធ្យម |
| ការផ្តោតលើដំណើរការ<br>(ឧ. ទាប មធ្យម ខ្ពស់) | ខ្ពស់ | មធ្យម | ខ្ពស់ | ខ្ពស់ |
| អន្តរកម្មជាមួយគ្រូ<br>(ឧ. ទាប មធ្យម ខ្ពស់) | ខ្ពស់ | មធ្យម | ខ្ពស់ | ខ្ពស់ |
| ការប្រើប្រាស់ការវាយតម្លៃបែបប្រពៃណី<br>(ឧ.ទាប មធ្យម ខ្ពស់) | មធ្យម | ខ្ពស់ | មធ្យម | ទាប |

បន្ទាប់ពីសកម្មភាពនេះ អ្នកសម្របសម្រួលណែនាំពីវីដេអូដែលផលិតដោយសាលារៀន ថ្មសរ ស្តីពីដំណើរការវាយតម្លៃ។ ក្នុងករណីនេះផងដែរ សាលារៀន ថ្មសរ បានរៀបចំវីដេអូនេះគឺដើម្បីជួយដល់សាលារៀនផ្សេងទៀតឱ្យយល់កាន់តែច្បាស់អំពីរបៀបវាយតម្លៃសិស្សក្នុងមុខវិជ្ជាបំណិនជីវិតមូលដ្ឋាន ដោយប្រើឧបករណ៍ដែលមាននៅក្នុងឯកសារណែនាំសម្រាប់ការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន (ឆ្នាំ២០១៩)។ មុនពេលចាប់ផ្តើមចាក់វីដេអូ អ្នកសម្របសម្រួលបង្ហាញអ្នកចូលរួមនូវឧបករណ៍វាយតម្លៃផ្សេងៗគ្នាដែលមាននៅក្នុងឯកសារណែនាំឆ្នាំ២០១៩ និងពន្យល់ពីគោលបំណងនីមួយៗ (ពីទំព័រទី៩៥ ដល់ទំព័រ...)។

## សកម្មភាព (៣០នាទី) ដំណើរការវាយតម្លៃ

https://www.youtube.com/watch?v=pZfYaZ8uZ_M

## សំណួរបំផុស

- តើវិសាលភាពនៃដំណើរវង្វាយតម្លៃនៅក្នុងដំណើរការបំណិនជីវិតតាមមូលដ្ឋានគឺជាអ្វី?
- តើឧបករណ៍ ឬបច្ចេកទេសប្រើប្រាស់អ្វីខ្លះនៅក្នុងសាលារៀនថ្មសរ? តើអ្នកទទួលស្គាល់អ្វីមួយពីការដែលខ្ញុំបានបង្ហាញអ្នកពីមុនមកទេ?
- តើអ្នកប្រើបច្ចេកទេសស្រដៀងគ្នាដើម្បីវាស់វែងសិស្សរបស់អ្នកនៅក្នុងសាលារៀន ដែរឬទេ? ជាឧទាហរណ៍ តើអ្នកធ្លាប់បានប្រើការពិនិត្យទៅវិញទៅមកជាមួយដៃគូដែរឬទេ? តើអ្នកគិតថាមានអត្ថប្រយោជន៍អ្វីខ្លះដល់សិស្ស?

**សកម្មភាព៖ ករណីសិក្សា(៣០នាទី)៖** បន្ទាប់ពីកិច្ចពិភាក្សា អ្នកសម្របសម្រួលពន្យល់ថាការត្រួតពិនិត្យបំណិនទន់គឺជាផ្នែកមួយនៃវិធីសាស្រ្តវាស់វែងផ្សេងៗគ្នា ដែលចាំបាច់សម្រាប់វិធីសាស្រ្តស្ថាបនានិយមដូចជាការសិក្សាអាស្រ័យលើបញ្ហា។ អ្នកសម្របសម្រួលចែកឯកសារ ៧.៦ ដំណើរវង្វាយតម្លៃបំណិនជីវិតតាមមូលដ្ឋាននៃអនុវិទ្យាល័យអរញ្ញវង្សី។
អ្នកសម្របសម្រួលថតចម្លងមួយច្បាប់នៃឧបករណ៍វាស់វែងដែលបានរៀបរាប់នៅក្នុងករណីសិក្សា និងចែកឱ្យក្រុមនីមួយៗដើម្បីឱ្យពួកគេអាចមើលឯកសារបាន។ ឧបករណ៍រួមមាន៖

ឃ. សេចក្តីណែនាំការសង្កេត ឧបសម្ព័ន្ធ ៧.២.២ (ទំព័រទី៩៩-១០១ ឯកសារណែនាំអនុវត្តរបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៩)។

ង. ស្វ័យវាយតម្លៃសិស្ស ឧបសម្ព័ន្ធ ៧.៤ (ទំព័រទី១០៣-១០៤ ឯកសារណែនាំអនុវត្តរបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៩)។

ច. វង្វាយតម្លៃលទ្ធផល ឧបសម្ព័ន្ធ ៧.១.១ (ទំព័រទី៩៥ ឯកសារណែនាំអនុវត្តរបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៩)។

## សំណួរបំផុស

- ហេតុអ្វីបានជាអ្នកគិតថាសាលារៀនត្រូវវាស់វែងទាំងចំណេះដឹង និងបំណិន?
- បើតាមគំនិតរបស់អ្នក តើអ្វីជាគោលដៅក្នុងអំឡុងពេលសង្កេត ដោយការប្រើសេចក្តីណែនាំការសង្កេត?
- តើអ្វីជាគោលដៅនៃការធ្វើស្វ័យវាយតម្លៃផ្ទាល់ខ្លួនរបស់សិស្ស?
- តើអ្នកមានអារម្មណ៍ជឿជាក់ក្នុងការប្រើប្រាស់ឧបករណ៍ទាំងនេះដែរឬទេ? បើមិនដូច្នេះទេ តើអ្នកត្រូវយល់ដឹងអ្វីខ្លះមុនពេលអាចប្រើប្រាស់វាបាន?
- តើអ្វីជាអត្ថប្រយោជន៍នៃការប្រើប្រាស់ឧបករណ៍នេះ (ជាពិសេសឧបករណ៍សម្រាប់វាយតម្លៃបំណិន)? តើអ្វីជាបញ្ហាប្រឈម?

ចុងក្រោយ អ្នកសម្របសម្រួលសួរអ្នកចូលរួម៖ តើបំណិនជីវិតតាមមូលដ្ឋាន ជាផ្នែកមួយនៃសៀវភៅពិន្ទុសិស្សដែរឬទេ?

នៅក្នុងប្រព័ន្ធអប់រំការធ្វើតេស្តសិស្សនៅតែជារឿងចាំបាច់បំផុត ការមានពិន្ទុនឹងជួយលើកទឹកចិត្តទាំងសិស្ស ទាំងគ្រូឱ្យចូលរួមក្នុងការសិក្សា។ នៅក្នុងការស្ទង់មតិពាក់ព័ន្ធដែលធ្វើឡើងដោយ ក្រសួងអប់រំដោយមានការគាំទ្រពី KAPE/UNICEF លើការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន លើសាលារៀនសរុបចំនួន ៦៩% ដែលអនុវត្តបំណិនជីវិតតាមមូលដ្ឋាន ហើយក៏មានបំណិនជីវិតតាមមូលដ្ឋានជាផ្នែកមួយនៃសៀវភៅសិក្សាគោល។ ដូចដែលបានពិភាក្សាតាំងពីមេរៀនទី១ បំណិនជីវិតតាមមូលដ្ឋាន គឺជាមុខវិជ្ជាកាតព្វកិច្ចនៅក្នុងសាលារៀនចាប់តាំងពីកម្មវិធីកំណែទម្រង់កម្មវិធីសិក្សាឆ្នាំ២០១៥។ សាលារៀនបានបញ្ចូលវា និងធានាថាវាជាផ្នែកមួយនៃរង្វាយតម្លៃសមត្ថភាពសិស្សចុងក្រោយ។ ដូចដែលយើងឃើញនៅក្នុងមេរៀនទី៧ គំរូវាយតម្លៃសម្រាប់មុខវិជ្ជាសិក្សាអាស្រ័យលើបញ្ហាអាចខុសគ្នាពីវិធីសាស្ត្របែបប្រពៃណី ដើម្បីអនុញ្ញាតឱ្យគ្រូត្រួតពិនិត្យ និងវាយតម្លៃដំណើរការសិក្សាបានល្អប្រសើរ ដែលជាចំណុចស្នូលនៅក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ច្រើនជាងលទ្ធផលចុងក្រោយ។

មុនពេលបញ្ចប់មេរៀន អ្នកសម្របសម្រួលចែករំលែកដល់អ្នកចូលរួមនូវឧត្តមានុវត្តរបស់អនុវិទ្យាល័យអរញ្ញរង្សី លើដំណើរការវាយតម្លៃ (ក្នុងតារាងខាងក្រោម) ដែលពន្យល់ពីវិធីដែលសាលារៀននេះ ក៏ដូចជាសាលារៀនផ្សេងទៀតដែលបានចូលរួមក្នុងការអនុវត្តបំណិនជីវិតតាមមូលដ្ឋានដែលរួមបញ្ចូលគ្នាទាំងរង្វាយតម្លៃជាផ្លូវការ និងក្រៅផ្លូវការ ជាមួយនឹងគោលបំណងអាទិភាពនៃការធ្វើការវាស់វែងបែបដំណាក់ដើម្បីកែលម្អការអភិវឌ្ឍបំណិនរបស់សិស្ស។ ពិន្ទុត្រូវបានកត់ត្រានៅក្នុងសៀវភៅសិស្សក្រោមប្រធានបទបំណិនជីវិតតាមមូលដ្ឋាន។

**បញ្ចប់មេរៀនទី៧**

### ផ្នែកទី៣៖ ការបង្កើតបរិស្ថានគាំទ្រនៅតាមសាលារៀន

# ២ មេរៀន

**សង្ខេប៖ ផ្នែក៣** ណែនាំអំពីបញ្ញត្តិនៃប្រព័ន្ធអេកូគរុកោសល្យនៅតាមសាលារៀន ដោយពន្យល់ថា ការកែលម្អសាលារៀនទទួលជោគជ័យទៅបាន គឺគ្រាន់តែអនុវត្តផ្នែកខ្លះៗនៃគរុកោសល្យថ្មីៗនៃការសិក្សាប៉ុណ្ណោះ។ បើគ្មានបរិយាកាសអំណោយផលទេ ការអនុវត្តការបង្រៀន និងការរៀន តាមគំរូថ្មីៗទាំងនេះក៏មិនអាចរីកចម្រើនទៅបានឡើយ។ ដោយយកតាមគំរូសាលារៀនជំនាន់ថ្មី (NGS) អ្នកចូលរួមអាចវិភាគធាតុផ្សំផ្សេងៗរបស់ប្រព័ន្ធអេកូគរុកោសល្យនេះ រួមទាំងធាតុសំខាន់ៗនៃអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព ប៉ុន្តែក៏មានយន្តការគាំទ្រដោយផ្ទាល់ដល់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន រួមទាំងសហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន (PLC) ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ( CPD) ប្រព័ន្ធក្រេឌីត និងប្រព័ន្ធប្រឹក្សា។ ជាចុងក្រោយ អ្នកចូលរួមនឹងរៀនពីរបៀបដែលធាតុទាំងនេះរួមបញ្ចូលគ្នាដើម្បីផ្តល់ឥទ្ធិពលវិជ្ជមានដល់ការសិក្សារបស់សិស្ស។



# មេរៀនទី៨៖ គាំទ្រការបង្កើតប្រព័ន្ធអេកូឡូស៊ីនៅតាមសាលារៀន

**រយៈពេលមេរៀន៖** បង្រៀន៥ ម៉ោង (បន្ថែម ១០ម៉ោង ស្វ័យសិក្សា ការហាត់សម និងការអនុវត្ត)

**សកម្មភាពអ្នកសម្របសម្រួលត្រូវត្រៀម៖**

- ពិនិត្យមើលស្លាយទាំងអស់ពី ស្លាយ (PPT) សម្រាប់មេរៀន រួមទាំងគោលបំណងសិក្សា
- ថតច្បាប់ចម្លងឯកសារចែកជូនសិស្សទាំងអស់ដូចដែលបានរាយខាងក្រោម

**ធនធាន និងសម្ភារៈ**

- ឯកសារជាស្លាយ ស្លាយ (PPT) កុំព្យូទ័រ ម៉ាស៊ីនបញ្ចាំង
- ក្រដាសខ្នាត A4 និងប៊ិក
- ថតចម្លង**ឯកសារចែក ៨.១៖** បន្ទាប់ពីការបណ្តុះបណ្តាល
- ថតចម្លង**ឯកសារចែក ៨.២៖** គំរូសិក្សា ៧០-២០-១០
- ថតចម្លង**ឯកសារចែក ៨.៣៖** សេណារីយ៉ូ៖ សុភា និងការសិក្សាថ្មីៗ
- ថតចម្លង**ឯកសារចែក ៨.៤៖** ប្រព័ន្ធអេកូគរុកោសល្យនៅតាមសាលារៀនរបស់អ្នក
- ថតចម្លង**ឯកសារចែក ៨.៥៖** អ្នកដឹកនាំល្អ និងអ្នកដឹកនាំខ្សោយ
- ថតចម្លង**ឯកសារចែក ៨.៦៖** សេណារីយ៉ូសាលារៀនបឋមសិក្សាភ្នាក់
- ថតចម្លង**ឯកសារចែក ៨.៧៖** បញ្ជីត្រួតពិនិត្យការគ្រប់គ្រងធនធាន

**វត្ថុបំណងសិក្សា៖**

ក្រោយបញ្ចប់មេរៀនទី៨ អ្នកចូលរួមនឹងអាច៖

- ពិពណ៌នាអំពីធាតុសំខាន់ៗនៃប្រព័ន្ធអេកូគរុកោសល្យ
- ពន្យល់ពីសារៈសំខាន់នៃបរិយាកាសគាំទ្រសម្រាប់ការពង្រឹងការអនុវត្តការបង្រៀន
- ពិពណ៌នាអំពីធាតុសំខាន់ៗនៃអភិបាលកិច្ចល្អនៅក្នុងសាលារៀន
- រៀបឡើងវិញនូវមធ្យោបាយមានប្រសិទ្ធភាពក្នុងការចូលរួមសហគមន៍នៅតាមសាលារៀន និងវិធីបង្កើតការជឿទុកចិត្ត និងកិច្ចសហប្រតិបត្តិការ

ការឆ្លុះបញ្ចាំង និងការអនុវត្តទ្រឹស្តីផ្សារភ្ជាប់ទៅនិងកន្លែការងារជាក់ស្តែង៖ អ្នកចូលរួមនឹង៖

- ឆ្លុះបញ្ចាំងពីសុពលភាព ៧០-២០-១០ នៅក្នុងការអនុវត្តតាមសាលារៀន
- ឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាព និងការអនុវត្តរបស់សាលារៀន
- ឆ្លុះបញ្ចាំងពីសារៈសំខាន់នៃការចូលរួមរបស់សហគមន៍ជាមួយសាលារៀន
- ឆ្លុះបញ្ចាំងពីសារៈសំខាន់នៃការបង្កើតទំនុកចិត្ត

**ឯកសារ និងកិច្ចការអាន**

- ក្រសួងអប់រំ (២០២១) ក្របខណ្ឌសតវត្សរ៍ទី២១ សម្រាប់ប្រទេសកម្ពុជា៖ ជំពូកទី៤៖ "ការប្រើប្រាស់ប្រព័ន្ធអេកូគរុកោសល្យ ដើម្បីបង្កើនប្រសិទ្ធភាពនៃវិធីសាស្ត្របង្រៀនថ្មី" Khmer version, English version.

# ផែនការវគ្គបណ្ដុះបណ្ដាល–មេរៀនទី៨

## ពិនិត្យវត្ថុបំណងមេរៀន

បិទក្រដាសផ្ទាំងធំលើក្ដារខៀន ដោយសង្ខេបលទ្ធផលសិក្សារបស់មេរៀន។ ក្រោយចប់វគ្គ ពន្យល់ថា អ្នកចូលរួមអាចធ្វើបានពីលទ្ធផលនៃការសិក្សានេះ។

### តើប្រព័ន្ធអេកូគរុកោសល្យគឺជាអ្វី?

### ក្រោយវគ្គសិក្សា

*ក្រោយចប់វគ្គ* អ្នកសម្របសម្រួលចែកឯកសារ ៨.១ ហើយស្នើសុំអ្នកចូលរួមអាន សេចក្ដីណែនាំដោយយកចិត្តទុកដាក់។ អ្នកចូលរួមធ្វើការជាក្រុមតូចសិន ដើម្បីឆ្លើយសំណួរ បន្ទាប់មក ពួកគេចូលជាក្រុមធំដើម្បីពិភាក្សា និងបង្ហាញបទពិសោធន៍រួម និងគន្លឹះនៅពេលដែលពួកគេវិលត្រឡប់ទៅបំពេញការងារក្រោយចប់វគ្គ។

**សម្រាប់អ្នកសម្របសម្រួល៖ ចម្លើយពាក់ព័ន្ធនឹងបញ្ហាប្រឈម។** ជារឿយៗ មិនមានលទ្ធភាពណាដែលសាលារៀនចែករំលែកវិជ្ជាសម្បទាដល់សហការីរបស់ខ្លួនដោយមានហេតុផលផ្សេងៗរួមមាន ខ្វះពេលវេលា គ្មានពេលដាក់លាក់ទុកសម្រាប់កិច្ចការចែករំលែកនេះ មានចំណាប់អារម្មណ៍តិចតួច និងមានការប្ដេជ្ញាចិត្តតិចតួច។ ទន្ទឹមនេះ កាលណាគ្រូព្យាយាមណែនាំវិធីសាស្ត្រសិក្សាបែបថ្មី សហការីរបស់ពួកគេ ឬនាយកនៅតាមសាលារៀននោះមិនសូវជាស្វាគមន៍គំនិតថ្មីនេះទេ។ មិនសូវមានការយល់គ្នាអ្វីទេ មានពេលខ្លះគណៈគ្រប់គ្រងគ្រាន់តែចង់ឱ្យគ្រប់គ្នាសប្បាយចិត្តប៉ុណ្ណោះ មិនសូវខ្វល់ពីគំនិតផ្ដួចផ្ដើមថ្មី ឬឱ្យតម្លៃគំនិតនេះឡើយ។
កត្តាទាំងអស់នេះហើយផ្សារភ្ជាប់ទៅនឹងកង្វះបរិយាកាសគាំទ្រនៅតាមសាលារៀន។ កាលណាទិដ្ឋភាពផ្សេងៗនៃការបង្រៀន និងការរៀនមិនទទួលបានការគាំទ្រត្រឹមត្រូវទេនោះ ការបណ្ដុះបណ្ដាលបែបនេះក៏មិនមានប្រសិទ្ធភាពអ្វីដែរ។ នៅមេរៀនពីរបន្ទាប់ យើងនឹងឈ្វេងយល់ពីរបៀបបង្កើតបរិយាកាសគាំទ្របែបនេះនៅតាមសាលារៀនដោយមានការអនុវត្ត និងឧទាហរណ៍ល្អៗ។

### គំរូសិក្សា ៧០-២០-១០

អ្នកសម្របសម្រួលចែកឯកសារ ៨.២៖ ***គំរូសិក្សា ៧០-២០-១០*** *បង្ហាញ*គំរូ៧០-២០-១០ តាមស្លាយ ឬផ្ទាំងក្រដាស់ ដោយមានរូបភាពខាងក្រោយ បន្ទាប់មកប្រាប់អ្នកចូលរួមធ្វើការជាគូ ចែករំលែកការគិតរបស់ខ្លួនពីន័យរបស់ក្រាហ្វិកនោះ។ ទុកពេលឱ្យពួកគេពិភាក្សាគ្នាចំនួន៥ទៅ១០នាទី។

សំណួរបំផុសៈ

- តើអ្នកធ្លាប់បានឮអំពីគំរូសិក្សា ៧០-២០-១០ ដែរឬទេ?
- តើក្រាហ្វិកនេះមានន័យយ៉ាងដូចម្ដេចសម្រាប់អ្នក? តើអ្នកយល់ស្របជាមួយន័យនេះដែរឬទេ?
- តើការបណ្ដុះបណ្ដាលដោយឯកឯងមានប្រសិទ្ធិភាពកម្រិតណា ផ្អែកលើក្រាហ្វិកនេះ?
- តើត្រូវមានធាតុផ្សំអ្វីខ្លះទៀតចាំបាច់ធ្វើឱ្យការបណ្ដុះបណ្ដាលមានប្រសិទ្ធភាព?




អ្នកសម្របសម្រួលបន្តពន្យល់សិស្សថា នេះជារូបមន្តដែលគេទទួលស្គាល់ច្រើន យកទៅប្រើក្នុងការហ្វឹកហាត់ការងារ។ រូបមន្តនេះមានកំណើតពីការស្រាវជ្រាវរបស់សហរដ្ឋអាមេរិកកាលពីទស្សវត្សរ៍ឆ្នាំ១៩៨០ លើការសិក្សាពីប្រភពសំខាន់ៗចេញពីអ្នកគ្រប់គ្រងជោគជ័យចំនួន២០០នាក់។ ការស្រាវជ្រាវនេះរកឃើញថាៈ

- លទ្ធផល ៧០% នៃការសិក្សាទទួលបានពីបទពិសោធផ្ទាល់ នៅពេលបុគ្គលិកជួបបញ្ហាជាក់ស្ដែងក្នុងការងារហើយទទួលបានមតិត្រឡប់ភ្លាមៗអំពីការបំពេញការងាររបស់ខ្លួន ពីអ្នកគ្រប់គ្រង និងអ្នកប្រឹក្សា
- លទ្ធផល  ២០% នៃការសិក្សាទទួលបានពីការទំនាក់ទំនង និងកិច្ចសហការជាមួយសហការីមិត្ត គ្រូបង្វឹក អ្នកប្រឹក្សាដែលបានលើកទឹកចិត្ត និងផ្ដល់មតិប្រឡប់
- លទ្ធផល ១០% នៃការអភិវឌ្ឍការងារទទួលបានពីការបង្រៀនតាមបែបប្រពៃណី និងបានពីព្រឹត្តិការណ៍អប់រំផ្សេងៗ

**សេចក្តីសន្និដ្ឋាន (សម្រាប់អ្នកសម្របសម្រួល)៖** ការសិក្សាទូទៅ និងការបង្រៀនជាលក្ខណៈប្រពៃណី តែប៉ុណ្ណឹង មិនមានឥទ្ធិពលផ្ទាល់ និងភ្លាមៗលើកិច្ចការរបស់អ្នកចូលរួមទេ។ នៅចំណុចនេះ អ្នកចូលរួមត្រូវប្រមូលសកម្មភាព ហើយឈ្វេងយល់ជាមុនសិនទើបចាប់ផ្តើមអនុវត្ត និងប្រឈមបញ្ហាជាក់ស្តែង រៀនសម្របដោះស្រាយបញ្ហានោះមុនពេលយកបទពិសោធទាំងនេះទៅប្រើដើម្បីទទួលបាន វិជ្ជាសម្បទាថ្មី។ បញ្ហានេះកើតឡើងចំពោះយើងទាំងអស់គ្នា៖ យើងបានទៅចូលវគ្គបណ្តុះបណ្តាល ហើយគិតថាយើងយល់ ប៉ុន្តែនៅពេលនោះយើងចាប់ផ្តើមអនុវត្តអ្វីដែលយើងបានរៀននៅក្នុងវគ្គបណ្តុះបណ្តាល នោះយើងដឹងថា យើងយល់មិនសូវច្បាស់ទេ។ អ្នកសម្របសម្រួលបន្តថា នៅវគ្គក្រោយទៀត គេនឹងរំឭកទិដ្ឋភាពគាំទ្រចម្បងៗ២៖

- ជាផ្នែកមួយនៃវគ្គបណ្តុះបណ្តាល សាលារៀនមានធាតុសំខាន់ៗដែលអាចគាំទ្រគ្រូបង្រៀនឱ្យចេះអនុវត្តចំណេះដឹងថ្មីៗតាមសាលាហើយជាអ្វីដែលយើងហៅថាប្រព័ន្ធអេកូគរុកោសល្យ។
- គេប្រើបច្ចេកទេស និងយន្តការគាំទ្រទៅលើ ៧០% ស្តីពី " សេណារីយ៉ូពិសោធន៍" ប៉ុន្តែ ២០% ផ្តោតលើ "ការសិក្សាសង្គម" ដើម្បីធានាថាសាលារៀនអាចជួយបុគ្គលិកបង្កើនប្រសិទ្ធភាពរៀនសូត្រ ក៏ដូចជាវឌ្ឍនភាពនៃការអភិវឌ្ឍវិជ្ជាជីវៈរបស់ពួកគេ។

## ប្រព័ន្ធអេកូគរុកោសល្យ

ការកែលម្អសាលារៀនទទួលជោគជ័យទៅបាន គឺគ្រាន់តែអនុវត្តផ្នែកខ្លះៗនៃគរុកោសល្យថ្មីៗនៃការសិក្សាប៉ុណ្ណោះ តាមការដកស្រង់ឃ្លាមួយលើកឡើងថា "គ្រាប់ពូជមួយអាចដុះលូតលាស់ទៅជារុក្ខជាតិដែលមានសុខភាពល្អបានចាំបាច់ត្រូវមានបរិស្ថានគាំទ្រ"។

**ការបំផុសគំនិត៖** អ្នកសម្របសម្រួលស្នើឱ្យអ្នកចូលរួមគិតអំពីប្រព័ន្ធនេះ ថាតើវាមានន័យយ៉ាងណាដែលត្រូវយកទៅអនុវត្តនៅតាមសាលារៀនបានយ៉ាងដូចម្តេច។

អ្នកសម្របសម្រួលបញ្ជាក់ថា ចំណុចនេះមានន័យថា ប្រព័ន្ធទាំងអស់ បរិស្ថានទាំងអស់នៅតាមសាលារៀន ត្រូវមានសុខភាពល្អ និងដំណើរការបានត្រឹមត្រូវ។ ឧទាហរណ៍ សាលារៀនអាចមានគ្រូបង្រៀនដែលមានសមត្ថភាពច្រើន ប៉ុន្តែប្រសិនបើ**អ្នកដឹកនាំ**មិនផ្តល់តម្លៃដល់ពួកគេ ហើយមិនជួយសម្រួលការងាររបស់ពួកគេ គ្រូបង្រៀននឹងមិនអាចធ្វើការងារប្រកបដោយគុណភាព និងឈានដល់សក្តានុពលពេញលេញរបស់ពួកគេឡើយ។ ឧទាហរណ៍មួយទៀតអាចត្រូវបានគេមើលឃើញនៅពេលដែលសាលារៀនមិនអាចបង្កើតទំនាក់ទំនងល្អជាមួយ**សហគមន៍។**

ក្នុងករណីនេះមិនមានការរួមចំណែក និងការសហការគ្នាក្នុងការរៀនសូត្ររបស់សិស្ស ហើយសិស្សនៅតែមិនទទួលបានការជួយពេញលេញ ដែលនឹងប៉ះពាល់ដល់ដំណើរសិក្សាទាំងមូលរបស់ពួកគេ។ អភិបាលកិច្ចខ្សោយនៅតាមសាលារៀននឹងប៉ះពាល់ដល់ការសិក្សារបស់សិស្ស។

អ្នកសម្របសម្រួលចែក**ឯកសារ ៨.៣៖** *សេណារីយ៉ូ៖ សុភា និងការសិក្សាថ្មី និងពន្យល់ពីសេណារីយ៉ូ*។ **រយៈពេល** ២០នាទី មេរៀន៖ ក្រុមតូចៗមានសមាជិក ៣-៤នាក់។

**សេណារីយ៉ូឆ្លុះបញ្ចាំង (សម្រាប់អ្នកសម្របសម្រួល)**

- ការគាំទ្រពីនាយកសាលារៀន និងសហការីផ្សេងទៀត មានភាពចាំបាច់ចំពោះការណែនាំការរៀនសូត្រថ្មីៗនៅតាមថ្នាក់រៀន។
- យន្តការគាំទ្រដ៏មានប្រសិទ្ធភាពនៅក្នុងថ្នាក់រៀន ជាទម្រង់នៃការ**ប្រឹក្សាណែនាំ** អាចមានប្រសិទ្ធភាពសម្រាប់គ្រូដែលណែនាំវិធីសាស្ត្រថ្មីៗ។ អ្នកប្រឹក្សានេះអាចជាគ្រូបង្រៀន នាយករង ផ្សេងទៀត ឬជាអ្នកប្រឹក្សាដែលបានទទួលការបណ្តុះបណ្តាលពីអង្គការក្រៅរដ្ឋាភិបាល ឬក្រសួងអប់រំ យុវជន និងកីឡា។
- វាមានសារៈសំខាន់ក្នុងការទទួលបាន**តម្លៃ និងការទទួលស្គាល់**ការងារ។
- វាមានសារៈសំខាន់ណាស់ក្នុងការទទួលបាន**ធនធាន** ចាំបាច់ដើម្បីអនុវត្តវិធីសាស្ត្រថ្មីៗ (ទីធ្លា ឬបរិវេន មន្ទីរពិសោធន៍ សម្ភារធនធាន ពេលវេលា)
- កង្វះការគាំទ្រ និងការចាប់អារម្មណ៍ក្នុងសាលារៀន បង្អាក់គ្រូបង្រៀនពីការណែនាំគំនិតថ្មីៗ។
- គ្មានការបែងចែកធនធានធ្វើឱ្យលទ្ធភាពក្នុងការស្វែងរកគំនិតថ្មីជួបផលលំបាក។

អ្នកសម្របសម្រួលពន្យល់ថា សេណារីយ៉ូនេះគឺជាចំណុចចាប់ផ្តើមនៃការឆ្លុះបញ្ចាំងពីអ្វីដែលត្រូវការដើម្បីគាំទ្រដល់ការរៀនប្រកបដោយគុណភាពនៅក្នុងសាលារៀន។ យើងបានចាប់ផ្តើមកំណត់សេណារីយ៉ូមួយចំនួននៅក្នុងការពិភាក្សារបស់យើង។ ធាតុទាំងនេះ រួមជាមួយនឹងលទ្ធភាពផ្សេងៗទៀតចាំបាច់ត្រូវប្រើនៅតាមសាលារៀន ដើម្បីធានាបាននូវគុណភាពនៃការបង្រៀន និងការរៀន និងការគាំទ្រដើម្បីរួមបញ្ចូលគំនិតថ្មីៗ។

បច្ចុប្បន្ន យើងខ្ញុំសូមណែនាំបញ្ញត្តិនៃ**ប្រព័ន្ធអេកូគរុកោសល្យ**។ ពាក្យនេះសំដៅលើប្រព័ន្ធគាំទ្រដែលអាចឱ្យវិធីសាស្ត្របង្រៀនថ្មីមានការអនុវត្តរីកចម្រើននៅតាមសាលារៀន និងជះឥទ្ធិពលជាវិជ្ជមានដល់លទ្ធផលសិក្សារបស់សិស្ស។

ចូរព្យាយាមបំពេញធាតុដែលបានកំណត់ ដែលអាចជួយការងារដល់គ្រូបង្រៀន។
អ្នកសម្របសម្រួលចែកឯកសារ ៨.៤៖ *ប្រព័ន្ធអេកូគរុកោសល្យ នៅក្នុងសាលារៀនរបស់អ្នក ហើយរៀបចំសកម្មភាព។*




- **មេរៀន៖** សមាជិកក្រុម ៤-៥នាក់
- **រយៈពេល៖** ៣០នាទី

**ជំហាន១៖** ពន្យល់សកម្មភាព ហើយឱ្យសិស្សគូរប្រព័ន្ធអេកូគរុកោសល្យរបស់ខ្លួន។
ប្រសិនបើចាំបាច់ ផ្តល់ឧទាហរណ៍ធាតុសំខាន់មួយចំនួនមានដូចជា ការជួបប្រជុំរវាងគ្រូ និងគ្រូ និងថ្នាក់ដឹកនាំគ្រប់គ្រងសាលារៀន។
អ្នកចូលរួមត្រូវស្រមៃថា សាលារៀនរបស់ពួកគេជាប្រព័ន្ធអេកូ ដែលផ្សំឡើងដោយធាតុផ្សេងៗគ្នាជាច្រើនដែលមានទំនាក់ទំនង និងគាំទ្រគ្នាទៅវិញទៅមកដើម្បីដំណើរការបានល្អ។
នៅពេលដែលអ្នកចូលរួមចប់សកម្មភាពនេះហើយ ឱ្យពួកគេបិទបង្ហាញផ្ទាំងរូបភាពទាំងអស់នៅលើជញ្ជាំងបន្ទប់ដើម្បីឱ្យពួកគេម្នាក់ៗអាចសង្កេតមើលអ្វីដែលក្រុមផ្សេងទៀតបានកំណត់ថាជាធាតុសំខាន់ៗ។ ពិភាក្សាអំពីចំណុចរួម និងភាពខុសគ្នា។
**ជំហានទី២៖** ជាចុងក្រោយ អ្នកសម្របសម្រួលបង្ហាញរូបភាពនៃប្រព័ន្ធអេកូគរុកោសល្យពីសាលារៀនជំនាន់ថ្មី។ ឱ្យអ្នកចូលរួមសង្កេតមើល។ តើអ្វីជាភាពខុសគ្នារវាងប្រព័ន្ធអេកូ និងសាលារៀនជំនាន់ថ្មី?




Self-awareness

| | |
|---|---|
| ១. អភិបាល<br>២. វិធីសាស្ត្រថ្មី<br>៣. បណ្ណាល័យសតវត្សរ៍ទី២១<br>៤. សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន | ៥. រចនាបន្ទប់រៀន<br>៦. ការប្រឹក្សាយោបល់<br>៧. បច្ចេកវិទ្យា |

**សេចក្តីសន្និដ្ឋាន៖** នេះគឺជារូបមន្តរបស់សាលារៀនជំនាន់ថ្មី ហើយរូបមន្តនេះអាចវិវត្តន៍ និងបន្ថែមធាតុផ្សំជាច្រើនឆ្នាំហើយ។ អាស្រ័យលើតម្រូវការរបស់អ្នក និងធនធានដែលមាន អ្នកអាចកំណត់អាទិភាព និងជ្រើសរើសធាតុមួយចំនួនសម្រាប់សាលារៀនរបស់អ្នក។

*សម្រាក*

## អភិបាលកិច្ច

យើងចាប់ផ្តើមមើលទៅលើ**អភិបាលកិច្ចប្រកបដោយប្រសិទ្ធភាពនៅក្នុងសាលារៀន** ក្រោមទស្សនទាននៃភាពជាអ្នកដឹកនាំសាលារៀនល្អ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងមានការចូលរួមពីសហគមន៍។

អភិបាលកិច្ចល្អត្រូវបានអ្នកជំនាញអប់រំភាគច្រើនចាត់ទុកថាជាបុរេលក្ខខណ្ឌនៃការផ្តល់សេវាអប់រំប្រកបដោយគុណភាពដល់សិស្ស។

អ្នកសម្របសម្រួលស្នើឱ្យអ្នកចូលរួមបំផុសគំនិតអំពីបញ្ញត្តិនៃអភិបាលកិច្ចល្អ៖ តើអ្វីជាអភិបាលកិច្ចល្អនៅតាមសាលារៀន?

ដើម្បីជួយដល់ការពិភាក្សា សូមបង្ហាញអំណះអំណាងខាងក្រោមដែលត្រូវបានរួមបញ្ចូលក្នុងឯកសារចែកជូន ដើម្បីលើកទឹកចិត្តដល់ការពិភាក្សា និងអនុញ្ញាតឱ្យអ្នកចូលរួមពន្យល់ពីបញ្ញត្តិសំខាន់ៗ (តួអង្គពាក់ព័ន្ធ ផ្នែកនៃកម្មវិធី) ហើយសួរអ្នកចូលរួមថាតើពួកគេយល់ស្របនឹងអំណះអំណាងបែបនេះដែរឬទេ។

*"អភិបាលកិច្ចសាលារៀនល្អ គឺជាមូលដ្ឋានស្តីពីភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាព ដែលធ្លាប់បានបង្កើតដំណើរការ ប្រព័ន្ធ និងការគ្រប់គ្រងសមស្រប ដើម្បីធានានិរន្តរភាព និងភាពជាប្រចាំនៃសាលារៀន។*

*"អភិបាលកិច្ចល្អ គឺជាដំណើរការមួយក្នុងការគ្រប់គ្រងសាលារៀន ដើម្បីបង្កើនការអភិវឌ្ឍ និងគណនេយ្យភាពរបស់សាលារៀន"។*

*"អភិបាលកិច្ចល្អ គឺគ្មានការអត់ឱនចំពោះអំពើពុករលួយក្នុងសាលារៀន"។*

*[អភិបាលកិច្ចសាលារៀន] មានការទទួលខុសត្រូវ គណនេយ្យភាព និងការប្រើប្រាស់ធនធានប្រកបដោយតម្លាភាព* (Risteska et al., 2010) *។*

**សេចក្តីសន្និដ្ឋាន (អ្នកសម្របសម្រួល)៖** អភិបាលកិច្ចល្អរួមមានបញ្ញត្តិសំខាន់ៗដូចជា ភាពជាអ្នកដឹកនាំល្អ ការចូលរួមក្នុងសហគមន៍ តម្លាភាព កិច្ចសហប្រតិបត្តិការល្អ យុទ្ធសាស្ត្រ ចក្ខុវិស័យសាលារៀន ការទទួលខុសត្រូវ ការប្រើប្រាស់ធនធានប្រកបដោយតម្លាភាព គ្មានអំពើពុករលួយក្នុងសាលា

រៀន គណនេយ្យភាពការងាររបស់បុគ្គលិកសាលារៀនទាំងអស់ចំពោះមាតាបិតា និងសហគមន៍ ដើម្បីធានានូវសេវាកម្មអប់រំប្រកបដោយគុណភាព។

អ្នកសម្របសម្រួលបន្តពន្យល់ថា ការក្លាយជាអ្នកដឹកនាំល្អ និងមានភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាព អាចជាចំណុចចាប់ផ្ដើមចេញពីអភិបាលកិច្ចល្អនៅសាលារៀន។
អ្នកសម្របសម្រួលបន្តដោយណែនាំអ្នកចូលរួមឱ្យគិត៖

- តើភាពជាអ្នកដឹកនាំមានន័យយ៉ាងណាចំពោះអ្នក?
- នៅពេលណាដែលអ្នកបានឃើញឧទាហរណ៍នៃភាពជាអ្នកដឹកនាំដ៏មានប្រសិទ្ធភាព ហើយតើលក្ខណៈនេះដូចអ្នកដែរឬទេ?
- តើអ្នកបានឃើញគំរូនៃភាពជាអ្នកដឹកនាំដែលបរាជ័យនៅពេលណា ហើយតើលក្ខណៈនេះមើលទៅដូចអ្នកដែរឬទេ?

អ្នកសម្របសម្រួលចែកឯកសារ ៨.៥៖ *អ្នកដឹកនាំល្អ និងអ្នកដឹកនាំខ្សោយ* ហើយពន្យល់ពីសកម្មភាព។ សុំឱ្យអ្នកចូលរួមត្រូវឆ្លុះបញ្ចាំងដោយធ្វើការជាដៃគូអំពីលក្ខណៈនៃអ្នកដឹកនាំដ៏អស្ចារ្យ និងអ្នកដឹកនាំខ្សោយ។
*ចម្លើយចំពោះលំហាត់នៅក្នុងឯកសារ ៨.៥៖*

| អំណះអំណាង | អ្នកដឹនដនាំល្អ | អ្នកដឹនដនាំខ្សោយ |
|---|---|---|
| ពួកគេបើកចំហចំពោះគំនិតច្នៃប្រឌិត និងអ្វីដែលថ្មីៗ | X | |
| ពួកគេអាចមើលឃើញសក្ដានុពលនៅក្នុងមនុស្សម្នាក់ៗ | X | |
| ពួកគេគ្រប់គ្រងកិច្ចការតូចតាច | | X |
| ពួកគេមិនចូលចិត្តការផ្លាស់ប្ដូរ ហើយនឹងមិនព្រមទទួលយកហានិភ័យ | | X |
| ពួកគេចាប់តែកំហុសជាមួយអ្នកដទៃ | | X |
| ពួកគេស្វាគមន៍ការទំនាក់ទំនងបើកចំហ | X | |
| ពួកគេមានភាពវិជ្ជមាន ហើយតែងតែលើកទឹកចិត្តអ្នកដទៃ | X | |
| ពួកគេដឹងថាពេលណាត្រូវផ្ទេរសិទ្ធិ | X | |
| ពួកគេមានគំនិតអវិជ្ជមាន ហើយតែងតែបន្ទោសសមាជិកក្រុម | | X |
| ពួកគេមិនឱ្យតម្លៃលើគោលការណ៍តម្លាភាពទេ | | X |
| ពួកគេមិនខ្វល់ពីភាពរីកចម្រើនរបស់បុគ្គលទេ | | X |

**សំណួរឆ្លុះបញ្ចាំង (ក្នុងឯកសារ ៨.៥)**

- តាមគំនិតរបស់អ្នក តើអ្វីជាភាពខុសគ្នាដ៏សំខាន់បំផុតរវាងអ្នកដឹកនាំដ៏ពូកែ និងអ្នកដឹកនាំខ្សោយ?
- តាមបទពិសោធន៍របស់អ្នក តើគំរូមួយណាដែលអ្នកបានឃើញសម្រាប់អ្នកដឹកនាំដ៏ពូកែ? តើអ្នកបានឃើញមានលក្ខណៈអ្វីខ្លះ?
- តាមបទពិសោធន៍របស់អ្នក តើគំរូមួយណាដែលអ្នកបានឃើញសម្រាប់អ្នកដឹកនាំខ្សោយ? តើអ្នកបានឃើញលក្ខណៈអ្វីខ្លះ?

**លទ្ធភាពនៃការសន្និដ្ឋាន (សម្រាប់អ្នកសម្របសម្រួល)៖** អ្នកដឹកនាំល្អបំផុតគំនិតឱ្យមនុស្សរីកចម្រើន មានការគាំទ្រ និងច្នៃប្រឌិត ហើយផ្តល់ការទទួលស្គាល់ចំពោះការរួមចំណែករបស់បុគ្គលិក។ លក្ខណៈទាំងអស់នេះចាំបាច់ក្នុងការលើកកម្ពស់កិច្ចសហការ និងការគាំទ្របរិស្ថានក្នុងសាលារៀន។

## តើភាពជាអ្នកដឹកនាំល្អត្រូវបានភ្ជាប់ដោយផ្ទាល់ជាមួយនឹងគុណភាពនៃការបង្រៀន និងការរៀនយ៉ាងដូចម្តេច?

អ្នកសម្របសម្រួលចាប់ផ្តើមពន្យល់ថា ការស្រាវជ្រាវមួយចំនួនបង្ហាញថា ការកែលម្អគុណភាពនៃការបង្រៀន និងរៀនគឺអាស្រ័យទៅលើគុណភាពនៃភាពជាអ្នកដឹកនាំ។ អ្នកចូលរួមត្រូវបានណែនាំឱ្យឆ្លុះបញ្ចាំងលើតំណភ្ជាប់ប្រធានបទនេះ ដោយសង្កេតមើលការអនុវត្តល្អៗរបស់សាលារៀនផ្សេងៗទៀត។

អ្នកសម្របសម្រួលណែនាំវីដេអូបន្ទាប់នោះគឺអំពីសាលារៀនគំរូ បំណិនជីវិតតាមមូលដ្ឋាន ចំនួនពីរ មួយនៅខេត្តតាកែវ និងមួយទៀតនៅខេត្តសៀមរាប។ យើងបានសុំឱ្យថ្នាក់ដឹកនាំពន្យល់យើងវិញថា តើលក្ខណៈអ្នកដឹកនាំល្អមានអ្វីខ្លះ ហើយតើភាពជាអ្នកដឹកនាំល្អនឹងផ្តល់ឥទ្ធិពលអ្វីដែរដល់បរិយាកាសសាលារៀន និងការសិក្សារបស់សិស្ស។ ពន្យល់អ្នកចូលរួមថាពួកគេត្រូវស្តាប់ដោយយកចិត្តទុកដាក់។ បន្ទាប់ពីវីដេអូនឹងមានសំណួរមួយចំនួនដើម្បីពិភាក្សាអំពីចំណុចសំខាន់ដែលបង្ហាញក្នុងវីដេអូ។

**វីដេអូទី៨.១** អ្នកដឹកនាំល្អ វីដេអូពីនាយក និងនាយករងមកពីអនុវិទ្យាល័យថ្មស និងអនុវិទ្យាល័យ ហ៊ុនសែន រលួស។

**សំណួរបំផុស (សម្រាប់ការពិភាក្សាវីដេអូ)**

- តើអ្វីទៅជាលក្ខណៈរបស់អ្នកដឹកនាំល្អសម្រាប់អ្នកសម្ភាសន៍?
- តើអ្វីជាអាទិភាពរបស់អ្នកដឹកនាំល្អចេញពីខ្សែវីដេអូ?

- តើទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំល្អ និងការបង្រៀន និងការរៀនប្រកបដោយគុណភាពមានអ្វីខ្លះ?
- តើបញ្ហាប្រឈមអ្វីខ្លះដែលអ្នកដឹកនាំអាចប្រឈម និងដំណោះស្រាយដែលអាចកើតមាន?
- តើពួកគេមានយោបល់អ្វីខ្លះដើម្បីក្លាយជាអ្នកដឹកនាំដ៏ល្អ?

ជាចុងក្រោយ អ្នកសម្របសម្រួលនិយាយទៅកាន់អ្នកចូលរួមថា នៅក្នុងគោលនយោបាយសកម្មភាពវិជ្ជាជីវៈគ្រូបង្រៀនឆ្នាំ២០២៤-៣០ ដែលបានធ្វើបច្ចុប្បន្នភាពបានកំណត់ចំណុចយុទ្ធសាស្ត្រចំនួន៤។ ចំណុចយុទ្ធសាស្ត្រទី២ **គឺការប្រែក្លាយជាភាពជាអ្នកដឹកនាំ៖**

ភាពប្រែក្លាយជាអ្នកដឹកនាំផ្តោតលើអ្នកដឹកនាំផ្តល់ការអប់រំ តាមរយៈការអនុវត្តប្រកបដោយភាពច្នៃប្រឌិត និងរួមបញ្ចូលការពង្រឹងស្វ័យភាព ពង្រីក និងលើកកម្ពស់ផលប្រយោជន៍របស់បុគ្គលិក បង្កើតការយល់ដឹង និងការទទួលយកគោលបំណង និងបេសកកម្មនៃការអប់រំ និងជំរុញបុគ្គលិករបស់ពួកគេឱ្យមើលទៅហួសពីខ្លួនឯង ដើម្បីជាប្រយោជន៍ដល់អ្នកដែលទទួលផល។ ភាពផ្លាស់ប្រែជាអ្នកដឹកនាំត្រូវបានគាំទ្រតាមរយៈកម្មវិធី CPD។

TPAP 2024-2030: https://sala.moeys.gov.kh/library/65726b8aa1e8078f763b1593




អ្នកសម្របសម្រួលបញ្ចប់ដោយសង្ខេបនូវបញ្ញត្តិសំខាន់ៗទាក់ទងនឹងការផ្សារភ្ជាប់គ្នារវាងភាពជាអ្នកដឹកនាំល្អ និងគុណភាពការបង្រៀន និងការរៀន៖

- **ចក្ខុវិស័យ និងគោលដៅ៖** អ្នកដឹកនាំប្រកបដោយប្រសិទ្ធភាពបង្កើតចក្ខុវិស័យ និងគោលដៅច្បាស់លាស់សម្រាប់ស្ថាប័ន ដោយផ្តល់ទិសដៅ និងគោលបំណងសម្រាប់ការបង្រៀន និងរៀន។
- **កិច្ចគាំទ្រ និងធនធាន៖** អ្នកដឹកនាំល្អផ្តល់ការគាំទ្រ និងធនធានចាំបាច់ដល់គ្រូ និងសិស្សអនុញ្ញាតឱ្យពួកគេចែករំលែក និងចូលរួមក្នុងការបង្រៀន និងការរៀនប្រកបដោយគុណភាពខ្ពស់។

- **ការសហការ និងសហគមន៍សិក្សាវិជ្ជាជីវៈ៖** អ្នកដឹកនាំជំរុញឱ្យមានវប្បធម៌នៃការសហការគ្នាក្នុងចំណោមគ្រូបង្រៀន លើកទឹកចិត្តឱ្យមានការចែករំលែកការអនុវត្តល្អប្រសើរ និងបង្កើនវិជ្ជាជីវៈ ជួយពង្រឹងយុទ្ធសាស្ត្របង្រៀន និងការអភិវឌ្ឍកម្មវិធីសិក្សា។
- **គណនេយ្យភាព និងការវាយតម្លៃ៖** អ្នកដឹកនាំបង្កើតប្រព័ន្ធសម្រាប់គណនេយ្យភាព និងការវាយតម្លៃ កំណត់ការរំពឹងទុកសម្រាប់គ្រូបង្រៀន ការផ្តល់មតិកែលម្អ និងការប្រើប្រាស់ទិន្នន័យដើម្បីកែលម្អការបង្រៀន និងការរៀនជាប្រចាំ។
- **វប្បធម៌សាលារៀនវិជ្ជមាន៖** អ្នកដឹកនាំល្អបង្កើតវប្បធម៌សាលារៀនប្រកបដោយភាពវិជ្ជមាន ជំរុញឱ្យមានសេចក្តីស្រឡាញ់ចំពោះការសិក្សា បរិយាប័ន្ន និងការគោរពគ្នាទៅវិញទៅមក បង្កើតបរិយាកាសអំណោយផលដល់ការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព។

វាជារឿងសំខាន់ គេត្រូវកត់សម្គាល់ថា ទោះបីជាការដឹកនាំល្អមានសារៈសំខាន់ក៏ដោយ កត្តាផ្សេងទៀតដូចជា ជំនាញគ្រូ ការរចនាកម្មវិធីសិក្សា ការលើកទឹកចិត្តសិស្ស និងការចូលរួមរបស់មាតាបិតា ក៏រួមចំណែកដល់គុណភាពអប់រំទាំងមូលផងដែរ។

## ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព

*"សាលារៀនដែលមានភាពខ្លាំង គេប្រើធនធានជាយុទ្ធសាស្ត្រដើម្បីសម្រេចបាននូវការផ្តល់សេវាកម្មប្រកបដោយគុណភាពខ្ពស់ និងជួលបង្កើនលទ្ធផលសិក្សារបស់សិស្ស"*

ដូចដែលយើងបានណែនាំខាងលើ ការប្រើប្រាស់ធនធានក្នុងសាលារៀនប្រកបដោយប្រសិទ្ធភាព រួមចំណែកក្នុងការផ្តល់នូវការបង្រៀន និងការរៀនប្រកបដោយគុណភាព។ ប៉ុន្តែតើធនធានរបស់សាលារៀនមានអ្វីខ្លះ?

អ្នកសម្របសម្រួលឱ្យអ្នកចូលរួមរាយបញ្ជីពីអ្វីដែលធនធានដែលពួកគេមាននៅក្នុងសាលារៀនរបស់ពួកគេ ហើយពិពណ៌នាដោយសង្ខេបធនធានទាំងនោះចែកជាក្រុម ដើម្បីបង្ហាញពីប្រភេទធនធានផ្សេងៗដែលមាននៅក្នុងសាលារៀន និងក្នុងសហគមន៍៖

- **ធនធានរូបវន្ត៖** សៀវភៅ សម្ភារបង្រៀននិងរៀន មន្ទីរពិសោធ បណ្ណាល័យ ហេដ្ឋារចនាសម្ព័ន្ធ
- **ធនធានមនុស្ស៖** គ្រូបង្រៀន នាយក បុគ្គលិករដ្ឋបាល (ឧទាហរណ៍ បណ្ណារក្ស) សហគមន៍
- **ធនធានហិរញ្ញវត្ថុ៖** មូលនិធិ ផែនការកែលម្អយុទ្ធសាស្ត្រ ការផ្តល់មូលនិធិពីភ្នាក់ងារខាងក្រៅ ការបរិច្ចាគរបស់សហគមន៍

ធនធានយុទ្ធសាស្ត្រគឺជាការរៀបចំគោលដៅនៃធនធានឱ្យត្រូវនឹងគំនិតផ្តួចផ្តើមរបស់សាលារៀន ដើម្បីធានាបាននូវផលជះទៅឥទ្ធិពលជាអតិបរមាលើលទ្ធផលសិក្សារបស់សិស្ស។

ផែនការយុទ្ធសាស្ត្រការអភិវឌ្ឍសាលារៀនហៅកាត់ថា (SIPs) របស់សាលារៀន កំណត់អំពីបុគ្គលិកសាលារៀន និងធនធានផ្សេងទៀតដែលត្រូវការដើម្បីសម្រេចបាននូវផលជះដែលចង់បាន។ សាលារៀនរបស់អ្នកគួរតាមដាន និងកែតម្រូវការបែងចែកធនធានជាប្រចាំដើម្បីធានាការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃផែនការយុទ្ធសាស្ត្រការអភិវឌ្ឍសាលារៀន (SIPs)។

**តើការប្រើប្រាស់ធនធានមានប្រសិទ្ធភាពមានន័យយ៉ាងដូចម្តេច?**

អ្នកសម្របសម្រួលចែកជូនឯកសារ ៨.៦៖ សេណារីយ៉ូរបស់សាលារៀនបឋមសិក្សាភ្នាក់ ហើយពន្យល់ករណីសិក្សានេះ និងពិពណ៌នាអំពីសកម្មភាពដែលសាលារៀនអាចធ្វើដើម្បីគ្រប់គ្រងធនធានរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

**មេរៀន៖** ការងារជាដៃគូ

**រយៈពេលផ្តល់៖** ៣០នាទី

**សេចក្តីណែនាំ**

- អានដោយប្រុងប្រយ័ត្ននូវករណីសិក្សាខាងក្រោម
- ឆ្លើយសំណួរ
- គំរូ៖ ធ្វើការជាដៃគូ

អ្នកសម្របសម្រួលចែកឯកសារ ៨.៧៖ បញ្ជីត្រួតពិនិត្យការគ្រប់គ្រងធនធាន និងពន្យល់អ្នកចូលរួមថា ឯកសារនេះជាឯកសារយោងដល់ពួកគេ នៅពេលពួកគេត្រឡប់ទៅសាលារៀនវិញ ដើម្បីពិនិត្យមើលថាខ្លួនបានបំពេញគ្រប់ដំណាក់កាលដើម្បីត្រួតពិនិត្យធនធានរបស់ពួកគេ។

*ការចូលរួមរបស់សហគមន៍*

*«នៅពេលដែលសាលារៀនសហការគ្នារៀបចំផែនការ អនុវត្តការចូលរួមរបស់មាតាបិតា និងក្រុមគ្រួសារ ធ្វើជាចេតនាយុទ្ធសាស្ត្រ សាលារៀនទទួលបានអត្ថប្រយោជន៍ និងរួមចំណែកផ្តល់ចំណេះដឹងបទពិសោធន៍ សមត្ថភាព និងបណ្តាញគ្រួសារដល់ក្រុមគ្រួសារទាំងនោះ។ សរុបមកនេះបង្កើនការរៀនសូត្រពេញមួយជីវិត និងពង្រឹងសហគមន៍»[3]*

អ្នកសម្របសម្រួលណែនាំអំពីបញ្ញត្តិដែលថា ការចូលរួមរបស់សហគមន៍គឺជាធាតុសំខាន់មួយដើម្បីកែលម្អសាលារៀន និងធានាឱ្យមានការសិក្សាកាន់តែប្រសើរឡើងសម្រាប់សិស្ស។ តាមពិតសហគមន៍អាចគាំទ្រសាលារៀនបានតាមរបៀបផ្សេងៗ។

[3] ដកស្រង់ពី “Key Driver of Leadership Effectiveness: Community Engagement” , NSW Department of Education © 2022 NSW Department of Education - School Leadership Institute.

ភាពជាអ្នកដឹកនាំសាលារៀន និងសមាជិកសហគមន៍ដដែក និងស្តាប់យោបល់ពីសមាជិកសហគមន៍។



សហគមន៍ចូលរួមក្នុងសកម្មភាព ដើម្បីធ្វើឱ្យសាលារៀន និងការសិក្សាកាន់តែប្រសើរ។

អ្នកសម្របសម្រួលណែនាំ**បញ្ញត្តិនៃអត្ថប្រយោជន៍ទៅវិញទៅមក** ទាំងសាលា និងសហគមន៍អាចទទួលបានអត្ថប្រយោជន៍ពីទំនាក់ទំនងរបស់ពួកគេ៖

"ហេតុអ្វីបានជាអ្នកគិតថាការចូលរួមរបស់សហគមន៍អាចជួយទាំងសាលារៀន និងសហគមន៍?

**ចម្លើយរំពឹងទុក**

- កសាងទំនុកចិត្ត និងទំនាក់ទំនងគាំទ្រ។
- គាំទ្រការអប់រំដល់កុមារ និងយុវជនទាំងអស់។
- នាំសហគមន៍រួមគ្នាជួយសាលារៀន។
- ជួយស្វែងរកមធ្យោបាយដើម្បីរក្សាសុវត្ថិភាពសិស្ស និងគ្រូ។
- គាំទ្រការសិក្សារបស់សិស្ស។

## តើយើងកសាងទំនុកចិត្តជាមួយសហគមន៍ដោយរបៀបណា?

ការជឿទុកចិត្តអាចជាជំហានដំបូងក្នុងការបង្កើតទំនាក់ទំនងណាមួយ ហើយទំនាក់ទំនងរវាងសាលារៀន និងសហគមន៍មិនមែនជាករណីលើកលែងនោះទេ។

ដើម្បីណែនាំបញ្ញត្តិនៃការជឿទុកចិត្ត អ្នកសម្របសម្រួលសួរអ្នកចូលរួម៖ "**តើអ្វីបានជាអ្នកជឿទុកចិត្តមនុស្ស?**" អ្នកសម្របសម្រួលលើកទឹកចិត្តអ្នកចូលរួមឱ្យគិតពីនរណាម្នាក់ដែលពួកគេពិតជាជឿទុកចិត្ត អាចជានរណាម្នាក់នៅក្នុងគ្រួសារ មិត្តភក្តិ មិត្តរួមការងារ។ តើបុគ្គលនេះទទួលបានការទុកចិត្តពីអ្នកដោយរបៀបណា?»

អ្នកសម្របសម្រួលបន្ត៖ «ឥឡូវនេះ គិតពីនរណាម្នាក់ដែលអ្នកគ្មានទំនុកចិត្តអ្វីសោះ ហើយព្យាយាមគិតពីហេតុផលដែលអ្នកមិនទុកចិត្តពួកគេ»។

អ្នកសម្របសម្រួលលើកទឹកចិត្តអ្នកចូលរួមឱ្យចែករំលែកគំនិតរបស់ពួកគេ ហើយសរសេរវានៅក្នុងផ្ទាំងរូបភាព (ដូចឧទាហរណ៍ខាងក្រោម)។

ចម្លើយរំពឹងទុក (សម្រាប់អ្នកសម្របសម្រួល)៖

| ទុកចិត្ត | មិនទុកចិត្ត |
|---|---|
| ស្ដាប់ដោយយកចិត្តទុកដាក់ | មិនស្ដាប់ |
| រក្សាការសន្យារបស់គាត់ | មិនរក្សាការសន្យា |
| សកម្មភាពត្រូវនឹងពាក្យ | មិនធ្វើដូចដែលបាននិយាយ |
| ទុកជាឯកជន | គ្មានឯកជនភាពទេ |
| តម្លាភាព | មិនច្បាស់លាស់ ឬគ្មានតម្លាភាពក្នុងទង្វើ |

**សេចក្ដីសន្និដ្ឋាន៖** គេត្រូវការពេលវេលាដើម្បីកសាងទំនុកចិត្ត ហើយចំណុចនេះកើតឡើងលុះត្រាតែទាំងនាយកសាលា គ្រូបង្រៀន និងសហគមន៍អនុវត្តអាកប្បកិរិយាសមស្របមួយចំនួន។ ធ្វើបែបនេះមានសុពលភាពនៅគ្រប់ប្រភេទទំនាក់ទំនង ហើយសហគមន៍សាលារៀនមិនមែនជាករណីមិនខុសពីគេនោះទេ។

**ការតាំងពិព័រណ៍ស្នាដៃរបស់សិស្ស និងទិវាជួបមាតាបិតា** គឺជាមធ្យោបាយប្រកបដោយតម្លាភាព និងប្រសិទ្ធភាពក្នុងការបង្ហាញដល់មាតាបិតានូវការងារដែលបានធ្វើជាមួយសិស្សក្នុងឆ្នាំសិក្សា និងបង្កើតការជឿទុកចិត្ត។ រូបថតខាងក្រោមបង្ហាញពីការតាំងពិព័រណ៍នៅសាលារៀនជំនាន់ថ្មីនៃវិទ្យាល័យសម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ព្រែកអញ្ចាញ នៅក្នុងខែកញ្ញា ឆ្នាំ២០២២។ សិស្សានុសិស្សមានលទ្ធភាពបង្ហាញមាតាបិតាអំពីការងារដែលបានធ្វើនៅក្នុងថ្នាក់រៀន ធ្វើឱ្យមាតាបិតាមានមោទនភាព និងទំនុកចិត្តលើគុណភាពនៃការសិក្សានៅក្នុងសាលារៀន។



ជាចុងក្រោយ អ្នកសម្របសម្រួលណែនាំវីដេអូដែលអ្នកចូលរួមស្តាប់ដោយផ្ទាល់ពីតួសម្តែងអំពីរបៀបដែលពួកគេគ្រប់គ្រងការកសាងទំនាក់ទំនងរបស់ពួកគេជាមួយសហគមន៍។

**វីដេអូទី ៨.២** ការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលារៀន (ពីអនុវិទ្យាល័យ ថ្មសរ និងអនុវិទ្យាល័យ ហ៊ុនសែន រលួស)។

អ្នកសម្របសម្រួលរំឭកឡើងវិញពីពាក្យគន្លឹះ និងភ្ជាប់ជាមួយនឹងអ្វីដែលបានពិភាក្សាក្នុងអំឡុងពេលមេរៀនទាំងមូល។ សង្កត់ធ្ងន់ថាទាំងនេះគឺជាឧទាហរណ៍ពីសាលារៀនដោយបង្ហាញថាគេធ្វើបាន។

**បញ្ចប់មេរៀនទី៨**

# មេរៀនទី៩៖ យន្តការគាំទ្រគ្រូបង្រៀន និងនាយក នាយិកាសាលារៀន

រយៈពេលមេរៀន៖ បង្រៀន ៥ម៉ោង (បន្ថែម ១០ម៉ោង ស្វ័យសិក្សា ការហាត់សម និងអនុវត្ត)

សកម្មភាពអ្នកសម្របសម្រួលគួរត្រៀម៖

- ពិនិត្យមើលស្លាយទាំងអស់ (PPT) សម្រាប់មេរៀននីមួយៗរួមទាំងវត្ថុបំណងសិក្សា
- ថតចម្លងឯកសារ

ធនធាន និងសម្ភារៈ

- ស្លាយ (PPT) កុំព្យូទ័រ ម៉ាស៊ីនបញ្ចាំងស្លាយ
- ថតចម្លងសកម្មភាព កិច្ចការ ឬគម្រោងអនុវត្តទាំងអស់ (ផ្នែកទន់ និងផ្នែករឹង)
- ក្រដាស A4 និងប៊ិក
- ថតចម្លងឯក**សារចែក ៩.១៖** វង្វាយតម្លៃចំណេះដឹងរបស់អ្នកស្តីពីការសិក្សាវិជ្ជាជីវៈជាប្រចាំ
- ថតចម្លង**ឯកសារចែក៩.២៖** ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលត្រូវពិចារណាសម្រាប់សាលារៀនរបស់អ្នក
- ថតចម្លង**ឯកសារចែក៩.៣៖** ការបង្កើតប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមួយដោយជោគជ័យ
- ថតចម្លង**ឯកសារចែក ៩.៤៖** ការវាយតម្លៃទទួលស្គាល់
- ថតចម្លងនៃក្របខណ្ឌការងារ CPD ក្របខណ្ឌផែនការគន្លងអាជីពគ្រូបង្រៀន សេចក្តីណែនាំ PLC (ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២១)
- ថតចម្លងឯកសារផែនការសកម្មភាពវិជ្ជាជីវៈគ្រូបង្រៀនឆ្នាំ២០២៤-៣០
- តេស្តខ្លីៗផ្នែកទី៣

វត្ថុបំណងសិក្សា៖

ពេលបញ្ចប់មេរៀនទី៩ អ្នកចូលរួមនឹងអាច៖

- យល់ដឹងពីគំរូផ្សេងគ្នាសម្រាប់លើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀននៅតាមសាលារៀន
- រៀបរាប់ពីប្រភេទផ្សេងគ្នានៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD)
- កំណត់ភាពពាក់ព័ន្ធគ្នាអាចធ្វើទៅបានរវាង PLC និងការប្រឹក្សាជាផ្នែកមួយនៃ (CPD)
- ពន្យល់ពីអ្វីដែលជាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ(CPD)មានបំណងសម្រាប់ និងលក្ខខណ្ឌសំខាន់ៗ

ការឆ្លុះបញ្ចាំង និងការអនុវត្តទ្រឹស្ដីផ្សារភ្ជាប់ទៅនិងការអនុវត្តជាក់ស្ដែងនៅកន្លែងធ្វើការ៖ អ្នកចូលរួមនឹងមាន៖

- ឆ្លុះបញ្ចាំងពីសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ(CPD) នៅតាមសាលារៀន
- ឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD) និងការគ្រប់គ្រងតាមសាលារៀន
- ឆ្លុះបញ្ចាំងការអនុវត្តនៃការប្រឹក្សាគរុកោសល្យនៅកម្រិតសាលារៀន
- ពិភាក្សាសកម្មភាព PLC នៅក្នុងសាលារៀន ដើម្បីឱ្យត្រូវគ្នានឹងតម្រូវការគ្រូបង្រៀន

ធនធានឯកសារចុងក្រោយសម្រាប់ការអានបន្ថែម

- ឯកសារ PLC (ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២១)
- សៀវភៅការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ(CPD) ឆ្នាំ២០២១
- ឯកសារណែនាំស្ដីពីគន្លងអាជីពគ្រូបង្រៀន
- គេហទំព័រ CPD ៖ http://cpd.moeys.gov.kh/course
- ក្រសួងអប់រំ យុវជន និងកីឡា (ឆ្នាំ២០១៦)៖ ព័ត៌មានត្រឡប់ឯកសារបំណិនជីវិតតាមមូលដ្ឋានជាភាសាខ្មែរ English Version; Khmer Version

# ផែនការបណ្តុះបណ្តាល-មេរៀនទី៩

## ពិនិត្យមើលគោលបំណងមេរៀន

បិទក្រដាសផ្ទាំងធំមួយសន្លឹកនៅលើក្តារខៀន ដោយសង្ខេបលទ្ធផលសិក្សានៅក្នុងមេរៀន។ ពន្យល់អ្នកចូលរួមអំពីលទ្ធផលនេះ និងកិច្ចការដែលពួកគេអាចធ្វើបានពេលរៀនចប់។

## ការវាយតម្លៃចំណេះដឹងចំពោះការបន្តអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

អ្នកសម្របសម្រួលគួរចាប់ផ្តើមប្រធានបទនេះ ដោយឱ្យអ្នកចូលរួមធ្វើតេស្តវាយតម្លៃខ្លួនឯង ស្តីពីចំណេះដឹងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ លំហាត់នេះគ្រាន់តែជួយឱ្យអ្នកសម្របសម្រួលដឹងថាខ្លួនត្រូវចំណាយរយៈពេលប៉ុន្មានដើម្បីពន្យល់បញ្ញត្តិ និងវាក្យសព្ទផ្សេងៗក្នុងមេរៀន។ ចែកឯកសារ ៩.១៖ *វាយតម្លៃចំណេះដឹងរបស់អ្នកអំពីបញ្ញត្តិ និងដំណើរការបន្តអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ* ទៅដល់អ្នកចូលរួម ហើយឱ្យពួកគេបំពេញឯកសារនេះរៀងៗខ្លួនក្នុងក្រុម។ សូមរំឭកពួកគេថា ត្រូវឆ្លើយដោយស្មោះត្រង់ក្នុងការបំពេញកិច្ចការនេះ។ សូមទុកពេលឱ្យអ្នកចូលរួមពី ៥នាទី ទៅ ១០នាទីដើម្បីធ្វើលំហាត់នេះ។ នៅពេលដល់ម៉ោងឱ្យអ្នកចូលរួមដាក់ពិន្ទុតេស្តស្វ័យវាយតម្លៃដោយខ្លួនឯង ហើយប្រាប់ពិន្ទុសរុបទៅប្រធានក្រុម។ ប្រធានក្រុមធ្វើមធ្យមភាគពិន្ទុទាំងអស់ ហើយរាយការណ៍ទៅអ្នកសម្របសម្រួល ដែលកត់ទុកក្នុងសៀវភៅដោយស្ងៀមស្ងាត់ មិនឱ្យក្រុមផ្សេងទៀតដឹងពីពិន្ទុមធ្យមភាគនេះទេ។ លំហាត់នេះ គ្រាន់តែជួយដល់អ្នកសម្របសម្រួលឱ្យយល់កាន់តែច្បាស់ ថាតើអ្នកចូលរួមបានយល់បញ្ញត្តិការបន្តអភិវឌ្ឍវិជ្ជាជីវៈបានកម្រិតណា។ ពិន្ទុមធ្យមភាគនៃការវាយតម្លៃនេះគឺ ៩ ហើយពិន្ទុខ្ពស់បំផុត១៤ និងទាបបំផុត៤។ ពិន្ទុមធ្យមណាមួយដែលមាន៩ ឬខ្ពស់ជាងនេះ

បង្ហាញពីការយល់ដឹងពីកម្រិតមធ្យមទៅកម្រិតខ្លាំងអំពីបញ្ញត្តិការបន្តអភិវឌ្ឍវិជ្ជាជីវៈ តែបើបានពិន្ទុទាបជាង៩ នឹងត្រូវចាត់ទុកថា ការយល់ដឹងរបស់អ្នកចូលរួមនៅខ្សោយ ឬខ្សោយខ្លាំង។ បន្ទាប់ធ្វើតេស្តនេះចប់ ចូរពិនិត្យត្រួសៗឡើងវិញនូវចំណុចសំខាន់ដែលមាននៅក្នុងសំណួរក្នុងតេស្ត (ឧទាហរណ៍ ក្រសួងអប់រំណែនាំថា មានគន្លងអាជីព៣។ ក្រសួងអប់រំកំណត់ប្រព័ន្ធបន្តអភិវឌ្ឍវិជ្ជាជីវៈប្រចាំនៅគ្រប់សាលារៀន)។ អ្នកសម្របសម្រួលត្រូវបង្ហាញឯកសារក្របខ័ណ្ឌការបន្តអភិវឌ្ឍវិជ្ជាជីវៈ និងឯកសារក្របខណ្ឌគន្លងអាជីពគ្រូ ដូច្នេះបើអ្នកចូលរួមណាមិនទាន់មានត្រូវថតចម្លងមួយច្បាប់។




អ្នកសម្របសម្រួលបន្តបង្ហាញក្រាហ្វិកខាងក្រោម ហើយចាប់ផ្តើមពន្យល់ពីធាតុផ្សំជាច្រើនដែលរួមចំណែកដល់ក្របខណ្ឌការងារ CPD នៅក្នុងសាលារៀន **ឯកសារទី៩.២៖** *ក្របខណ្ឌការងារ CPD នៅសាលារៀន។*

**ចំណុចសំខាន់សម្រាប់ពិភាក្សា**

- គោលដៅចុងក្រោយនៃប្រព័ន្ធបន្តអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ គឺធ្វើឱ្យប្រសើរឡើងនូវការសិក្សារបស់សិស្ស
- ក្រោមអភិក្រម SBM សាលារៀនមានសិទ្ធិកំណត់ខ្លឹមសារដំណើរការការបន្តអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលបានលើកឡើង
- សាលារៀនមិនចាំបាច់ប្រើរចនាសម្ព័ន្ធទាំងអស់ដែលមាននៅក្នុងដ្យាក្រាម យកទៅរៀបចំប្រព័ន្ធបន្តអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនោះទេ ប៉ុន្តែយ៉ាងហោចណាស់ក៏ត្រូវមានចំណុចមួយចំនួនជាពិសេស ក្រុមបច្ចេកទេសគ្រូ និងគណៈកម្មការរៀបចំការបន្តអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅតាមសាលារៀន។

## សកម្មភាពការបន្តអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលត្រូវពិចារណាសម្រាប់សាលារៀនរបស់អ្នក

អ្នកសម្របសម្រួលគួរចាប់ផ្តើមប្រធានបទបន្ទាប់នៅក្នុងមេរៀននេះ ដោយពន្យល់ថា មានសកម្មភាពជាក់លាក់ជាច្រើនដែលសាលារៀនអាចអនុវត្តនៅពេលចាប់ផ្តើមរៀបចំកម្មវិធីវិក្រឹតការ កំណត់នូវអ្វីដែលគ្រូអាចធ្វើបាន និងរៀនដើម្បីកែលម្អប្រកបដោយវិជ្ជាជីវៈជាប្រចាំ។ ថ្មីៗនេះក្រសួងអប់រំ យុវជន និងកីឡា បានកែសម្រួលឡើងវិញនូវផែនការសកម្មភាពវិជ្ជាជីវៈគ្រូបង្រៀន ឆ្នាំ២០២៤-៣០ ហើយយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រទាំងបួនគឺ **អត្តសញ្ញាណគ្រូបង្រៀន** និងការអភិវឌ្ឍដែលនឹងជាឯកសារយោងរបស់យើងសម្រាប់ការឆ្លុះបញ្ចាំងដែលយើងនឹងធ្វើនៅវគ្គនេះ។

"**សកម្មភាពយុទ្ធសាស្ត្រទី៤៖** អត្តសញ្ញាណ និងការអភិវឌ្ឍរបស់គ្រូបង្រៀនផ្តោតលើការលើកកម្ពស់អត្តសញ្ញាណ គុណតម្លៃ និងវិជ្ជាជីវៈរបស់គ្រូបង្រៀន។ គ្រូបង្រៀនត្រូវតែទទួលស្គាល់អត្តសញ្ញាណ និងវិជ្ជាជីវៈរបស់ខ្លួន ហើយអភិវឌ្ឍវានៅក្នុងការអនុវត្តផ្ទាល់ ដែលគាំទ្រដោយការកែលម្អកម្រិតជីវភាពរស់នៅ តម្លៃវិជ្ជាជីវៈ ឋានៈ និងឋានៈសង្គម។ កម្មវិធីវិក្រឹត្តការ (INSET) ត្រូវតែបង្កប់នៅក្នុងជីវិតរស់នៅប្រកបដោយវិជ្ជាជីវៈរបស់គ្រូបង្រៀន និងការងារពិតជាក់ស្តែងរបស់ពួកគាត់។ គ្រូបង្រៀនត្រូវតែបានផ្តល់សិទ្ធិអំណាចក្នុងការរៀបចំ បកស្រាយ និងគ្រប់គ្រងកម្មវិធីសិក្សា និងផ្តល់អាទិភាពដល់ខ្លឹមសារ និងវិធីសាស្ត្រ។"

ប្រភព៖ TPAP 2024-2030: https://sala.moeys.gov.kh/library/65726b8aa1e8078f763b1593

ចែកឯកសារ ៩.៣៖ *សកម្មភាពនៃការបន្តអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដែលអាចយកទៅពិចារណាសម្រាប់សាលារៀនរបស់អ្នក* ដែលផ្តល់ឧទាហរណ៍នៃប្រភេទសកម្មភាពបន្តអភិវឌ្ឍ*វិជ្ជាជីវៈជាប្រចាំ* ដែលសាលារៀនអាចយកទៅប្រើប្រាស់នៅតាមសាលារៀនរបស់ខ្លួនបាន។ មើលសកម្មភាពនីមួយៗអាស្រ័យទៅលើការពន្យល់នៅទំព័រទី២ ក្នុងឯកសារ ដែលជួយឱ្យអ្នកចូលរួមអាចសួរសំណួរ។ នៅពេលអ្នកសម្របសម្រួលពិនិត្យសកម្មភាពចប់ចូររំឭកអ្នកចូលរួមថា នៅក្រោមអភិក្រម SBM សាលារៀនមានស្វ័យភាព និងឯករាជ្យភាពកំណត់យកសកម្មភាពណាមួយដែលគេចង់អនុវត្ត ដោយផ្អែកលើការវាយតម្លៃតម្រូវការរបស់ពួកគេ។ នៅតាមក្រុមតូចនីមួយៗ អ្នកសម្របសម្រួលត្រូវផ្តល់ក្រដាសផ្ទាំងធំឱ្យពួកគេធ្វើតារាងការបន្តអភិវឌ្ឍ*វិជ្ជាជីវៈជាប្រចាំ*(CPD)ដែលអនុវត្ត SBM នៅក្នុងសាលារៀនពួកគេដូចខាងក្រោម បំពេញវាទៅតាមបទពិសោធន៍កន្លងមក និងតម្រូវការដែលមាននៅពេលខាងមុខ។ ផ្តល់រយៈពេល២៥ ទៅ៣០នាទីដល់អ្នកចូលរួមសម្រាប់សកម្មភាពនេះ។

| គំរូសកម្មភាពលើកកម្ពស់ការបន្តអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | តើសាលារៀនរបស់អ្នកធ្លាប់បានអនុវត្តសកម្មភាពនេះដែរឬទេ? | | តើសាលារៀនរបស់អ្នកអាចធ្វើបានដែរឬទេ? | | តើត្រូវការថវិកាដើម្បីអនុវត្តដែរឬទេ? |
|---|---|---|---|---|---|
| | បាទ/ចាស | ទេ | បាទ/ចាស | ទេ | |
| 1. សកម្មភាពស្រាវជ្រាវ | | | | | |
| 2. សៀវភៅសិក្សា | | | | | |
| 3. ទស្សនកិច្ចសិក្សា | | | | | |
| 4. បង្វឹក | | | | | |
| 5. ធ្វើការជាមួយអង្គការសហគមន៍ | | | | | |
| 6. ធ្វើផែនទីកម្មវិធីសិក្សា | | | | | |
| 7. វិភាគទិន្នន័យសិស្ស | | | | | |
| 8. ជម្រុញដំណើរការបង្រៀន និងរៀន | | | | | |
| 9. ធ្វើផែនការកម្មវិធីសិក្សារួម | | | | | |
| 10. ការរក្សាទិនានុប្បវត្តិ | | | | | |
| 11. បណ្តាញប្រព័ន្ធផ្សព្វផ្សាយសង្គម | | | | | |
| 12. កម្មវិធីអភិវឌ្ឍវិជ្ជាជីវៈអនឡាញ | | | | | |
| 13. ការចូលរួមជាមួយស្ថាប័នវិជ្ជាជីវៈ | | | | | |
| 14. ការសិក្សាបន្ថែមនៅពេលវិស្សមកាល | | | | | |
| 15. ប្រធានក្រុមដឹកនាំបច្ចេកទេស | | | | | |

នៅពេលអ្នកចូលរួមបំពេញក្នុងតារាងម៉ាទ្រីសរួច ឱ្យពួកគេបិទក្រដាសផ្ទាំងធំនោះនៅលើក្ដារខៀន ដូច្នេះអាចមើលឃើញគ្រប់គ្នា។ បន្ទាប់មកអ្នកសម្របសម្រួលធ្វើសេចក្ដីសន្និដ្ឋានមួយចំនួនពីបទបង្ហាញតាមក្រុមដូចខាងក្រោម៖

**សេចក្ដីសន្និដ្ឋាន និងការសង្កេត**

- សន្និដ្ឋានថាមានក្រុម ឬអ្នកចូលរួមប៉ុន្មាននាក់បានអនុវត្តសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំពីមុនមក
- សន្និដ្ឋានថា តើក្រុមអាចគិតថា គេអាចអនុវត្តសកម្មភាពភាគច្រើនទាំងនេះ នៅតាមសាលារៀនរបស់ពួកគេ។ ប្រសិនបើពួកគេភាគច្រើននិយាយថា សកម្មភាពភាគច្រើនមិនអាចធ្វើបាន ចូររកមូលហេតុ? (ឧ. គ្មានធនធាន? គ្មានអ្នកដឹកនាំសកម្មភាព? គ្មានអ្នកជំនាញត្រូវធ្វើសកម្មភាព)
- សន្និដ្ឋានថាតើមានអ្នកចូលរួមប៉ន្មាននាក់ ឬប៉ុន្មានក្រុមគិតថា សកម្មភាពទាំងនេះ ត្រូវការថវិកាដើម្បីអនុវត្ត? ប្រសិនបើក្រុមជាច្រើននិយាយថា គេត្រូវការថវិកានៅពេលដែលមិនមានថវិកា (ឧ. បង្វឹក ឬរក្សាទិនានុប្បវត្តិ។ល។) ត្រូវប្រាកដថាហានជំនះធ្វើវា ប្រសិនបើត្រូវការថវិកាតិចតួច តើគេនៅតែថាធ្វើមិនបានមែនទេ។ល។

ពិនិត្យឡើងវិញលើសកម្មភាពទាំង៥ ដែលក្រុមនីមួយៗបានជ្រើសរើស ហើយសួរពួកគេហេតុអ្វីបានជ្រើសរើសសកម្មភាពនេះ(ឧ. ស្រួលធ្វើ មិនទាមទារថវិកា មានប្រយោជន៍ ដោះស្រាយបញ្ហាជាក់លាក់។ល។)

**ជំហានក្នុងការបង្កើតប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅកម្រិតសាលារៀន**

អ្នកសម្របសម្រួលណែនាំប្រធានបទនេះ ជាជំហានសំខាន់ដែលសាលារៀនគួរពិចារណាការបង្កើតប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅតាមសាលារៀនរបស់ពួកគេ។ សម្រាប់គោលបំណងនេះ ចូរចែក ឯកសារ ៩.៣៖ *ការបង្កើតប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំប្រកបដោយភាពជោគជ័យ។* អ្នកសម្របសម្រួលគួរសង្កត់ធ្ងន់ថា ក្នុងមេរៀនគេសង្ឃឹមថាអ្នកចូលរួមនឹងទទួលបានមគ្គុទេសក៏រឹងមាំចំពោះអ្វីដែលគេគួរធ្វើ នៅពេលត្រឡប់ទៅកាន់សាលារៀនរបស់ខ្លួន ដើម្បីធានាថា មានរចនាសម្ព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំបន្ថែមទៀតសម្រាប់លោកគ្រូ-អ្នកគ្រូ។

អ្នកសម្របសម្រួលពិនិត្យឡើងវិញនូវការណែនាំនីមួយៗ ដែលផ្ដល់ដូចខាងក្រោម ហើយសួរអ្នកចូលរួមថាតើពួកគេអាចអនុវត្តនៅតាមសាលារៀនរបស់ពួកគេបានឬយ៉ាងណា។ បើមិនបាន?ហេតុអ្វី? បើបាន?ហេតុអ្វី? តើមាននរណាខ្លះអាចជួយបាន? មានក្រុមខ្លះថាអាចអនុវត្តសកម្មភាពនេះបាន តែមានក្រុមខ្លះថាមិនអាច។ ហេតុអ្វីបានជាពួកគេគិតឃើញខុសគ្នា? ហេតុអ្វីមានសាលារៀនខ្លះធ្វើតាមការណែនាំនេះបាន តែសាលារៀនខ្លះមិនអាចធ្វើបាន?

| ជំហានដែលត្រូវអនុវត្តនៅពេលត្រឡប់ទៅមូលដ្ឋានសាលារៀនវិញ | |
|---|---|
| សំណើទី១៖ | ប្រមូលឯកសារសំខាន់ៗដែលមានប្រយោជន៍មួយចំនួន ដែលអាចធ្វើឱ្យអ្នកយល់កាន់តែច្បាស់លើក្របខណ្ឌគោលនយោបាយរបស់ក្រសួងអប់រំ ដែលទាក់ទងទៅនឹងប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ |
| សំណើទី២៖ | ជួបពិភាក្សាជាមួយបុគ្គលិកផ្នែកបង្រៀនសំខាន់ៗ នៅសាលារៀនរបស់អ្នក (ឧ. នាយករង អ្នកដឹកនាំក្រុមបច្ចេកទេស។ល។) ដើម្បីបង្កើនការយល់ដឹងរបស់គេស្តីពីបញ្ហាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ អ្នកអាចពិចារណាចម្លងមេរៀននេះឡើងវិញដោយប្រើឯកសារចែកជូន។ |
| សំណើទី៣៖ | បង្កើតគណៈកម្មការការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅតាមសាលារៀនរបស់អ្នកតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំស្តីអំពីក្របខណ្ឌការការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដោយរួមមានអ្នកដឹកនាំសំខាន់ៗក្នុងចំណោមគ្រូ។ ព្យាយាមធានាថាអ្នកដឹកនាំមានភាពស្វាហាប់បំផុតនៅក្នុងសាលារៀនដែលមានចំណេះដឹងខ្ពស់ផ្នែកគរុកោសល្យ ស្ថិតនៅក្នុងតួនាទីដឹកនាំនៅក្នុងគណៈកម្មការនេះ។ |
| សំណើទី៤៖ | អនុវត្តការវាយតម្លៃអំពីតម្រូវការដើម្បីកំណត់ពីតម្រូវការសមត្ថភាពសំខាន់ជាងគេនៅសាលារៀនរបស់អ្នកតាមរយៈការស្ទង់មតិ សម្ភាសន៍ និងមធ្យោបាយផ្សេងទៀត។ |
| សំណើទី៥៖ | លើកទឹកចិត្តគ្រូឱ្យឆ្ពោះទៅរកការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈ។ ចំណុចនេះមិនងាយស្រួលធ្វើទេ ពីព្រោះសហគមន៍សិក្សាវិជ្ជាជីវៈ មិនមែនជាគណៈកម្មការផ្លូវការ ឬជារចនាសម្ព័ន្ធ វាជាបណ្តាញគ្រូមិនផ្លូវការមួយ ដែលជួយគ្នាទៅវិញទៅមក ឬចែករំលែកឯកសារ។ ប៉ុន្តែយ៉ាងហោចណាស់សាលារៀនអាចចាប់ផ្តើមដំណើរការភ្ជាប់បណ្តាញគ្រូនៅក្នុងក្រុមបណ្តាញសង្គម ដោយមានគោលបំណងចែករំលែក និងបង្កើនទំនាក់ទំនងរវាងគ្រូបង្រៀន។ អនុក្រុមនានានឹងត្រូវបង្កើតនៅពេលក្រោយ។ ចូរអានសៀវភៅសហគមន៍សិក្សាវិជ្ជាជីវៈដែលបានរៀបរាងដោយក្រសួងអប់រំ ដើម្បីទទួលបានការណែនាំបន្ថែមអំពីការបង្កើតសហគមន៍បែបនេះនៅសាលារៀនរបស់អ្នក។ |
| សំណើទី៦៖ | កំណត់អ្នកផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅតាមផ្នែករបស់អ្នក ដែលអាចផ្តល់ការគាំទ្រវិក្រិតការ និងការសិក្សាអនឡាញ (ឧ. LNGOS, TTIs) ។ |
| សំណើទី៧៖ | ត្រូវប្រាកដថា បញ្ចូលថវិកាសម្រាប់សកម្មភាពគាំទ្រការការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅក្នុងផែនការកែលម្អសាលារៀនរបស់អ្នក។ |

## ដោះស្រាយបញ្ហាប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅតាមកម្រិតសាលារៀន

ប្រធានបទនៃមេរៀននេះព្យាយាមដាស់តឿនអ្នកចូលរួមថា ការបង្កើតប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅតាមកម្រិតសាលារៀនមិនងាយស្រួលទេ។ អ្នកសម្របសម្រួលគួរត្រឡប់ទៅមើលឯកសារ ៩.៤៖ ហើយពិនិត្យឡើងវិញនូវបញ្ហាដកស្រង់នៅទំព័រទី២ ដោយកត់សម្គាល់ថា ចំណុចទាំងនោះហើយគឺជាបញ្ហាដែលរារាំងប្រតិបត្តិការប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដែលត្រូវបានដកស្រង់ពីការស្រាវជ្រាវផ្នែកអប់រំ។ ពិនិត្យមើលបញ្ហាទាំងនេះម្តងមួយៗជាមួយអ្នកចូលរួម។

| បញ្ហាទូទៅក្នុងការបង្កើតប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | |
|---|---|
| **១. អាទិភាពទាប៖** គ្រូគ្រាន់តែផ្តោតលើថ្នាក់ឯកជនរបស់ពួកគេ និងការងារធម្មតាផ្សេងទៀតហើយផ្តល់អាទិភាពទាបលើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ | **៥. ភាពពាក់ព័ន្ធខ្សោយ៖** គ្រូពិតជាមើលមិនឃើញពីសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំពាក់ព័ន្ធគ្នានឹងបញ្ហាជាក់ស្តែង ឬភាពរីកចម្រើននៅសាលារៀន។ វាគ្រាន់តែជាបន្ទុកការិយាធិបតេយ្យបន្ថែមមួយដែលពួកគេត្រូវធ្វើដោយមិនចាំបាច់ដឹងហេតុផលអ្វីទេ។ |
| **២. ខ្វះភាពជាអ្នកដឹកនាំ៖** នៅតាមសាលារៀនគ្មានអ្នកជំនាញផ្នែកការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីសម្របសម្រួលកិច្ចការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ឱ្យមានប្រសិទ្ធិភាព ដូច្នេះវាក្លាយជាស្ថានភាព 'មនុស្សខ្វាក់ដឹកដៃមនុស្សខ្វាក់'។ | **៦.ខ្វះធនធាន៖** សូម្បីតែនៅពេលដែលសាលារៀនខិតខំប្រឹងប្រែងអនុវត្តគោលនយោបាយការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំក៏ដោយ ក៏គ្មានធនធានសម្រាប់ធ្វើសិក្ខាសាលា ដំណើរទស្សនកិច្ចសិក្សា និងសកម្មភាពស្រាវជ្រាវនានា។ |
| **៣.ការលើកទឹកចិត្តទាប៖** គ្រូគ្រាន់តែបំពេញកិច្ចការការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំឱ្យតែរួចៗទៅដោយមិនយកចិត្តទុកដាក់។ ដូច្នេះមានឥទ្ធិពលតិចតួចក្នុងការអនុវត្តតាមថ្នាក់រៀន។ | **៧.ពិបាកផ្លាស់ប្តូរពីការវាយតម្លៃទៅសកម្មភាពជាក់ស្តែង៖** ក្រោយវាយតម្លៃស្ថានភាពនៅតាមសាលារៀន គេមិនឃើញមានសមត្ថភាពដែលអាចបង្កើតដំណោះស្រាយសំខាន់ៗនោះទេ។ |
| **៤. ពេលតិច៖** រយៈពេលសម្រាប់សកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ( ឧ. ២ម៉ោងក្នុង១សប្តាហ៍ ) ពិតជាខ្លី ធ្វើឱ្យគ្រូទទួលបានចំណេះដឹង និងជំនាញតិចតួច។ | **៨.ខ្វះឯកសារ៖** សាលារៀនមានលទ្ធភាពតិចតួចក្នុងការទទួលបានឯកសារជាភាសាជាតិ ដើម្បីជួយពួកគេឱ្យយល់ពីដំណើរការអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ ឯកសារទាំងនោះក្រាស់ហើយពិបាកអាន។ |

ក្រោយពីពិនិត្យបញ្ហាទូទៅនេះហើយ អ្នកសម្របសម្រួលឱ្យអ្នកចូលរួមធ្វើការក្នុងក្រុមរបស់ពួកគេ ដើម្បីឆ្លើយសំណួរនៅក្រោមឯកសារចែកជូន។ ផ្តល់ក្រដាសផ្ទាំងធំ ទៅក្រុមនីមួយៗ ត្រូវប្រាកដថាអ្នកចូលរួមបានចម្លងចម្លើយរបស់ខ្លួនឆ្លើយនឹងសំណួរខាងក្រោម៖

### សំណួរពិភាក្សា

1. តើអ្នកគិតថាមានបញ្ហាដកស្រង់ខាងលើប៉ុន្មានពាក់ព័ន្ធនឹងស្ថានភាពក្នុងប្រទេសកម្ពុជា (ឧ. ទាំងអស់? ភាគច្រើន? ឬមួយចំនួន?)
2. ចំពោះការដកស្រង់បញ្ហាខាងលើ បញ្ហា**២ ឬ៣** ណាមួយដែលអ្នកគិតថាសំខាន់បំផុតនៅក្នុងបរិបទប្រទេសកម្ពុជា ហើយពិបាកដោះស្រាយបំផុត?
3. សម្រាប់បញ្ហា២ឬ៣ ដែលអ្នកបានដកស្រង់ជាអាទិភាពខ្ពស់ជាងគេ តើអ្នកព្យាយាមដោះស្រាយបញ្ហាទាំងនោះដោយរបៀបណានៅតាមមូលដ្ឋានសាលារៀន ឬតាមខេត្តរបស់អ្នក? ចូរព្យាយាមផ្តល់ព័ត៌មានជាក់លាក់នៅពេលពិពណ៌នាដំណោះស្រាយ។

ផ្តល់ពេលដល់អ្នកចូលរួម៣០ទៅ៣៥នាទីដើម្បីបង្កើតចម្លើយរបស់ពួកគេ។ នៅពេលគេធ្វើចប់ឱ្យក្រុមបិទចម្លើយនៅក្រដាសផ្ទាំងធំជាប់នឹងក្តារខៀន និងធ្វើបទបង្ហាញទស្សនរបស់ខ្លួនចំពោះបញ្ហា និងវិធីដែលគេអាចដោះស្រាយបញ្ហាទាំងនេះប្រសិនបើគេជួបប្រទះនៅមូលដ្ឋានសាលារៀនរបស់ខ្លួន។

## រចនាសម្ព័ន្ធស្ថាប័នដែលគាំទ្រ CPD៖ សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន (PLC)

PLC ផ្តល់ឱ្យគ្រូបង្រៀននូវការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ PLC ផ្តោតលើ**ការសិក្សា** និង**ការសហការ** ក្នុងគោលបំណងចុងក្រោយដើម្បីកែលម្អលទ្ធផលសិក្សាសិស្ស។

អ្នកសម្របសម្រួលសួរអ្នកចូលរួម "តើអ្នកណាត្រូវរៀននៅសាលារៀន?" អ្នកសម្របសម្រួលឱ្យអ្នកចូលរួមពិភាក្សាជាក្រុមតូចៗជាមុនសិន បន្ទាប់មកណែនាំអ្នកចូលរួមនូវទស្សនទានដែលទាំងសិស្សទាំងគ្រូត្រូវបានរំពឹងថានឹងរៀននៅក្នុងសាលារៀនផងដែរ។
PLC មានវិសាលភាពក្នុងការលើកកម្ពស់ការសិក្សារបស់សិស្ស និងគ្រូ ឧទាហរណ៍៖

| សិស្ស | គ្រូបង្រៀន |
|---|---|
| • ការវិភាគការលំបាករបស់សិស្ស<br>• រៀបចំកិច្ចការ និងការវាយតម្លៃកាន់តែប្រសើរ ទាំងវង្វាយតម្លៃជាដំណាក់ និងវង្វាយតម្លៃបូកសរុប<br>• ការកែលម្អកម្មវិធីសិក្សា | • ការពង្រឹងសមត្ថភាពគ្រូបង្រៀន<br>• ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD នៅក្នុងរចនាសម្ព័ន្ធរបស់ខ្លួនក្រោមក្រសួងអប់រំ) |

នៅពេលដែលសាលារៀនសម្រេចចិត្តរៀបចំ PLC នៅក្នុងសាលារៀន ពួកគេត្រូវសម្រេចចិត្តជាមុនសិន ថាតើពួកគេត្រូវការអ្វី និងមានជម្រើសផ្សេងៗ។

**សកម្មភាព**រយៈពេល ១៥នាទី៖

អ្នកសម្របសម្រួលចែកក្រដាសពណ៌កត់ចំណាំស្អិតដល់អ្នកចូលរួមទាំងអស់(មាន២ពណ៌ផ្សេងគ្នា)។ នៅក្នុងក្រដាសស្អិតដែលមានពណ៌ដាក់លាក់មួយ ពួកគេត្រូវតែឆ្លើយតបទៅនឹងសំណួរទី១ និងនៅក្នុងក្រដាសផ្សេងទៀត ឆ្លើយតបចំពោះសំណួរទី២ ។ ចម្លើយមួយសម្រាប់ក្រដាសស្អិតនីមួយៗ។

- **សំណួរទី១៖** តើគ្រូបង្រៀនសហការគ្នានៅក្នុងសាលារៀនរបស់អ្នកដោយរបៀបណា?
- **សំណួរទី២៖** តើអ្វីជាចំណុចសំខាន់នៃការសហការ? (ផ្នែកបច្ចេកទេសនៃការងារមួយណា? ឧទាហរណ៍៖ ការកែសម្រួលកិច្ចតែងការមេរៀន រៀបចំពិព័រណ៍សាលារៀន។ល។)
- **សំណួរទី៣៖** ប្រសិនបើគ្រូមិនសហការគ្នាទេ តើមានហេតុផលអ្វីខ្លះ?

អ្នកសម្របសម្រួលប្រមូលក្រដាសកំណត់ត្រាស្អិត ហើយរៀបចំចម្លើយនៅក្រោមសំណួរសំខាន់ៗចំនួន៣ (នៅលើក្រដាសផ្ទាំងធំ ឬនៅលើក្ដារខៀន)។

**សេចក្តីសន្និដ្ឋាន៖** មានវិធីផ្សេងៗគ្នាសម្រាប់គ្រូក្នុងការសហការ ហើយ PLC អាចយកទម្រង់ផ្សេងៗគ្នា។ ប្រហែលជាសាលារៀនភាគច្រើនបានរៀបចំសកម្មភាពគាំទ្រការសហការហើយ ទោះបីជាមិនដាក់ស្លាក PLC ក៏ដោយ។ សកម្មភាព PLC ត្រូវឆ្លើយតបទៅនឹងតម្រូវការរបស់គ្រូដោយចុងក្រោយផ្តោតលើលទ្ធផលសិក្សាសិស្ស។ អ្នកអាចប្រឈមមុខនឹងបញ្ហាប្រឈមមួយចំនួនក្នុងការរៀបចំ PLC ដែលរួមមានកង្វះចំណាប់អារម្មណ៍ កង្វះពេលវេលាដែលបានបែងចែកសម្រាប់សកម្មភាព កង្វះចក្ខុវិស័យលើអត្ថប្រយោជន៍ ទំនាក់ទំនងមិនល្អរវាងគ្រូបង្រៀននៅក្នុងសាលារៀន។ បញ្ហាប្រឈមទាំងអស់នេះអាចដោះស្រាយបាន។ ភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាព ការចង្អុលបង្ហាញច្បាស់លាស់ ការបែងចែកពេលវេលាជាក់លាក់សម្រាប់ PLC គឺជាដំណោះស្រាយមួយចំនួនដែលចាំបាច់ត្រូវកែសម្រួលដោយផ្អែកលើស្ថានភាពសាលារៀននីមួយៗ។

**គំនិតបន្ថែមនៃវិធីសហការ (សម្រាប់អ្នកសម្របសម្រួល)**

- PLC **តាមកម្រិតថ្នាក់៖** ក្រុមគ្រូមកពីកម្រិតថ្នាក់ដូចគ្នាជួបប្រជុំគ្នាដើម្បីពិភាក្សាអំពីកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន និងវឌ្ឍនៈភាពរបស់សិស្ស។
- PLC **តាមប្រភេទមុខវិជ្ជា៖** គ្រូដែលមានមុខវិជ្ជាដូចគ្នាមករួមគ្នាដើម្បីចែករំលែកឧត្តមានុវត្តពិភាក្សាគ្នាពីបញ្ហាប្រឈម និងឱ្យស្របគ្នាពីវិធីសាស្ត្របង្រៀន។
- PLC **នៃការណែនាំ៖** ប្រធានក្រុមបច្ចេកទេសគាំទ្រ និងណែនាំសហសេវិករបស់ខ្លួនដោយការសម្របសម្រួលការពិភាក្សា ការសង្កេត និងមតិកែលម្អលើការអនុវត្តការបង្រៀន។

- PLC **ក្នុងការវិភាគទិន្នន័យ៖** គ្រូបង្រៀនសហការគ្នាក្នុងការវិភាគទិន្នន័យសិស្ស និងប្រើប្រាស់វាដើម្បីកែលម្អការបង្រៀនជាថ្មី និងកំណត់ចំណុចត្រូវកែលម្អ។
- PLC **កិច្ចសហប្រតិបត្តិការឆ្លងថ្នាក់៖** គ្រូមកពីថ្នាក់ផ្សេងៗគ្នាសហការគ្នាដើម្បីធានាឱ្យមានការផ្លាស់ប្តូរដោយរលូនសម្រាប់សិស្ស និងដោះស្រាយចន្លោះប្រហោងក្នុងការសិក្សា។
- PLC **សម្រាប់ការអប់រំពិសេស និងបរិយាបន្ន៖** គ្រូបង្រៀន និងបុគ្គលិកជំនួយដែលធ្វើការជាមួយសិស្សដែលមានតម្រូវការពិសេសសហការគ្នាលើការអនុវត្តប្រកបដោយបរិយាបន្ន និងយុទ្ធសាស្ត្រតាមតម្រូវការ។

PLC ទាំងនេះផ្តល់ឱកាសឱ្យមានការសហការ ការសិក្សា និងការកែលម្អក្នុងចំណោមអ្នកអប់រំ ដើម្បីលើកកម្ពស់លទ្ធផលសិក្សាសិស្ស។

**ការប្រឹក្សា ឬការបង្វឹក និង PLC (សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន)** នៅក្នុងសាលារៀនមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ។ ការប្រឹក្សាអាចជាផ្នែកមួយនៃ PLC និងគាំទ្រដល់ការរីកចម្រើននៃវិជ្ជាជីវៈរបស់អ្នកអប់រំ។ នេះគឺជាវិធីមួយចំនួនដែលពួកគេភ្ជាប់៖

1. ការប្រឹក្សានៅក្នុង PLC៖ អ្នកអប់រំដែលមានបទពិសោធន៍អាចប្រឹក្សាមិត្តរួមការងារដែលមានបទពិសោធន៍តិចនៅក្នុងកម្មវិធី PLC ។ ពួកគេផ្តល់ការណែនាំ គាំទ្រ និងចែករំលែកឯកទេសរបស់ពួកគេ។ នេះជួយឱ្យគ្រូរៀនពីគ្នាទៅវិញទៅមក និងអភិវឌ្ឍបំណិនជីវិតតាមមូលដ្ឋានរួមគ្នា។
2. ការប្រឹក្សាសម្រាប់គ្រូថ្មី៖ PLC អាចមានកម្មវិធីប្រឹក្សាសម្រាប់គ្រូថ្មី។ គ្រូបឹក្សាគរុកោសល្យជួយពួកគេជាមួយនឹងយុទ្ធសាស្ត្របង្រៀន ការគ្រប់គ្រងថ្នាក់រៀន និងផ្នែកផ្សេងៗទៀត។ ជំនួយបែបនេះជួយឱ្យគ្រូថ្មីមានការរីកចម្រើនលឿនជាងមុន និងបន្តនៅក្នុងអាជីព។
3. ការអភិវឌ្ឍវិជ្ជាជីវៈគោលដៅ៖ ការប្រឹក្សានៅក្នុង PLC មួយអាចដោះស្រាយតម្រូវការអភិវឌ្ឍជាក់លាក់។ គ្រូបង្រៀនអាចស្វែងរកការណែនាំនៅក្នុងផ្នែកដែលពួកគេចង់កែលម្អ។ គ្រូបឹក្សាគរុកោសល្យផ្តល់ជំនួយបុគ្គល ចែករំលែកធនធាន ហើយនិងផ្តល់មតិត្រឡប់ដើម្បីជួយគ្រូបង្រៀនឱ្យកាន់តែប្រសើរឡើងនៅក្នុងផ្នែកទាំងនោះ។

តាមរយៈការរួមបញ្ចូលទាំងការប្រឹក្សា និងការធ្វើ PLC សាលារៀនបង្កើតបរិយាកាសសហការ និងគាំទ្រសម្រាប់កំណើនវិជ្ជាជីវៈ។ វាផ្តល់អត្ថប្រយោជន៍ច្រើនដល់គ្រូបង្រៀន និងកែលម្អលទ្ធផលសិក្សាសិស្ស។ **ចំណាំ៖** ការបង្វឹក និងការប្រឹក្សា គឺជាវិធីសាស្ត្រអភិវឌ្ឍសមត្ថភាព ដើម្បីគាំទ្រដល់គ្រូបង្រៀន។ មានភាពខុសគ្នាបន្តិចបន្តួចរវាងសកម្មភាពទាំងពីរនេះ។ បំណិនការបង្វឹក និងការប្រឹក្សាគឺជាធាតុផ្សំដ៏សំខាន់មួយសម្រាប់អ្នកដឹកនាំសាលារៀន ឬគ្រូបឹក្សាគរុកោសល្យដើម្បីលើកទឹកចិត្ត ឬដោះស្រាយសក្តានុពលរបស់គ្រូបង្រៀននៅក្នុងដំណើរការសិក្សារបស់ពួកគេ។

តារាងខាងក្រោមសង្ខេបពីភាពខុសគ្នាសំខាន់ៗមួយចំនួនរវាងការបង្វឹក និងការប្រឹក្សា ប៉ុន្តែការវិភាគស៊ីជម្រៅគួរតែកើតឡើងនៅក្នុងកញ្ចប់បណ្តុះបណ្តាលជាក់លាក់ និងដាច់ដោយឡែក។

| | **ការប្រឹក្សា** | **ការបង្វឹក** |
|---|---|---|
| **ការផ្តោត** | ការអភិវឌ្ឍអាជីពទាំងមូល និងបំណិនជីវិតតាមមូលដ្ឋាន | លទ្ធផលប្រសើរឡើងនៅកន្លែងធ្វើការបច្ចុប្បន្ន |
| **គ្របខណ្ឌពេលវេលា** | រយៈពេលវែង | រយៈពេលខ្លី |
| **រចនាសម្ព័ន្ធ** | ទំនាក់ទំនង និងការប្រជុំក្រៅផ្លូវការ | ទំនាក់ទំនងជារចនាសម្ព័ន្ធ និងផ្លូវការ |
| **របៀបវារៈ** | បើកចិត្តទូលាយ កំណត់ដោយអ្នកទទួលសេវាប្រឹក្សា | កំណត់ បង្កើតរួមគ្នាដោយគ្រូបង្វឹក និងគ្រូបង្រៀន |
| **លទ្ធផល** | ការអភិវឌ្ឍ | ការបំពេញការងារ |

មុននឹងឈានទៅដល់ប្រធានបទបន្ទាប់ សូមស្តាប់ព័ត៌មានមកពីអនុវិទ្យាល័យ ហ៊ុនសែន រលួស ក្នុងខេត្តសៀមរាប ថាតើមានយន្តការអ្វីខ្លះដើម្បីគាំទ្រដល់ការបង្រៀន និងរៀន៖

វីដេអូ៖ យន្តការគាំទ្រសម្រាប់ការបង្រៀនការអប់រំបំណិនជីវិតមូលដ្ឋាននៅកម្រិតសាលារៀន៖
https://www.youtube.com/watch?v=aYA5z7pycKw

**សំណួរបំផុស (ការពិភាក្សា)**

- តើយន្តការអ្វីខ្លះដែលត្រូវអនុវត្ត?
- តើយន្តការទាំងនេះមានប្រយោជន៍យ៉ាងណាសម្រាប់គ្រូបង្រៀន?
- តើនាយករងសាលារៀនមានតួនាទីអ្វី?
- តើអ្នកមានយន្តការស្រដៀងគ្នានៅក្នុងសាលារៀនរបស់អ្នកដែរឬទេ?

## រចនាសម្ព័ន្ធស្ថាប័នដែលគាំទ្រ CPD៖ **គ្រូប្រឹក្សាគរុកោសល្យតាមសាលារៀន**

ហេតុផលនៅពីក្រោយការវិនិយោគនៅក្នុងការប្រឹក្សាគរុកោសល្យ គឺផ្អែកលើគំរូ ៧០-២០-១០។ គំនិតនេះគឺថាការប្រឹក្សាក្នុងទម្រង់ផ្សេងៗគ្នាអាចផ្តល់ការគាំទ្រប្រកបដោយប្រសិទ្ធភាព និងជំរុញដល់គ្រូបង្រៀននៅក្នុងសាលារៀននៅពេលដែលពួកគាត់ត្រូវការព័ត៌មានត្រឡប់លើការអនុវត្តការបង្រៀន។ ការប្រឹក្សាគរុកោសល្យ កំពុងក្លាយជាពាក្យពេញនិយមក្នុងវិស័យអប់រំគ្រប់កម្រិត ហើយជាទូទៅវាត្រូវបានគេចាត់ទុកថាសំខាន់ក្នុងការបង្កើតគុណតម្លៃជាវិជ្ជមាន អាកប្បកិរិយា និងបំណិនជីវិតមូលដ្ឋាន។

អ្នកសម្របសម្រួលចាប់ផ្តើម ដោយសួរអ្នកចូលរួម៖ តើការប្រឹក្សាគរុកោសល្យគឺជាអ្វី? ហើយតើវាអាចអនុវត្តក្នុងបរិយាកាសសាលារៀនបែបណាទើបមានប្រសិទ្ធភាព?

**និយមន័យ៖** គ្រូប្រឹក្សាគរុកោសល្យគឺជាគ្រូមានបទពិសោធន៍ ដែលផ្តល់ការគាំទ្រដល់គ្រូថ្មីថ្មោង ឬគ្រូដែលមានបទពិសោធន៍តិច។

(កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល)៖ អ្នកចូលរួមប្រហែលជាធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលពីមុនស្តីពីការប្រឹក្សា និងស្តាប់និយមន័យផ្សេងៗ។ សូមចំណាំថា ការប្រឹក្សាអាចត្រូវបានពិពណ៌នាតាមវិធីផ្សេងៗគ្នា ប៉ុន្តែមានធាតុសំខាន់ៗមួយចំនួនដែលសាមញ្ញធម្មតា៖

- វាគឺជាទំនាក់ទំនងរវាងមនុស្ស (ជាធម្មតាមនុស្ស ២នាក់៖ គ្រូប្រឹក្សា និងគ្រូបង្រៀន)។
- មានការផ្លាស់ប្តូរចំណេះដឹង និងជំនាញទៅវិញទៅមក។
- មានគោលបំណងកសាងការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន។
- គ្រូប្រឹក្សាទទួលបានអត្ថប្រយោជន៍ពីទំនាក់ទំនងនេះ ក៏ដូចជាគ្រូបង្រៀនផងដែរ។

ក្នុងអំឡុងពេលមេរៀនថ្ងៃនេះ យើងនឹងចាប់ផ្តើមណែនាំពីកម្មវិធីនៃការប្រឹក្សាគរុកោសល្យតាមសាលារៀននៅក្នុងសាលារៀន ដែលជាផ្នែកមួយនៃ CPD នៅកម្រិតសាលារៀន។

ឧទាហរណ៍នៃការប្រឹក្សាគរុកោសល្យនៅតាមសាលារៀន៖
https://kapeict.sharepoint.com/:v:/s/KampucheaActiontoPromoteEducationKAPE/Ea1HH01eoHJFjbEV6a6W9RMBWqLiFBWvCtcdjTRJK8akzQ?e=RjYmSA

- តើអ្វីជាទម្លាប់នៃការប្រឹក្សាគរុកោលសល្យ?
- តើអ្វីជាបញ្ហាប្រឈមដំបូង និងរបៀបដោះស្រាយវា? (សម្រាប់គ្រូប្រឹក្សា)
- តើអ្វីទៅជាអត្ថប្រយោជន៍សម្រាប់គ្រូប្រឹក្សា និងគ្រូបង្រៀន?

**សេចក្តីសន្និដ្ឋាន៖** វដ្តនៃការប្រឹក្សាគឺជាដំណើរការសិក្សាទាំងមូលដែលរួមមាន ៣ដំណាក់កាល៖

1. មុនពេលប្រជុំ ត្រូវរៀបចំសកម្មភាពវិជ្ជាជីវៈ។
2. ការអង្កេតសកម្មភាពវិជ្ជាជីវៈ។
3. ក្រោយប្រជុំត្រូវពិភាក្សាពីសកម្មភាព ផ្តល់ព័ត៌មានត្រឡប់ និងកំណត់គោលបំណងសិក្សាថ្មី។

ប្រសិនបើការប្រជុំធ្វើបានត្រឹមត្រូវ គ្រូប្រឹក្សា និងគ្រូបង្រៀនគួរតែឈានដល់ការឯកភាពគ្នាលើគោលបំណងសិក្សាដែលត្រូវនឹងតម្រូវការរបស់គ្រូបង្រៀន។ យើងធ្វើការតាមជំហានតូចៗ និងអាចគ្រប់គ្រងបាន។ ជាធម្មតា គោលបំណងមួយ ឬពីរគឺគ្រប់គ្រាន់សម្រាប់វគ្គមួយ។ **សូមចាំថា ការប្រឹក្សាគឺជាដំណើរការរយៈពេលវែង**។

## មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRC/NIE)

បង្កើតឡើងក្នុងឆ្នាំ២០១៩ មជ្ឈមណ្ឌលបណ្តុះបណ្តាលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី គឺជាអង្គភាពស្វយ័តមួយនៅក្នុងវិទ្យាស្ថានជាតិអប់រំ ដែលត្រូវបានផ្តល់សិទ្ធិអំណាចដោយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបណ្តុះបណ្តាល**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំលើឯកទេសក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងការប្រឹក្សាគរុកោសល្យ** គរុនិស្សិតដែលបានបញ្ចប់វគ្គសិក្សារយៈពេលមួយឆ្នាំដោយ

ជោគជ័យ។ គោលបំណងសំខាន់របស់ NGPRC គឺដើម្បីបណ្តុះបណ្តាលគ្រូប្រឹក្សាដែលនឹងផ្តល់ការគាំទ្រជាបុគ្គលដល់គ្រូបង្រៀននៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ គ្រូប្រឹក្សាទាំងនេះភាគច្រើននឹងទៅបម្រើការងារនៅសាលារៀនមធ្យមសិក្សា ប៉ុន្តែការងារមួយចំនួននៅក្នុងស្ថាប័នបណ្តុះបណ្តាលគ្រូបង្រៀនដូចជា NIE (វិទ្យាស្ថានជាតិអប់រំ) ឬ TEC (វិទ្យាស្ថានបណ្តុះបណ្តាលគ្រូ) ខណៈពេលដែលការស្វែងរកកិច្ចសហប្រតិបត្តិការនាពេលអនាគតនៅកម្រិតការិយាល័យបឋមសិក្សា និងមន្ទីរអប់រំ ឬការិយាល័យអប់រំ ។ NGPRC ចូលរួមចំណែកក្នុងការបង្កើតសាលារៀនកម្រិតខ្ពស់ដែលមិនមានអំពើពុករលួយ បង្ហាញពីស្តង់ដាអភិបាលកិច្ចខ្ពស់ និងលើកកម្ពស់ឧត្តមានុវត្តដែលនឹងរៀបចំយុវជនឱ្យធ្វើការប្រកបដោយប្រសិទ្ធភាពក្នុងសតវត្សរ៍ទី២១ ។

គ្រូទាំងអស់ដែលមានលក្ខសម្បត្តិគ្រប់គ្រាន់សម្រាប់ការចុះឈ្មោះ ត្រូវបានលើកទឹកចិត្តឱ្យដាក់ពាក្យ។ សូមលើកទឹកចិត្តគ្រូរបស់អ្នកឱ្យដាក់ពាក្យ។

## ការវាយតម្លៃទទួលស្គាល់គុណភាព CPD

ដំណើរការទូទៅមួយនៃ CPD ដែលមានវត្តមានគឺប្រទេសកម្ពុជាក៏មានការទទួលស្គាល់គុណភាព CPD ផងដែរ។

ចុងក្រោយ អ្នកសម្របសម្រួលណែនាំអ្នកចូលរួមអំពីជាតុទីបីដែលរួមចំណែកដល់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន។

ក្រសួងអប់រំ យុវជន និងកីឡា កំពុងធ្វើការដើម្បីធ្វើឱ្យវាអាចប្រើប្រាស់បានចំពោះគ្រូបង្រៀន និងនាយកសាលារៀនទាំងអស់ក្នុងប្រទេស ហើយជាតុនេះត្រូវបានគេហៅថា ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD)។ អ្នកសម្របសម្រួលបន្តដោយពន្យល់ថា ក្រសួងអប់រំ យុវជន និងកីឡាបានកំពុងសាកល្បងប្រព័ន្ធនេះសម្រាប់សាលារៀនក្នុងខេត្តសៀមរាបក្នុងឆ្នាំ២០២២ ដែលមានលទ្ធផលដូចការរំពឹងទុក។

អ្នកសម្របសម្រួលសួរថា តើមាននរណាម្នាក់នៅក្នុងបន្ទប់នេះស្គាល់ CPD ដែរឬទេ។ អនុញ្ញាតឱ្យអ្នកចូលរួមចែករំលែកចំណេះដឹងអ្វីដែលពួកគេបានឮ ឬបទពិសោធន៍ទាក់ទងនឹង CPD។

**សកម្មភាព** វីដេអូ (រយៈពេល៖ ២០នាទី) អ្នកសម្របសម្រួលណែនាំដូចតទៅ៖ «សុខា បានក្លាយជាគ្រូបង្រៀនថ្មី បន្ទាប់ពីបានបញ្ចប់ការសិក្សាពីសាលារៀនគរុកោសល្យ និងវិក្រឹតការខេត្តសៀមរាប ក្នុងកម្មវិធីបណ្តុះបណ្តាល១២+២។ សុខា កំពុងបង្រៀននៅសាលារៀនបឋមសិក្សាមួយក្នុងខេត្តសៀមរាប។ គាត់ចង់លើកកម្ពស់គុណវុឌ្ឍិរបស់គាត់រហូតដល់កម្រិតបរិញ្ញាបត្រ ប៉ុន្តែគាត់មិនមានសមត្ថភាព និងឱកាស»។ ចាំមើល តើ សុខា សម្រេចធ្វើអ្វី!

**វីដេអូ ៩.១៖** https://www.youtube.com/watch?v=C1JvH1JxtZo

**សំណួរបំផុស៖**

- តើសុខាត្រូវការអ្វីខ្លះ ?
- តើសុខាសម្រេចធ្វើអ្វី ? ធ្វើដូចម្តេច ?
- តើការទទួលស្គាល់គុណភាព CPD គឺជាអ្វី ?
- តើ សុខា ប្រើប្រាស់ក្រេឌីត CPD ដូចម្តេច ?
- តើគាត់ស្វែងរកព័ត៌មាននៅឯណា ?

អ្នកសម្របសម្រួលបន្តពន្យល់ថាលក្ខណៈសំខាន់មួយនៃ CPD គឺគោលបំណងដើម្បីផ្តល់នូវការសិក្សាជាក់ស្តែង។ គ្រូបង្រៀន និងនាយកសាលានឹងចូលរួមក្នុងសកម្មភាពដែលតម្រូវឱ្យអនុវត្តក្នុងការងារប្រចាំថ្ងៃ និងការឆ្លុះបញ្ចាំងរបស់ពួកគេ។ នេះបកប្រែន័យក្នុងការផ្តល់ជូននូវសកម្មភាពសិក្សាដែលរួមមានការអនុវត្តការសិក្សានៅកន្លែងធ្វើការ (ថ្នាក់រៀន សាលា ការិយាល័យ) និងកិច្ចការ។ ការអានបន្ថែមលើការវាយតម្លៃទទួលស្គាល់គុណភាព CPD ។ សម្រាប់ព័ត៌មានបន្ថែមស្តីពីវគ្គសិក្សា INSET CPD ផ្តល់ជូន និងប្រព័ន្ធទទួលស្គាល់គុណភាព អ្នកចូលរួមអាចស្វែងរកព័ត៌មាននេះបាននៅលើគេហទំព័រ៖

http://cpd.moeys.gov.kh/home. (ប្រសិនបើមានពេល អ្នកសម្របសម្រួលនឹងបើកមើលគេហទំព័រ និងបង្ហាញដល់អ្នកចូលរួមនូវខ្លឹមសារសំខាន់ៗរួមមានគេហទំព័រនៃវគ្គសិក្សាដែលមាននៅ http://cpd.moeys.gov.kh/course )។

ហើយអ្នកសម្របសម្រួលចែកឯកសារ ៩.៥៖ *មើលមួយស្របក់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។* ឱ្យអ្នកចូលរួមអានសង្ខេបបញ្ញត្តិសំខាន់ៗ

## ការរៀបចំតេស្តក្រោយគ្រា

### បញ្ចប់មេរៀនទី៩ និងបញ្ចប់វគ្គសិក្សា

# ៣. ឯកសារចែកសម្រាប់អ្នកចូលរួម

## ឯកសារផ្នែកទី១៖ សេចក្ដីណែនាំការអប់រំបំណិនជីវិតតាមមូលដ្ឋាននៅកម្ពុជា

### ឯកសារ ១.១៖ ការបង្រៀនបំណិនជីវិត

**សេចក្ដីណែនាំ៖** សូមអានអត្ថបទដកស្រង់ខាងក្រោម ស្ដីពីការអប់រំបំណិនជីវិត និងឆ្លើយសំណួរ។

**ដកស្រង់ពីអត្ថបទ**

**"ក្រសួងអប់រំ មានផែនការអនុវត្តការអប់រំបំណិនជីវិតតាមមូលដ្ឋាន" ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ (កាសែត** Khmer Times)" ។

"ក្រសួងអប់រំ យុវជន និងកីឡា មានគោលបំណងបង្រៀនកម្មវិធីបំណិនជីវិតដែលជួយឱ្យយុវជនវ័យក្មេងទទួលបានគោលដៅអនុវត្តជាក់ស្ដែងដើម្បីធ្វើឱ្យជីវិតទាន់សម័យជោគជ័យនៅក្នុងសតវត្សរ៍ទី២១" ។

...បំណិនទន់អាចនិយាយបានថាជាបំណិនដ៏មានសារៈសំខាន់សម្រាប់ដោះស្រាយបញ្ហាប្រឈមជាមួយគ្រួសារ និងបញ្ហាប្រឈមប្រចាំថ្ងៃដែលកើតមាននៅក្នុងសង្គម និងកន្លែងធ្វើការងារ។

### សំណួរសម្រាប់ពិភាក្សា

1. បើតាមទស្សនៈរបស់អ្នក តើអ្វីទៅជាការអប់រំបំណិនជីវិត ?

2. ហេតុអ្វីបានជាអ្នកគិតថា ក្រសួងអប់រំត្រូវលើកទឹកចិត្តសាលារៀនឱ្យបង្រៀនកម្មវិធីបំណិនជីវិត ឬបំណិនទន់ ?

3. បើតាមទស្សនៈរបស់អ្នក តើកម្មវិធីបំណិនជីវិតអាចជួយដល់យុវជនបានដោយរបៀបណាខ្លះ ?

## ឯកសារ ១.២៖ ករណីសិក្សារបស់សម្បត្តិ និងមករា

### សេចក្តីណែនាំ

**គំរូនៃការងារ៖** ធ្វើការជាដៃគូ

- **ជំហានទី១៖** សូមអានករណីសិក្សាខាងក្រោមដោយប្រុងប្រយ័ត្ន។
- **ជំហានទី២៖** ឆ្លើយសំណួរខាងក្រោម។

### ករណីសិក្សា

**សម្បត្តិ និងមករា** ជាកសិករមកពីខេត្តកំពង់ចាម។ អ្នកទាំងពីរដាំបន្លែ និងលក់ខ្លួនឯងផ្ទាល់នៅផ្សារ។ ពួកគេម្នាក់ៗមានតូបផ្ទាល់រៀងៗខ្លួន។ នៅក្នុងអំឡុងពេលការរីករាលដាលជំងឺកូវីដ ទីផ្សារបានបិទ។ សម្រាប់ពួកគេ ក៏ដូចជាកសិករជាច្រើនផ្សេងទៀត រឿងនេះបានក្លាយជាបញ្ហាយ៉ាងឆាប់រហ័សព្រោះពួកគេមិនអាចលក់ផលិតផលបានទៀត។ ពួកគេទាំងពីរត្រូវសម្រេចចិត្តថាត្រូវធ្វើអ្វី ពួកគេទាំងពីរគឺជាកសិករដ៏ល្អ ប៉ុន្តែពួកគេមិនធ្លាប់បានជួបប្រទះបញ្ហាបែបនេះក្នុងជីវិតរបស់ពួកគេពីមុនមកទេ។





**សម្បត្តិ៖** សម្បត្តិបានចំណាយពេលជាច្រើនថ្ងៃគិតពីអ្វីដែលត្រូវធ្វើ ប៉ុន្តែគាត់មិនដឹងថាត្រូវចាប់ផ្តើមពីណាមុនទេ។ គាត់មិនបានសុំជំនួយពីអ្នកណាទេ។ នៅទីបំផុត គាត់បានសម្រេចចិត្តកាត់បន្ថយការផលិតបន្លែ ហើយរង់ចាំទីផ្សារបើកវិញ។ នៅពេលដែលទីផ្សារបានបើកម្តងទៀត គាត់អាចត្រលប់មកប្រក្រតីវិញ ប៉ុន្តែគាត់បានបាត់បង់លុយយ៉ាងច្រើន។

**មករា៖** មករាបានចំណាយពេលជាច្រើនថ្ងៃគិតអំពីដំណោះស្រាយចំពោះបញ្ហានេះ។ គាត់បានទាក់ទងអតិថិជនមួយចំនួនដើម្បីសួរពួកគេថាតើពួកគេនៅត្រូវការបន្លែរបស់គាត់ឬអត់។ ទាំងអស់បានឆ្លើយថាបាទ ប៉ុន្តែវាពិបាកសម្រាប់ពួកគេក្នុងការធ្វើបន្ថែមទៀត។ គាត់បានបង្កើតគំនិតមួយ គាត់អាចប្រមូលផ្តុំក្រុម Telegram ជាមួយអតិថិជនរបស់គាត់ទាំងអស់ ហើយរៀបចំឱ្យពួកគេធ្វើផ្លែឈើដោយផ្ទាល់នៅមុខផ្ទះរបស់ពួកគេជៀសវាងការទាក់ទងគ្នាដោយផ្ទាល់ជាមួយអតិថិជន ប៉ុន្តែនៅតែអាចលក់បាន។ នៅទីបំផុត អាជីវកម្មរបស់គាត់បានរីកចម្រើនក្នុងអំឡុងជំងឺកូវីដ គាត់ទទួលបានអតិថិជនច្រើនជាងមុន។ ឥឡូវនេះ ទោះបីជាទីផ្សារបើកម្តងទៀតក៏ដោយ គាត់នៅតែទទួលយកការបញ្ជាទិញតាមតេឡេក្រាម ហើយអាជីវកម្មរបស់គាត់កាន់តែរឹងមាំដែលអនុញ្ញាតឱ្យគាត់ជួលជំនួយការម្នាក់។

**សំណួរ៖ សូមអាន និងឆ្លើយដោយប្រុងប្រយ័ត្ននូវសំណួរទាំង៤ខាងក្រោម៖**

1. តើ **មករា** ធ្វើអ្វីដើម្បីប្រឈមមុខនឹងបញ្ហា ?

2. តើ **សម្បត្តិ** បានធ្វើអ្វីខ្លះ ?

3. តើលទ្ធផលដូចម្តេច ?

4. តើបំណិនអ្វីដែល **មករា** អនុវត្តដើម្បីព្យាយាមរកដំណោះស្រាយ ?

## ឯកសារ ១.៣៖ មុខវិជ្ជាបំណិនទន់ និងបំណិនជីវិតតាមមូលដ្ឋាន

"**បំណិនទន់** ជាផ្នែកមួយដែលត្រូវការដើម្បីសម្របខ្លួនទៅនឹងបរិបទជីវិតផ្សេងៗ ហើយ មនុស្សអាចផ្ទេរប្រកបដោយសក្តានុពលទៅលើផ្នែកសង្គម វប្បធម៌ ឬការងារផ្សេងៗគ្នា។ បំណិនទន់ រួមបញ្ចូលទាំងបំណិនការយល់ដឹង បំណិនសង្គម និងចិត្តអារម្មណ៍ ដែល អាចឱ្យកុមារ និងក្មេងជំទង់បន្តការសិក្សាពេញមួយជីវិត និងក្លាយជាពលរដ្ឋសកម្ម និង ប្រកបដោយផលិតភាព។ **បំណិនទន់** ដំណើរការដោយសម្របសម្រួលជាមួយបំណិន ផ្សេងទៀតរួមមាន (មូលដ្ឋានគ្រឹះ ការងារជាក់លាក់ និងបំណិនឌីជីថល) និងជួយពួក គេឱ្យមានទំនាក់ទំនង និងពង្រឹងគ្នាទៅវិញទៅមក" ។



## ឯកសារ ១.៤៖ ការអប់រំបំណិនជីវិតនៅកម្ពុជា

ការអប់រំបំណិនជីវិតនៅកម្ពុជាអាចត្រូវបានចែកចាយតាមទម្រង់ផ្សេងៗគ្នា៖

1. ការអប់រំបំណិនិជីវិត ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាជាតិក្នុងប្រទេសកម្ពុជា។ វាត្រូវបានបង្រៀនជាផ្នែកនៃមុខវិជ្ជាផ្សេងៗដូចជា ការសិក្សាសង្គម ការអប់រំសុខភាព និងការអប់រំសីលធម៌ និងពលរដ្ឋវិជ្ជា។ កម្មវិធីសិក្សាផ្តោតសំខាន់លើការអភិវឌ្ឍបំណិនជីវិតយ៉ាងទូលំទូលាយ រួមទាំងការប្រាស្រ័យទាក់ទង ការគិតពិចារណាស៊ីជម្រៅ ការដោះស្រាយបញ្ហា ការសម្រេចចិត្ត ការយល់ចិត្ត ការយល់ឃើញពីខ្លួនឯង និងបំណិនអន្តរបុគ្គល។

2. វាក៏អាចត្រូវបានបង្រៀននៅក្នុងកន្លែងក្រៅផ្លូវការបន្ថែមទៀតដែលជាផ្នែកមួយនៃការអប់រំក្រៅប្រព័ន្ធ ឬសកម្មភាពក្រៅកម្មវិធីសិក្សាក្នុងទម្រង់ក្លឹបសិក្សា និងក្រុមប្រឹក្សាកុមារ ឬយុវជន។

3. បំណិនជីវិតតាមមូលដ្ឋាន គឺជាឧទាហរណ៍នៃការអប់រំបំណិនជីវិតនៅកម្ពុជា។ វាជាផ្នែកមួយនៃកម្មវិធីសិក្សាផ្លូវការ ប៉ុន្តែជារឿយៗត្រូវបានបង្រៀនតាមរយៈវិធីសាស្ត្រកូនកាត់ ដែលរួមបញ្ចូលការបង្រៀនក្នុងម៉ោងផ្លូវការ ក្រៅកម្មវិធីសិក្សា និងសកម្មភាពផ្សេងៗ។ វាត្រូវបានបំបែកនៅក្នុងដ្យាក្រាម ដោយសារតែការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន មិនផ្អែកលើសៀវភៅសិក្សាគោលនោះទេ ដែលធ្វើឱ្យវាក្លាយជាបទពិសោធន៍តែមួយគត់នៃគំនិតផ្តួចផ្តើមក្នុងការអភិវឌ្ឍកម្មវិធីសិក្សា នៅតាមសាលារៀន ដើម្បីលើកកម្ពស់ការសិក្សាបែបសកម្មរបស់សិស្ស និងការចូលរួមរបស់សហគមន៍ក្នុងការងារអប់រំ។ វាទាមទារឱ្យមានភាពជាអ្នកដឹកនាំដ៏រឹងមាំរបស់នាយកសាលាដែលមានចក្ខុវិស័យច្បាស់លាស់ ដែលមនុស្សគ្រប់គ្នាដឹងពីតួនាទីរបស់ពួកគេក្នុងការចូលរួមចំណែកធ្វើឱ្យសម្រេចតាមចក្ខុវិស័យរបស់សាលារៀន។


កម្មវិធីសិក្សាផ្លូវការ និង
ក្រៅផ្លូវការ
៣. ការបង្រៀនបំណិនជីវិតជាក់
លាក់ ដោយដៃគូអភិវឌ្ឍន៍
(អេដស៍ សហគ្រិនភាព ក្លឹបកុមារី ក្លឹប
សន្តិភាព ក្លឹបយុវជន...)
កម្មវិធីសិក្សាផ្លូវការ
ការ
បង្រៀន
និងរៀន
សតវត្សរ៍ទី២១
១. កម្មវិធីសិក្សាគោល
ការបញ្ជ្រាបបំណិនមូលដ្ឋាន
២. ការបង្រៀនបំណិន
ជីវិតតាមមូលដ្ឋាន
កម្មវិធីសិក្សាបែបពិគ្រោះ:
យោបល់នៅកម្រិតសាលារៀន(គំរូ
សង្គម និងគំរូអាជីពងាយ)
កម្មវិធីសិក្សាផ្លូវការ

## ឯកសារ ២.១៖ កម្មវិធីសិក្សាដែលបានចរចានៅកម្រិតសាលារៀន

### សេចក្តីណែនាំ

គំរូនៃការងារ៖ ជាដៃគូ

| | |
|---|---|
| (១) ដែលបានចរចា៖<br><br>+ | |
| (២) នៅតាមសាលារៀន៖<br><br>+ | |
| (៣) កម្មវិធីសិក្សា៖ | |
| **សរុបនិយមន័យ៖** | |

## ឯកសារ ២.២៖ ការជ្រើសរើសប្រធានបទ (វីដេអូ)

### សេចក្ដីណែនាំ

គំរូនៃការងារ៖ ជាក្រុមតូច (៣-៤នាក់)

- **ជំហានទី១៖** សូមអានសំណួរខាងក្រោមមុនពេលមើលវីដេអូ វានឹងជួយអ្នកឱ្យយល់អំពីគោលគំនិតសំខាន់ៗដែលបានពន្យល់។
- **ជំហានទី២៖** មើលវីដេអូអំពីដំណើរការជ្រើសរើសប្រធានបទ។
- **ជំហានទី៣៖** ពិភាក្សាក្នុងក្រុម ហើយឆ្លើយសំណួរនៅក្នុងឯកសារចែកជូន។
- **ជំហានទី៤៖** ចែករំលែកចម្លើយរបស់អ្នកនៅក្នុងក្រុម។

**សំណួរ**

- តើនរណាខ្លះចូលរួមនៅក្នុងដំណើរការនេះ?

- តើអ្វីជាសារៈសំខាន់នៃការចូលរួមរបស់តំណាងសហគមន៍ ឪពុកម្ដាយ នាយកសាលា គ្រូបង្រៀន និងសិស្ស?

- តើអ្វីជាអត្ថប្រយោជន៍នៃការជ្រើសរើសប្រធានបទជាមួយអ្នកពាក់ព័ន្ធទាំងអស់នេះ? ហេតុអ្វីបានជាអ្នកគិតថាវាត្រឹមត្រូវ?

- តើអ្នកឃើញបញ្ហាប្រឈមណាមួយដែរឬទេ? តើអ្នកនឹងដោះស្រាយវាដោយរបៀបណា?

## ឯកសារ ២.៣៖ ការកំណត់បញ្ហា

គំរូនៃការងារ៖ ជាក្រុម

រយៈពេល ៤៥នាទី

### សេចក្តីណែនាំ

**ទិសដៅ និងតួនាទី** មនុស្សម្នាក់ក្នុងក្រុមដើរតួជានាយកសាលា។ មនុស្សម្នាក់ដើរតួតំណាងសហគមន៍ មនុស្ស២នាក់ដើរតួជាគ្រូបង្រៀន និងមួយនាក់ទៀតដើរតួជាសិស្ស។ នាយកសាលាមានតួនាទីដឹកនាំការសន្ទនា និងធានាថាបញ្ហាដែលបានស្នើឡើងអនុវត្តតាមលក្ខណៈវិនិច្ឆ័យដែលបានផ្តល់ ហើយចុងក្រោយកំណត់ការរួមចំណែកពីភាគីពាក់ព័ន្ធនីមួយៗ។

**ដំណើរការ**

**ជំហានទី១៖** សមាជិកម្នាក់ៗត្រូវតែជ្រើសរើសប្រធានបទឱ្យបាន ១ទៅ២ ពាក់ព័ន្ធនឹងតួនាទីរបស់ពួកគេ និងព្យាយាមតស៊ូមតិ។

**ជំហានទី២៖** ចុះបញ្ជីប្រធានបទដែលបានកំណត់ និងវិភាគវាដោយប្រើប្រាស់តារាងលក្ខណៈវិនិច្ឆ័យខាងក្រោម៖

- បញ្ហាកើតឡើងញឹកញាប់ (**ញឹកញាប់**)
- បញ្ហាកើតមានមួយរយៈ (**រយៈពេល**)
- បញ្ហាប៉ះពាល់ដល់មនុស្សជាច្រើន ជាពិសេសសិស្ស (**វិសាលភាព ឬទំហំ**)
- បញ្ហាគឺមានសុវត្ថិភាពសម្រាប់សិស្សក្នុងការអង្កេត (**សុវត្ថិភាព**)
- បញ្ហាត្រូវបានគេយល់ថាជាបញ្ហា (**ការយល់ឃើញ**)

| **ប្រធានបទដែលបានស្នើ** | **លក្ខណៈវិនិច្ឆ័យ** | | | | |
|---|---|---|---|---|---|
| | តើវាកើតឡើងញឹកញាប់? | តើវាកើតមានមួយរយៈយូរប៉ុណ្ណា? | តើវាប៉ះពាល់ដល់មនុស្សច្រើន និងសិស្សច្រើនគ្នា? | តើមានសុវត្ថិភាពដើម្បីអង្កេត? | តើបញ្ហាត្រូវបានកំណត់ថាជាបញ្ហាសម្រាប់សហគមន៍ ឬសិស្សដែរឬទេ? |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

- **ជំហានទី៣៖** បន្ទាប់ពីការវិភាគ សូមជ្រើសរើសបញ្ហាពីប្រធានបទដែលត្រូវនឹងលក្ខណៈវិនិច្ឆ័យដែលអ្នកគិតថាពាក់ព័ន្ធបំផុត។

**ចុងក្រោយ ប្រធានបទ៖** …………………………………………………………………………………………….

***កំណត់ចំណាំ៖*** *ប្រធានបទចុងក្រោយត្រូវការបញ្ជាក់ថាពាក់ព័ន្ធនឹងសិស្សដោយកាតីពាក់ព័ន្ធទាំងអស់។*

**ជំហានទី៤៖** គិតអំពីអ្នកដែលអាចមាននៅក្នុងសហគមន៍ ដែលអាចមានចំណេះដឹងលើប្រធានបទ និងរបៀបដែលពួកគេអាចចែករំលែកចំណេះដឹងជាមួយសិស្ស ឬជួយទំនាក់ទំនងជាមួយមនុស្សដែលមានចំណេះដឹង តើករណីនេះនៅពេលណា។

| ល.រ | អ្នកឯកទេស (ឈ្មោះ ឬទំនាក់ទំនង) | តើពួកគេអាចគាំទ្រគម្រោងរបស់សិស្សបានដូចម្តេច? |
|---|---|---|
| ១ | | |
| ២ | | |
| ៣ | | |
| ៤ | | |

**ជំហានទី៥៖** សូមត្រៀមខ្លួនដើម្បីចែករំលែកប្រធានបទរបស់អ្នក ពន្យល់ពីអ្វី និងធ្វើការឆ្លុះបញ្ចាំងចុងក្រោយជាមួយអ្នកសម្របសម្រួល។

## ឯកសារ ២.៤៖ ប្រធានបទ និងការរំពឹងទុកនៃការសិក្សា

**ជំហានទី១៖** ធ្វើការជាក្រុមដើម្បីចុះបញ្ជីប្រធានបទយ៉ាងហោចណាស់ ៥ ដែលតាមគំនិតរបស់អ្នកជាផ្នែកមួយនៃប្រធានបទអាជីពងាយ និង៥ សម្រាប់ប្រធានបទសង្គម។

| ប្រធានបទអាជីពងាយ | ប្រធានបទសង្គម |
|---|---|
| | |

**ជំហានទី២៖** ជ្រើសរើសអាជីពងាយ និងប្រធានបទសង្គមមួយពីប្រធានបទដែលអ្នកបានកំណត់ក្នុងជំហានទី១។ ដោយប្រើក្រដាសផ្ទាំងធំ ថតចម្លងតារាងខាងក្រោម និងប្រើវាដើម្បីបញ្ជាក់លទ្ធផលសិក្សាដែលបានរំពឹងទុកនៅកម្រិតវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។

- កម្រិតវិជ្ជាសម្បទា៖ តើចំណេះដឹងប្រភេទណាដែលពួកគេនឹងរៀន? បានមកពីអ្នកណា និងដោយរបៀបណា?
- កម្រិតបំណិនសម្បទា៖ តើបំណិនប្រភេទណាដែលអ្នកគិតថាសិស្សរបស់អ្នកនឹងប្រសើរឡើង? ហើយដោយរបៀបណា?
- កម្រិតចរិយាសម្បទា៖ តើតម្លៃមួយណាដែលអ្នករំពឹងថានឹងលើកកម្ពស់ ឬសម្រាប់សិស្សរបស់អ្នកក្នុងការរីកចម្រើន?

| លទ្ធផលសិក្សារំពឹងទុក | ប្រធានបទអាជីពងាយដែលបានជ្រើសរើស (…………….. សូមបញ្ជាក់) | ប្រធានបទសង្គមដែលបានជ្រើសរើស (…………….. សូមបញ្ជាក់) |
|---|---|---|
| **វិជ្ជាសម្បទា** | | |
| **បំណិនសម្បទា** | | |
| **ចរិយាសម្បទា** | | |

**ជំហានទី៣៖** ត្រៀមខ្លួនជាស្រេចដើម្បីបង្ហាញខ្លឹមសារនៅក្នុងតារាងដល់ក្រុមទាំងអស់។

## ឯកសារ ២.៥៖ បំណែងចែកកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន-ឧទាហរណ៍លើប្រធានបទ

- **កម្មវិធីលម្អិតបំណិនជីវិតតាមមូលដ្ឋាននៅកម្រិតបឋមសិក្សា៖ ទំព័រទី២៥-២៨**
  កម្មវិធីសិក្សាលម្អិត មុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានសម្រាប់កម្រិតបឋមសិក្សា - សាលាឌីជីថល (moeys.gov.kh)
- **កម្មវិធីលម្អិតបំណិនជីវិតតាមមូលដ្ឋាននៅកម្រិតមធ្យមសិក្សាបឋមភូមិ៖ ទំព័រទី២២-២៥**
  កម្មវិធីសិក្សាលម្អិត មុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានសម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ - សាលាឌីជីថល (moeys.gov.kh)

Handout 2.5 LLS Syllabus-topics examp ឯកសារភ្ជាប់សម្រាប់បោះពុម្ព

# ឯកសារផ្នែកទី២៖ វិធីសាស្ត្រការសិក្សាអាស្រ័យលើបញ្ហា សម្រាប់ការអប់រំបំណិនជីវិតតាមមូលដ្ឋាន

## ឯកសារ ៣.២៖ ការសិក្សាបែបស្ថាបនានិយម និងវិធីសាស្ត្រពាក់ព័ន្ធការសិក្សាបែបស្ថាបនានិយម



## ឯកសារ ៣.៣៖ ឧទាហរណ៍នៃការងារគម្រោងនៅក្នុងថ្នាក់រៀន

**ឧទាហរណ៍ទី១៖** សិស្សថ្នាក់ទី៩ នៅវិទ្យាល័យរំដួល ខេត្តស្វាយរៀង បានសម្រេចចិត្តអង្កេតបញ្ហានៃការបោះបង់ការសិក្សានៅសាលារៀនរបស់ពួកគេ។ តាមពិតទៅពេលចូលរៀនវិញសម្រាប់ឆ្នាំសិក្សាថ្មី មិត្តភក្តិរបស់ពួកគេមួយចំនួនបានឈប់រៀនបន្ទាប់ពីត្រីមាសទីមួយ។ ពួកគេបារម្ភថាប្រហែលពួកគេមិនបានមករៀនវិញទេ។

*សេចក្តីបញ្ជាក់ពីបញ្ហា*

*ការបោះបង់ការសិក្សាមានកម្រិតខ្ពស់បន្ទាប់ពីត្រីមាសទី១*

ដើម្បីដោះស្រាយបញ្ហានេះ សិស្សក្នុងថ្នាក់បានសម្រេចចិត្តចាប់ផ្តើមស្វែងយល់ពីបញ្ហា និងមូលហេតុរបស់វាឱ្យកាន់តែច្បាស់។ ពួកគេបានចាប់ផ្តើមដោយការសម្ភាសជាមួយសិស្សដែលបោះបង់ការសិក្សាមួយចំនួន ប៉ុន្តែក៏មានសហគមន៍ និងក្រុមគ្រួសាររបស់ពួកគេចូលរួមផងដែរ។ ពួកគេបានវិភាគព័ត៌មាន និងបានចាប់ផ្តើមយល់ឃើញថា ការបោះបង់ការសិក្សាទាំងអស់មានលក្ខណៈមួយ ឬច្រើន៖ ឪពុកម្តាយរបស់ពួកគេម្នាក់បានបាត់បង់ការងារនាពេលថ្មីៗនេះ។ ការសិក្សារបស់ពួកគេនៅសាលារៀនគឺខ្សោយណាស់ ពួកគេបានអវត្តមានច្រើនមុនពេលបោះបង់។ រួមគ្នាជាមួយសហគមន៍ សិស្សានុសិស្សបានរៀបចំមូលនិធិមួយដើម្បីជួយដល់គ្រួសារនីមួយៗជារៀងរាល់ខែ តាមលក្ខខណ្ឌក្នុងការចុះឈ្មោះកូនរបស់ពួកគេឡើងវិញ។ ជាមួយគ្នានេះ មាននាយកសាលា ពួកគេបានរៀបចំប្រព័ន្ធមួយដើម្បីបង្កើតការគាំទ្រពីមិត្តភក្តិសម្រាប់សិស្សដែលជួបការលំបាកជាមួយមុខវិជ្ជាមួយចំនួន (ដើម្បីកែលម្អពិន្ទុរបស់ពួកគេឱ្យប្រសើរឡើង) និងតាមដានអវត្តមាន ដែលជាការរំលឹកអំពីហានិភ័យនៃការបោះបង់ការសិក្សា។ មិត្តភក្តិរបស់ពួកគេភាគច្រើនបានត្រឡប់ទៅសាលារៀនវិញ ហើយសហគមន៍កំពុងជួយតាមដានថាពួកគេនៅបន្តការសិក្សា។

*ករណីសិក្សានេះគឺជាឧទាហរណ៍ដ៏ល្អនៃគម្រោងដែលមានការប្រើប្រាស់ជាក់ស្តែងបំផុតនៅក្នុងសេចក្តីសន្និដ្ឋាន។ ក្នុងករណីនេះ សិស្សមួយក្រុមបានកំណត់បញ្ហាជាក់ស្តែងនៅក្នុងសាលារៀន ហើយបានប្រើប្រាស់ថ្នាក់បំណិនជីវិតតាមមូលដ្ឋាន ដើម្បីអង្កេតបញ្ហា និងស្វែងរកដំណោះស្រាយសម្រាប់សាលារៀន ដោយមានការចូលរួមពីសហគមន៍ដែលនឹងបន្តរហូតបន្ទាប់ពីការបញ្ចប់ការអង្កេត។*

**ឧទាហរណ៍ទី២៖** សិស្សមួយក្រុមចាប់អារម្មណ៍នឹងការស្វែងយល់ស៊ីជម្រៅទៅលើគោលការណ៍នៃការស្រូបទឹករបស់រុក្ខជាតិ។ ដើម្បីបង្ហាញពីគោលការណ៍នេះ ក្រុមពួកគេបានដាក់ផ្កាកុលាបស និងបន្លែស្ពៃបូកគោមួយចំនួនទៅក្នុងកែវមានទឹកពណ៌ផ្សេងៗគ្នា។ ពួកគេអង្កេតពីការប្រែពណ៌នៃផ្កា និងបន្លែទាំងអស់នោះ។



*សិស្សបង្ហាញពីគម្រោងមួយលើគោលការណ៍នៃការស្រូបទឹករបស់រុក្ខជាតិដោយប្រើប្រាស់សម្ភារងាយៗដូចជាល័ក្ខអាហារ ផ្កា បន្លែ និងកែវទឹក។*

ទោះជាគម្រោងនេះចប់ទៅ ហើយផលិតផលមិនត្រូវបានយកទៅប្រើប្រាស់បានក៏ពិតមែន តែវាជួយសិស្សឱ្យយល់បានកាន់តែច្បាស់ពីគោលការណ៍សម្រូបទឹកនៃរុក្ខជាតិផ្សេងៗក្នុងមេរៀនជីវៈវិទ្យា។

**ឧទាហរណ៍ទី៣៖** **សុភា** ជាសិស្សថ្នាក់ទី៩ នៃវិទ្យាល័យ ហ៊ុន សែន កំពង់ចាម ក្នុងក្រុងកំពង់ចាម។ **សុភា** និងក្រុមគាត់មានបញ្ហាមួយដែលជួបប្រទះក្នុងសួនជីវៈចម្រុះនៅសាលារៀនរបស់ពួកគេ។ នេះជាការបរិយាយបញ្ហារបស់គាត់៖



*ល្បះបង្ហាញពីបញ្ហា*

*រុក្ខជាតិក្នុងសួនប្រែប្រួលរហូត ថ្ងៃខ្លះរលួយព្រោះស្រោចទឹកច្រើនពេក និងថ្ងៃខ្លះស្រពោនខ្លាំងពេលស្រោចទឹកតិចពេក។*

ដើម្បីដោះស្រាយបញ្ហានេះ **សុភា** សម្រេចចិត្តបង្កើតឧបករណ៍អេឡិចត្រូនិចមួយដើម្បីតាមដានកម្រិតទឹកត្រូវស្រោចស្រពក្នុងសួនដំណាំដោយប្រើចំណេះដឹងសរសេរកូដពីមុខវិជ្ជាកុំព្យូទ័រ និងចំណេះដឹងអេឡិចត្រូនិច បានពីការចូលរួមក្នុងក្លឹបអេឡិចត្រូនិច។ ផ្នែកសំខាន់នៃឧបករណ៍នេះគឺប្រព័ន្ធចាប់ស៊ីញ៉ាល់ (Sensing Device) សំណើមដីក្នុងការកំណត់កម្រិតបរិមាណទឹកឧបករណ៍ត្រូវបិទ ឬបើកបង្ហូរទឹកចូលក្នុងសួនដំណាំដោយស្វ័យប្រវត្តិ។



ករណីសិក្សានេះ ជាឧទាហរណ៍ល្អមួយបង្ហាញពីការសិក្សាបែបគម្រោងបន្សល់ជាផលិតផលដោះស្រាយបញ្ហាទោះជាគម្រោងនេះបានបញ្ចប់ក៏ដោយ។ ក្នុងករណីនេះ សិស្សត្រូវកំណត់បញ្ហាកើតឡើងជាក់ស្តែង និងប្រើប្រាស់ចំណេះដឹងដែលបានសិក្សាក្នុងថ្នាក់ និងក្នុងក្លឹបសិក្សាដើម្បីបង្កើតជាដំណោះស្រាយលើបញ្ហាដែលបានកើតឡើងជាក់ស្តែង។

https://www.facebook.com/NGSAction/videos/540970754473055

## សេចក្តីណែនាំ

1. សម្រាប់ឧទាហរណ៍នីមួយៗ សូមគូសលើវិធីសាស្រ្តដែលពាក់ព័ន្ធ អនុវត្ត (ក្រឡោនទី១)។
2. ពន្យល់ពីជម្រើសរបស់អ្នក តើអ្វីទៅជាធាតុដែលធ្វើឱ្យអ្នកឆ្លើយតប (ក្រឡោនទី២)។

| | ក្រឡោនទី១ | ក្រឡោនទី២ |
|---|---|---|
| ឧទាហរណ៍ទី១ | ☐ ការងារគម្រោង (មូលដ្ឋាន)<br>☐ អាស្រ័យលើគម្រោង<br>☐ អាស្រ័យលើបញ្ហា | ពន្យល់មូលហេតុ៖ |
| ឧទាហរណ៍ទី២ | ☐ ការងារគម្រោង (មូលដ្ឋាន)<br>☐ អាស្រ័យលើគម្រោង<br>☐ អាស្រ័យលើបញ្ហា | ពន្យល់មូលហេតុ៖ |
| ឧទាហរណ៍ទី៣ | ☐ ការងារគម្រោង (មូលដ្ឋាន)<br>☐ អាស្រ័យលើគម្រោង<br>☐ អាស្រ័យលើបញ្ហា | ពន្យល់មូលហេតុ៖ |

## សំណួរបំផុស

- តើអ្វីជាភាពស្រដៀងគ្នា និងភាពខុសគ្នារវាងឧទាហរណ៍ទាំងបីនេះ? (សូមមើលក្រាហ្វិកនៃគោលវិធីការសិក្សាបែបស្ថាបនានិយមព្រមទាំងការរួមបញ្ចូលគោលការណ៍សំខាន់ៗ) ។

- តើមានអត្ថប្រយោជន៍អ្វីខ្លះសម្រាប់សិស្សដើម្បីចូលរួមក្នុងការងារគម្រោង?

## ឯកសារ ៣.១៖ ការសិក្សាបែបស្ថាបនានិយម និងការងារគម្រោង

**ការណែនាំ** នៅក្នុងឯកសារនេះ អ្នកនឹងអាននិយមន័យនៃបញ្ញត្តិសំខាន់ៗចំនួន២ ដែលទាក់ទងដោយផ្ទាល់ជាមួយបំណិនជីវិតតាមមូលដ្ឋាន សម្រាប់វិធីសាស្ត្រនៃការបង្រៀន និងរៀន។ សូមអាននិយមន័យ និងពិភាក្សាជាក្រុមតូចៗ តើអ្វីដែលអ្នកគិតថាជាទំនាក់ទំនងរវាងគំនិតទាំងពីរនេះ។

**និយមន័យ៖ ការសិក្សាស្ថាបនានិយម**

*ការសិក្សាស្ថាបនានិយម ជាគោលវិធីសិក្សាដែលសិស្សសិក្សាយ៉ាងសកម្ម "សាងសង់" បង្កើតចំណេះដឹងដោយខ្លួនឯង និងពីបទពិសោធន៍របស់ពួកគេ។ សិស្សត្រូវធ្វើការឆ្លុះបញ្ចាំងចំណេះដឹង ឬបទពិសោធន៍មានស្រាប់ ឬស្រាវជ្រាវជាក្រុមតាមរយៈការងារគ្រូដាក់ឲ្យ។ ចំណេះដឹងថ្មី ដែលសិស្សបង្កើតមានទម្រង់ជាច្រើនដូចជា ការងារគម្រោង ការធ្វើបទបង្ហាញ ឯកសារបោះពុម្ពរបាយការណ៍ ការសម្តែង ឬផលិផលច្នៃប្រឌិតណាមួយ។*

### គោលការណ៍សំខាន់ៗ

- ការសិក្សាគឺសកម្ម និងដឹកនាំដោយខ្លួនឯង។
- ការសិក្សាដែលបង្កើតលើចំណេះដឹង និងបទពិសោធន៍ពីមុន
- ការឆ្លុះបញ្ចាំងលើការផ្សារភ្ជាប់គ្នារវាងបញ្ញត្តិដើម្បីបង្កើតបញ្ញត្តិថ្មីៗ។
- ការផ្លាស់ប្តូរគំនិតតាមរយៈការសហការជួយបង្កើនដំណើរការបង្កើតគំនិត។

**និយមន័យការសិក្សាបែបគម្រោង**

**វិធីសាស្ត្រសិក្សាបែបគម្រោង** *គឺជាជាវិធីសាស្ត្រសហការគ្នាដែលសម្របសម្រួលដោយគ្រូក្នុងសិក្សាដែលសិស្សទទួលបាន និងអនុវត្តចំណេះដឹង ឬបំណិន ដើម្បីកំណត់ និងដោះស្រាយបញ្ហាជាក់ស្តែងដោយប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវ ឬរិះរក។ ការសិក្សាបែបគម្រោង ជាវិធីសាស្ត្រសិក្សាតាមគោលវិធីសិស្សមជ្ឈមណ្ឌល ដោយសិស្សអនុវត្តផ្ទាល់ទៅតាមស្តង់ដា និងជំហានជាក់លាក់។*

### គោលការណ៍សំខាន់ៗ

ទោះបីជាមានប្រភេទផ្សេងៗនៃការសិក្សាបែបគម្រោងក៏ដោយ ក៏ពួកវាមានលក្ខណៈទូទៅមួយចំនួន៖

- ការសហការ
- ការសិក្សាអនុវត្ត
- ផ្អែកលើការស្រាវជ្រាវ
- ផ្តោតលើផលិតផលច្នៃប្រឌិត

### សំណួរ

បើតាមទស្សនៈរបស់អ្នក តើអ្វីជាទំនាក់ទំនងរវាងគោលវិធីសិក្សាបែបស្ថាបនានិយម និងការងារបែបគម្រោង ?

## ឯកសារ ៣.៤៖ ការសិក្សាអាស្រ័យលើគម្រោង និងអាស្រ័យលើបញ្ហា

ខណៈដែលការសិក្សាអាស្រ័យលើគម្រោង (PrBL) និងការសិក្សាអាស្រ័យលើបញ្ហា (PBL) មានលក្ខណៈស្រដៀងគ្នាមួយចំនួន ពួកវាគឺជាវិធីសាស្ត្របង្រៀនផ្សេងគ្នាដោយផ្តោតលើបច្ចេកទេសខុសៗគ្នា។ នេះជាភាពខុសគ្នាសំខាន់ៗរវាងការសិក្សាអាស្រ័យលើគម្រោង និងការសិក្សាអាស្រ័យលើបញ្ហា៖

| | **ការសិក្សាអាស្រ័យលើគម្រោង** | **ការសិក្សាអាស្រ័យលើបញ្ហា** |
|---|---|---|
| ការផ្តោត និងចំណុចចាប់ផ្តើម | ចាប់ផ្តើមជាមួយនឹងគម្រោង ឬកិច្ចការស្មុគស្មាញដែលបម្រើជាការភ្ជាប់សម្រាប់ការសិក្សា។ ជារឿយៗគម្រោងនេះត្រូវបានរៀបចំឡើងដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងពិភពពិត ឬបញ្ហាពិតប្រាកដ។ | ចាប់ផ្តើមជាមួយនឹងបញ្ហាជាក់លាក់ ឬសេណារីយ៉ូដែលបង្ហាញពីបញ្ហាប្រឈម ឬបញ្ហាដែលត្រូវដោះស្រាយ។ បញ្ហានេះជាកត្តាជំរុញដល់ការសិក្សា និងការសាកសួរ។ |
| ចរិតនៃកិច្ចការ | សិស្សចូលរួមនៅក្នុងគម្រោងស៊ីជម្រៅបន្ថែម ដែលពាក់ព័ន្ធនឹងការស្រាវជ្រាវ ការធ្វើផែនការ ការរៀបចំ និងការបង្កើតផលិតផលជាក់ស្តែង។ | សិស្សធ្វើការលើបញ្ហាដែលមិនមានរចនាសម្ព័ន្ធបើកចំហដែលទាមទារឱ្យមានបំណិនដូចជាការគិតពិចារណាស៊ីជម្រៅ ការវិភាគ និងបំណិនដោះស្រាយបញ្ហា។ ការផ្តោតសំខាន់គឺលើការស្វែងរកដំណោះស្រាយ ឬដំណោះស្រាយចំពោះបញ្ហា។ |
| រចនាសម្ព័ន្ធ និងដំណើរការ | ជារឿយៗការអនុវត្តក្របខណ្ឌគម្រោងដែលមានរចនាសម្ព័ន្ធជាមួយនឹងដំណាក់កាល ឬជំហានដែលកំណត់ ដូចជាការអង្កេត ការធ្វើផែនការ ការបង្កើត និងការធ្វើបទបង្ហាញ។ ដំណើរការនេះជាធម្មតាដឹកនាំដោយគ្រូ ឬអ្នកសម្របសម្រួល។ | សិស្សចូលរួមក្នុងការសាកសួរដឹកនាំដោយខ្លួនឯង ស្រាវជ្រាវ និងការសហការគ្នាដើម្បីកំណត់អត្តសញ្ញាណ និងស្វែងរកដំណោះស្រាយប្រកបដោយសក្តានុពលចំពោះបញ្ហា។ ដំណើរការនេះពាក់ព័ន្ធនឹងការធ្វើឡើងវិញ និងការសម្របខ្លួនជាច្រើន។ |
| ការសហការ និងការទំនាក់ទំនង | កិច្ចសហការត្រូវបានសង្កត់ធ្ងន់ជាញឹកញាប់នៅពេលដែលសិស្សធ្វើការរួមគ្នាជាក្រុមដើម្បីបញ្ចប់គម្រោង និងបង្កើតផលិតផលចុងក្រោយ។ | ការសហការគ្នាគឺចាំបាច់នៅពេលដែលសិស្សធ្វើការរួមគ្នាដោះស្រាយបញ្ហា ចែករំលែកគំនិតយោបល់ និងចូលរួមក្នុងការពិភាក្សា។ ការសង្កត់ធ្ងន់ភាគច្រើនលើការដោះស្រាយបញ្ហាបុគ្គល និងការដោះស្រាយបញ្ហាជាក្រុម ជាជាងការផលិតផលិតផលចុងក្រោយ។ |

**សំណួរឆ្លុះបញ្ចាំង៖** តើអ្វីជាគោលការណ៍ជាក់លាក់នៃការសិក្សាអាស្រ័យលើបញ្ហា?

## ឯកសារ ៣.៥៖ ដំណើរការទាំង ៦ដំណាក់កាល

**សេចក្តីណែនាំ**

ដំណាក់កាលទី១៖ រៀបចំក្រុមដោយមានសមាជិក ៦នាក់ក្នុងមួយក្រុម។

ដំណាក់កាលទី២៖ សមាជិកម្នាក់ៗនៃក្រុមនីមួយៗត្រូវទទួលខុសត្រូវលើ ១ដំណាក់កាល (សរុប ៦ ដំណាក់កាល)។

ដំណាក់កាលទី៣៖ សមាជិកក្រុមនីមួយៗមានទំនួលខុសត្រូវក្នុងការកត់ត្រាលើដំណាក់កាលដែលពួកគេទទួលខុសត្រូវ ខណៈពេលកំពុងមើលវីដេអូ ពួកគេត្រូវបានគេចាត់ទុកថាជា "អ្នកជំនាញ" សម្រាប់ដំណាក់កាលនោះ។

**សំណួរបំផុសអំឡុងពេលមើលវីដេអូសម្រាប់ដំណាក់កាលនីមួយៗ៖**

- តើអ្វីជាវិសាលភាពនៃដំណាក់កាលនេះ?
- តើអ្នកណាពាក់ព័ន្ធ?
- តើសកម្មភាពអ្វីខ្លះដែលអ្នកអាចធ្វើដើម្បីបញ្ចប់ដំណាក់កាលនេះ?
- តើឧបករណ៍មួយណាដែលអ្នកអាចប្រើក្នុងដំណាក់កាលនេះ ប្រសិនបើមាន?

ដំណាក់កាលទី៤៖ បន្ទាប់ពីមើលវីដេអូរួច ឱ្យអ្នកចូលរួមរៀបចំក្រុមឡើងវិញដោយផ្អែកលើដំណាក់កាលដែលពួកគេទទួលខុសត្រូវ (ក្រុមអ្នកជំនាញ)។ សុំឱ្យ "ក្រុមអ្នកជំនាញ" នីមួយៗបញ្ចូលគ្នានូវកំណត់ត្រារបស់ពួកគេហើយយល់ព្រមលើព័ត៌មានសំខាន់បំផុតអំពីដំណាក់កាលដែលពួកគេទទួលខុសត្រូវ។ សម្រាប់ការធ្វើកិច្ចការនេះ ឱ្យអ្នកចូលរួមបែងចែកសន្លឹកក្រដាស ឬទ្រនាប់ចាន (Placemat) មួយផ្នែកដល់អ្នកចូលរួម ដោយមានផ្ទៃនៅកណ្តាល និងតំបន់ដាច់ដោយឡែកគ្រប់គ្រាន់នៅជុំវិញខាងក្រៅ ដើម្បីផ្គូរផ្គងចំនួនសមាជិកក្នុងក្រុម ដូចដែលបានបង្ហាញខាងក្រោម។ សមាជិកនីមួយៗមានផ្នែកមួយសម្រាប់សរសេរកំណត់ត្រារបស់គាត់។




*រូបភាពទី៦៖ ឧទាហរណ៍នៃរបៀបរៀបចំព័ត៌មាននៅក្នុងក្រុមអ្នកជំនាញដែលមានអ្នកជំនាញចំនួន៤នាក់។*

- **ដំណាក់កាលទី ៤ក៖** អ្នកជំនាញនីមួយៗកត់ត្រាការឆ្លើយតបនៅក្នុងចន្លោះដែលបានបែងចែករបស់ពួកគេនៅក្នុងផ្នែកមួយខាងក្រៅ។
- **ដំណាក់កាលទី ៤ខ៖** ឱ្យក្រុមសម្រេចចិត្តជាសមូហភាពលើធាតុសំខាន់ៗ ឬវត្ថុសំខាន់ៗចំនួន៥ ឬការឆ្លើយតប និងកត់ត្រាវានៅចំកណ្ដាលកន្លែងដាក់ ឬវាមានសារៈសំខាន់ដែលសមាជិកក្រុមទាំងអស់យល់ព្រមលើធាតុទាំង៥ ខាងលើ។

ដំណាក់កាលទី៥៖ សមាជិកម្នាក់ៗវិលត្រឡប់ទៅក្រុមដើមវិញ។ ឱ្យសមាជិកក្រុមនីមួយៗចែករំលែកនូវអ្វីដែលពួកគេបានរៀនបន្ទាប់ពីការពិភាក្សាជាមួយក្រុមអ្នកជំនាញ។

ដំណាក់កាលទី៦៖ ត្រៀមខ្លួនដើម្បីឆ្លុះបញ្ចាំងជាមួយក្រុមដែលនៅសល់។

## ឯកសារ ៣.៦៖ ផ្ទាំងប៉ុស្ទ័រដំណើរការទាំង ៦ដំណាក់កាល

### សេចក្តីណែនាំ

ផ្ទាំងប៉ុស្ទ័រនេះតំណាងឱ្យឧទាហរណ៍នៃសកម្មភាពដែលអាចកើតមាន និងបំណិនជីវិតតាមមូលដ្ឋាន ដែលអ្នកអាចអភិវឌ្ឍដល់សិស្ស ខណៈពេលដែលកំពុងអនុវត្តគម្រោងមួយដើម្បីដោះស្រាយបញ្ហា ដោយអនុវត្តតាមដំណើរការទាំង ៦ដំណាក់កាល។




អាចទាញយក៖ https://sala.moeys.gov.kh/contents/65c31a14ac65e6f94cb134b1

# ឯកសារ ៣.៧៖ បំណិនទន់នៅក្នុងប៉ុស្ទ័របំណិនជីវិតតាមមូលដ្ឋាន




ទាញយកពី៖ https://sala.moeys.gov.kh/contents/65c3198aac65e6f94cb134b0

## ឯកសារ ៣.៨៖ ការយល់ដឹងអំពីបំណិនទន់

សេចក្ដីណែនាំ៖ អ្នកចូលរួមទាំងអស់ត្រូវបានរៀបចំជាក្រុម ២-៣នាក់។ ក្រុមនីមួយៗទទួលបានឯកសារមួយទាក់ទងនឹងបំណិនទន់ចំនួន១ ក្រដាសផ្ទាំងធំ និងហ្វឺត ហើយមានឯកសារច្បាប់ចម្លងអំពីដំណើរការទាំង ៦ដំណាក់កាលនៅក្នុងដៃ។

**ជំហានទី១៖** អានឯកសារទាក់ទងនឹងបំណិនទន់ដែលអ្នកទទួលខុសត្រូវ។

**ជំហានទី២៖** ជ្រើសរើសដំណាក់កាលណាមួយនៅក្នុងដំណើរការដែលអ្នកចង់រៀបចំសកម្មភាពជាក់លាក់ដើម្បីជំរុញបំណិននោះដល់សិស្ស។

**ជំហានទី៣៖** កំណត់សកម្មភាព ឬសកម្មភាពនានាដែលអ្នកស្នើឱ្យអនុវត្តដែលត្រូវគ្នានឹងការអភិវឌ្ឍបំណិនបែបនេះ (ដោយប្រើឯកសារ និងព័ត៌មានដែលបានរាយបញ្ជីជាឧទាហរណ៍) បំពេញក្នុងតារាងខាងក្រោមដែលក្រុមនីមួយៗនឹងសរសេរក្នុងក្រដាសផ្ទាំងធំ។

**ជំហានទី៤៖** ជ្រើសរើសវាគ្មិនពីក្រុមរបស់អ្នកដែលនឹងទទួលខុសត្រូវក្នុងការពន្យល់ដល់អ្នកដទៃ និងឆ្លើយសំណួរ។

**ជំហានទី៥៖** ព្យួរក្រដាសផ្ទាំងធំនៅជញ្ជាំងបន្ទប់។ ឱ្យអ្នកចូលរួមផ្លាស់ទីជុំវិញ អានពាក្យនៅលើក្រដាសផ្ទាំងធំ និងសរសេរសំណួរដែលពួកគេមាន។

| | |
|---|---|
| **បំណិនទន់គោលដៅ៖** | |
| **តើអ្នកជ្រើសរើសដំណាក់កាលមួយណា?** | |
| **ពន្យល់សកម្មភាព៖** | |
| *តើសកម្មភាព ឬសកម្មភាពនានា រួមចំណែកក្នុងការជំរុញបំណិនទន់បែបនេះដល់សិស្សរបស់អ្នកយ៉ាងដូចម្ដេច?* | |

## ឯកសារ ៤.១៖ ដើមឈើបញ្ហា និងឬដើមឈើវត្ថុបំណង

**សេចក្តីណែនាំ៖** ករណីសិក្សានេះស្វែងយល់ពីកម្មវិធីឧបករណ៍ដើមឈើបញ្ហាដើម្បីវិភាគ និងដោះស្រាយបញ្ហាគ្រោះថ្នាក់ចរាចរណ៍ក្នុងតំបន់ជាក់លាក់មួយ។ ឧបករណ៍ដើមឈើបញ្ហា គឺជាបច្ចេកទេសដែលមើលឃើញ ដែលជួយកំណត់មូលហេតុឫសគល់នៃបញ្ហា និងបង្កើតដំណោះស្រាយប្រកបដោយប្រសិទ្ធភាព។

សូមអានបញ្ហាដែលបានពិពណ៌នាខាងក្រោម និងរៀបចំព័ត៌មាននៅក្នុងទម្រង់មែកធាងបញ្ហារួមមាន៖

- មានបញ្ហាអ្វី?
- តើអ្វីជាមូលហេតុ?
- តើមានផលប៉ះពាល់អ្វីខ្លះ?

**សារបាន៖**

ការសិក្សានេះផ្តោតលើសង្កាត់ដែលមានការកើនឡើងគួរឱ្យកត់សម្គាល់នៃគ្រោះថ្នាក់ចរាចរណ៍ក្នុងរយៈពេលមួយឆ្នាំកន្លងមក។ សិស្សានុសិស្សនៃវិទ្យាល័យរំដួល បារម្ភពីសុវត្ថិភាពប្រជាពលរដ្ឋ និងចង់ស្វែងយល់ពីមូលហេតុនៃមូលដ្ឋានដើម្បីអនុវត្តវិធានការតាមគោលដៅក្នុងការបង្ការគ្រោះថ្នាក់។

ការកំណត់អត្តសញ្ញាណបញ្ហា៖

ជំហានដំបូងក្នុងការប្រើឧបករណ៍ដើមឈើបញ្ហា គឺដើម្បីកំណត់អត្តសញ្ញាណបញ្ហាស្នូល។ ក្នុងករណីនេះបញ្ហាគឺ "គ្រោះថ្នាក់ចរាចរណ៍"។

ការកំណត់អត្តសញ្ញាណមូលហេតុ៖

**ក) ហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់៖** តំបន់នេះអាចខ្វះហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ត្រឹមត្រូវ រួមទាំងផ្លាកសញ្ញា និងភ្លើងបំភ្លឺ។

**ខ) ការថែទាំផ្លូវមិនបានល្អ៖** ការមិនអើពើថែទាំផ្លូវ អាចជាការចូលរួមចំណែកដល់គ្រោះថ្នាក់។

**គ) ការបើកបរមិនប្រុងប្រយ័ត្ន៖** អ្នកបើកបរមួយចំនួននៅក្នុងតំបន់នេះអាចបង្ហាញឥរិយាបថមិនប្រុងប្រយ័ត្ន ដូចជាការបើកបរលើសល្បឿនកំណត់ បើកបរមិនគោរពភ្លើងចរាចរណ៍ ឬការបើកបរក្នុងស្ថានភាពងងុយគេងដែលបង្កើនលទ្ធភាពនៃគ្រោះថ្នាក់។

**ឃ) ការយល់ដឹងរបស់សាធារណៈជននៅមានកម្រិត៖** ប្រជាពលរដ្ឋ និងអ្នកបើកបរអាចមិនមានការយល់ដឹងគ្រប់គ្រាន់អំពីច្បាប់សុវត្ថិភាពចរាចរណ៍ ដែលបណ្តាលឱ្យមានហានិភ័យខ្ពស់នៃគ្រោះថ្នាក់។

**ការវិភាគទំនាក់ទំនងមូលហេតុ-ផលប៉ះពាល់៖**

នៅពេលដែលមូលហេតុត្រូវបានកំណត់ វិភាគទំនាក់ទំនងមូលហេតុ-ផលប៉ះពាល់។ ទំនាក់ទំនងនៃបុព្វហេតុនីមួយៗជាមួយបញ្ហាស្នូលត្រូវបានពិនិត្យ៖

**ក) ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់មិនគ្រប់គ្រាន់៖** ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់មិនគ្រប់គ្រាន់ប៉ះពាល់ផ្ទាល់ដល់សុវត្ថិភាពចរាចរណ៍ ធ្វើឱ្យគ្រោះថ្នាក់កាន់តែច្រើន។

**ខ) ការថែទាំផ្លូវមិនបានល្អ៖** ការមិនអើពើថែទាំផ្លូវថ្នល់អាចជាការចូលរួមចំណែកដល់គ្រោះថ្នាក់ បង្កើនហានិភ័យនៃគ្រោះថ្នាក់។

**គ) ការបើកបរមិនប្រុងប្រយ័ត្ន៖** ឥរិយាបថបើកបរមិនទទួលខុសត្រូវដោយផ្ទាល់នាំទៅរកការកើនឡើងនៃចំនួនគ្រោះថ្នាក់។

**ឃ) ការយល់ដឹងរបស់សាធារណៈជននៅមានកម្រិត៖** ចំណេះដឹងមិនគ្រប់គ្រាន់នៃច្បាប់សុវត្ថិភាពចរាចរណ៍ និងមិនមានការប្រុងប្រយ័ត្នអាចបណ្តាលឱ្យមានអត្រាគ្រោះថ្នាក់ខ្ពស់។

**ជំហានទី១៖** ដើមឈើបញ្ហា (សរសេរវាឱ្យធំនៅក្នុងក្រដាសផ្ទាំងធំ)៖ ដើម្បីបំពេញ



## ជំហានទី២៖ ដើមឈើវត្ថុបំណង

### ការចង្អុលបង្ហាញ៖

- អានដំណោះស្រាយដែលកំណត់ដោយសិស្ស (ក្នុងអត្ថបទខាងក្រោម)។ រួមបញ្ចូលក្នុងដើមឈើវត្ថុបំណង៖
    - ដំណោះស្រាយជាសកម្មភាព
    - ផលប៉ះពាល់នៃសកម្មភាពបែបនេះ
    - វត្ថុបំណងនៅក្នុងប្រអប់នៅកណ្តាល
- ឆ្លើយសំណួរចុងក្រោយខាងក្រោម។ ត្រៀមខ្លួនចែករំលែកការងាររបស់អ្នកជាមួយក្រុមដែលនៅសល់។

វត្ថុបំណងចុងក្រោយ៖ កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ក្នុងសហគមន៍

ការអភិវឌ្ឍដំណោះស្រាយ៖ បន្ទាប់ពីស្វែងយល់ពីទំនាក់ទំនងផលប៉ះពាល់ អាជ្ញាធរមូលដ្ឋានអាចបង្កើតដំណោះស្រាយគោលដៅដើម្បីដោះស្រាយមូលហេតុដែលបានកំណត់។ ឧទាហរណ៍៖

**ក) កែលម្អហេដ្ឋារចនាសម្ព័ន្ធ៖** ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ដំឡើងផ្លាកសញ្ញាឱ្យបានត្រឹមត្រូវ រៀបចំភ្លើងបំភ្លឺ។

**ខ) ពង្រឹងការថែទាំផ្លូវ៖** បែងចែកធនធានសម្រាប់ការថែទាំផ្លូវជាប្រចាំ ដោះស្រាយបញ្ហាគ្រលុក ជួសជុលផ្ទៃមិនស្មើគ្នា និងជួសជុលស្លាកសញ្ញាតាមផ្លូវដើម្បីធានាបាននូវស្ថានភាពបើកបរប្រកបដោយសុវត្ថិភាព។

**គ) ពង្រឹងការអនុវត្តច្បាប់ចរាចរណ៍៖** បង្កើនវត្តមានប៉ូលិស ពង្រឹងច្បាប់ចរាចរណ៍ឱ្យបានហ្មត់ចត់ និងប្រើប្រាស់កាមេរ៉ាចាប់ល្បឿន ដើម្បីទប់ស្កាត់ការបើកបរមិនប្រុងប្រយ័ត្ន។

**ឃ) លើកកម្ពស់ការយល់ដឹងរបស់សាធារណជន៖** ធ្វើយុទ្ធនាការសុវត្ថិភាពចរាចរណ៍ ចែកចាយសម្ភារអប់រំ និងរៀបចំសិក្ខាសាលារៀនតាមសហគមន៍ ដើម្បីបង្កើនចំណេះដឹងសាធារណៈអំពីច្បាប់សុវត្ថិភាពចរាចរណ៍។

**ដើមឈើវត្ថុបំណង** (សរសេរវាឱ្យធំនៅក្នុងក្រដាសផ្ទាំងធំ)៖ ដើម្បីបំពេញ



**សេចក្ដីសន្និដ្ឋាន៖**

ឧបករណ៍ដើមឈើបញ្ហាផ្ដល់នូវវិធីសាស្ត្ររចនាសម្ព័ន្ធដើម្បីកំណត់អត្តសញ្ញាណឫសគល់បញ្ហានៃគ្រោះថ្នាក់ចរាចរណ៍ និងបង្កើតបានដំណោះស្រាយគោលដៅសម្រាប់ការបង្ការគ្រោះថ្នាក់។ តាមរយៈការប្រើប្រាស់ឧបករណ៍នេះ សិស្សានុសិស្សអាចកំណត់បានពីអត្តសញ្ញាណមូលហេតុចម្បងៗដែលរួមចំណែកដល់អត្រាគ្រោះថ្នាក់ខ្ពស់នៅក្នុងតំបន់ជាក់លាក់ និងកំណត់សកម្មភាពដែលអាចអនុវត្តបានសម្រាប់ការកែលម្អសុវត្ថិភាពចរាចរណ៍ និងកាត់បន្ថយចំនួនគ្រោះថ្នាក់។

## ឯកសារ ៤.២៖ ការកំណត់សកម្មភាព

សេចក្តីណែនាំ៖ សូមអានសកម្មភាពដែលបានកំណត់នៅក្នុងដើមឈើវត្ថុបំណង (សកម្មភាពឯកសារ ៤.១) ហើយឆ្លើយនឹងសំណួរដូចខាងក្រោម៖

**សំណួរ**

១. អ្នកត្រូវជ្រើសរើសសកម្មភាពមួយក្នុងចំណោមសកម្មភាពបន្ថែមទៀតសម្រាប់សិស្ស៖ តើសកម្មភាពអ្វីដែលអ្នកនឹងណែនាំសិស្សឱ្យធ្វើ? ជ្រើសរើសមួយសម្រាប់សិស្សបឋមសិក្សា និងមួយសម្រាប់សិស្សមធ្យមសិក្សា។

សកម្មភាពសិស្សបឋមសិក្សា៖

……………………………………………………………………………………………………

…………………………………………………………………………………………………

សកម្មភាពសិស្សមធ្យមសិក្សា៖

………………………………………………………………………………………………

………………………………………………………………………………………………

២. តើអ្នកជ្រើសរើសសកម្មភាពនេះដោយរបៀបណា? តើអ្នកនឹងអនុវត្តលក្ខខណ្ឌអ្វីខ្លះ? (ឧ. ធនធាន វិសាលភាពនៃសកម្មភាព អាយុ។ល។ )។ សូមរាយក្នុងបញ្ជីលក្ខណៈវិនិច្ឆ័យ ២-៣។

លក្ខណៈវិនិច្ឆ័យទី១៖

……………………………………………………………………………………….

លក្ខណៈវិនិច្ឆ័យទី២៖

……………………………………………………………………………………….

លក្ខណៈវិនិច្ឆ័យទី៣៖

……………………………………………………………………………………….

លក្ខណៈវិនិច្ឆ័យផ្សេងៗ៖

……………………………………………………………………………………………………

…………………………………………………………………………………………….

៣. តើអ្នកអាចកំណត់អត្តសញ្ញាណបញ្ហាប្រឈមណាមួយដែលសាលារៀនរបស់អ្នកអាចប្រឈមមុខក្នុងការអនុវត្តសកម្មភាពនេះទេ បើមាន?

## ឯកសារទី៤.៣៖ ការបង្កើតក្រុមអនុវត្តការសិក្សាបែបគម្រោងប្រកបដោយប្រសិទ្ធភាព និងតុល្យភាព

### ភាពខុសគ្នារវាងក្រុម និងជីម

ក្នុងការសិក្សាបែបគម្រោង ផ្នែកសំខាន់មួយនៃការអនុវត្តគឺការបង្កើតក្រុមធ្វើគម្រោង។ ហេតុអ្វីយើងត្រូវការសិស្សធ្វើការជាជីម ដែលមិនមែនធ្វើការជាក្រុមធម្មតា? ពិនិត្យមើលពីភាពដូចគ្នា និងខុសគ្នារវាងក្រុម និងជីម[4]។

| | ក្រុម | ជីម |
| --- | --- | --- |
| **អាទិភាព** | សមាជិកក្រុមម្នាក់ៗមានអាទិភាពការងារផ្សេងៗគ្នា តែធ្វើការជាមួយគ្នាបានបើមានបទពិសោធន៍ និងចំណាប់អារម្មណ៍ដូចគ្នា | សមាជិក្រុមទាំងអស់មានអាទិភាពការងាររួមដូចគ្នា |
| **គោលដៅ** | សមាជិកម្នាក់ៗមានគោលដៅរៀងខ្លួន | សមាជិកទាំងអស់មានគោលដៅរួមដូចគ្នា |
| **ការធ្វើការងារ** | សមាជិកក្រុមធ្វើការរៀងៗខ្លួន | សមាជិកធ្វើការរួមគ្នា |
| **គណនេយ្យភាព** | មានគណនេយ្យភាពបុគ្គល(និងជាមួយគ្រូ) | មានគណនេយ្យភាពបុគ្គល និងសមាជិកទាំងអស់(និងជាមួយគ្រូ) |
| **ភាពជាអ្នកដឹកនាំ** | ទូទៅមានអ្នកដឹកនាំម្នាក់ចាត់ចែងកិច្ចការក្រុម | អ្នកដឹកនាំម្នាក់ (ឬច្រើននាក់) ជាអ្នកសម្របសម្រួលជួយសមាជិកទាំងអស់ឱ្យធ្វើការសហការក្រុមដើម្បីសម្រេចគោលបំណងរួម |
| **ផលិតផល** | សមាជិកម្នាក់ៗមានលទ្ធផលផ្សេងៗគ្នា | សមជិកទាំងអស់បង្កើតបានលទ្ធផលរួមគ្នាមួយ |

[4] Herrity, J. (2022, December 23). *Group vs. Team: What's the Difference?* Retrieved February 1, 2023, from https://www.indeed.com/career-advice/career-development/group-vs-team.

សិស្សដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នា ដោយមានគោលដៅរួមគ្នា និងបង្កើតផលិតផលតែមួយ វាទំនោរទៅរកការអភិវឌ្ឍបំណិនសំខាន់ៗក្នុងសតវត្សរ៍ទី២១ នេះ។

## តួនាទីសមាជិកធីម



គ្រូបង្រៀន និងសិស្សទាំងអស់សុទ្ធតែមានបទពិសោធន៍អនុវត្តគម្រោងអ្វីមួយដែលមានលទ្ធផលមិនគាប់ចិត្ត ឬបរាជ័យ ដោយសារតែសមាសភាពក្រុមមិនល្អ។ ប្រហែលជាអាចមកពីចំណុចទាំងអស់ខាងក្រោម៖

- សំបូរសមាជិកចូលចិត្តដើរខ្សែលើគេ ហើយក្រុមមិនអាចសម្រេចការងារបាន
- សំបូរសមាជិកយកចិត្តទុកដាក់ពីផ្នែកនីមួយៗល្អិតល្អន់ពេក តែមិនមានសមាជិកជា **អ្នករៀបចំ** ដើម្បីបញ្ចូលផ្នែកទាំងអស់ឱ្យរួមគ្នាបាន។
- បុគ្គលិកលក្ខណៈមិនត្រូវគ្នា ដែលធ្វើឱ្យសមាជិកទាំងអស់ពិបាកធ្វើការជាមួយគ្នា។

ហានិភ័យទាំងនេះអាចកាត់បន្ថយបាន ប្រសិនបើគ្រូឆ្លុះបញ្ចាំងដោយយកចិត្តទុកដាក់លើបុគ្គលិកលក្ខណៈរបស់សិស្ស និងតួនាទីចាំបាច់សម្រាប់ប្រសិទ្ធភាពធីម។

ទីប្រឹក្សាលើការស្រាវជ្រាវ និងគ្រប់គ្រង លោកវេជ្ជបណ្ឌិត មេរេឌិត ប៊ែលប៊ីន (Meredith Belbin) បានកំណត់តួនាទីចំនួន៩ ត្រូវការសម្រាប់ធីមមួយឱ្យដំណើរការល្អ[5]។ តួនាទីទាំងនេះត្រូវបានបំបែកជា ៣ប្រភេទ៖ អ្នកផ្តោតលើសកម្មភាព អ្នកផ្តោតលើគំនិត អ្នកផ្តោតលើមនុស្ស[6]។ ក្រុមដែលមានប្រសិទ្ធភាពការងារល្អមានសមាសភាពនៃតួនាទីទាំងអស់នេះ។

[5] Belbin, M. R. (2010). *Management Teams: Why They Succeed or Fail.* Butterworth-Heinemann.
[6] Team Asana (2021, August 16). *Team roles: 9 types to create a balanced team.* Retrieved February 1, 2023, from https://asana.com/resources/team-roles.

### អ្នកផ្តោតលើសកម្មភាព

**អ្នកអនុវត្ត**
អនុវត្ត រក្សាសណ្តាប់ធ្នាប់ ធ្វើឲ្យគំនិតលេចចេញជាលទ្ធផល មានវិន័យ

**អ្នកជំរុញ**
ជំរុញក្រុមឲ្យទៅមុខ ជាអ្នកដឹកនាំ និងជាអ្នករកដំណោះស្រាយលឿនពេលជួបបញ្ហា

**អ្នកបញ្ចប់**
ជាអ្នកពិនិត្យពិច័យល្អិតល្អន់ ផ្តោតលើគុណភាពខ្ពស់ ហើយជាទូទៅជាមនុស្សអៀនច្រើន

### អ្នកផ្តោតលើគំនិត

**អ្នកពិនិត្យតាមដាន**
មានយុទ្ធសាស្ត្រច្រើន មានចំណេះដឹងច្រើន

**អ្នកអនុវត្តបង្កើតថ្មី**
មានគំនិតច្នៃប្រឌិត ពូកែប្រមូលគំនិត ហើយចែករំលែក ទូទៅចូលចិត្តធ្វើការងារតែម្នាក់ឯង

**អ្នកមានឯកទេស**
ស្ទាត់ជំនាញលើផ្នែកណាមួយ ហើយធ្វើការម្នាក់ឯងបានផលច្រើនជាង

### អ្នកផ្តោតលើមនុស្ស

**អ្នកពូកែអង្កេត**
រកឱកាសថ្មីៗ មនុស្សចូលចិត្តបង្កើតទំនាក់ទំនង

**អ្នកគាំទ្រធីម**
ជាអ្នកគាំទ្រ អ្នកពូកែស្តាប់ ជាអ្នកបង្កើតសុខដុមក្រុម សម្របខ្លួនបាន

**អ្នកសម្របសម្រួល**
អ្នកពូកែទំនាក់ទំនង
អ្នកលើកទឹកចិត្ត
អ្នកសហការដ៏ល្អ
អ្នកគួរឲ្យទុកចិត្តបាន

## ភាពចម្រុះនៃតួនាទីក្រុម

ក្នុងសាលារៀនជាក់ស្តែង តួនាទីក្រុមមានភាពច្បាស់លាស់ ដោយក្រុមមួយកើតឡើងពីសមាជិកដែលមានចំណាប់ចំណូលចិត្តប្រហាក់ប្រហែលគ្នា និងចុះសម្រុងគ្នា តែលទ្ធផលអាចមិនល្អ។



ជាទូទៅ ការបែងចែកក្រុមដូចខាងក្រោមអាចបង្កជាបញ្ហាសម្រាប់សិស្សពេលអនុវត្តគម្រោង៖

- មានសិស្សតែមួយប្រភេទ៖ ក្រុមមួយមានតែសមាជិកជាប្រភេទអ្នកផ្តោតលើគំនិតតែម្យ៉ាង ដូចនេះពួកគេមិនអាចជំរុញគំនិតនោះទៅជាផលិផលមានគុណភាពខ្ពស់បានទេ ហើយមួយវិញទៀតពួកគេប្រហែលមិនសូវមានទំនាក់ទំនងល្អជាមួយគ្នា។
- ការបាត់តួនាទីណាមួយ៖ ការខ្វះតួនាទីណាមួយក្នុងក្រុម អាចជាបញ្ហាបើក្រុមមួយមិនមានសមាជិកណាម្នាក់ទទួលតួនាទីជាអ្នកបញ្ចប់នោះទេ ក្រុមនោះមិនអាចមានគំនិតបង្កើតផលិតផលអស្ចារ្យណាមួយ ប៉ុន្តែផលិតផលផលិតមិនអាចនឹងមានគុណភាពខ្ពស់ ព្រោះមិនមានតួនាទីអ្នកបញ្ចប់ ត្រួតពិនិត្យគុណភាពផលិតផលសម្រេចនោះឡើងវិញ។

គ្រូបង្រៀនអាច៖

- ស្វែងយល់ឱ្យបានច្បាស់ពីភាពខ្លាំង ចំណាប់អារម្មណ៍ និងបុគ្គលិកលក្ខណៈរបស់សិស្ស។

- មានបច្ចេកទេសពេលបង្កើតក្រុមធ្វើការងារគម្រោង។
- ប្រាកដថាក្រុមនីមួយៗមានយ៉ាងហោចណាស់សិស្សម្នាក់អាចដើរតួនាទីមួយក្នុងចំណោមទាំង ៣ - អ្នកផ្តោតលើសកម្មភាព អ្នកផ្តោតលើគំនិត និងអ្នកផ្តោតលើមនុស្ស។



### គម្រោងបណ្តុះបំណិន

"សិស្សានុសិស្សអភិវឌ្ឍខ្លួនតាមមធ្យោបាយផ្សេងៗគ្នាជាច្រើន។ គ្រូបង្រៀនត្រូវទទួលស្គាល់ថា សិស្សម្នាក់ៗប្រហែលមិនមែនជាអ្នកអង្កេតដែលមានជំនាញ ពួកគេបង្ហាញពីទំនោរពីធម្មជាតិនៅក្នុងសង្គមជាក់ស្តែងដែលអាចក្លាយជាអ្នកបណ្តាញ។ សិស្សម្នាក់ទៀតប្រហែលមិនមានទំនុកចិត្តធ្វើជាអ្នកអនុវត្តដ៏ពូកែ ប៉ុន្តែគាត់មានបំណិនធ្វើផ្នែកនេះខ្លះដែរ។ គ្រូត្រូវមានភាពឆ្លាតវៃក្នុងការតម្រង់ទិសសិស្សឱ្យត្រូវនឹងតួនាទីពួកគេ ដើម្បីជំរុញការលូតលាស់ បង្កើតការសិក្សាបែបគម្រោងបែបបណ្តុះបំណិន ជាឱកាសសម្រាប់ពួកគេអភិវឌ្ឍខ្លួន"។

## ឯកសារ ៥.១៖ ការកសាងប្រអប់ឧបករណ៍ ICT របស់អ្នក៖ ស្វែងរកផ្នែកឧបករណ៍ប្លែកៗ

**បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT)** សំដៅលើឧបករណ៍ និងបច្ចេកវិទ្យាដែលប្រើដើម្បីបង្កើត រក្សាទុក បញ្ជូន និងផ្លាស់ប្តូរព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិក។

### នៅក្នុងវិស័យអប់រំ ICT ដើរតួនាទីសំខាន់ដូចជា៖

- **ការកែលម្អការសិក្សា៖** ឧបករណ៍ ICT អាចធ្វើការសិក្សាមានភាពទាក់ទាញយ៉ាងខ្លាំង ចូលរួម និងការសិក្សាបែបសិស្សមជ្ឈមណ្ឌល។
- **ការកែលម្អការចូលប្រើប្រាស់ព័ត៌មាន៖** សិស្សអាចចូលប្រើប្រាស់ធនធានអប់រំ និងព័ត៌មានយ៉ាងច្រើននៅតាមអនឡាញ។



*សិស្សប្រជុំជាមួយមិត្តភក្តតាមរយៈកម្មវិធី Zoom*

- **ការអភិវឌ្ឍន៍បំណិនអក្ខរកម្មឌីជីថល៖** ការរួមបញ្ចូល ICT ផ្តល់ឱ្យសិស្សនូវបំណិនសំខាន់ៗសម្រាប់យុគសម័យឌីជីថល ដូចជាការគិតពិចារណាស៊ីជម្រៅ ការដោះស្រាយបញ្ហា និងព័ត៌មានសារគមនាគមន៍។
- **ការលើកកម្ពស់កិច្ចសហការ និងការប្រាស្រ័យទាក់ទងគ្នា៖** ឧបករណ៍ ICT ជួយសម្រួលដល់ការទំនាក់ទំនង និងការសហការគ្នារវាងសិស្ស លោកគ្រូ អ្នកគ្រូ និងឪពុកម្តាយ។
- **គាំទ្រការបង្រៀនតាមតម្រូវការសិស្ស៖** គ្រូបង្រៀនអាចប្រើប្រាស់ឧបករណ៍ ICT ដើម្បីបំពេញតាមបែបបទ និងតម្រូវការសិក្សារបស់សិស្ស។
- **លើកកម្ពស់ការអនុវត្តការវាយតម្លៃ៖** ឧបករណ៍ទាក់ទាញអាចផ្តល់នូវការវាយតម្លៃជាដំណាក់ និងការវាយតម្លៃបូកសរុប។

តាមរយៈការបញ្ចូលឧបករណ៍ ICT ប្រកបដោយប្រសិទ្ធភាព អ្នកអប់រំអាចបង្កើតបរិយាកាសថាមវន្ត (Dynamic) និងការសិក្សាប្រកបដោយប្រសិទ្ធភាពបន្ថែមទៀតដល់សិស្ស។ ឯកសារនេះណែនាំអ្នកចូលរួមអំពីប្រភេទផ្សេងៗគ្នានៃឧបករណ៍ ICT ដែលអាចបញ្ចូលទៅក្នុងមេរៀនទូទៅដើម្បីបង្កើនការរៀនសូត្រ និងការចូលរួមរបស់សិស្ស។




**ផ្នែក និងការបរិយាយសង្ខេប ឬឧបករណ៍ឧទាហរណ៍សម្រាប់ផ្នែកនីមួយៗ**

| ផ្នែក | ការបរិយាយសង្ខេប | ឧបករណ៍ ឧទាហរណ៍ | គេហទំព័រ ឬបញ្ជីកម្មវិធី |
|---|---|---|---|
| ការគ្រប់គ្រងថ្នាក់រៀន | ជ្រើសរើសសិស្សសម្រាប់ការចូលរួម រៀបចំក្រុមៗលៗ និងគ្រប់គ្រងពេលវេលាប្រកបដោយប្រសិទ្ធភាពក្នុងអំឡុងពេលធ្វើសកម្មភាព និងធ្វើកិច្ចការ។ | Online Random Name Pickers<br><br>Picker Wheel<br><br>Online Stopwatches and Timers | https://www.online-stopwatch.com/, https://old.wheelofnames.com/, https://wheelofnames.com/, https://random.onl/<br><br>https://pickerwheel.com/<br><br>https://www.online-stopwatch.com/, https://countingdownto.com/, https://www.bigtimer.net/ , https://www.tickcounter.com/ |
| ការបង្កើត និងការបំផុសគំនិត | រៀបចំគំនិតដោយមើលឃើញ បំផុសគំនិតប្រធានបទ និងបង្កើតគំនិត។ បង្កើត | **Mind Mapping Tools** (e.g., Miro, Coggle, XMind)<br><br>Digital Whiteboards (e.g | https://miro.com/, https://coggle.it/, https://xmind.app/<br><br>https://jamboard.google.com/, https://miro.com/) – |

| | | | |
|---|---|---|---|
| | ក្រុមប្រឹក្សាអនឡាញ ដែលសហការគ្នា សម្រាប់វគ្គបំផុស គំនិត បទបង្ហាញ និងការចែករំលែក គំនិតក្នុងពេលជាក់ស្តែង។ រៀបចំ តំណាងនៃពាក្យ ឬ គំនិតឱ្យបានញឹក ញាប់ដែលលេច ឡើងក្នុងដំណើរការ បំផុសគំនិត | Google Jamboard, Miro)<br><br>**Word Cloud Generators** (e.g. Wordart) | https://wordart.com/, https://monkeylearn.com/word-cloud/, https://stormboard.com/, https://mural.co/, https://www.ayoa.com/) |
| កម្មវិធីរចនា និង ការបង្កើត មាតិកា | ឧបករណ៍រចនា ដូច ជា Photoshop, Canva ជាដើម។ ល។ (សម្រាប់បង្កើត រូបភាព ការធ្វើបទ បង្ហាញ ក្រាហ្វិច) | Photoshop | កម្មវិធី Windows ឬចូលមើល៖ https://www.photopea.com |
| | | Canva | https://www.canva.com |
| | | Illustrator | កម្មវិធី Windows |
| | | GIMP | កម្មវិធី Windows ឬចូលមើល៖ https://www.gimp.org |
| | | Krita | កម្មវិធី Windows ឬចូលមើល៖ https://krita.org |
| | | Paint | កម្មវិធី Windows ឬចូលមើល៖ https://www.microsoft.com/en-us/windows/paint |
| ប្រព័ន្ធគ្រប់គ្រង ការសិក្សា | ទម្រង់ដូចជា Moodle, Canvas, ។ល។ (សម្រាប់ គ្រប់គ្រងវគ្គសិក្សា តាមអនឡាញ ចែក រំលែកមាតិកា ការ វាយតម្លៃ) | Classroom | https://classroom.google.com |
| | | Band | https://band.us |
| | | Moodle | https://moodle.org |
| | | Talent LMS | https://www.talentlms.com |
| | | Weteka | https://weteka.org/kh |
| | | Sala | https://sala.moeys.gov.kh/kh |
| | | Canvas | https://www.instructure.com |

| | | | |
|---|---|---|---|
| ទំនាក់ទំនង | អ៊ីម៉ែល កម្មវិធីផ្ញើសារ (សម្រាប់ទំនាក់ទំនងរវាងសិស្ស គ្រូបង្រៀន និងមាតាបិតាសិស្ស) | Email | https://mail.google.com |
| | | Messenger | https://www.messenger.com |
| | | Whatsapp | https://web.whatsapp.com |
| | | We Chat | https://www.wechat.com/ |
| | | Band | https://band.us |
| | | Line | https://line.me |
| | | Telegram | https://telegram.org |
| ថតលើអេក្រង់ | ឧបករណ៍សម្រាប់ថតសកម្មភាពលើអេក្រង់ (សម្រាប់បង្កើតវីដេអូបង្រៀនបង្ហាញជាក់ស្តែង ធ្វើបទបង្ហាញ) | Camtasia | កម្មវិធី Windows ឬចូលមើល៖ https://www.techsmith.com/video-editor.html |
| | | Filmora | កម្មវិធី Windows ឬចូលមើល៖ https://filmora.wondershare.net |
| | | Gilisoft, | កម្មវិធី Windows ឬចូលមើល៖ https://www.gilisoft.com/product-video-recorder.htm |
| | | Movavi | កម្មវិធី Windows ឬចូលមើល៖ https://www.movavi.com |
| | | OBS | https://obsproject.com |
| | | PowerPoint | កម្មវិធី Windows ឬចូលមើល៖ |
| កាត់តវីដេអូ | ឧបករណ៍សម្រាប់កាត់ត និងរៀបចំឈុតវីដេអូ (សម្រាប់បង្កើតវីដេអូអប់រំ បទបង្ហាញ) | Camtasia | https://www.techsmith.com/video-editor.html |
| | | Sony Vegas | កម្មវិធី Windows ឬចូលមើល៖ https://www.vegascreativesoftware.com |
| | | Adobe Premiere | កម្មវិធី Windows ឬចូលមើល៖ https://www.adobe.com/products/premiere.html |
| | | Movavi Kine | កម្មវិធី Windows ឬចូលមើល៖ https://www.movavi.com |

| | | | |
|---|---|---|---|
| | | Master | កម្មវិធីលើទូរស័ព្ទ ថេបប្លេត ឬ Ipad ឬចូលមើល៖ https://kinemaster.com |
| | | Filmora, | កម្មវិធី Windows ឬចូលមើល៖ https://filmora.wondershare.net |
| ការវាយតម្លៃ | ឧបករណ៍ដែលទាក់ទាញសម្រាប់ធ្វើតេស្ត ការស្ទង់មតិ និងការវាយតម្លៃជាដំណាក់ (សម្រាប់ការវាយតម្លៃជាដំណាក់ និងបូកសរុប) | Quizizz | https://quizizz.com |
| | | Kahoot | https://kahoot.com |
| | | Mentimeter | https://www.mentimeter.com |
| | | Kobo | https://www.kobotoolbox.org |
| | | Blooket | https://www.blooket.com |
| | | Wordwall | https://wordwall.net |
| | | Nearpod | https://nearpod.com |
| | | Band | https://band.us |
| ឯកសារ និងតារាង | ដំណើរការសរសេរ ការធ្វើតារាង និងកម្មវិធីធ្វើបទបង្ហាញ (សម្រាប់បង្កើតឯកសារ របាយការណ៍ បទបង្ហាញ) | Ms. Word | កម្មវិធី Windows |
| | | Ms. Excel | កម្មវិធី Windows |
| | | Ms. PowerPoint | កម្មវិធី Windows |
| | | Docs, | https://docs.google.com |
| | | Sheets, | https://spreadsheets.google.com |
| | | Slides, | https://docs.google.com |
| | | Canva | https://www.canva.com |
| ការប្រជុំ និងការសហការ | វេទិកាអនឡាញសម្រាប់ការប្រជុំ និងការងារសហការ (សម្រាប់ថ្នាក់អនឡាញ គម្រោងក្រុម) | Meet | https://meet.google.com |
| | | Ms. Teams | កម្មវិធី Windows ឬចូលមើល៖ https://teamsdemo.office.com |
| | | Jitsi Meet | https://meet.jit.si |
| | | Zoom | https://zoom.us |
| កម្មវិធីខ្លោត | វេទិកាសម្រាប់រក្សាទុក និងចូលប្រើឯក | G. Drive | https://drive.google.com |
| | | Drop-box | https://www.dropbox.com |

| | | | |
|---|---|---|---|
| | សារតាមអ៊ីនធឺណិត (សម្រាប់ការចែករំលែកធនធានឯកសារ ការរក្សាទុក) | iCloud | https://www.icloud.com |
| | | One Drive | https://onedrive.live.com |
| **បញ្ញាសិប្បនិម្មិត (AI)៖** | AI អាចដោះស្រាយបញ្ហាប្រឈមដ៏ធំបំផុតមួយចំនួននៅក្នុងការអប់រំនាពេលបច្ចុប្បន្ននេះ បង្កើតថ្មីការអនុវត្តការបង្រៀន និងការរៀន និងការពន្លឿនដំណើរការឆ្ពោះទៅរកគោលដៅអប់រំ។ វាអាចកំណត់ការរៀនដោយខ្លួនឯង ធ្វើចំណាត់ថ្នាក់ដោយស្វ័យប្រវត្តិ ផ្តល់ព័ត៌មានត្រឡប់ និងអ្វីៗជាច្រើនទៀត។ | Chat GPT | https://openai.com |
| | | Bing Chat | https://www.bing.com/chat |
| | | Bing Image | https://www.bing.com/images/create |
| | | Gemini | https://gemini.google.com/ |

## ឯកសារ ៥.២៖ ការបញ្ចូល ICT ទៅក្នុងដំណាក់កាលទាំង៦ នៃការអប់រំបំណិនជីវិតតាមមូលដ្ឋាន

ឯកសារនេះផ្តល់ទិដ្ឋភាពសង្ខេបនៃវិធីដែលឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍អាចត្រូវបានគេបញ្ចូលទៅក្នុងដំណាក់កាលនីមួយៗនៃដំណើរការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន។

### ដំណាក់កាលទី១៖ ស្វែងយល់ពីប្រធានបទ

- **គោលដៅ៖** ណែនាំប្រធានបទបំណិនជីវិត និងវាស់វែងពីបុរេពុទ្ធិ។
- **ឧបទាហរណ៍នៃឧបករណ៍ ICT ៖**
    - ធ្វើតេស្តតាមអនឡាញ( ឧ.Kahoot!, Quizizz ) ដើម្បីវាស់វែងការយល់ដឹងមូលដ្ឋាន
    - វីដេអូអប់រំ និងគំនូរជីវចលដែលពាក់ព័ន្ធនឹងប្រធានបទបំណិនជីវិតតាមមូលដ្ឋាន
    - សូហ្វែផែនទីគំនិត( ឧ. Miro,Coggle )សម្រាប់ប្រមូលគំនិត និងរៀបចំចំណេះដឹង

### ដំណាក់កាលទី២៖ ការប្រមូលព័ត៌មានពីសហគមន៍

- **គោលដៅ៖** ប្រមូលទិន្នន័យ និងទិដ្ឋភាពផ្សេងៗពីសមាជិកសហគមន៍។
- **ឧទាហរណ៍នៃឧបករណ៍ ICT៖**
    - ការស្ទង់មតិតាមអនឡាញ( ឧ. Google Forms ) ដើម្បីប្រមូលធាតុចូលពីសហគមន៍
    - ឧបករណ៍ថតបែបឌីជីថល ឬកម្មវិធីស្មាតហ្វូនសម្រាប់ការសម្ភាសជាសំឡេង ឬវីដេអូ
    - ឧបករណ៍បង្កើតឯកសារសហការ ( ឧ. Google Docs ) សម្រាប់ការកត់ត្រាជាក្រុម និងការវិភាគទិន្នន័យ

### ដំណាក់កាលទី៣៖ ការវិភាគព័ត៌មានជាមួយដើមឈើបញ្ហា

- **គោលដៅ៖** រៀបចំ និងវិភាគព័ត៌មានដែលប្រមូលបានដើម្បីកំណត់ឫសគល់បញ្ហា។
- **ឧបទាហរណ៍នៃឧបករណ៍ ICT ៖**
    - កម្មវិធីធ្វើបទបង្ហាញ ( ឧ. Google ស្លាយ ) ដើម្បីបង្កើតដើមឈើបញ្ហាច្បាស់ និងទាក់ទាញដោយមើលឃើញ។
    - ឧបករណ៍រៀបចំផែនទីគំនិតតាមអ៊ីនធឺណិត ( ឧ. Miro, XMind ) សម្រាប់ការអភិវឌ្ឍមែកធាងបញ្ហារួមគ្នា។

## ដំណាក់កាលទី៤៖ ការអភិវឌ្ឍផែនការសកម្មភាពផ្សព្វផ្សាយ

- **គោលដៅ៖** ធ្វើផែនការ និងរៀបចំសកម្មភាពផ្សព្វផ្សាយដល់សហគមន៍
- **ឧបទាហរណ៍នៃឧបករណ៍ ICT៖**
    - ឧបករណ៍គ្រប់គ្រងគម្រោង ( ឧ. Trello, Asana ) សម្រាប់ការបែងចែកភារកិច្ច និងតាមដានវឌ្ឍនភាព។
    - វេទិកាទំនាក់ទំនងតាមអ៊ីនធឺណិត ( ឧ. ក្រុម WhatsApp, ក្រុមហ្វេសប៊ុក ) សម្រាប់ការពិភាក្សាជាក្រុម និងការធ្វើបច្ចុប្បន្នភាព។

## ដំណាក់កាលទី៥៖ ការអនុវត្តផែនការនៅក្នុងសហគមន៍

- **គោលដៅ៖** អនុវត្តសកម្មភាពផ្សព្វផ្សាយតាមផែនការនៅក្នុងសហគមន៍។
- **ឧបទាហរណ៍នៃឧបករណ៍ ICT៖**
- ហ្គេមអប់រំ ( ឧ. Kahoot!, Mentimeter ) ដើម្បីធ្វើឱ្យការរៀនមានអន្តរកម្ម និងការចូលរួមក្នុងអំឡុងពេលសិក្ខាសាលា។
- ឧបករណ៍និទានរឿងឌីជីថល ( ឧ. Spark Adobe, Canva ) សម្រាប់បង្កើតបទបង្ហាញ ឬព័ត៌មានក្រាហ្វិកសម្រាប់យុទ្ធនាការផ្សព្វផ្សាយសហគមន៍។



*សិស្សានុសិស្សធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាបំណិនជីវិតតាមមូលដ្ឋានរបស់ពួកគេទៅសហគមន៍*

## ដំណាក់កាលទី៦៖ ការឆ្លុះបញ្ចាំង និងការវាយតម្លៃ

- **គោលដៅ៖** ឆ្លុះបញ្ចាំងស្តីពីដំណើរការ វាយតម្លៃផលជះ និងកំណត់កន្លែងសម្រាប់កែលម្អ។
- **ឧបទាហរណ៍នៃឧបករណ៍ ICT៖**
    - វេទិកាអ៊ិនធឺណិត ( ឧ.ការពិភាក្សាតាម Google Classroom ) សម្រាប់ការឆ្លុះបញ្ចាំងក្រុម និងចែករំលែកព័ត៌មានត្រឡប់

## ឯកសារចែកជូន ៥.៣ បំណិន និងគុណវុឌ្ឍិសម្រាប់អាជីព ICT នៅកម្ពុជា

នេះជាទិដ្ឋភាពសង្ខេបនៃបំណិន និងគុណវុឌ្ឍិដែលត្រូវការសម្រាប់អាជីព ICT មួយចំនួនដែលបាន លើកឡើង៖

| អាជីព | បំណិន | គុណវុឌ្ឍិ |
|---|---|---|
| **១. អ្នកបង្កើតគេហទំព័រ និងអ្នករចនា** | •បំណិនបច្ចេកទេស៖ HTML, CSS, JavaScript (ការអភិវឌ្ឍផ្នែកខាងមុខ) ភាសាដែលមានសក្តានុពលដូចជា (Python ឬ PHP)។<br><br>• បំណិនរចនា៖ ចំណុចប្រទាក់អ្នកប្រើ (UI) និងបទពិសោធន៍អ្នកប្រើប្រាស់ (UX) គោលការណ៍រចនា ការយល់ដឹងជាមូលដ្ឋាននៃគោលការណ៍រចនាក្រាហ្វិក។<br><br>• បំណិនទន់៖ ការដោះស្រាយបញ្ហា ការទំនាក់ទំនង ការសហការ ការយកចិត្តទុកដាក់ចំពោះព័ត៌មានលម្អិត។ | បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ការអភិវឌ្ឍគេហទំព័រ ឬផ្នែកដែលពាក់ព័ន្ធ។ ផលប័ត្រដែលបង្ហាញពីបំណិនអភិវឌ្ឍន៍គេហទំព័រមានតម្លៃ។ |
| **២.អ្នកបង្កើតកម្មវិធី និងអ្នកសរសេរកម្មវិធី** | •បំណិនបច្ចេកទេស៖ បំណិនភាសាសរសេរកម្មវិធី (ឧ. Java, Python, C++) បំណិនដោះស្រាយបញ្ហា ការគិតវិភាគ សមត្ថភាពការសម្អាតនិងការសរសេរកូដឱ្យមានប្រសិទ្ធភាព។<br><br>• បំណិនទន់៖ ការងារជាក្រុម ការទំនាក់ទំនង សមត្ថភាពក្នុងការធ្វើការដោយឯករាជ្យ ការគ្រប់គ្រងពេលវេលា។ | បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ វិស្វកម្មសូហ្វវែរ ឬផ្នែកដែលពាក់ព័ន្ធ។ ផលប័ត្រដ៏រឹងមាំនៃគម្រោងសរសេរកូដអាចមានអត្ថប្រយោជន៍។ |
| **៣.អ្នកគ្រប់គ្រងបណ្តាញ និងអ្នកជំនួយការជំនាញផ្នែកព័ត៌មានវិទ្យា** | •បំណិនបច្ចេកទេស៖ ការយល់ដឹងពីបណ្តាញកុំព្យូទ័រ ការដោះស្រាយបញ្ហាបណ្តាញ ចំណេះដឹងផ្នែករឹងនិងសូហ្វវែរជាមូលដ្ឋាន ខ្លាំងបំណិនដោះស្រាយបញ្ហា។ | បរិញ្ញាបត្ររង ឬការបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែកជំនួយផ្នែកព័ត៌មានវិទ្យា ឬការគ្រប់គ្រងបណ្តាញ។ វិញ្ញាបនប័ត្រដូចជា |

| | | |
|---|---|---|
| | •បំណិនទន់៖ ជំនាញទំនាក់ទំនងល្អ និងអន្តរបុគ្គល សមត្ថភាពក្នុងការធ្វើការក្រោមសម្ពាធ បំណិនសេវាកម្មអតិថិជន។ | CompTIA A+ ឬ Network+ អាចមានប្រយោជន៍។ |
| **៤.អ្នករចនាក្រាហ្វិក និងអ្នកឯកទេសពហុព័ត៌មាន** | •បំណិនបច្ចេកទេស៖ ជំនាញផ្នែកកម្មវិធីរចនាក្រាហ្វិច (ឧ. Adobe Photoshop, Illustrator) ចំណេះដឹងអំពីឧបករណ៍បង្កើតពហុព័ត៌មាន (ឧ. កម្មវិធីកែវីដេអូ)។<br><br>• បំណិនទន់៖ ភាពច្នៃប្រឌិត អារម្មណ៍មើលឃើញខ្លាំង បំណិនទំនាក់ទំនងល្អ សមត្ថភាពក្នុងការបំពេញតាមកាលកំណត់។ | បរិញ្ញាបត្រផ្នែករចនាក្រាហ្វិច សិល្បៈពហុព័ត៌មាន ឬផ្នែកដែលពាក់ព័ន្ធ។ ផលប័ត្របង្ហាញពីបំណិនរចនាគឺសំខាន់ណាស់។ |
| **៥.អ្នកជំនាញផ្នែកទីផ្សារមាតិកា និងប្រព័ន្ធផ្សព្វផ្សាយសង្គម** | • បំណិនទីផ្សារឌីជីថល៖ ការយល់ដឹងអំពីវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម បំណិនបង្កើតមាតិកា (ការសរសេរ ការកាត់តវីដេអូ) ចំណេះដឹងនៃការវិភាគប្រព័ន្ធផ្សព្វផ្សាយសង្គម។<br><br>• បំណិនទន់៖ បំណិនទំនាក់ទំនង និងការសរសេរដ៏ល្អឥតខ្ចោះ ភាពច្នៃប្រឌិត ការគិតវិភាគ សមត្ថភាពក្នុងការរក្សាភាពទាន់សម័យជាមួយនឹងនិន្នាការប្រព័ន្ធផ្សព្វផ្សាយសង្គម។ | បរិញ្ញាបត្រផ្នែកទីផ្សារ ទំនាក់ទំនង ឬផ្នែកដែលពាក់ព័ន្ធ។ បទពិសោធន៍ជាមួយយុទ្ធនាការទីផ្សារប្រព័ន្ធផ្សព្វផ្សាយសង្គមមានតម្លៃ។ |
| **៦.អ្នកវិភាគទិន្នន័យ និងអ្នកឯកទេសសុវត្ថិភាពអ៊ីនធឺណិត** | (អាជីពទាំងនេះទាមទារបំណិនកម្រិតខ្ពស់បន្ថែមទៀត)<br><br>• វិភាគទិន្នន័យ៖ បំណិនវិភាគទិន្នន័យ ចំណេះដឹងនៃកម្មវិធីស្ថិតិសូហ្វវែ (ឧ. R, Python) សមត្ថភាពខ្លាំងលើការដោះស្រាយបញ្ហា និងការគិតវិភាគបែបស៊ីជម្រៅ<br><br>• ឯកទេសសុវត្ថិភាពអ៊ីនធឺណិត៖ ស្តាប់ស៊ីជម្រៅអំពីប្រព័ន្ធ និងកម្មវិធីកំណត់សុវត្ថិភាពតាមអ៊ីនធឺណិត | បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រទិន្នន័យ សន្តិសុខព័ត៌មាន ឬផ្នែកដែលពាក់ព័ន្ធ។ វិញ្ញាបនបត្រដែលទាក់ទងនឹងឯកទេសជាក់លាក់ត្រូវបានពេញចិត្ត។ |

**ចំណាំ៖** នេះមិនមែនជាបញ្ជីពេញលេញទេ ហើយតម្រូវការជាក់លាក់អាចប្រែប្រួលអាស្រ័យលើនិយោជិក និងមុខតំណែង។ ទោះជាយ៉ាងណាក៏ដោយ វាផ្តល់នូវចំណុចចាប់ផ្តើមទូទៅសម្រាប់ការយល់ដឹងពីបំណិន និងគុណវឌ្ឍិដែលត្រូវការសម្រាប់អាជីព ICT នៅក្នុងប្រទេសកម្ពុជា។

# ឯកសារ ៥.៤៖ គន្លឹះខ្លះៗសម្រាប់ការបញ្ចូល ICT ដោយជោគជ័យនៅក្នុងបំណិនជីវិតតាមមូលដ្ឋាន

## សេចក្ដីផ្ដើម៖

ឯកសារនេះផ្ដល់នូវការណែនាំជាក់ស្ដែងសម្រាប់គ្រូបង្រៀន ដើម្បីធានាបាននូវការបញ្ចូលឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដោយជោគជ័យនៅក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន។

## គន្លឹះសំខាន់ៗ៖

- **ការធ្វើផែនការ និងការរៀបចំ៖**
  - ពិចារណាបរិបទរបស់អ្នក (ធនធាន បំណិនរបស់សិស្ស) នៅពេលជ្រើសរើសឧបករណ៍ ICT ។
  - តម្រឹមការបញ្ចូល ICT ជាមួយនឹងវត្ថុបំណងសិក្សា និងតម្រូវការកម្មវិធីសិក្សា។
  - រៀបចំផែនការសកម្មភាពចូលរួមដែលប្រើប្រាស់ឧបករណ៍ ICT ដែលបានជ្រើសរើសប្រកបដោយប្រសិទ្ធភាព។
  - សាកល្បង និងដោះស្រាយបញ្ហាឧបករណ៍ ICT ជាមុនដើម្បីជៀសវាងការរំខានក្នុងអំឡុងពេលសិក្សា។
- **ការអភិវឌ្ឍគ្រូបង្រៀន៖** បន្តអភិវឌ្ឍបំណិន ICT ផ្ទាល់ខ្លួនរបស់អ្នកដើម្បីបញ្ចូលវាទៅក្នុងមេរៀនប្រកបដោយទំនុកចិត្ត។



- **ការចូលរួមរបស់សិស្ស៖** ជ្រើសរើសឧបករណ៍ ICT ដែលសមស្របតាមអាយុ និងការចូលរួមសម្រាប់សិស្ស។
- **ការបង្រៀនតាមតម្រូវការសិស្ស៖** គ្រូបង្រៀនអាចប្រើប្រាស់ឧបករណ៍ ICT ដើម្បីបំពេញតាមបែបបទ និងតម្រូវការសិក្សារបស់សិស្ស។
- **ការវាយតម្លៃ៖** ឧបករណ៍ទាក់ទាញអាចផ្ដល់នូវការវាយតម្លៃជាដំណាក់ និងបូកសរុប (ឧ. កម្រងសំណួរតាមអ៊ីនធឺណិត ការស្ទង់មតិដែលទាក់ទាញ)។
- **ជំនួយផ្នែកបច្ចេកទេស៖** កំណត់បញ្ហាប្រឈមបច្ចេកទេសដែលអាចកើតមាន និងស្វែងរកដំណោះស្រាយ (ឧ. ជំហានដោះស្រាយបញ្ហាជាមូលដ្ឋាន ធនធានផ្សេងៗ)។

- **កិច្ចសហប្រតិបត្តិការ៖** សហការជាមួយសហសេវិក និងចែករំលែកការអនុវត្តល្អបំផុតសម្រាប់ការបញ្ចូល ICT ។
- **ស្វែងរកជំនួយ៖** ប្រើប្រាស់ធនធានដែលមានដូចជា គោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា សិក្ខាសាលា និងសហគមន៍អនឡាញ។

**សេចក្តីសន្និដ្ឋាន៖** ដោយធ្វើតាមគន្លឹះទាំងនេះ និងស្វែងរកការកែលម្អជាបន្តបន្ទាប់ អ្នកអាចបញ្ចូលឧបករណ៍ ICT ប្រកបដោយប្រសិទ្ធភាពទៅក្នុងមេរៀនបំណិនជីវិតតាមមូលដ្ឋានរបស់អ្នកដោយបង្កើនបទពិសោធន៍សិក្សាសម្រាប់សិស្សរបស់អ្នក។

## ឯកសារ ៦.១៖ និយមន័យ

នៅក្រោមការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន សាលារៀនត្រូវបានផ្តល់សិទ្ធិអំណាចក្នុងការកំណត់ខ្លឹមសារនៃការសិក្សារបស់ពួកគេ និងស្វែងរកការស៊ីសង្វាក់គ្នាជាមួយគំនិតផ្តួចផ្តើមផ្សេងៗទៀត។ ដើម្បីធ្វើកិច្ចការនេះប្រកបដោយប្រសិទ្ធភាព អ្នកគ្រប់គ្រងសាលារៀននិងគ្រូបង្រៀនត្រូវតែមានចំណេះដឹងអំពីបញ្ញត្តិ និងយន្តការទាំងនោះ និងយល់ពីការរៀបចំ និងវិសាលភាពរបស់ពួកគេ។

**សេចក្តីណែនាំ៖** ដោយផ្អែកលើចំណេះដឹងរបស់អ្នក សូមផ្គូរផ្គងលក្ខខណ្ឌដែលបានផ្តល់ឱ្យខាងក្រោម និងនិយមន័យសមស្របដែលមាននៅក្នុងតារាង។

| **ពាក្យគន្លឹះសំខាន់ៗ** | |
|---|---|
| • SEAMEO<br>• ក្រុមប្រឹក្សាកុមារ ឬយុវជន<br>• ការជជែកដេញដោលក្នុងសាលារៀន | • ការជជែកដេញដោលយុវជនថ្នាក់ជាតិ<br>• ការស្ម័គ្រចិត្តសម្រាប់កម្មវិធីសហគមន៍ខ្ញុំ<br>• ក្លឹបជជែកដេញដោលសិស្ស |

| **ពាក្យគន្លឹះ** | **និយមន័យ** |
|---|---|
| ………………………….. | ការពិភាក្សា ឬសកម្មភាពអំណះអំណាងដែលមានរចនាសម្ព័ន្ធ ដែលសិស្សបង្ហាញពីទស្សនៈ និងអំណះអំណាងរបស់ពួកគេលើប្រធានបទ ឬបញ្ហាមួយជាក់លាក់។ ជាធម្មតាវាពាក់ព័ន្ធនឹងក្រុមពីរ ឬច្រើនជឹម ឬបុគ្គលដែលឈរជាក្រុមបដិសេដ និងចូលរួមក្នុងការពិភាក្សាផ្លូវការ បង្ហាញពីអំណះអំណាង និងបដិសេធអំណះអំណាងរបស់គូប្រជែងរបស់ពួកគេ។ គោលបំណងនៃការជជែកដេញដោលរបស់សាលារៀនគឺដើម្បីបង្កើនការគិតពិចារណាស៊ីជម្រៅ បំណិននិយាយជាសាធារណៈ និងសមត្ថភាពក្នុងការបង្កើតអំណះអំណាងដែលបញ្ចុះបញ្ចូល ខណៈពេលដែលលើកទឹកចិត្តឱ្យមានការសន្ទនាប្រកបដោយការគោរព និងបែបស្ថាបនា។ |
| ………………………….. | អង្គការអន្តររដ្ឋាភិបាលក្នុងតំបន់មួយដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៦៥ ក្នុងចំណោមរដ្ឋាភិបាលនៃប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងតំបន់ក្នុងវិស័យអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ក្នុងតំបន់។ |
| ………………………….. | រចនាសម្ព័ន្ធសិស្សបង្កើតឡើងនៅក្នុងសាលារៀន ដើម្បីពង្រឹងការចូលរួមរបស់កុមារ ឬយុវជននៅក្នុងសាលារៀន និងការយល់ដឹងពីពលរដ្ឋវិជ្ជា។ |

| | |
|---|---|
| ………………………….. | របនាសម្ព័ន្ធសិស្សដែលផ្តល់ជាវេទិកាសម្រាប់សិស្ស ចូលរួមក្នុងការជជែកដេញដោល អនុវត្តការនិយាយជាសាធារណៈ អភិវឌ្ឍបំណិនគិតពិចារណាស៊ីជម្រៅ និងចូលរួមក្នុងព្រឹត្តិការណ៍ជជែកពិភាក្សាដែលមានការប្រកួតប្រជែង។ |
| ………………………….. | ការប្រកួតប្រចាំឆ្នាំដ៏មានកិត្យានុភាពដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា នៅគ្រប់ខេត្តក្រុងក្នុងប្រទេសកម្ពុជា។ ក្រុមត្រូវបានវិនិច្ឆ័យលើការរៀបចំ និងភាពច្បាស់លាស់ ការនិយាយជាសាធារណៈ ការប្រើអំណះអំណាង និងការប្រើប្រាស់ទម្រង់ការចោទសួរ និងរបៀបធ្វើបទបង្ហាញ។ |
| ………………………….. | គឺជាកម្មវិធីជាតិដ៏ធំបំផុតសម្រាប់ការងារស្ម័គ្រចិត្ត និងការគៀងគរសហគមន៍ក្នុងប្រទេសកម្ពុជា។ វាជាកម្មវិធីរបស់នាយកដ្ឋានយុវជននៃក្រសួងអប់រំ យុវជន និងកីឡា។ កម្មវិធីនេះមានគោលបំណងបង្កើតឱកាសសម្រាប់យុវជនក្នុងមូលដ្ឋាន ដើម្បីស្វែងយល់ និងផ្តួចផ្តើមគំនិតថ្មីៗ ដោយចូលរួមក្នុងការកសាង និងអភិវឌ្ឍសហគមន៍ដែលពួកគេរស់នៅ។ |

# ឯកសារ ៦.២៖ កម្រិតផ្សេងៗគ្នា – លទ្ធភាពផ្សេងៗគ្នា

ឯកសារនេះផ្តល់នូវបញ្ជីគំនិតផ្តួចផ្តើមនឹងអាចកើតមានដែលសាលាអាចពិចារណាបង្កើតការស៊ីសង្វាក់គ្នាជាមួយប្រធានបទបំណិនជីវិតតាមមូលដ្ឋានដែលបានពិពណ៌នារួចហើយនៅក្នុងឯកសារ ៦.១។

**ភារកិច្ច**

១. បំពេញតារាងខាងក្រោមដោយសញ្ញាធីក (√) នៅក្នុងក្រុមរបស់អ្នកនៅលើសន្លឹកក្រដាសផ្ទាំងធំ និងត្រូវរៀបចំដើម្បីចែករំលែកការពិចារណារបស់អ្នកជាមួយក្រុមធំ។

| ឧទាហរណ៍នៃសកម្មភាពដើម្បីបង្កើតការស៊ីសង្វាក់គ្នា | តើសាលារៀនរបស់ធ្លាប់បានធ្វើសកម្មភាពបែបនេះដែរឬទេ? | | តើនៅសាលារៀនរបស់អ្នកអាចកើតមានសកម្មភាពនេះដែរឬទេ? | | តើអ្នកត្រូវការថវិកាដើម្បីធ្វើដែរឬទេ? | | ជ្រើសរើសសកម្មភាព ២-៣ ដែលសាលារៀនរបស់អ្នកពិតជាអាចធ្វើបាន |
|---|---|---|---|---|---|---|---|
| | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ | |
| | | | | | | | |
| ក្រុមប្រឹក្សាកុមារ ឬយុវជនផ្តល់ការគាំទ្រដល់សកម្មភាពផ្សព្វផ្សាយបំណិនជីវិតតាមមូលដ្ឋាន | | | | | | | |
| សិស្សានុសិស្សជជែកដេញដោលនៅក្នុងថ្នាក់រៀន | | | | | | | |
| រៀបចំឱ្យសិស្សចូលរួមការជជែកដេញដោលយុវជនថ្នាក់ជាតិ | | | | | | | |
| បញ្ចូលទំនាក់ទំនងជាមួយអ្នកស្ម័គ្រចិត្តសម្រាប់កម្មវិធីសហគមន៍ខ្ញុំ និងស្វែងរកកិច្ចសហការដែលអាចធ្វើទៅបាន | | | | | | | |
| បង្កើតក្លឹបជជែកដេញដោលសិស្សនៅក្នុងសាលារៀន | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ចុះឈ្មោះសិស្ស ឬគម្រោងសាលារៀនដើម្បីទទួលបានពានរង្វាន់អន្តរជាតិ | | | | | | | |
| តស៊ូមតិ គ.ស.ន.ក ឃុំ ស្រុក ខេត្ត ដើម្បីផ្តល់មូលនិធិដល់គម្រោងសហគមន៍ | | | | | | | |
| បញ្ចុះបញ្ចូលអង្គការក្រៅរដ្ឋាភិបាលឱ្យគាំទ្របំណិនជីវិតតាមមូលដ្ឋាន ដើម្បីអភិវឌ្ឍបំណិនរបស់ក្មេងជំទង់ និងគៀងគរមនុស្សឱ្យចូលរួម | | | | | | | |
| រៀបចំសកម្មភាពរៃអង្គាសថវិកាដើម្បីអនុញ្ញាតឱ្យសិស្សចូលរួមក្នុងព្រឹត្តិការណ៍នៅក្រៅសាលារៀនសម្រាប់គាំទ្រសកម្មភាពដែលដឹកនាំដោយសិស្ស | | | | | | | |

1. ត្រៀមខ្លួនដើម្បីពន្យល់ពីមូលហេតុដែលអ្នកជ្រើសរើសសកម្មភាពសក្តានុពល២ ដែលអ្នកបានធ្វើ។ តើអ្វីទាក់ទាញអ្នកឱ្យមានជម្រើសទាំងនេះ? តើអ្នកត្រូវការថវិកាដែរឬទេ? តើអ្វីអាចជាតំណភ្ជាប់ជាមួយនឹងការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន?

2. ប្រសិនបើអ្នកឆ្លើយថា "ទេ" ចំពោះសំណួរទីពីរ "តើនៅសាលារៀនរបស់អ្នកអាចកើតមានសកម្មភាពនេះដែរឬទេ?" សូមត្រៀមខ្លួនដើម្បីពន្យល់។

## ឯកសារ ៦.៣៖ វីដេអូ ស្រី ចិន និងសមិទ្ធិផលរបស់នាង

**សេចក្ដីណែនាំ៖** បន្ទិចទៀតនេះ អ្នកនឹងចាប់ផ្ដើមមើលវីដេអូអំពីសិស្សម្នាក់ឈ្មោះ **ស្រី ចិន**។ នាងជាសិស្សនៅអនុវិទ្យាល័យ ហ៊ុនសែន រលួស។ អនុវិទ្យាល័យ ហ៊ុនសែន រលួស ជាសាលារៀនរដ្ឋមួយនៅខេត្តសៀមរាប ដែលបានចាប់ផ្ដើមអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋានក្នុងឆ្នាំសិក្សា២០១៥-១៦។

**ភារកិច្ច**

- មើលវីដេអូ រួចឆ្លើយសំណួរខាងក្រោមជាក្រុមតូចៗពី ៤ ទៅ ៥នាក់។
- ត្រៀមខ្លួនចែករំលែកគំនិតរបស់អ្នកជាមួយក្រុមផ្សេងៗទៀត។

**សំណួរ**

- តើមានគំនិតផ្ដួចផ្ដើមអ្វីទៀតដែល **ស្រី ចិន** បានចូលរួម?
- តើអ្វីជាអត្ថប្រយោជន៍សម្រាប់នាងក្នុងការចូលរួមក្នុងគំនិតផ្ដួចផ្ដើមបែបនេះ?
- តើសាលារៀនទទួលបានអត្ថប្រយោជន៍អ្វីខ្លះ? ហើយសម្រាប់អាជ្ញាធរមូលដ្ឋាន?

## ឯកសារ ៧.១៖ ផ្នែកសំខាន់ៗនៃរង្វាយតម្លៃបំណិនជីវិតតាមមូលដ្ឋាន[8]



ការសិក្សាបំណិនជីវិតតាមមូលដ្ឋាន ពាក់ព័ន្ធនឹងការទទួលបានចំណេះដឹងច្រើនជាងមុន ប៉ុន្តែរួមបញ្ចូលទិដ្ឋភាពផ្សេងទៀតនៃការអភិវឌ្ឍចិត្តសាស្ត្ររបស់មនុស្ស។ ទិដ្ឋភាពទាំងនេះរួមបញ្ចូលមិនត្រឹមតែចំណេះដឹងប៉ុណ្ណោះទេ ថែមទាំងការអភិវឌ្ឍបំណិន និងឥរិយាបថដែលជួនកាលគេស្គាល់ថា KSA ផងដែរ។ ទិដ្ឋភាពនីមួយៗនៃការសិក្សាបន្ថែមត្រូវបានពន្យល់ដូចខាងក្រោម៖

- **ការអភិវឌ្ឍចំណេះដឹង ('អ្វី' យើងរៀន)៖** ប្រភេទនៃការសិក្សាដូចនេះផ្តោតលើខ្លឹមសារមួយជាក់លាក់ដែលជួយអ្នកសិក្សាឱ្យធ្វើការសម្រេចចិត្តបានត្រឹមត្រូវដោយផ្អែកលើព័ត៌មានដ៏ទូលំទូលាយលើប្រធានបទដែលត្រូវរៀន។ លក្ខណៈវិនិច្ឆ័យសម្រាប់ការវង្វាយតម្លៃនៃទិដ្ឋភាពនការសិក្សានេះនឹងផ្តោតលើចំណេះដឹងដែលទទួលបាននៅកម្រិតផ្ទាល់ខ្លួន គ្រួសារ និងសហគមន៍។
- **ការអភិវឌ្ឍបំណិន (ឧបករណ៍ដែលយើងប្រើដើម្បី 'អនុវត្ត' អ្វីដែលយើងរៀន)៖** ការសិក្សាបែបនេះផ្តោតលើការសិក្សាបំណិន ដោយយោងលើប្រធានបទ និងតម្រូវការរបស់សិស្ស។ បំណិនជីវិតតាមមូលដ្ឋាន ជាធម្មតាពាក់ព័ន្ធនឹងការទទួលបានសមត្ថភាពផ្លូវចិត្តសង្គម និងបំណិនអន្តរបុគ្គល ដែលជួយអ្នកឱ្យធ្វើការសម្រេចចិត្តប្រកបដោយការយល់ដឹង ដោះស្រាយបញ្ហា គិតប្រកបដោយភាពច្នៃប្រឌិត និងប្រកបដោយប្រសិទ្ធភាព ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព កសាងសុខភាពទំនាក់ទំនងឱ្យបានល្អ យល់ចិត្តអ្នកដទៃ និងដោះស្រាយជាមួយ ការគ្រប់គ្រងជីវិតរបស់ពួកគេឱ្យមានសុខភាពល្អ និងប្រកបដោយផលិតភាព (យើងសំដៅលើភាពជាក់លាក់ចំពោះគោលដៅទាំង១២ នៃបំណិនទន់នៅក្នុងការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន)។
- **ការអភិវឌ្ឍអាកប្បកិរិយា និងគុណតម្លៃ (នេះជាអ្វីដែលជំរុញយើងឱ្យប្រើអ្វីដែលយើងរៀន)៖** ការរៀនប្រភេទនេះគឺផ្តោតលើអាកប្បកិរិយា និងជំនឿរបស់សិស្ស ដែលត្រូវបានបង្កើតឡើងតាមរយៈការសិក្សាបំណិនជីវិតតាមមូលដ្ឋាន ដែលមានកម្មវិធីអនុវត្តជាក់ស្តែង និងឆ្លើយតបទៅនឹងស្ថានភាពជាក់លាក់ដែលសិស្សត្រូវធ្វើការឆ្លុះបញ្ចាំងពីឥរិយាបថ និងផលប៉ះពាល់នៃសកម្មភាពរបស់ពួកគេ។ ដំណើរការនេះរួមបញ្ចូលទាំងការអភិវឌ្ឍតម្លៃដូចជា ការយល់ចិត្ត ភាពស្មោះត្រង់ ការយកចិត្តទុកដាក់ចំពោះអ្នកដទៃ ការស្ម័គ្រចិត្តជាដើម។ ជាទូទៅ សំណួរដែលត្រូវសួរគឺ 'ប្រសិនបើអ្នកជាគាត់ ឬនាង តើអ្នកគួរធ្វើដូចម្តេច? ជាពលរដ្ឋសកម្ម?

## ការសង្ខេប

**អំពីវិជ្ជាសម្បទា៖** វិជ្ជាសម្បទាសំដៅលើខ្លឹមសារពិតដែលយើងបានសិក្សា និងសមត្ថភាពរបស់យើងក្នុងការយល់ដឹងខ្លឹមសារនោះ។

**អំពីបំណិនសម្បទា៖** ម្យ៉ាងវិញទៀត បំណិនសម្បទាសំដៅលើសមត្ថភាពក្នុងការអនុវត្តចំណេះដឹងរបស់មនុស្សម្នាក់ក្នុងបរិបទជាច្រើន។ សមត្ថភាពបែបនេះ (ឧ. ការគិតពិចារណាស៊ីជម្រៅ ទំនាក់ទំនង ការសម្រេចចិត្ត។ល។) អាចមានភាពចម្រុះ និងអាចពង្រឹងឱ្យគ្នាទៅវិញទៅមក។ ឧទាហរណ៍ បំណិនការគិតពិចារណាស៊ីជម្រៅ អាចគាំទ្រការគិតបែប "ច្នៃប្រឌិត" ខណៈពេលដែលសមត្ថភាពទំនាក់ទំនងស៊ីជម្រៅ និងគំនិតច្នៃប្រឌិត ធ្វើឱ្យការគិតបែបនេះកាន់តែទូលំទូលាយ។

**អំពីចរិយាសម្បទា៖** ជាចុងក្រោយ ការអភិវឌ្ឍចរិយាសម្បទា និងគុណតម្លៃ សំដៅលើឆន្ទៈរបស់បុគ្គលម្នាក់ក្នុងការរៀបចំការទទួលស្គាល់ថា ចំណេះដឹង និងបំណិនដែលយើងបានសិក្សាមានសារៈសំខាន់ណាស់ និងគួរតែអនុវត្តនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើងម្នាក់ៗ។ ទោះបីជាមនុស្សម្នាក់អាច "យល់ដឹង" អ្វីមួយហើយមាន "សមត្ថភាពដើម្បីការអនុវត្ត" ការយល់ដឹងនោះនៅក្នុងការកំណត់ពិតប្រាកដក៏ដោយ យើងប្រហែលនៅតែមិនធ្វើដូច្នេះទេ ប្រសិនបើយើងមិនជឿថាវាសំខាន់។

*ដ្យាក្រាមដែលមានប្រយោជន៍ដើម្បីពន្យល់អន្តរភ្ជាប់រវាងវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា*



# សំណួរពិភាក្សា

1. តើអ្នកធ្លាប់ជួបសិស្សដែលហាក់ដូចជាយល់មេរៀនពីបញ្ហាសង្គមដ៏សំខាន់ ប៉ុន្តែមិនដែលអនុវត្តចំណេះដឹងរបស់ពួកគេទេ? នៅពេលដែលការវាយតម្លៃរបស់អ្នកបង្ហាញថា សិស្សមិនបានរៀបចំអាកប្បកិរិយាសំខាន់ៗស្តីពីប្រធានបទទេ តើអ្នកអាចធ្វើអ្វីដើម្បីបង្វែរស្ថានភាពនេះ?
2. នៅពេលពិចារណាអំពីការទទួលបានចំណេះដឹង និងការរៀបចំផ្ទៃក្នុងនៃឥរិយាបថ តើអ្នកគិតថា វាងាយស្រួលជាងក្នុងការសម្រេចបានសម្រាប់សិស្សដែរឬទេ។ ពន្យល់ចម្លើយរបស់អ្នក។
3. ពីករណីសិក្សា យើងបានឃើញថា បំណិនគឺជាឧបករណ៍ដ៏សំខាន់មួយដែលសិស្សប្រើប្រាស់ដើម្បីអនុវត្តចំណេះដឹងដែលខ្លួនបានសិក្សា។ តើអ្នកអាចកំណត់បានដោយរបៀបណា ថាតើសិស្សកំពុងទទួលបានបំណិនជាក់លាក់ដែរឬទេ? តើអ្នកគិតថាការធ្វើតេស្តដោយប្រើក្រដាសនិងខ្មៅដៃមានប្រយោជន៍សម្រាប់ការវាយតម្លៃបែបនេះទេ?

## លំហាត់

**សេចក្តីណែនាំ៖** លំហាត់បន្តបន្ទាប់ខាងក្រោមបង្ហាញករណីសិក្សាខ្លីៗមួយចំនួនដែលអ្នកត្រូវធ្វើការវាស់ស្ទង់ជាបុគ្គល ឬនៅក្នុងក្រុមរបស់អ្នក។ ព្យាយាមកំណត់ពីកម្រិតមួយណាជា វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទានៃប្រធានបទជាក់លាក់មួយដែលបានសិក្សាដោយនរណាម្នាក់ដែលករណីសិក្សាអាចអនុវត្តបាន។ សូមគូសធីកក្នុងក្រឡោន "បាទ/ចាស" ប្រសិនបើ វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ត្រូវបានសិក្សាទទួលយក ឬ "ទេ" ប្រសិនបើមិនបានសិក្សាឬទទួលយក។ សូមត្រៀមពិភាក្សាចម្លើយរបស់អ្នកជាមួយក្រុមធំនៅពេលអ្នកបញ្ចប់។

| **ករណីសិក្សា** | បានយល់ដឹងនូវវិជ្ជាសម្បទា | | បានទទួលបំណិនសម្បទា | | ចរិយាសម្បទាត្រូវបានទទួលយក | |
|---|---|---|---|---|---|---|
| | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ |
| ប្រធានបទ៖ ការអប់រំសុខភាព<br>**ករណីសិក្សាទី១៖ វណ្ណៈ** បានបញ្ចប់វគ្គបណ្តុះបណ្តាលបំណិនជីវិតតាមមូលដ្ឋាន ស្តីពីការការពារគ្រោះថ្នាក់ដោយជំងឺក្នុងសហគមន៍ ដូចជាជំងឺគ្រុនចាញ់ ជំងឺគ្រុនឈាម និងជំងឺរាករូស។ គាត់បានយល់ច្បាស់អំពីរោគសញ្ញានៃជំងឺ | | | | | | |

| ករណីសិក្សា | បានយល់ដឹងនូវវិជ្ជាសម្បទា | | បានទទួលបំណិនសម្បទា | | ចរិយាសម្បទាត្រូវបានទទួលយក | |
|---|---|---|---|---|---|---|
| | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ |
| នីមួយៗ និងរបៀបដែលពួកគេទាក់ទងគ្នា។ ទោះជាយ៉ាងណាក៏ដោយគាត់ខ្វះបំណិនទំនាក់ទំនងខ្លាំងដើម្បីផ្សព្វផ្សាយព័ត៌មាននេះហើយមានអារម្មណ៍ថាការលេងបាល់ជាមួយមិត្តភក្តិគឺជារឿងអាទិភាពខ្ពស់ជាងការចំណាយពេលសិក្សាលើប្រធានបទនេះ។ | | | | | | |
| **ករណីសិក្សាទី២៖ ធីតា** បានចូលរៀនដូចគ្នានឹង **វណ្ណៈ** ដែរ។ នាងក៏មានការយល់ដឹងយ៉ាងខ្លាំងអំពីខ្លឹមសារនៃវគ្គសិក្សានេះដែរ (ឧ. រោគសញ្ញាជំងឺ វិធីចម្លងមេរោគ)។ ជាអកុសល **ធីតា** មានបំណិនទំនាក់ទំនងខ្សោយណាស់ ហើយមិនអាចពន្យល់អ្នកដទៃបានល្អអំពីអ្វីដែលនាងបានសិក្សានោះទេ។ | | | | | | |
| ប្រធានបទ៖ តួនាទីពលរដ្ឋ<br>**ករណីសិក្សាទី៣៖ សុខា** មានអាយុ ១៤ឆ្នាំ ពេលនាងបញ្ចប់វគ្គសិក្សាខ្លីស្តីពីតួនាទីពលរដ្ឋក្នុងពេលសិក្សាបំណិនជីវិតតាមមូលដ្ឋានរបស់នាង។ វគ្គនេះទាក់ទងនឹងសារៈសំខាន់នៃការតាមដានព័ត៌មាន ការព្យាយាមស្វែងយល់ពីបញ្ហាប្រចាំថ្ងៃ ការចុះឈ្មោះបោះឆ្នោតនៅពេលដល់អាយុ និងការបោះឆ្នោតពិតប្រាកដនៅពេលដល់ពេលកំណត់។ **សុខា** បានក្លាយជាអ្នកចេះដឹងខ្ពស់អំពីពលរដ្ឋ និងទទួលបានបំណិនពិចារណាស៊ីជម្រៅ ដូច្នេះនាងអាចមើលឃើញបញ្ហា ពីទស្សនៈផ្សេងៗជាច្រើន។ មិនត្រឹមតែប៉ុណ្ណឹងទេ ពេលនេះដល់អាយុហើយ នាងតែងតែទៅបោះឆ្នោតរាល់ពេលមានការបោះឆ្នោត ហើយជ្រើសរើសបេក្ខជនណាដែលតំណាងឱ្យទស្សនៈរបស់នាងបានល្អបំផុត។ | | | | | | |

| ករណីសិក្សា | ការយល់ដឹងទូទៅអំពី សង្គម | | ការទទួលបំណិន សង្គម | | ចរិយាសម្បទាថ្មី ការទទួលយក | |
|---|---|---|---|---|---|---|
| | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ |
| **ករណីសិក្សាទី៤៖ សុភា** បានបញ្ចប់វគ្គសិក្សាដូចគ្នានឹង **សុខា** ដែរ។ គាត់យល់ដឹងបានយ៉ាងច្បាស់អំពីបញ្ញត្តិនៃតួនាទីពលរដ្ឋ ហើយគាត់ក៏បានបង្ហាញពីសមត្ថភាពមួយចំនួនក្នុងការនិយាយយ៉ាងឆ្លាតវៃអំពីបញ្ហាផ្សេងៗ នៅពេលដែលគាត់បានអនុវត្តផ្ទាល់ដោយខ្លួនឯង។ ប៉ុន្តែទោះបីជាជារឿយៗគាត់យល់អំពីបញ្ហា និងអាចវិភាគពីគុណសម្បត្តិ និងគុណវិបត្តិនៃទស្សនៈផ្សេងគ្នាក៏ដោយ គាត់យល់ឃើញថានយោបាយគួរឱ្យធុញទ្រាន់ ហើយដូច្នេះមិនដែលប្រើសិទ្ធិរបស់គាត់ក្នុងការបោះឆ្នោត ឬអនុវត្តអ្វីដែលគាត់បានរៀនពីមុនមក ដើម្បីកែលម្អសហគមន៍របស់គាត់នៅក្នុងសាលារៀននោះទេ។ | | | | | | |
| ប្រធានបទ៖ ការងារ<br>**ករណីសិក្សាទី៥៖ វណ្ណារ៉ា** ផ្តោតខ្លាំងលើការសិក្សាលើជម្រើសអាជីពផ្សេងៗ ក្នុងមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន ដូច្នេះគាត់អាចធ្វើការសម្រេចចិត្តបានច្បាស់លាស់អំពីអ្វីដែលគាត់គួរធ្វើបន្ទាប់ពីបញ្ចប់ការសិក្សា។ គាត់មានជំនឿយ៉ាងមុតមាំថា ការសិក្សាជម្រើសអាជីពផ្សេងៗ មានសារៈសំខាន់ចំពោះសុភមង្គលនាពេលអនាគត ក្នុងការងាររបស់គាត់។ ទោះជាយ៉ាងណាក៏ដោយ លោក **វណ្ណារ៉ា** យល់ឃើញថា ជម្រើសការងារជាច្រើនដែលលោកបានពិនិត្យទាំងអស់ ហាក់ដូចជាស្រដៀងគ្នា ហើយលោកមិនអាចបែងចែកឱ្យបានច្បាស់ពីគុណសម្បត្តិ និងគុណវិបត្តិនៃជម្រើសអាជីពផ្សេងៗនោះបានទេ។ ដូច្នេះហើយ សមត្ថភាពក្នុងការសម្រេចចិត្តរបស់គាត់ត្រូវបានថយចុះ ដោយសារតែគាត់មានការយល់ដឹងតិចតួចអំពីជម្រើសអាជីពនីមួយៗ និងមិនអាចប្រៀប | | | | | | |

| ករណីសិក្សា | បានយល់ដឹងនូវវិជ្ជាសម្បទា | | បានទទួលបំណិនសម្បទា | | ចរិយាសម្បទាត្រូវបានទទួលយក | |
|---|---|---|---|---|---|---|
| | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ |
| ជៀបអាជីពទាំងនោះដោយស៊ីជម្រៅបាន។ ដូច្នេះ សមត្ថភាពធ្វើការសម្រេចចិត្តរបស់គាត់ត្រូវបានអន់ថយយ៉ាងខ្លាំង។ នៅទីបំផុតគាត់គ្រាន់តែធ្វើតាមជម្រើសអាជីពដែលឪពុកម្ដាយរបស់គាត់ចង់ឱ្យគាត់ធ្វើប៉ុណ្ណោះ។ | | | | | | |
| **ករណីសិក្សាទី៦៖ បូរ៉ា** មិនមានចំណាប់អារម្មណ៍ច្រើនក្នុងការសិក្សាអំពីជម្រើសអាជីពទេ ដោយសារគាត់គ្រាន់តែគ្រោងនឹងធ្វើការនៅចំការរបស់ពូគាត់តែប៉ុណ្ណោះ។ ប៉ុន្តែគាត់បានធ្វើតាមការចាប់អារម្មណ៍លើបំណិនជីវិតតាមមូលដ្ឋានដែលហៅជម្រើសអាជីពព្រោះមិត្តស្រីរបស់គាត់ក៏នៅក្នុងថ្នាក់រៀនដែរ។ គាត់យល់ឃើញថាប្រធានបទនៃវគ្គសិក្សានេះគួរឱ្យធុញទ្រាន់ ហើយបានអវត្តមានច្រើនក្នុងថ្នាក់ និងមិនដែលអានកិច្ចការដែលគ្រូបានដាក់ឱ្យណាមួយឡើយ។ គាត់មិនអាចប្រៀបធៀបការងារផ្សេងគ្នាបានដោយសារតែគាត់ខ្វះចំណាប់អារម្មណ៍ក្នុងការធ្វើដូច្នេះ។ | | | | | | |

## ឯកសារ ៧.២៖ ការយល់ដឹងពីវិធីផ្សេងគ្នានៃវង្វាយតម្លៃ និងនិន្នភាពសម្រាប់ប្រភេទផ្សេងគ្នានៃការសិក្សាបំណិនជីវិត

### ការប្រើប្រាស់វង្វាយតម្លៃជាដំណាក់ និងបូកសរុបនៅក្នុងការអប់រំបំណិនជីវិតតាមមូលដ្ឋាន៖

ក្នុងការវាយតម្លៃការសិក្សាបំណិនជីវិតតាមមូលដ្ឋាន មានវិធីសាស្ត្រសំខាន់ពីរដើម្បីសង្កេត៖

- **ការវាយតម្លៃជាដំណាក់** (ការអង្កេតរបស់គ្រូ ព័ត៌មានត្រឡប់ និងកម្រងសំណួរខ្លីៗ)៖ សំដៅលើដំណើរការនៃការវាយតម្លៃជាបន្តបន្ទាប់ បន្ទាប់ពីបញ្ចប់ផ្នែកសិក្សានីមួយៗ ដើម្បីតាមដានការសិក្សារបស់សិស្ស និងធ្វើសកម្មភាពត្រឹមត្រូវតាមតម្រូវការ (ឧ. ការបង្រៀនឡើងវិញ)។ **លក្ខណៈសំខាន់ៗ**នៃការវង្វាយតម្លៃជាដំណាក់រួមមាន៖

| | |
|---|---|
| តេស្តដែលមានកម្រិតលម្អៀងខ្ពស់ | សំណួរមានកម្រិតលំបាកទាប |
| សំណួរបើកផ្តោតលើដំណើរការ | តេស្តគ្រប់ដណ្តប់លើខ្លឹមសារមួយចំនួន ឬខ្លី |

- **ការវង្វាយតម្លៃបូកសរុប** (ការសង្កេតរបស់គ្រូ មិត្តភក្តិ និងស្វ័យវាយតម្លៃ ការធ្វើតេស្តជាលាយលក្ខណ៍អក្សរ)៖ សំដៅលើវង្វាយតម្លៃចុងក្រោយនៅចុងខែ ឬឆមាស ដោយមិនចាំបាច់មានការបង្រៀនឡើងវិញទេ។ លក្ខណៈសំខាន់ៗនៃវង្វាយតម្លៃសង្ខេបរួមមាន៖

| | |
|---|---|
| តេស្តមានកម្រិតលម្អៀងទាប | សំណួរមានកម្រិតលំបាកមធ្យម |
| សំណួរបិទផ្តោតលើផលិតផល (សំណួរវត្ថុបំណង) | តេស្តគ្រប់ដណ្តប់ខ្លឹមសារច្រើន ឬវែង |

គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀនគួរផ្តល់ព័ត៌មានឱ្យបានច្បាស់លាស់ដល់សិស្ស និងមាតាបិតា ឬអាណាព្យាបាលអំពីលទ្ធផលនៃការសិក្សារបស់សិស្សក្នុងដំណាក់កាលនីមួយៗ។ សិស្សត្រូវទទួលបានព័ត៌មានច្បាស់លាស់អំពីចំណុចខ្លាំង ចំណុចខ្សោយ និងជំហានដែលពួកគេត្រូវអភិវឌ្ឍដើម្បីបង្កើនលទ្ធផលសិក្សារបស់ពួកគេ ក៏ដូចជាការអភិវឌ្ឍបំណិន និងឥរិយាបថ។ គ្រូបង្រៀនគួរបង្ហាញពីលក្ខណៈវិនិច្ឆ័យវង្វាយតម្លៃដល់សិស្សទាំងអស់នៅដើមឆ្នាំសិក្សា ដើម្បីឱ្យសិស្សបានដឹងពីអ្វីដែលនឹងត្រូវវាយតម្លៃ និងត្រៀមខ្លួនបានល្អប្រសើរដើម្បីឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យ។



## សំណួរពិភាក្សា

1. តើគ្រូធ្វើអ្វីបន្ទាប់ពីវង្វាយតម្លៃជាដំណាក់?
2. ហេតុអ្វីបានជាអ្នកគិតថាការធ្វើវង្វាយតម្លៃជាដំណាក់គួរតែខ្លី?
3. ហេតុអ្វីបានជាអ្នកគិតថាសំណួរលើការវាយតម្លៃជាដំណាក់គួរតែងាយស្រួល?
4. តើការវាយតម្លៃជាដំណាក់ និងបូកសរុបមានគោលបំណងដូចគ្នាដែរឬទេ?
5. តើការធ្វើវង្វាយតម្លៃបូកសរុបគួរតែអនុវត្តដោយការបង្រៀនឡើងវិញដែរឬទេ? សូមពន្យល់ចម្លើយរបស់អ្នក។

## ទម្រង់នៃការវាយតម្លៃ៖

មានឧបករណ៍ជាច្រើនប្រភេទដែលគ្រូអាចប្រើដើម្បីប្រមូលទិន្នន័យវាយតម្លៃលើការរៀនបំណិនជីវិតរបស់សិស្ស។ ឧបករណ៍ទាំងនេះមួយចំនួនអាចសមរម្យសម្រាប់ការប្រមូលទិន្នន័យវាយតម្លៃលើទិដ្ឋភាពមួយចំនួននៃក្របខណ្ឌវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា (KSA) ប៉ុន្តែមិនមែនសម្រាប់ផ្នែកផ្សេងទេ។ សូមអានតាមរយៈផ្នែកខ្លះនៃឧបករណ៍វង្វាយតម្លៃដែលប្រើជាទូទៅមួយចំនួនដែលមានរាយខាងក្រោម ហើយធ្វើការពិភាក្សាជាមួយអ្នកសម្របសម្រួលអំពីប្រភេទនៃការសិក្សា (ឧទាហរណ៍ វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា) ដែលនីមួយៗអាចមានប្រយោជន៍។ តាមដានចម្លើយរបស់អ្នកនៅក្នុងតារាងលំហាត់ដែលបានផ្តល់ជូនខាងក្រោម។

- **តេស្តសរសេរ៖** ការធ្វើតេស្តសរសេរតម្រូវឱ្យសិស្សបង្ហាញការយល់ដឹងរបស់ពួកគេអំពីប្រធានបទមួយ ដោយសរសេរចម្លើយរបស់ពួកគេចំពោះសំណួរជាលាយលក្ខណ៍អក្សរ ជាជាងធ្វើអ្វីមួយដែលជាក់ស្តែង ឬផ្តល់ចម្លើយដោយនិយាយ។

- **ការសង្កេតរបស់គ្រូក្នុងអំឡុងពេលរៀនក្នុងថ្នាក់៖** វង្វាយតម្លៃបែបនេះពាក់ព័ន្ធនឹងការសង្កេតសិស្សនៅពេលពួកគេធ្វើការ ហើយបន្ទាប់មកទទួលយកកំណត់ត្រាព័ត៌មានផ្ទាល់មាត់នៃការសង្កេត។ កំណត់ត្រាព័ត៌មានផ្ទាល់មាត់ទាំងនេះរួមមានកំណត់ចំណាំដែលចុះកាលបរិច្ឆេទ និងកំណត់ចំណាំក្រៅផ្លូវការដែលពិពណ៌នាអំពីលទ្ធផលសិក្សា និងសមត្ថភាពរបស់សិស្សលើកិច្ចការជាក់លាក់។
- **ការអនុវត្តជាក់ស្តែង៖** នេះសំដៅលើគ្រប់ទម្រង់វង្វាយតម្លៃដែលតម្រូវឱ្យសិស្សបង្ហាញបំណិនជាក់ស្តែងនៅក្នុងន័យដែលអាចប្រើដើម្បីកំណត់កម្រិតសមត្ថភាពរបស់ពួកគេនៅក្នុងបំណិននោះតាមរយៈការរៀបចំវត្ថុបំណងជាក់ស្តែង។
- **ការវាយតម្លៃជាដៃគូ ឬការវាយតម្លៃជាក្រុម៖** នៅក្រោមលក្ខខណ្ឌនៃការវាយតម្លៃបែបនេះ សិស្សវាយតម្លៃសមាជិកក្រុមនីមួយៗ (រួមទាំងខ្លួនឯង) ទាក់ទងនឹងគុណភាពការងារ ទំនួលខុសត្រូវ បំណិនអន្តរបុគ្គល អាកប្បកិរិយា និងការចែករំលែក។
- **ស្វ័យវង្វាយតម្លៃរបស់សិស្ស៖** ស្វ័យវង្វាយតម្លៃផ្តល់ឱ្យសិស្សនូវឱកាសមួយដើម្បីធ្វើស្វ័យវង្វាយតម្លៃ ឬធ្វើការវិនិច្ឆ័យអំពីដំណើរការសិក្សា និងលទ្ធផលនៃការសិក្សារបស់ពួកគេ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលពួកគេបានយល់ព្រមជាមួយគ្រូរបស់ពួកគេ។

# លំហាត់

**សេចក្តីណែនាំ៖** ពិចារណាអំពីនិយមន័យនៃទម្រង់នៃការវាយតម្លៃនីមួយៗដែលបានផ្តល់ជូនខាងលើ ហើយចង្អុលបង្ហាញថាតើការវាយតម្លៃប្រភេទនេះអាចត្រូវបានប្រើសម្រាប់ការវាស់វែងចំណេះដឹង បំណិនទទួលបាន និងឥរិយាបថដែលប្រកាន់យកដោយគូសធីក (√) នៅក្នុងក្រឡោននៃតារាងខាងក្រោម។ បន្ថែមមតិយោបល់ណាមួយដើម្បីបង្ហាញពីភាពត្រឹមត្រូវនៃការវិភាគរបស់អ្នកនៅក្នុងផ្នែកមតិយោបល់នៅក្នុងតារាង។

| ទម្រង់នៃវង្វាយតម្លៃ | វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា |
|---|---|---|---|
| តេស្តសរសេរ | | | |
| ការសង្កេតគ្រូអំឡុងពេលបង្រៀន | | | |
| អនុវត្តជាក់ស្តែង | | | |
| ការវាយតម្លៃជាដៃគូ ឬជាក្រុម | | | |
| ស្វ័យវាស់វែងសិស្ស | | | |

## ឯកសារទី ៧.៣៖ ភាពផ្ទុយគ្នានៃការវាយតម្លៃការសិក្សាបែបប្រពៃណី និងការសិក្សាបែបគម្រោង

**សេចក្តីណែនាំ៖** ចូរអានការសន្ទនា និងចូលរួមពិភាក្សាជាក្រុមដើម្បីឆ្លើយសំណួរខាងក្រោម៖




### សំណួរពិភាក្សា

១. តើកម្រិតនៃការគិតមួយណាដែលត្រូវនឹងការវាយតម្លៃក្នុងរូបភាព(ក)? រូបភាព(ខ)? ចូរប្រើប្រាស់ទ្រឹស្តីប្លូមតាក់សូណូមីដើម្បីឆ្លើយនឹងសំណួរនេះ។

២. រកគុណសម្បត្តិ និងគុណវិបត្តិនៃយុទ្ធសាស្ត្រវាយតម្លៃទាំងក្នុងរូបភាព(ក) និងរូបភាព(ខ)។

៣. ហេតុអ្វីបានជាអ្នកគិតថា គ្រូបង្រៀននៅកម្ពុជាមិនសូវប្រើយុទ្ធសាស្ត្រវាយតម្លៃក្នុងរូបភាព(ខ)?

# ឯកសារ ៧.៤៖ យុទ្ធសាស្ត្រវាយតម្លៃនៅក្នុងការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន

## គំនិតគន្លឹះខ្លះៗ

- អំឡុងពេលវាយតម្លៃ គ្រូប្រើការសិក្សាបែបគម្រោង ចាប់អារម្មណ៍ពី **របៀប** សិស្សរកចម្លើយ ឬធ្វើសេចក្តីសន្និដ្ឋានជាជាងលើតែ **ចម្លើយ**។
- ដំណើរការសិក្សាមានសារៈសំខាន់ដូចគ្នានឹងផលិតផលសិក្សាដែរ។
- ការវាយតម្លៃបែបប្រពៃណី និងតេស្តស្តង់ដាមិនសមស្របសម្រាប់វាយតម្លៃការសិក្សាបែបគម្រោងទេ។
- ខណៈពេលដែលសាលារៀនជាច្រើននៅអនុវត្តតាមបរិបទតេស្តផ្លូវការ គ្រូបង្រៀនត្រូវបង្កើតដោយសំយោគបច្ចេកទេសវាយតម្លៃលទ្ធផលសិក្សាសិស្សថ្មីៗបន្ថែមលើប្រព័ន្ធដែលមានស្រាប់។

### បច្ចេកទេសមួយចំនួនសម្រាប់វាយតម្លៃការសិក្សាអាស្រ័យលើគម្រោង និងការសិក្សាអាស្រ័យលើបញ្ហា



## បច្ចេកទេសសម្រាប់វាយតម្លៃ[៩]

អ្នកទ្រឹស្តីអប់រំបានផ្តល់នូវបច្ចេកទេស ៤ សម្រាប់វាយតម្លៃក្នុងបរិបទសិក្សាតាមរយៈការបង្កើតការងារគម្រោង។ បច្ចេកទេសទាំងនេះ អាចមានភាពជាន់គ្នាខ្លះ តែក៏មានចំណុចពិសេសរៀងៗខ្លួនដែរ។

- **ការវាយតម្លៃបែបឌីណាមិក៖** បច្ចេកទេសនេះណែនាំគ្រូឱ្យបញ្ចូលការវាយតម្លៃលទ្ធផលសិក្សាសិស្សទៅក្នុងដំណើរបង្រៀន និងរៀនតែម្តង។ បច្ចេកវិទ្យាមួយចំនួនអាចប្រើប្រាស់សម្រាប់ការវាយតម្លៃជាប្រចាំតាមបែបឌីណាមិកនេះដូចជាបណ្តាញទំនាក់ទំនងសង្គម អ៊ីមែលជាដើម។ ការវាយតម្លៃអាចត្រូវបានចាត់ទុកជាបទពិសោធន៍សិក្សា និងមិនត្រូវបានរាប់បញ្ចូលទៅក្នុងការសម្រេចចុងក្រោយទៅលើលទ្ធផលសិក្សារបស់សិស្សនោះទេ។ ការវាយតម្លៃប្រភេទនេះត្រូវការគ្រូមានអន្តរកម្មដោយផ្ទាល់ជាមួយសិស្សក្នុងដំណើរការវាយតម្លៃ។
- **ការវាយតម្លៃផ្អែកលើកម្រងស្នាដៃសិស្ស៖** បច្ចេកទេសនេះ គ្រូធ្វើការរិះគន់ និងពិភាក្សាពីផលិតផលសិក្សាកើតឡើងក្នុងបរិបទជាក់ស្តែងរួមមាន កម្រងស្នាដៃសិស្ស ការងារគម្រោង ការសម្តែង ការតែងនិពន្ធ និងការធ្វើតេស្តនៅផ្ទះ។ ការប្រើប្រាស់ផលិតផលសិក្សាប្រភេទនេះអាចបំពេញបន្ថែមនូវចន្លោះប្រហោងនៃការវាយតម្លៃបែបប្រពៃណីលើការសិក្សារបស់សិស្ស។
- **ការវាយតម្លៃបែបដំណើរការ៖** បច្ចេកទេសនេះ គ្រូវាយតម្លៃលើដំណើរការ និងផលិផលសិក្សា។ បច្ចេកទេសប្រភេទនេះ គ្រូខ្លះអនុវត្តដោយប្រើប្រាស់ការសួរសំណួរ ការសម្ភាស ការពិភាក្សាក្រុម បញ្ជីត្រួតពិនិត្យ ការអង្កេតរួមគ្នា ការពិនិត្យលើសកម្មភាពដោះស្រាយបញ្ហាណាមួយជាដើម។
- **ការវាយតម្លៃបែបក្រៅផ្លូវការ៖** ការវាយតម្លៃបែបក្រៅផ្លូវការនេះ សំដៅលើការអង្កេតលើទំនាក់ទំនងតាមកែវភ្នែក ភាសាកាយវិការ ការសម្តែងទឹកមុខ និងរបៀបអនុវត្តការងារ។ ការសង្កេតបែបនេះអាចបំពេញបន្ថែមលើការវាយតម្លៃផ្លូវការផ្សេងៗដោយវាផ្តល់ជាមូលដ្ឋានសម្រាប់គ្រូក្នុងការកែលម្អការបង្រៀន។

| តើគេវាយតម្លៃដោយរបៀបណា ? |
|---|
| **ស្លាបនានិយម** ទាមទារឲ្យមានការកាត់បន្ថយការដាក់ចំណាត់ថ្នាក់សិស្ស និងការប្រឡងដោយប្រើតេស្តស្តង់ដា។ |



# ឯកសារទី ៧.៥៖ ឧទាហរណ៍ជាក់ស្តែងពីបច្ចេកទេសនៃការវាយតម្លៃបែបស្ថាបនានិយម និងបំណិនជីវិតតាមមូលដ្ឋា

| បច្ចេកទេសវាយតម្លៃ | ឧទាហរណ៍ និងសេចក្តីពន្យល់អំពីការអនុវត្តលើការបង្រៀន និងរៀនកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន |
|---|---|
| ការវាយតម្លៃបែបឌីណាមិក<br><br> | ✚ ឧទាហរណ៍៖ ការរៀនបំណិនជីវិតតាមមូលដ្ឋាន តាមរយៈដំណើរការ ៦ដំណាក់កាល ដែលសិស្សត្រូវរៀបចំសកម្មភាពផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីយល់ពីបញ្ហា និងស្វែងរកដំណោះស្រាយដែលអាចធ្វើទៅបាន។ គ្រូបង្រៀនវាយតម្លៃដោយការប្រាស្រ័យទាក់ទងជាមួយសិស្សក្នុងអំឡុងពេលដំណើរការដើម្បីវាយតម្លៃការងារជាក្រុម និងការយល់ដឹងរបស់ពួកគេ។<br>✚ **តួនាទីគ្រូបង្រៀន៖**<br>○ ធ្វើអន្តរកម្មជាមួយសិស្សដើម្បីកំណត់ថាតើពួកគេធ្វើការជាមួយគ្នាជាធីមបានល្អប៉ុណ្ណា?<br>○ កំណត់ថាតើសិស្សអាចអនុវត្តដំណាក់កាលនិងយល់ពីការណែនាំរបស់អ្នកនូវអ្វីដែលជាបញ្ហាប្រឈម (ការឆ្លុះបញ្ចាំងជាបន្តបន្ទាប់នៅចុងបញ្ចប់នៃដំណាក់កាលនីមួយៗ)។<br>○ ឆ្លុះបញ្ចាំងជាមួយសិស្សដើម្បីកំណត់ពីរបៀបដែលពួកគេសម្រេចបាននូវផលិតផលចុងក្រោយ។<br>○ អនុវត្តការវាយតម្លៃនៃរយៈពេលណាមួយជាមួយសិស្សអំពីរបៀបដែលពួកគេកំពុងអនុវត្តទាក់ទងនឹងបំណិន (ឧទាហរណ៍ ការវាយតម្លៃខ្លួនឯងជាប្រចាំសប្តាហ៍ សូមមើលខាងក្រោម)។<br>○ គ្រូបង្រៀនគួរកត់ចំណាំរាល់អន្តរកម្មទាំងអស់របស់សិស្ស ហើយប្រើលក្ខណៈទាំងអស់នេះដើម្បីជួយពួកគេនៅពេលក្រោយ។ |
| ការវាយតម្លៃលើកម្រងស្នាដៃសិស្ស | ✚ ឧទាហរណ៍៖ សិស្សម្នាក់ៗត្រូវនិពន្ធកំណាព្យជាភាសាខ្មែរដោយប្រើក្បួនតែងកាព្យផ្សេងៗ។ គ្រូបង្រៀនវាយតម្លៃដោយពិនិត្យមើលផលិតផល និងនិយាយជាមួយសិស្ស បន្ទាប់ពីផលិតផលកម្រងស្នាដៃពួកគេត្រូវបានបញ្ចប់។<br>✚ **តួនាទីគ្រូបង្រៀន៖**<br>○ ផ្តល់សម្ភារដល់សិស្សរក្សាទុក ឬចងក្រងកំណាព្យ |

| | |
|---|---|
|  | ○ អនុញ្ញាតឱ្យសិស្សធ្វើការសិក្សាបែបគម្រោងក្រៅថ្នាក់រៀន<br>○ ណែនាំសម្ភារផ្សេងៗដើម្បីជួយសិស្សធ្វើគម្រោង<br>○ ពិនិត្យមើលផលិតផល និងសួរសំណួរពីរបៀបសិស្សកំណត់ខ្លឹមសារ ចំណុចងាយស្រួល ចំណុចលំបាកជាដើម។ ល។<br>○ កំណត់កម្រិតពិន្ទុដោយផ្អែកលើផលិតផល និងការសម្ភាសជាមួយសិស្ស។ |
| ការវាយតម្លៃបែបដំណើរការ<br> | ✚ ឧទាហរណ៍៖ សិស្សបង្កើតគម្រោងគណិតវិទ្យាមួយបង្ហាញពីគោលការណ៍ក្នុងជំពូកណាមួយ។ គម្រោងនេះនឹងត្រូវបានបង្ហាញនៅលើក្តារខៀនពិព័រណ៍ក្នុងថ្នាក់។ គ្រូបង្រៀនជួបសិស្សជាទៀងទាត់ដើម្បីពិភាក្សាពីគម្រោង និងធ្វើការវាយតម្លៃក្នុងពេលជាមួយគ្នានោះ។<br>✚ **តួនាទីគ្រូបង្រៀន៖**<br>○ គ្រូបង្រៀនផ្តល់ប៉ារ៉ាម៉ែត្រគម្រោងដល់សិស្សប៉ុន្តែផ្តល់ឱកាសឱ្យពួកគេកំណត់ពីទម្រង់ខ្លឹមសារត្រូវអនុវត្ត។<br>○ គ្រូបង្រៀនធ្វើការប្រជុំពិភាក្សាជាទៀងទាត់ជាមួយសិស្សដើម្បីមើលថាតើពួកគេមានការវិវត្តអ្វីខ្លះ អំឡុងពេលអនុវត្តគម្រោង?<br>○ គ្រូបង្រៀនប្រើតារាងត្រួតពិនិត្យ(checklist)ដើម្បីត្រួតពិនិត្យការវិវត្ត និងបញ្ហាប្រឈម ហើយប្រើប្រាស់ការអង្កេតនេះសម្រាប់វាយតម្លៃគម្រោងចុងក្រោយ។ |
| ការវាយតម្លៃក្រៅផ្លូវការ<br> | ✚ ឧទាហរណ៍៖ គ្រូបង្រៀនឱ្យសិស្សធ្វើការជជែកដេញដោលជាភាសាអង់គ្លេសលើប្រធានបទណាមួយ។ បន្ថែមពីលើការសង្កេតមើលពីការតស៊ូការពារគំនិតរបស់ក្រុមនីមួយៗ គ្រូបង្រៀនធ្វើការសង្កេតទឹកមុខកម្រិតថាមពល និងការចូលរួមរបស់សិស្សផងដែរ។<br>✚ **តួនាទីគ្រូបង្រៀន៖**<br>○ គ្រូបង្រៀនសង្កេតមើលការជជែកដេញដោល។<br>○ បន្ថែមលើបញ្ជីត្រួតពិនិត្យវាយតម្លៃលើបច្ចេកទេសជជែកដេញដោយរបស់សិស្ស គ្រូបង្រៀនក៏អាចសង្កេតពីទឹកមុខកម្រិតថាមពល និងការចូលរួមផងដែរ។<br>○ បន្ទាប់មក គ្រូសង្កេតលើលទ្ធផលពីការអង្កេតក្រៅផ្លូវការ និងលក្ខណៈវិនិច្ឆ័យការវាយតម្លៃបែបដំណើរការ (ឧ. ពិន្ទុបញ្ជីផ្ទៀងផ្ទាត់) ដើម្បីធ្វើការវាយតម្លៃរួមពីលទ្ធផលសិក្សារបស់សិស្ស។ |

## ការពិភាក្សាជាក្រុមតូច

នៅក្នុងក្រុមតូចៗរបស់អ្នក សូមចូលរួមដល់ការពិភាក្សាពីភាពស្រដៀងគ្នា និងខុសគ្នារវាងយុទ្ធសាស្ត្រវាយតម្លៃផ្សេងៗដែលបានពិពណ៌នាក្នុងតារាងខាងលើ។ បន្ទាប់មក សូមបំពេញតារាងដែលបានផ្ដល់ជូនខាងក្រោម ដែលសង្ខេបពីរបៀបដែលបច្ចេកទេសទាំងនេះស្រដៀងគ្នា និងរបៀបដែលវាខុសគ្នា។

| កត្តា | ការវាយតម្លៃបែបឌីណាមិច | ការវាយតម្លៃបែបកម្រងស្នាដៃសិស្ស | ការវាយតម្លៃបែបដំណើរការ | ការវាយតម្លៃបែបក្រៅផ្លូវការ |
|---|---|---|---|---|
| ពេលវេលា<br>(ឧ.មុនពេល អំឡុងពេល ក្រោយពេលបញ្ចប់កិច្ចការជាប្រចាំ) | | | | |
| ការផ្ដោតលើគុណភាពផលិតផល<br>(ឧ. ទាប មធ្យម ខ្ពស់) | | | | |
| ការផ្ដោតលើដំណើរការ<br>(ឧ. ទាប មធ្យម ខ្ពស់) | | | | |
| អន្តរកម្មជាមួយគ្រូ<br>(ឧ. ទាប មធ្យម ខ្ពស់) | | | | |
| ការប្រើប្រាស់ការវាយតម្លៃបែបប្រពៃណី<br>(ឧ.ទាប មធ្យម ខ្ពស់) | | | | |

## ឯកសារ ៧.៦៖ ដំណើរការវាស់វែងបំណិនជីវិតតាមមូលដ្ឋាននៃអនុវិទ្យាល័យអរញ្ញវង្សី

**សេចក្តីណែនាំ៖** សូមអានករណីសិក្សាខាងក្រោម និងចូលរួមក្នុងការពិភាក្សាជាមួយក្រុមរបស់អ្នក ដើម្បីឆ្លើយសំណួរខាងក្រោម៖

| **ករណីសិក្សា អនុវិទ្យាល័យអរញ្ញវង្សី**<br>នៅពេលសម្ភាសន៍ គ្រូបង្រៀនដែលជានាយកសាលារៀនអរញ្ញវង្សី អាចពន្យល់លម្អិតពីដំណើរការរបស់ពួកគេ និងដកស្រង់កន្លែងដែលអាចស្វែងរកឧបករណ៍នៅក្នុងឯកសារណែនាំអនុវត្តបំណិនជីវិតតាមមូលដ្ឋាន ឆ្នាំ២០១៩ ដែលបង្ហាញថាពួកគេបានប្រើប្រាស់ឯកសារ។ នេះជាអ្វីដែលពួកគាត់បានពន្យល់។<br><br>**ការវាស់វែងធ្វើឡើងជាពីរដំណាក់កាល៖**<br>១) ការវាស់វែងចំណេះដឹងជារៀងរាល់ខែ៖ គ្រូគួរតែបង្កើតតេស្តដូចមុខវិជ្ជាផ្សេងៗទៀត។ សំណួរទាក់ទងនឹងប្រធានបទ ក៏ដូចជាដំណើរការស៊ើបអង្កេត។<br>២) ការវាស់វែងបំណិនជីវិតតាមមូលដ្ឋាន៖<br>ក. **ការសង្កេត** ផ្អែកលើឧបសម្ព័ន្ធ ៧.២.២ (ទំព័រទី៩៩-១០១ ឯកសារណែនាំអនុវត្តរបស់ក្រសួងអប់រំ យុវជន និងកីឡា (ឆ្នាំ២០១៩)។<br>ខ. ស្វ័យវាយតម្លៃរបស់សិស្ស ឧបសម្ព័ន្ធ ៧.៤។ គ្រូបង្រៀនសង្កេតមើលសិស្សក្នុងអំឡុងពេលសកម្មភាពដែលតម្រូវឱ្យធ្វើការងារជាក្រុម កិច្ចសហការជាមួយសមាជិក ការប្រាស្រ័យទាក់ទងគ្នា ការច្នៃប្រឌិត និងជាទូទៅការអនុវត្តបំណិនជីវិតតាមមូលដ្ឋានផ្សេងទៀតទាំងអស់ (សរុបចំនួន១២ ឬជ្រើសរើសដោយគ្រូតាមអាទិភាពថ្នាក់រៀន)។ ឧបករណ៍ស្វ័យវាយតម្លៃមាននៅទំព័រទី១០៣-១០៤ នៃឯកសារណែនាំអនុវត្តរបស់ក្រសួងអប់រំ (ឆ្នាំ២០១៩)។<br><br>ចុងក្រោយ វាយតម្លៃជារួមរបស់សិស្ស (រួមបញ្ចូលគ្នាទាំងការធ្វើតេស្តចំណេះដឹង និងការវាយតម្លៃលើបំណិនជីវិតតាមមូលដ្ឋាន)៖ ដោយប្រើឧបករណ៍ "ឧបករណ៍វាយតម្លៃការអនុវត្ត" ឧបសម្ព័ន្ធ ៧.១.១ ទំព័រទី៩៥ នៃសេចក្តីណែនាំ។ |
|---|
| |

## សំណួរបំផុស

- ហេតុអ្វីបានជាអ្នកគិតថាសាលារៀនវាស់វែងទាំងចំណេះដឹង និងបំណិនជីវិតតាមមូលដ្ឋាន?
- តាមយោបល់របស់អ្នកដោយប្រើសេចក្ដីណែនាំសង្កេត តើអ្វីជាគោលដៅនៃអំឡុងពេលការសង្កេត?
- តើអ្វីជាគោលដៅនៃការសួរសិស្សឱ្យវាយតម្លៃខ្លួនឯង?
- តើអ្នកមានអារម្មណ៍ជឿជាក់ក្នុងការប្រើប្រាស់ឧបករណ៍ទាំងនេះដែរឬទេ? បើមិនដូច្នេះទេ តើអ្នកត្រូវយល់ដឹងដូចម្ដេចមុននឹងអាចប្រើវាបាន?
- តើអ្វីជាអត្ថប្រយោជន៍នៃការប្រើប្រាស់ឧបករណ៍បែបនេះ (ជាពិសេសឧបករណ៍សម្រាប់វង្វាយតម្លៃបំណិន)? តើអ្វីអាចជាបញ្ហាប្រឈម?

# ឯកសារផ្នែកទី៣៖ ការបង្កើតបរិយាកាសគាំទ្រនៅក្នុងសាលារៀន

## ឯកសារ ៨.១៖ ក្រោយបណ្តុះបណ្តាល

**សេចក្តីណែនាំ៖**

១.គិតអំពីពេលវេលាចុងក្រោយដែលអ្នក ឬមិត្តរួមការងាររបស់អ្នកបានចូលរួមវគ្គបណ្តុះបណ្តាលទាក់ទងនឹងការងារប្រចាំថ្ងៃរបស់អ្នក។

២. គិតអំពីអ្វីដែលបានរៀន និងអ្វីដែលបានកើតឡើងនៅពេលត្រលប់ទៅសាលារៀនវិញ។

៣. ឆ្លើយតបទៅនឹងសំណួរខាងក្រោម។

៤. ចែករំលែកចម្លើយរបស់អ្នកជាមួយអ្នកចូលរួមផ្សេងទៀត។

**សំណួរបំផុស៖**

**អំឡុងពេលវគ្គបណ្តុះបណ្តាល៖**

- តើអ្នកអាចរំឭកពេលចុងក្រោយដែលអ្នកបានចូលរួមវគ្គបណ្តុះបណ្តាលអំពីអ្វីមួយដែលទាក់ទងនឹងការងាររបស់អ្នកបានដែរឬទេ? ដើម្បីងាយស្រួលដល់អ្នក ចូរគិតអំពីមិត្តរួមការងារ ឬមិត្តភក្តិ។
- តើអ្នកមានឱកាសដើម្បីសាកល្បងអនុវត្តការរៀនសូត្រថ្មីអំឡុងពេលហ្វឹកហាត់ដែរឬទេ?
- តើអ្នកមានពេលពិភាក្សា និងការឆ្លុះបញ្ចាំងដែរឬទេ?

**ត្រឡប់មកសាលារៀនវិញ**

- តើអ្នកអាចអនុវត្តអ្វីដែលបានរៀននៅក្នុងការបណ្តុះបណ្តាលក្នុងការងារប្រចាំថ្ងៃរបស់អ្នកដែរឬទេ? បើមិនដូច្នេះទេ តើមានបញ្ហាប្រឈមអ្វីខ្លះ?
- តើការខិតខំប្រឹងប្រែងរបស់អ្នកត្រូវបានទទួលស្គាល់ និងផ្តល់តម្លៃដោយអ្នកគ្រប់គ្រងសាលារៀនដែរឬទេ?
- តើអ្នកបានទទួលការគាំទ្រណាមួយដើម្បីអនុវត្តការរៀនថ្មីដែរឬទេ?
- តើអ្នកបានចែករំលែកការរៀនសូត្ររបស់អ្នកជាមួយអ្នកដទៃនៅក្នុងសាលារៀនរបស់អ្នកដែរឬទេ? យ៉ាងដូចម្តេច?

# ឯកសារ ៨.២៖ គំរូសិក្សា ៧០-២០-១០

**សេចក្ដីណែនាំ៖**

១. សូមមើលក្រាហ្វិកខាងក្រោម។ ប្រសិនបើអ្នកមិនច្បាស់លាស់ សូមសួរទៅកាន់អ្នកសម្របសម្រួល ឬទៅដៃគូរបស់អ្នក។

២. ឆ្លើយទៅនឹងសំណួរខាងក្រោម

៣. ត្រៀមខ្លួនដើម្បីចែករំលែកជាមួយក្រុម




**សំណួរបំផុស៖**

- តើអ្នកធ្លាប់បានឮអំពីគំរូសិក្សា ៧០-២០-១០ ទេ?
- តើក្រាហ្វិកនេះមានន័យអ្វី? តើអ្នកយល់ស្របជាមួយវាដែរឬទេ?
- តើការហ្វឹកហាត់តែម្នាក់ឯងមានប្រសិទ្ធិភាពកម្រិតណា ដោយផ្អែកលើក្រាហ្វិកនេះ?
- តើមានធាតុផ្សំអ្វីខ្លះដែលចាំបាច់ត្រូវមានដើម្បីធ្វើឱ្យការបណ្ដុះបណ្ដាលមានប្រសិទ្ធភាព?

# ឯកសារ ៨.៣៖ សេណារីយ៉ូ៖ សុភា និងការសិក្សាថ្មីៗ

**សេចក្តីណែនាំ**

១. អានសេណារីយ៉ូខាងក្រោម
២. ឆ្លើយសំណួរ
៣. ត្រៀមចែករំលែកទៅក្រុម

**សេណារីយ៉ូ៖ សុភា** បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀនថ្មីកាលពីខែមុន។ គាត់បានទៅសាលារៀនវិញ ប៉ុន្តែបញ្ហាមិននឹកស្មានដល់មួយចំនួនបានកើតឡើង។ គាត់បានព្យាយាមណែនាំវិធីសាស្ត្ររៀនអាស្រ័យលើបញ្ហានៅក្នុងការបង្រៀន មានឈ្មោះថា បំណិនជីវិតតាមមូដ្ឋាន ប៉ុន្តែគាត់មិនអាចចាំបានទាំងអស់ដែលគាត់បានរៀនក្នុងអំឡុងពេលបណ្តុះបណ្តាលនោះទេ។ គ្មាននរណាម្នាក់នៅក្នុងសាលារៀនរបស់គាត់ហាក់ដូចជាមានចំណេះដឹងច្រើនអំពីការសិក្សាអាស្រ័យលើគម្រោង ដូច្នេះគាត់មិនដឹងថាត្រូវសុំជំនួយពីអ្នកណាទេ។ មិត្តរួមការងារផ្សេងទៀតតែងតែរវល់ និងប្រញាប់ប្រញាល់ត្រឡប់ទៅផ្ទះភ្លាមៗនៅពេលបង្រៀនចប់ហើយពិបាកមានពេលជួបពិភាក្សារឿងជាមួយគ្នា។

នាយកសាលាឈ្មោះលោកស្រី **ផល្លី** បានចូលរួមវគ្គបណ្តុះបណ្តាលជាមួយគាត់ផងដែរ ព្រោះគាត់ថ្មីទាំងអស់ ប៉ុន្តែគាត់ព្យាយាមជួយ។ គាត់បានបែងចែកថវិកាបន្ថែមមួយចំនួនសម្រាប់សកម្មភាពរបស់ **សុភា** ដោយលើកទឹកចិត្តឱ្យគាត់ព្យាយាមអនុវត្តហើយនាយកសាលារៀបចំកាលវិភាគគ្រូទាំងអស់ឡើងវិញដើម្បីបែងចែកពេលវេលាជាក់លាក់សម្រាប់កិច្ចប្រជុំ និងពិភាក្សាការអនុវត្តការបង្រៀន។ គាត់ក៏បានទាក់ទងទៅនាយកសាលាផ្សេងទៀតដែលគាត់បានជួបនៅវគ្គបណ្តុះបណ្តាលដើម្បីសុំយោបល់។ គាត់បានកំណត់គ្រូបង្រៀនដែលជាគ្រូប្រឹក្សារបស់ **សុភា** សម្រាប់ឆ្នាំបច្ចុប្បន្ន និងជួយគាត់ក្នុងការងារជាគ្រូបង្រៀនដើម្បីកែលម្អការណែនាំការសិក្សាអាស្រ័យលើបញ្ហានៅតាមថ្នាក់រៀន។

ក្រោយមក **សុភា** ចាប់ផ្តើមបំពេញការងារ និងអនុវត្ត! មិនតែប៉ុណ្ណោះ គាត់បានរកឃើញថា គ្រូបង្រៀនមួយចំនួននៅក្នុងសាលារៀនរបស់គាត់បានប្រើប្រាស់ការរៀនអាស្រ័យលើបញ្ហារួចហើយ ប៉ុន្តែគ្រាន់តែមិនមានពេលចែករំលែកពីមុនមក។ នាយកសាលាបានធ្វើការជាមួយពួកគេ ដើម្បីរៀបចំកាលវិភាគរបស់ពួកគេឡើងវិញ និងធានាថាពេលវេលាសម្រាប់គ្រូបង្រៀនជួបជុំគ្នាជារៀងរាល់សប្តាហ៍ ហើយមិនត្រឹមតែប៉ុណ្ណោះ កិច្ចប្រជុំបច្ចេកទេសជាផ្លូវការត្រូវធ្វើនៅថ្ងៃព្រហស្បតិ៍។

### សំណួរ

- តើអ្វីជាបញ្ហាចម្បងដែលសុភាជួបប្រទះនៅពេលគាត់ព្យាយាមណែនាំពីការរៀនបែបថ្មីនៅក្នុងសាលារៀន ?

- តើអ្វីបានជួយគាត់ឱ្យផ្សព្វផ្សាយវិធីសាស្ត្របែបថ្មី ?

- តើនាយកសាលាបានធ្វើអ្វីដើម្បីជួយគាត់ ? តើអ្នកបានធ្វើអ្វីប្លែកពីនេះដែរឬទេ ?

- តើអ្វីមិនដំណើរការ ?

- ហេតុអ្វីបានជាគ្រូផ្សេងទៀតមិនជួយ ? តើមានអ្វីស្រដៀងគ្នានេះកើតឡើងនៅក្នុងសាលារៀនរបស់អ្នកដែរឬទេ ? តើធ្វើដូចម្តេចដើម្បីទប់ទល់នឹងការខ្វះខាតកិច្ចសហប្រតិបត្តិការនេះ ?

# ឯកសារ ៨.៤៖ ប្រព័ន្ធអេកូគរុកោសល្យនៅតាមសាលារៀនរបស់អ្នក

**សេចក្ដីណែនាំ៖**

- **ជំហានទី១៖** គិតអំពីអ្វីដែលបានពិភាក្សានៅក្នុងសេណារីយ៉ូ ហើយរំឭកឡើងវិញនូវធាតុដែលអាចគាំទ្រការងាររបស់គ្រូនៅតាមសាលារៀន។
- **ជំហានទី២៖** គូររូបក្រាហ្វិកក្នុងក្រដាសផ្ទាំងធំ ហើយបញ្ចូលគំនិតរបស់អ្នកបន្ថែមរង្វង់ជុំវិញគំនិតគោលប្រសិនបើអ្នកត្រូវការដើម្បីបន្ថែមគំនិតរបស់អ្នក។
- **ជំហានទី៣៖** ឆ្លុះបញ្ចាំងនៅក្នុងក្រុម ប្រសិនបើអ្នកមានគំនិតបន្ថែមណាមួយនៃការគាំទ្រដែលអ្នកចង់មាននៅក្នុងសាលារៀនទាក់ទងនឹងសេវា ធនធាន ឬយន្តការគាំទ្រ។
- **ជំហានទី៤៖** បង្ហាញរូបភាពក្រដាស់ផ្ទាំងធំនៅលើជញ្ជាំង។
- **ជំហានទី៥៖** សុំឱ្យអ្នកចូលរួមមើលក្រដាស់ផ្ទាំងធំដែលបិទផ្សាយរបស់ក្រុមផ្សេងទៀត ហើយមើលភាពខុសគ្នា និងភាពស្រដៀងគ្នាដែលអាចកើតមាន។

ប្រព័ន្ធអេកូគរុកោសល្យនៅក្នុងសាលារៀនរបស់ខ្ញុំ



## ឯកសារ ៨.៥៖ អ្នកដឹកនាំល្អ និងអ្នកដឹកនាំខ្សោយ

### សេចក្តីណែនាំ

១. សូមអានតារាងខាងក្រោមដែលរាយបញ្ជីពីលក្ខណៈនៃអ្នកដឹកនាំល្អ និងអ្នកដឹកនាំខ្សោយ។
២. ជ្រើសរើសមួយណាសម្រាប់អ្នកដឹកនាំល្អ និងមួយណាសម្រាប់អ្នកដឹកនាំខ្សោយ
៣. ឆ្លើយតបទៅនឹងសំណួរខាងក្រោម
៤. ត្រៀមខ្លួនដើម្បីចែករំលែកជាមួយក្រុម

---

### ក. សូមគូសធីក ប្រសិនបើអំណះអំណាងនេះសំដៅលើអ្នកដឹកនាំល្អ ឬអ្នកដឹកនាំខ្សោយ

| អំណះអំណាង | អ្នកដឹកនាំល្អ | អ្នកដឹកនាំខ្សោយ |
|---|---|---|
| ពួកគេបើកចំហចំពោះគំនិតច្នៃប្រឌិត និងអ្វីដែលថ្មីៗ | | |
| ពួកគេអាចមើលឃើញសក្តានុពលរបស់បុគ្គលម្នាក់ៗ | | |
| ពួកគេគ្រប់គ្រងលម្អិត | | |
| ពួកគេមិនចូលចិត្តការផ្លាស់ប្តូរ ហើយនឹងមិនទទួលយកហានិភ័យ | | |
| ពួកគេរកតែកំហុសអ្នកដទៃ | | |
| ពួកគេស្វាគមន៍ការទំនាក់ទំនងបើកចំហ | | |
| ពួកគេមានភាពវិជ្ជមាន ហើយតែងតែលើកទឹកចិត្តអ្នកដទៃ | | |
| ពួកគេដឹងថាពេលណាត្រូវផ្ទេរសិទ្ធិ | | |
| ពួកគេអវិជ្ជមាន ហើយតែងតែបន្ទោសសមាជិកក្រុម | | |
| ពួកគេមិនឱ្យតម្លៃលើតម្លាភាពទេ | | |
| គេមិនខ្វល់ពីកំណើនមនុស្សទេ | | |

### ខ. សំណួរឆ្លុះបញ្ចាំង៖

- តាមគំនិតរបស់អ្នក តើអ្វីជាភាពខុសគ្នាដ៏សំខាន់បំផុតរវាងអ្នកដឹកនាំល្អ និងអ្នកដឹកនាំខ្សោយ ?

- តាមបទពិសោធន៍របស់អ្នក តើគំរូមួយណាដែលអ្នកបានឃើញសម្រាប់អ្នកដឹកនាំល្អ? តើលក្ខណៈអ្វីខ្លះដែលអ្នកបានឃើញ?

- តាមបទពិសោធន៍របស់អ្នក តើគំរូមួយណាដែលអ្នកបានឃើញសម្រាប់អ្នកដឹកនាំខ្សោយ? តើលក្ខណៈអ្វីខ្លះដែលអ្នកបានឃើញ?

## ឯកសារ ៨.៦៖ ករណីសិក្សានៅសាលារៀនបឋមសិក្សាភ្នាក់

**សេចក្តីណែនាំ**

- អានដោយប្រុងប្រយ័ត្ននូវករណីសិក្សាខាងក្រោម
- ឆ្លើយសំណួរ
- មេរៀន៖ ធ្វើការជាដៃគូ

**មេរៀន៖** ការងារជាដៃគូ

**ករណីសិក្សា**

នៅសាលារៀនបឋមសិក្សាភ្នាក់ គេគ្រប់គ្រងធនធានរបស់ពួកគេប្រកបដោយប្រសិទ្ធភាព ដើម្បីគាំទ្រដល់ការសិក្សារបស់សិស្ស។ នេះជារបៀបដែលពួកគេធ្វើវា៖

១. ពួកគេគូសផែនទីនូវអ្វីដែលសាលារៀនត្រូវការ ដោយសួរគ្រូ ឪពុកម្តាយ និងសហគមន៍។
២. ពួកគេបង្កើតថវិកាដោយផ្អែកលើតម្រូវការទាំងនោះ និងផ្តល់អាទិភាពដល់ធនធានដែលមានឥទ្ធិពលបំផុតលើ**ការសិក្សារបស់សិស្ស**។
៣. ពួកគេចែកចាយធនធានដោយស្មើភាព ដោយគិតពីតម្រូវការផ្សេងៗគ្នារបស់សិស្ស។ ឧទាហរណ៍ ពួកគេផ្តល់ជំនួយបន្ថែមសម្រាប់សិស្សដែលជួបការលំបាក និងបន្ថែមកិច្ចការលំបាកសម្រាប់សិស្សដែលរៀនពូកែ។
៤. ពួកគេប្រើប្រាស់ទិន្នន័យដូចជា ពិន្ទុតេស្ត និងការចូលរួម ដើម្បីសម្រេចថាតើធនធានណាដែលត្រូវការច្រើនបំផុត។ ចំណុចនេះជួយពួកគេកំណត់គោលដៅការខិតខំប្រឹងប្រែងរបស់ពួកគេ។
៥. ពួកគេធ្វើការជាមួយអាជីវករ និងអង្គការក្នុងស្រុកដើម្បីទទួលបានធនធាន និងជំនួយបន្ថែម។ ឧទាហរណ៍ ក្រុមហ៊ុនបច្ចេកវិទ្យាមួយអាចបរិច្ចាគកុំព្យូទ័រ និងកម្មវិធី។
៦. ពួកគេផ្តល់ឱកាសដល់គ្រូដើម្បីរៀន និងរីកចម្រើនតាមរយៈវគ្គបណ្តុះបណ្តាល។ ចំណុចនេះជួយឱ្យពួកគេទទួលបានធនធានច្រើនដែលអាចប្រើប្រាស់បាន។
៧. ពួកគេប្រើប្រាស់បច្ចេកវិទ្យាដើម្បីសម្រួលការងារ ដូចជាការគ្រប់គ្រងកិច្ចការសាលារៀន និងជួយសិស្សឱ្យរៀន។
៨. ពួកគេថែរក្សាអគារសិក្សា និងសម្ភារបរិក្ខារ ឱ្យមានសណ្តាប់ធ្នាប់ និងមានសុវត្ថិភាព។
៩. ពួកគេតាមដានថាតើការគ្រប់គ្រងធនធានរបស់ពួកគេថាតើដំណើរការបានល្អប៉ុណ្ណា ហើយចាំបាច់ផ្លាស់ប្តូរដែរឬទេ។

តាមរយៈការធ្វើកិច្ចការទាំងនេះ សាលារៀនបឋមសិក្សាភ្នាក់ យល់ថាពួកគេប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពដើម្បីបង្កើតបរិយាកាសសិក្សាល្អសម្រាប់សិស្ស។

**សំណួរៈ**

- តើសកម្មភាពសំខាន់ៗអ្វីខ្លះដែលសាលារៀនបឋមសិក្សាភ្នាក់បានធ្វើដើម្បីធានាឱ្យមានការប្រើប្រាស់ធនធានបានល្អ?

- ហេតុអ្វីបានជាពួកគេប្រើទិន្នន័យដូចជា ពិន្ទុតេស្ត និងការចូលរួម ដើម្បីសម្រេចថាតើធនធានណាដែលត្រូវការច្រើនបំផុត។ ចំណុចនេះជួយពួកគេកំណត់គោលដៅការខិតខំប្រឹងប្រែងរបស់ពួកគេ។ តើអ្នកធ្វើវានៅឯសាលារៀនរបស់អ្នកដែរឬទេ?

- តើអ្នកអាចតាមដានស្ថានភាពឧបករណ៍ និងអគារនៅក្នុងសាលារៀនរបស់អ្នកដោយរបៀបណា?

- ហេតុអ្វីបានជាសាលារៀនរួមបញ្ចូលសកម្មភាពជាក់លាក់មួយដើម្បីផ្តល់ឱកាសដល់គ្រូបង្រៀនដើម្បីរៀន និងរីកចម្រើនតាមរយៈវគ្គបណ្តុះបណ្តាល? តើវាទាក់ទងនឹងការគ្រប់គ្រងធនធានយ៉ាងដូចម្តេច?

- តើមានសកម្មភាពបន្ថែមណា ដែលអ្នកធ្វើនៅឯសាលារៀនរបស់អ្នក ដើម្បីប្រើប្រាស់ធនធានសាលារៀនប្រកបដោយប្រសិទ្ធភាពដែរឬទេ?

## ឯកសារ ៨.៧៖ បញ្ជីត្រួតពិនិត្យការគ្រប់គ្រងធនធាន

**សេចក្ដីណែនាំ**

ដោយប្រើបញ្ជីត្រួតពិនិត្យនេះ សាលារៀនអាចធានាបាននូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៃធនធានរបស់ពួកគេ ដើម្បីគាំទ្រដល់ការរៀនសូត្រ និងសមិទ្ធផលការសិក្សារបស់សិស្ស។

**តារាងត្រួតពិនិត្យ**

| ល.រ | បញ្ជីត្រួតពិនិត្យការគ្រប់គ្រងធនធាន | រួចរាល់ | បន្ត | មិនទាន់ធ្វើ |
|---|---|---|---|---|
| ១ | **ធ្វើការវាយតម្លៃតម្រូវការដែលពាក់ព័ន្ធនឹងគ្រូ ឪពុកម្ដាយ និងសហគមន៍៖** | | | |
| | ចូលរួមជាមួយភាគីពាក់ព័ន្ធក្នុងការកំណត់តម្រូវការធនធានជាក់លាក់របស់សាលារៀន។ | | | |
| | ពិចារណាលើកត្តាមួយចំនួនដូចជា ចំនួនសិស្ស តម្រូវការកម្មវិធីសិក្សា ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកវិទ្យា និងការអភិវឌ្ឍបុគ្គលិក។ | | | |
| ២ | **បង្កើតថវិកាដោយផ្អែកលើតម្រូវការដែលបានកំណត់ និងកំណត់អាទិភាពធនធានសម្រាប់ផលប៉ះពាល់ជាអតិបរមាលើការសិក្សារបស់សិស្ស៖** | | | |
| | បង្កើតថវិកាជាក់ស្ដែងស្របតាមតម្រូវការដែលបានកំណត់។ | | | |
| | ចូលរួមជាមួយភាគីពាក់ព័ន្ធសំខាន់ៗក្នុងដំណើរការរៀបចំផែនការថវិកា។ | | | |
| | ផ្ដល់អាទិភាពដល់ធនធានដោយផ្អែកលើផលប៉ះពាល់សក្ដានុពលរបស់ពួកគេលើលទ្ធផលសិក្សារបស់សិស្ស។ | | | |
| ៣ | **បែងចែកធនធានដោយស្មើភាព គិតពីតម្រូវការផ្សេងៗគ្នារបស់សិស្ស ៖** | | | |
| | ចែកចាយធនធានដោយសមធម៌ ដើម្បីដោះស្រាយតម្រូវការចម្រុះរបស់សិស្ស។ | | | |
| | ផ្ដល់ការគាំទ្របន្ថែមសម្រាប់សិស្សដែលជួបការលំបាក រួមទាំងអន្តរាគមន៍ និងជំនួយតាមគោលដៅ។ | | | |
| | ផ្ដល់ឱកាសបន្ថែមសម្រាប់សិស្សដែលទទួលបានជោគជ័យខ្ពស់ក្នុងការបន្តការសិក្សារបស់ពួកគេ។ | | | |
| ៤ | **ប្រើទិន្នន័យដូចជា ពិន្ទុតេស្ដ និងការចូលរួម ដើម្បីកំណត់អាទិភាពនៃការបែងចែកធនធាន៖** | | | |

| | | | | |
|---|---|---|---|---|
| | វិភាគទិន្នន័យសមិទ្ធផលរបស់សិស្សឱ្យទៀងទាត់ និងវង្វាស់ពាក់ព័ន្ធផ្សេងទៀត។ | | | |
| | កំណត់ផ្នែកដែលត្រូវការធនធានបន្ថែម ឬអន្តរាគមន៍។ | | | |
| | ដឹកនាំធនធានទៅកាន់តំបន់ដែលមានតម្រូវការ និងសក្តានុពលបំផុតសម្រាប់ការកែលម្អ។ | | | |
| | វិភាគទិន្នន័យសមិទ្ធផលរបស់សិស្សទៀងទាត់ និងវង្វាស់ដែលពាក់ព័ន្ធផ្សេងទៀត។ | | | |
| ៥ | **បង្កើតភាពជាដៃគូអាជីវកម្ម និងអង្គការក្នុងស្រុក ដើម្បីចូលប្រើធនធាន និងជំនួយបន្ថែម៖** | | | |
| | សហការជាមួយអង្គការខាងក្រៅ អាជីវកម្ម និងអ្នកពាក់ព័ន្ធសហគមន៍។ | | | |
| | ស្វែងរកការបរិច្ចាគ ជំនួយ ឬការឧបត្ថម្ភ ដើម្បីបង្កើនមូលដ្ឋានធនធានរបស់សាលារៀន។ | | | |
| | ប្រើប្រាស់ធនធានសហគមន៍ ដើម្បីផ្តល់ឱកាសសិក្សាតែមួយគត់សម្រាប់សិស្ស។ | | | |
| ៦ | **ផ្តល់ឱកាសអភិវឌ្ឍវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន ដើម្បីបង្កើនជំនាញរបស់ពួកគេ និងបង្កើនការប្រើប្រាស់ធនធាន៖** | | | |
| | ផ្តល់ជូនកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈដែលកំពុងដំណើរការ ស្របតាមតម្រូវការដែលបានកំណត់។ | | | |
| | ផ្តោតលើការអនុវត្តការបង្រៀន ការរួមបញ្ចូលបច្ចេកវិទ្យា និងផ្នែកផ្សេងទៀតនៃការរីកចម្រើន។ | | | |
| | ផ្តល់អំណាចដល់គ្រូបង្រៀនក្នុងការប្រើប្រាស់ធនធានដែលមានប្រកបដោយប្រសិទ្ធភាពដើម្បីគាំទ្រដល់ការរៀនសូត្ររបស់សិស្ស។ | | | |
| ៧ | **ប្រើប្រាស់បច្ចេកវិទ្យា ដើម្បីសម្រួលការងាររដ្ឋបាល និងលើកកម្ពស់ការបង្រៀន និងរៀន៖** | | | |
| | កំណត់ដំណោះស្រាយបច្ចេកវិទ្យាដែលមានប្រសិទ្ធភាពសម្រាប់ការងាររដ្ឋបាល។ | | | |
| | ស្វែងរកឧបករណ៍បច្ចេកវិទ្យាអប់រំដើម្បីគាំទ្រការបង្រៀន និងស្វ័យសិក្សា។ | | | |
| | ធានាថាគ្រូបង្រៀន និងសិស្សមានលទ្ធភាពទទួលបានធនធានបច្ចេកវិទ្យាសមស្រប។ | | | |
| ៨ | **អនុវត្តផែនការថែទាំយ៉ាងសកម្ម ដើម្បីធានាសុវត្ថិភាព និងភាពជាប់បានយូរនៃហេដ្ឋារចនាសម្ព័ន្ធ និងឧបករណ៍សាលារៀន៖** | | | |

| | | | | |
|---|---|---|---|---|
| | បង្កើតកាលវិភាគថែទាំសម្រាប់ការត្រួតពិនិត្យ ជួសជុល និងកែលម្អជាប្រចាំ។ | | | |
| | ផ្តល់អាទិភាពដល់វិធានការសុវត្ថិភាពក្នុងការថែទាំហេដ្ឋារចនាសម្ព័ន្ធ។ | | | |
| | រក្សាឧបករណ៍ និងគ្រឿងបរិក្ខារមានសណ្តាប់ធ្នាប់ល្អ ដើម្បីជៀសវាងការរំខាន។ | | | |
| ៩ | **តាមដាន និងវាយតម្លៃជាប្រចាំនូវប្រសិទ្ធភាពនៃយុទ្ធសាស្ត្រគ្រប់គ្រងធនធាន និងធ្វើការកែតម្រូវតាមតម្រូវការ៖** | | | |
| | បង្កើតប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃការបែងចែកធនធាន និងការប្រើប្រាស់។ | | | |
| | ប្រមូលមតិកែលម្អពីគ្រូបង្រៀន សិស្សានុសិស្ស និងមាតាបិតាអំពីផលប៉ះពាល់នៃធនធាន។ | | | |
| | ប្រើលទ្ធផលវាយតម្លៃដើម្បីជូនដំណឹងដល់ការសម្រេចចិត្ត និងធ្វើការកែតម្រូវចាំបាច់។ | | | |

## ឯកសារ ៩.១៖ ការវាយតម្លៃចំណេះដឹងរបស់អ្នកអំពីបញ្ញត្តិ និងដំណើរការនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

**សេចក្តីណែនាំ៖** ចូរអានសំណួរទាំងឡាយខាងក្រោម ដើម្បីទទួលបាននូវគំនិតអំពីទីតាំងរបស់អ្នកក្នុងន័យការយល់ដឹងរបស់អ្នកអំពីបញ្ញត្តិ និងដំណើរការនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ ចូរដាក់ពិន្ទុសម្រាប់ការយល់ដឹងរបស់អ្នកដោយស្មោះត្រង់ដើម្បីឱ្យអ្នកសម្របសម្រួលអាចដឹងបានយ៉ាងល្អថាគាត់ត្រូវតែពន្យល់បកស្រាយ។ បន្ទាប់ពីបានឆ្លើយសំណួរ និងដាក់ពិន្ទុសំណួរនីមួយៗ ចូររាយការណ៍ពិន្ទុសរុបរបស់អ្នកទៅកាន់ប្រធានក្រុមរបស់អ្នក ដើម្បីឱ្យគាត់អាចកំណត់មធ្យមភាគវាជាមួយនឹងពិន្ទុរបស់សមាជិកក្រុមផ្សេងទៀត។

| ល.រ | សំណួរ | ពិន្ទុ |
|---|---|---|
| 1. | តើអ្នកពិពណ៌នាអំពីការយល់ដឹងទូទៅរបស់អ្នកអំពីបញ្ញត្តិនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំយ៉ាងដូចម្តេច?<br>☐ ខ្លាំង (៣) ☐ មធ្យម (២) ☐ ខ្សោយ (១) | |
| 2. | តើអ្នកពិពណ៌នាអំពីការអនុវត្តនូវការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅសាលារៀនឬខេត្តរបស់អ្នកយ៉ាងដូចម្តេច?<br>☐ ខ្លាំង (៣) ☐ មធ្យម (២) ☐ ខ្សោយ (១) | |
| 3. | តើអ្នកបានឃើញ ឬអានឯកសារក្របខណ្ឌការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលបានអនុម័តដោយក្រសួងអប់រំហើយឬនៅ?<br>☐ ខ្ញុំបានឃើញវា និងបានអានវា (២)<br>☐ ខ្ញុំបានឃើញវា ប៉ុន្តែមិនបានអានវាទេ (១)<br>☐ ខ្ញុំពុំបានដឹងអំពីឯកសារនេះទេ (០) | |
| 4. | តើអ្នកពិពណ៌នាអំពីការយល់ដឹងរបស់អ្នកអំពីក្របខណ្ឌគន្លងអាជីពគ្រូបង្រៀនរបស់ក្រសួងអប់រំយ៉ាងដូចម្តេច?<br>☐ ខ្លាំង (៣) ☐ មធ្យម (២) ☐ ខ្សោយ (១) | |
| 5. | តើអ្នកនិងពិពណ៌នាអំពីទំនុកចិត្តរបស់អ្នកក្នុងការរៀបចំប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅតាមសាលារៀន នៅសាលារៀន ឬខេត្តរបស់អ្នកយ៉ាងដូចម្តេច?<br>☐ ខ្លាំង (៣) ☐ មធ្យម (២) ☐ ខ្សោយ (១) | |
| | **ពិន្ទុសរុប** | |

**ពិន្ទុខ្ពស់បំផុត៖ ១៤**

**ពិន្ទុទាបបំផុត៖ ៤**

**ពិន្ទុមធ្យម៖ ៩**

# ឯកសារ ៩.២៖ ក្របខណ្ឌការងារ CPD នៅកម្រិតសាលារៀន



## ឯកសារ ៩.៣៖ សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលត្រូវពិចារណាសម្រាប់សាលារៀនរបស់អ្នក

ឯកសារនេះផ្តល់ជូននូវបញ្ជីសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំចំនួន១៥ ដែលអ្នកអាចធ្វើទៅបាននៅសាលារៀនរបស់អ្នក។ ចូរពិនិត្យមើលបញ្ជីនេះជាមួយអ្នកសម្របសម្រួលរបស់អ្នក ដើម្បីស្វែងយល់ឱ្យបានកាន់តែប្រសើរនូវអ្វីដែលសកម្មភាពនីមួយៗតម្រូវ។ បញ្ជីសកម្មភាព CPD ដែលមានលក្ខណៈទូលំទូលាយជាងនេះមាននៅក្នុង *ក្របខណ្ឌអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលា* នៅក្នុងឧបសម្ព័ន្ធ ជ  របស់ក្រសួងអប់រំ។

លំហាត់ជាក្រុម៖ ក្រោយពីបានពិនិត្យមើលសកម្មភាពនីមួយៗរួចហើយ ចូរបំពេញតារាងខាងក្រោមជាមួយនឹងសញ្ញាធីក (✓) នៅក្នុងក្រុមរបស់អ្នកនៅលើសន្លឹកក្រដាសផ្ទាំងធំ ហើយត្រៀមខ្លួនចែករំលែកការពិចារណារបស់អ្នកជាមួយក្រុមធំ។
សូមត្រៀមខ្លួនពន្យល់ ហេតុអ្វីអ្នកជ្រើសរើសសម្មភាពមានសកក្តានុពល ៥ ដែលអ្នកបានជ្រើសរើស។ អ្វីដែលធ្វីឱ្យអ្នកចាប់អារម្មណ៍ក្នុងការជ្រើសរើសសកម្មភាពទាំងនេះ? តើអ្នកមានធនធានបច្ចេកទេសដើម្បីធ្វើវាដែរឬទេ? តើអ្នកមានថវិកាដើម្បីធ្វើដែរឬទេ?

### សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំទូទៅសម្រាប់កម្រិតសាលារៀន

| | |
|---|---|
| ១. ការស្រាវជ្រាវសកម្ម | គ្រូអាចប្រើប្រាស់ថ្នាក់រៀនរបស់ខ្លួនជាទីតាំងស្រាវជ្រាវ។ |
| ២. សៀវភៅសិក្សា | គ្រូជ្រើសរើសសៀវភៅមួយក្បាលស្តីពីបញ្ហានៃភាពទាក់ទងអប់រំដែលសំខាន់ រួចហើយអានរួមគ្នា ពិភាក្សាអំពីគំនិតទាំងឡាយនៅក្នុងការប្រជុំតាមពេលគ្រោងទុក។ |
| ៣. ទស្សនកិច្ចផ្ទាល់ | គ្រូចុះទស្សនកិច្ចតាមថ្នាក់រៀនរបស់សហការី ឬសាលារៀនផ្សេងទៀត ដើម្បីពិនិត្យ និងពង្រីកគរុកោសល្យផ្ទាល់ខ្លួនរបស់ពួកគេ។ ការចុះទស្សនកិច្ចគួរមានរចនាសម្ព័ន្ធនិងជាតុចេញច្បាស់លាស់។ |
| ៤. ការបង្វឹក | គ្រូស្នើសុំ និងទទួលព័ត៌មានត្រឡប់អំពីការប្រតិបត្តិរបស់ខ្លួនបន្ទាប់ពីបានសង្កេតដោយគ្រូបង្វឹកមួយរូប (ឧ. សហការី ឬអ្នកសង្កេតដទៃទៀត (TTI, ។ល។)។ |
| ៥. ធ្វើការជាមួយសហគមន៍ | គ្រូទទួលឱកាសក្នុងការធ្វើការជាមួយអង្គការសហគមន៍ ដើម្បីអភិវឌ្ឍបំណិនដឹកនាំរបស់ខ្លួន និងស្វែងយល់អំពីសហគមន៍មូលដ្ឋានបានកាន់តែប្រសើរថែមទៀត។ |

| | |
|---|---|
| ៦. ការធ្វើផែនទីកម្មវិធីសិក្សា | ផែនទីកម្មវិធីសិក្សា គឺជាឧបករណ៍រៀបចំការបង្រៀន។ តាមរយៈការធ្វើផែនទីអ្វីដែលបានបង្រៀនជាក់ស្តែង និងពេលវេលា គ្រូអាចកែសម្រួលការបង្រៀនរបស់ខ្លួនបាន។ |
| ៧. វិភាគទិន្នន័យសិស្ស | គ្រូប្រើទិន្នន័យដើម្បីសម្រេចចិត្តបានកាន់តែប្រសើរអំពីអ្វីដែលត្រូវបង្រៀន របៀបកំណត់ថាតើសិស្សយល់នូវអ្វីដែលបានបង្រៀនដែរឬទេ ។ល។ គ្រូអាចប្រើតេស្ត កម្រងស្នាដៃសិស្ស ឬការសង្កេតសម្រាប់គោលបំណងនេះ។ |
| ៨. ការទទួលគរុសិស្ស | ការទទួលគរុសិស្ស ដាក់គ្រូបង្រៀននៅក្នុងតួនាទីប្រឹក្សាគរុកោសល្យមួយ។ គ្រូប្រឹក្សាគរុកោសល្យរៀនសូត្របានកាន់តែច្រើនអំពីការប្រតិបត្តិផ្ទាល់ខ្លួនខណៈពេលពួកគេកំពុងធ្វើផង និងជួយដល់គ្រូបង្រៀនថ្មីផងក្នុងការអភិវឌ្ឍការប្រតិបត្តិរបស់ខ្លួនផ្ទាល់។ |
| ៩. ការធ្វើផែនការកម្មវិធីសិក្សាបែបចម្រុះ | គ្រូរៀបចំកម្មវិធីសិក្សាដើម្បីឱ្យវាឆ្លងកាត់ខ្សែបន្ទាត់នៃកម្មវត្ថុ ដោយនាំយកប្រធានបទនានាទៅក្នុងសមាគមដ៏មានន័យ និងអនុញ្ញាតឱ្យសិស្សផ្តោតលើជំនាញសិក្សាទូលំទូលាយ។ |
| ១០. សៀវភៅកំណត់ត្រា | សៀវភៅកំណត់ត្រាគរុកោសល្យគឺជាបច្ចេកទេសមួយសម្រាប់កត់ត្រាការសង្កេត និងការឆ្លុះបញ្ចាំងទៅលើការបង្រៀនរបស់គ្រូណាម្នាក់។ វារួមចំណែកដល់ការបង្រៀនបែបឆ្លុះបញ្ចាំង។ |
| ១១. បណ្តាញផ្សព្វផ្សាយសង្គម | បណ្តាញបច្ចេកវិទ្យាអាចជួយដល់គ្រូក្នុងការប្រាស្រ័យទាក់ទងជាមួយក្រុមអ្នកអប់រំកាន់តែទូលំទូលាយ និងចម្រុះ ដែលលើសពីសាលារៀនរបស់គ្រូណាម្នាក់ ដើម្បីចែករំលែកគំនិត និងការប្រតិបត្តិថ្មីៗ។ |
| ១២. កម្មវិធី CPD តាមអនឡាញ | គ្រូអាចទទួលបានក្រេឌីតពីអង្គការនានាដែលផ្តល់កម្មវិធីបណ្តុះបណ្តាលអនឡាញ ដែលប្រើប្រាស់ការបង្រៀន និងកម្មវិធីដឹកនាំខ្លួនឯង។ |
| ១៣. ការចូលរួមអង្គការវិជ្ជាជីវៈ | សមាគមសម្រាប់គ្រូមុខវិជ្ជា (ឧ. សមាគមគណិតវិទ្យា) ផ្តល់នូវឱកាសដ៏ល្អមួយសម្រាប់កែលម្អចំណេះដឹងវិជ្ជាជីវៈរបស់គ្រូបង្រៀន។ |
| ១៤. ការសិក្សាពេលវិស្សមកាល | គ្រូក៏អាចចូលរួមវគ្គសិក្សាពិសេសៗដែលមានការគាំទ្រអាហារូបករណ៍ពីសាលារៀននៅវិទ្យាស្ថាន ឬសាកលវិទ្យាល័យនានាក្នុងស្រុកផងដែរ។ |
| ១៥. គម្រោងប្រធានក្រុមបច្ចេកទេស | តួនាទីមួយរបស់ប្រធានក្រុមបច្ចេកទេសគឺ ជួយក្រុមគ្រូបង្រៀនកំណត់រកគម្រោងមួយដែលមានន័យពេលលេញចំពោះពួកគេ បន្ទាប់មកធ្វើការជាដំណាក់កាលៗដែលត្រូវការអនុវត្តវា។ |

## ឯកសារ ៩.៤៖ ការបង្កើតប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដ៏ជោគជ័យមួយ

## ការដាក់ផែនការរួមគ្នាមួយដើម្បីដាក់ប្រព័ន្ធ CPD មួយតាមសាលារៀន

គោលបំណងមួយក្នុងចំណោមគោលបំណងសំខាន់ៗនៃម៉ូឌុលនេះគឺដើម្បីជួយឱ្យអ្នកគ្រប់គ្រងសាលារៀនបានដឹងនូវអ្វីដែលពួកគេគួរតែធ្វើនៅពេលពួកគេត្រឡប់ទៅកាន់សាលារៀនរបស់ពួកគេវិញ ដើម្បីរៀបចំប្រព័ន្ធ CPD មួយតាមសាលារៀន។ ខាងក្រោមនេះគឺជាយោបល់មួយចំនួន៖

យោបល់ទី១៖ **ប្រមូលឯកសារមានប្រយោជន៍មួយចំនួន** ដើម្បីឱ្យអ្នកបានយល់ដឹងកាន់តែប្រសើរអំពីក្របខណ្ឌគោលនយោបាយរបស់ក្រសួងអប់រំ ពីព្រោះវាពាក់ព័ន្ធនឹងប្រព័ន្ធ CPD ។ ឯកសារសំខាន់ៗមួយចំនួនដែលត្រូវអានរួមមានជាអាទិ៍ដូចជា៖

- *ក្របខណ្ឌអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលា ឆ្នាំ២០១៩-២៣*
- *សៀវភៅណែនាំការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ*
- *សៀវភៅណែនាំសហគមន៍សិក្សាវិជ្ជាជីវៈ*

ឯកសារទាំងនេះអាចរកបាននៅលើវេបសាយរបស់ក្រសួងអប់រំ
( https://www.moeys.gov.kh/index.php/kh/ )

យោបល់ទី២៖ **ជួបជាមួយបុគ្គលិកបង្រៀនសំខាន់ៗនៅក្នុងសាលារៀនរបស់អ្នក ( ឧ. នាយករង ប្រធានក្រុមបច្ចេកទេស ។ល។) និងបង្កើនការយល់ដឹងរបស់ពួកគេអំពីបញ្ហា CPD ។** អ្នកអាចពិចារណាចម្លងតាមម៉ូឌុលនេះ ដោយប្រើឯកសារទាំងឡាយដែលបានផ្តល់ជូនអ្នក។

យោបល់ទី៣៖ **រៀបចំគណៈកម្មការ CPD តាមសាលារៀននៅក្នុងសាលារៀនរបស់អ្នក** តាមគោលការណ៍ណែនាំនៅក្នុងឯកសារក្របខណ្ឌអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់ក្រសួងអប់រំ ដែលដាក់បញ្ចូលនូវអ្នកដឹកនាំសំខាន់ៗនៅក្នុងចំណោមគ្រូបង្រៀនរបស់អ្នក។ ព្យាយាមធានាឱ្យបានថា អ្នកដឹកនាំដែលមានឋាមវន្ត( ឌីណាមិក )បំផុតក្នុងសាលារៀន ដែលមានចំណេះដឹងល្អផ្នែកគរុកោសល្យស្ថិតនៅក្នុងតួនាទីជាថ្នាក់ដឹកនាំនៅក្នុងគណៈកម្មការនេះ។

យោបល់ទី៤៖ ធ្វើការវាយតម្លៃតម្រូវការដើម្បីកំណត់នូវតម្រូវការសមត្ថភាពសំខាន់ៗបំផុតនៅសាលារៀនរបស់អ្នក តាមរយៈការស្ទង់មតិ សម្ភាសន៍ និងមធ្យោបាយផ្សេងៗ។

យោបល់ទី៥៖ **លើកទឹកចិត្តឱ្យគ្រូបង្រៀនផ្លាស់ទីឆ្ពោះទៅរកការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈមួយ។** នេះពុំមែនជាកិច្ចការងាយស្រួលធ្វើរហូតទេ ពីព្រោះសហគមន៍សិក្សាវិជ្ជាជីវៈ (PLC) ពុំមែនជាគណៈកម្មការ ឬចេនាសម្ព័ន្ធផ្លូវការមួយឡើយ ប៉ុន្តែជាបណ្តាញគ្រូបង្រៀនក្រៅផ្លូវការមួយដែលជួយគ្នាទៅវិញទៅមក និងចែករំលែកអ្វីៗជាមួយគ្នា។ ប៉ុន្តែយ៉ាងហោចណាស់សាលារៀនអាចចាប់ផ្តើមដំណើរការដោយភ្ជាប់ទំនាក់ទំនងគ្រូបង្រៀនជាមួយគ្នានៅក្នុងក្រុមផ្សព្វផ្សាយសង្គម ដែលគោលបំណងរបស់ពួកគេគឺចែករំលែក និងបង្កើនការប្រាស្រ័យទាក់ទងក្នុងចំណោមគ្រូបង្រៀន។ ក្រុមផ្សេងៗទៀតអាច

បង្កើតឡើងនៅពេលក្រោយ។ សូមអានសៀវភៅណែនាំសហគមន៍សិក្សាវិជ្ជាជីវៈរបស់ក្រសួងអប់រំ ដើម្បីទទួលបានការណែនាំបន្ថែមអំពីការបង្កើតសហគមន៍នេះនៅសាលារៀនរបស់អ្នក។

យោបល់ទី៦៖ **កំណត់អត្តសញ្ញាណអ្នកផ្តល់សេវា CPD មួយចំនួននៅក្នុងតំបន់របស់អ្នក ដែលអាចផ្តល់នូវការគាំទ្រជាមួយនឹង INSET ឬវគ្គសិក្សាអនឡាញ (ឧ. LNGOS, TTIs ។ល។) ។**

យោបល់ទី៧៖ **ធានាថា អ្នកបានដាក់បញ្ចូលថវិកាសម្រាប់សកម្មភាពគាំទ្រ CPD ទៅក្នុងផែនការកែលម្អសាលារៀនរបស់អ្នក។**

### តើការស្រាវជ្រាវសាកលនិយាយដូចម្តេចអំពីការអនុវត្តប្រព័ន្ធ CPD នៅកម្រិតសាលារៀន?

ប្រទេសផ្សេងៗជាច្រើនក្រៅពីកម្ពុជា កំពុងស្វែងរកការប្រើប្រាស់គោលវិធីគ្រប់គ្រងតាមសាលារៀន ដើម្បីកែលម្អការរៀបចំសាលារៀន ជាមធ្យោបាយក្នុងការរៀបចំប្រព័ន្ធ CPD នៅកម្រិតសាលារៀន។ ការស្រាវជ្រាវសាកលបញ្ជាក់ថា ប្រទេសជាច្រើនកំពុងតែបរាជ័យនៅក្នុងកិច្ចប្រឹងប្រែងទាំងនេះ[១០]។ ទាំងនេះគឺជាហេតុផលមួយចំនួន ដែលអ្នកស្រាវជ្រាវរាយការណ៍អំពីមូលហេតុដែលប្រព័ន្ធ CPD នៅកម្រិតសាលារៀនតែងតែបរាជ័យ៖

**១. អាទិភាពទាប៖** គ្រូបង្រៀនផ្តោតតែទៅលើថ្នាក់សិក្សាឯកជនរបស់ពួកគេ និងកិច្ចការផ្សេងៗតាមទម្លាប់ ហើយផ្តល់អាទិភាពទាបទៅលើការអភិវឌ្ឍវិជ្ជាជីវៈ។

**២. ខ្វះភាពជាអ្នកដឹកនាំ៖** ពុំមាននរណាម្នាក់នៅសាលារៀន ដែលមានជំនាញឯកទេសខ្ពស់ផ្នែក CPD ដើម្បីសម្របសម្រួលសកម្មភាព CPD ប្រកបដោយប្រសិទ្ធភាព ដូច្នេះមានស្ថានភាពមួយហៅថា "អ្នកខ្វាក់ដឹកនាំអ្នកខ្វាក់"។

**៣. ការជំរុញទឹកចិត្តទាប៖** គ្រូបង្រៀនបំពេញតែភារកិច្ច CPD តាមរបៀបជាយន្តការមួយដោយពុំអស់ពីបេះដូងទៅលើកិច្ចការនោះឡើយ។ ដូច្នេះ មានផលជះតិចតួចទៅលើការប្រតិបត្តិជាក់ស្តែងនៅក្នុងថ្នាក់រៀន។

**៤. លទ្ធភាពប្រើប្រាស់ពេលវេលានៅមានកម្រិត៖** ពេលវេលាដែលបានចាត់ចែងសម្រាប់សកម្មភាព CPD (ឧ. ២ម៉ោងក្នុងមួយសប្តាហ៍) ហាក់ដូចជាតិចតួចពេកដើម្បីធ្វើឱ្យមានផលជះពិតប្រាកដទៅលើចំណេះដឹង និងបំណិនរបស់គ្រូបង្រៀន។

**៥. ភាពទាក់ទងមានកម្រិតទាប៖** គ្រូបង្រៀនពុំបានមើលឃើញជាក់ស្តែងថា សកម្មភាព CPD ពាក់ព័ន្ធនឹងការអភិវឌ្ឍខ្លួន ឬបញ្ហាជាក់ស្តែងនៅសាលារៀនឡើយ។ វាគ្រាន់តែជាបន្ទុកការិយាធិបតេយ្យបន្ថែមដែលពួកគេត្រូវតែធ្វើដោយពុំបានដឹងពីមូលហេតុប៉ុណ្ណោះ។

**៦. ខ្វះធនធាន៖** ទោះពេលដែលសាលារៀនព្យាយាមបង្កើតនូវកិច្ចប្រឹងប្រែងមួយដើម្បីអនុវត្តគោលការណ៍ CPD ក៏ដោយ ក៏ពុំមានធនធានសម្រាប់វគ្គសិក្ខាសាលារៀន ទស្សនកិច្ច ការស្រាវជ្រាវសកម្មឡើយ ។ល។

**៧. ពិបាកផ្លាស់ទីពីការវាយតម្លៃទៅកាន់សកម្មភាព៖** បន្ទាប់ពីសាលារៀនបានធ្វើការវាយតម្លៃទៅលើស្ថានភាពនៅក្នុងសាលារៀនរបស់ពួកគេរួចហើយ មានភាពអសមត្ថភាពមួយក្នុងការផ្គូរផ្គងលទ្ធផលជាមួយនឹងដំណោះស្រាយជាដុំកំភួនដែលអាចមានផលជះ។

**៨. ខ្វះសម្ភារជាឯកសារ៖** សាលារៀនទទួលបានតិចតួចនូវឯកសារជាភាសាជាតិ ដើម្បីជួយឱ្យពួកគេយល់បានកាន់តែប្រសើរថែមទៀតអំពីដំណើរការ CPD ។ ឯកសារដែលមានទាំងនោះសុទ្ធតែក្រាស់ និងពិបាកអាន។

ក្រុមពិភាក្សា ៖ ចូរពិនិត្យមើលសំណួរទាំងឡាយខាងក្រោមតាមក្រុមតូចៗរបស់អ្នក ហើយបង្កើតចម្លើយដោយផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នក និងបទពិសោធន៍របស់អ្នកដទៃ។ ត្រូវរៀបចំខ្លួនដើម្បីពិភាក្សាចម្លើយរបស់អ្នកជាមួយក្រុមធំទាំងមូល។

### សំណួរពិភាក្សា៖

១. តើមានបញ្ហាដែលបានដកស្រង់នៅខាងលើនេះចំនួនប៉ុន្មាន ដែលអ្នកយល់ថាពាក់ព័ន្ធនឹងប្រទេសកម្ពុជា ( ឧ. បញ្ហាទាំងអស់ ? បញ្ហាភាគច្រើន ? បញ្ហាខ្លះ ? ។ល។ ) ?

២. ក្នុងចំណោមបញ្ហាទាំងឡាយដែលបានដកស្រង់ខាងលើ តើបញ្ហា **ពីរ ឬ បី** ណាខ្លះដែលអ្នកយល់ថាសំខាន់ជាងគេបំផុតនៅក្នុងបរិបទកម្ពុជា ហើយក៏ពិបាកដោះស្រាយជាងគេបំផុតផងដែរ ?

៣. ចំពោះបញ្ហាចំនួនពីរ ឬ បី ដែលអ្នកបានដកស្រង់ថាមានអាទិភាពខ្ពស់ជាងគេ តើអ្នកនឹងព្យាយាមដោះស្រាយវានៅសាលារៀនរបស់អ្នក ឬនៅក្នុងខេត្តរបស់អ្នកដោយរបៀបណា ? ចូរព្យាយាមមានភាពជាក់លាក់នៅពេលបរិយាយអំពីដំណោះស្រាយរបស់អ្នក។

| ចម្លើយ៖ |
| --- |
| |

## ឯកសារ ៩.៥៖ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

**តើអ្នកណាជាអ្នកសម្របសម្រួលប្រព័ន្ធទទួលស្គាល់** CPD?
CPDMO (ការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ)។

**តើអ្នកណាអាចផ្តល់សកម្មភាព CPD ដែលផ្តល់ជាក្រេឌីត**? ដោយអ្នកផ្តល់សេវា CPD ដែលមានការទទួលស្គាល់ (អង្គភាពទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា) ឧទាហរណ៍ វិទ្យាស្ថានបណ្តុះបណ្តាលគ្រូ ឬដៃគូអភិវឌ្ឍន៍ ឬនាយកដ្ឋានបច្ចេកទេសនៃក្រសួងអប់រំ យុវជន និង កីឡា សហការជាមួយវិទ្យាស្ថានបណ្តុះបណ្តាលគ្រូ។

**តើអ្នកណាអាចទទួលបានអត្ថប្រយោជន៍**ពីសកម្មភាព CPD? គ្រូបង្រៀន នាយកសាលា អ្នកឯកទេសអប់រំ (រួមទាំងបុគ្គលិកក្រសួងអប់រំ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បុគ្គលិកវិទ្យាស្ថានបណ្តុះបណ្តាលគ្រូ)។

**តើអ្វីជាឧទាហរណ៍នៃសកម្មភាព** CPD? CPD មានគោលបំណងផ្តល់ឱកាសសិក្សាយ៉ាងទូលំទូលាយពីការសិក្សាផ្លូវការដល់ការសិក្សាក្រៅផ្លូវការ។ នៅប៉ុន្មានឆ្នាំខាងមុខនេះ ក្រសួងអប់រំ យុវជន និងកីឡា នឹងពង្រីកការផ្តល់ជូននេះ ដែលសម្រាប់ពេលនេះត្រូវបានតំណាងដោយការសិក្សាទល់មុខផ្លូវការ និងឱកាសសិក្សាតាមបែបចម្រុះតែប៉ុណ្ណោះ។

**តើខ្ញុំអាចស្វែងរកព័ត៌មានអំពីវគ្គសិក្សា** CPD **ដែលអាចរកបាននៅឯណា**? នៅលើគេហទំព័រ CPD ។

**តើក្រេឌីត** CPD **ជាអ្វី**?
អ្នកចូលរួមអាចសន្សំក្រេឌីត CPD ដែលអាចត្រូវបានប្រើក្នុងទម្រង់ផ្សេងៗគ្នា រួមទាំងក្រេឌីតនៅក្នុងកម្រិតខ្ពស់ ឬវឌ្ឍនភាពអាជីពវិជ្ជាជីវៈ។ អ្នកផ្តល់សេវា CPD កត់ត្រាក្រេឌីតនៅក្នុងប្រព័ន្ធ HRMIS ដោយផ្ទាល់។
១ក្រេឌីត CDP គឺស្មើនឹង ១៥ម៉ោង រៀនផ្ទាល់(F2F) និង៣០ម៉ោងទៀតសម្រាប់ការអនុវត្ត និងការឆ្លុះបញ្ចាំងខ្លួនឯង។

- *ជម្រើសផ្សេងទៀតនឹងមាននៅពេលអនាគត៖* ៤៥ម៉ោងនៃការអនុវត្តការបង្រៀនដែលមានការត្រួតពិនិត្យ ឬ ១៥ម៉ោង "បញ្ចូលជាតុចូល" ពីប្រភពដែលអាចទទួលយកបាន បូកថែម ៣០ម៉ោងស្វ័យសិក្សា (ការងារជាក់ស្តែង ការស្រាវជ្រាវ ការងារមន្ទីរពិសោធន៍ និងការអនុវត្ត

នៃជាតុចូល) ឬ ៤៥ម៉ោងនៃការសិក្សាដោយឯករាជ្យ ការពិសោធ ឬការងារតាមមូលដ្ឋាន (លទ្ធផលដែលត្រូវបញ្ជាក់ដោយអ្នកគ្រប់គ្រង ឬអ្នកគ្រប់គ្រងអង្គការ)។

អ្នកត្រូវមានអត្តសញ្ញាណ HRMIS របស់អ្នក ដើម្បីកត់ត្រាការសិក្សា និងទទួលបានក្រេឌីត CPD ។

**ពេលវេលាកំណត់សម្រាប់ CPD៖**

ក្របខណ្ឌ CPS រួមបញ្ចូលទាំងសិទ្ធិ និងកាតព្វកិច្ចសម្រាប់គ្រូបង្រៀនដើម្បីអនុវត្ត CPD ១០០ម៉ោងក្នុងមួយឆ្នាំ។ នេះប្រហែលស្មើនឹង ៣ម៉ោងក្នុងមួយសប្ដាហ៍ក្នុងមួយឆ្នាំសិក្សា។

**តើអ្នកអាចប្រើក្រេឌីត CPD បានដោយរបៀបណា?**

- សម្រាប់ការតម្លើងគុណវុឌ្ឍិគ្រូបង្រៀន (TQU)។
    - ឧ. ការកែលម្អការអប់រំទៅកម្រិតបរិញ្ញាបត្រផ្នែកអប់រំ (B Ed) ឬខ្ពស់ជាងនេះ។

**ធនធានបន្ថែមស្ដីពី CPD៖**

- គេហទំព័រចម្បង (ភាសាខ្មែរ)៖ http://cpd.moeys.gov.kh/blog
- ធនធានដែលរកបាន៖ http://cpd.moeys.gov.kh/resource
- ទំព័រ Facebook នៃ CPDMO:
- វីដេអូ៖ https://www.facebook.com/CPDMO.MoEYS/videos
- វីដេអូស្ដីពីប្រព័ន្ធ HRMIS៖ https://www.facebook.com/CPDMO.MoEYS/videos/309758614791446

unicef

PLAN INTERNATIONAL

Save the Children

ChildFund Cambodia

Room to Read

អង្គការមូលនិធិសិទ្ធិកុមារ
Child Rights Foundation Organization

អង្គការអប់រំពិភពលោក
WORLD EDUCATION